សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ កក្កដា ឆ្នាំ ២០១៦

# លីអាហូណា



## ការស្ថាបនាទីក្រុងស៊ីយ៉ូននាសម័យបច្ចុប្បន្ននេះ ទំព័រ ៤, ២០

ជួបជាមួយនឹងអែលឌើរ រេនឡាន់ ទំព័រ ១៤

គន្លឹះ៨យ៉ាងដើម្បីបង្រៀនយុវវ័យ និង កុមារ ទំព័រ ២៨, ៣០

សេចក្ដីសញ្ញា និង ការថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធ ៖ បង្កើនទំនាក់ទំនងរបស់អ្នកជាមួយព្រះឲ្យកាន់តែជ្រាលជ្រៅ ទំព័រ ៣២, ៣៦



*« គ្រប់ការណ៍ទាំងអស់បង្ហាញ ថា មានព្រះមួយអង្គមែន មែន ហើយ ហើយសូម្បីតែផែនដី និងរបស់សព្វសារពើដែលនៅ លើផ្ទៃផែនដី មែនហើយ និង ចលនារបស់ផែនដី មែន ហើយ ព្រមទាំងពិភពទាំងអស់ ដែលធ្វើចលនាតាមទម្រង់ ធម្មតារបស់គេក៏ធ្វើជាសាក្សី ថា មានព្រះបង្កបង្កើតដ៏ មហិមាមួយអង្គ » ។*

អាលម៉ា ៣០:៤៤

រូបថតនៃកាឡាក់ស៊ី មីលគីវ៉េ ដកស្រង់ចេញ ពី ដែកសិន លេក រដ្ឋ វ៉ាយអូមីង ស.រ.អា. ។

# លីអាហូណា ខែ កក្កដា ឆ្នាំ ២០១៦



៤


២៤ **ដូចជាស្ត្រីមេម៉ាយនៅសារិបតា ៖ អព្ភូតហេតុនៃដង្វាយតមអាហារ**
ដោយ ប៉ូ នៀន ( ហ្វេលីព ) ជូ និង ពេត្រា ជូ
*យើងចង់ជួយជនក្រីក្រ និង ខ្វះខាត ។ ហើយយើងចង់ឲ្យគ្រួសាររបស់យើងយកឈ្នះលើទំនោរចិត្តនៃភាពអាត្មានិយម ។ យើងបានឃើញដំណោះស្រាយរបស់យើងចំពោះបញ្ហានោះនៅក្នុងដង្វាយតមអាហារ ។*

៣៦ **ការគោរពព្រះដោយការគោរពសេចក្ដីសញ្ញារបស់យើង**
ដោយ អែលឌើរ យ៉ូសែប ដបុលយូ ស៊ីតាទី
*យើងគោរពប្រតិបត្តិព្រះវរបិតាសួគ៌នៅពេលយើងធ្វើឲ្យទំនាក់ទំនងយើងជាមួយទ្រង់កាន់តែស៊ីជម្រៅ ដោយការធ្វើ ហើយរក្សាសេចក្ដីសញ្ញា និង ពិធីបរិសុទ្ធនៃការសង្គ្រោះ ។*


## សារលិខិត


៤ **សារលិខិតគណៈប្រធានទីមួយ ៖ ស្មោះនឹងជំនឿនៃពួកបុព្វការីជនរបស់យើង**
ដោយ ប្រធាន ថូម៉ាស អេស ម៉នសុន

៧ **សារលិខិតបង្រៀនសួរសុខទុក្ខ ៖ សក្ដានុពលរបស់យើងសម្រាប់ភាពជាឪពុកម្ដាយ**


## អត្ថបទពិសេសៗ


១២ **ការផ្លាស់ប្ដូរក្នុង ក្រុមប្រឹក្សាគ្រូបង្រៀន**
ដោយ សាន់ដ្រា ខាតធែល
*ការផ្ដល់យោបល់នៅក្នុងក្រុមប្រឹក្សាគ្រូបង្រៀនបានជួយកែលម្អការបង្រៀនរបស់គាត់បានប្រសើរឡើង ។*

១៤ **អែលឌើរ ឌេល ជី រេនឡាន់ ៖ អ្នកបម្រើដែលគោរពប្រតិបត្តិ**
ដោយ អែលឌើរ ឃ្វីនធិន អិល ឃុក
*ពេញមួយជីវិតនៃការបម្រើ អែលឌើរ រេនឡាន់ ដែលជាសាវកថ្មី ដឹងថាព្រះអម្ចាស់ប្រទានគុណសម្បត្តិដល់អ្នកដែលទ្រង់ហៅបម្រើ ។*

២០ **ការធ្វើដំណើររបស់ខ្ញុំក្នុងនាមជាអ្នកត្រួសត្រាយម្នាក់មកពីប្រទេសឥណ្ឌា**
ដោយ មែនហ្គាល ដែន ឌីពធី ដូចដែលបានប្រាប់ចន សានតូស្ស មូរ៉ាឡា
*ការរៀបចំរបស់ព្រះអម្ចាស់សម្រាប់ជីវិតរបស់ខ្ញុំគឺវាអស្ចារ្យជាងអ្វីដែលខ្ញុំរំពឹងគិតទៅទៀត — ចេញពីការធំឡើងពី « ក្មេងរស់នៅក្នុងព្រៃស្បាត » នៅក្នុងតំបន់ដាច់ស្រយាលមួយនៅក្នុងប្រទេសឥណ្ឌា ទៅដល់ការទទួលបុណ្យជ្រមុជទឹក និង ធ្វើជាមិត្តជាមួយនឹងសាវក ។*




**នៅលើក្របមុខ**
ខាងមុខ ៖ *មិននៅតែឯងឡើយ* ដោយ មីនើវ៉ា ធីឆើត ខាងក្នុងក្របខាងមុខ ៖ រូបថតដោយ វ៉យស៍ ប៉ែរ ។ ខាងក្នុងក្របខាងក្រោយ ៖ រូបថតដោយ ហ្គុយ កូហិន ។

## ផ្នែកនានា


៨ **ព្យាការី និង សាវកថ្លែងនាសម័យនេះ ៖ ការគាំទ្រសេរីភាពខាងសាសនា**

១០ **យើងនិយាយអំពីព្រះគ្រីស្ទ ៖ ស្រឡាញ់អ្នកដទៃដែលមានគុណតម្លៃផ្សេងពីយើង**
ឈ្មោះត្រូវបានដកចេញ

២៨ **មួយសិក្ខាបទម្ដងៗ ៖ ការយល់ចិត្តយុវវ័យដែលអ្នកបង្រៀន**

៣០ **មួយសិក្ខាបទម្ដងៗ ៖ « មើលទំកូនតូចៗរបស់អ្នករាល់គ្នា » — ការរៀនបង្រៀនកុមារ**

៣២ **ដំណឹងល្អពីបុរាណ ៖ ការថ្វាយបង្គំនៅព្រះវិហារបរិសុទ្ធ — គន្លឹះដើម្បីស្គាល់ព្រះ**
ដោយ អែលឌើរ ម៉ារីអុន ឌី ហាងស៍

៤០ **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

៨០ **លុះត្រាជួបទៀត ៖ ក្រពើខាងវិញ្ញាណ**
ដោយ ប្រធាន បិយដ៍ យេ ផាកកឺ

## យុវមជ្ឈិមវ័យ




**៤៤ ការដោះស្រាយបញ្ហាជាមួយនឹងការត្រឡប់មកផ្ទះវិញមុនកំណត់**
ដោយ ដេនី រ៉ូលីន
*ការត្រឡប់មកផ្ទះវិញមុនកំណត់ពីបេសកកម្មរបស់ខ្ញុំគឺជាការបាក់ទឹកចិត្តមួយដ៏ខ្លាំង ។ នេះគឺជាចំណុចមួយចំនួនដែលខ្ញុំចង់ឲ្យមនុស្សជាទីស្រឡាញ់របស់ខ្ញុំ និង រូបខ្ញុំបានដឹងដើម្បីធ្វើវា ។*

**៤៨ ទំព័រយុវមជ្ឈិមវ័យ : ការបន្តនៅរឹងមាំនៅក្នុងប្រទេសបារាំង**
ដោយ មីនឌី អាន សេលូ
*ការធ្វើជាកងទ័ពបារាំង ផ្ទៃពឹងផ្អែកលើការអធិស្ឋាន និង ការសិក្សាព្រះគម្ពីរដើម្បីធ្វើជាគំរូអំពីសេចក្ដីជំនឿរបស់ខ្លួន ។*



*ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ តើពួកមរមនកាតូលិកជានរណា ?*

## យុវវ័យ

**៥០ ចម្លើយមកពីថ្នាក់ដឹកនាំនៃសាសនាចក្រ : របៀបទទួលបានពរជ័យក្នុងព្រះវិហារបរិសុទ្ធ**
ដោយ អែលឌើ រ៉ូណាល អេ រ៉ាសបាន

**៥១ ចំទៅនឹងគោលដៅ**
*មានអារម្មណ៍ប្រតិព័ទ្ធគ្នាឬ ? អព្វូតហេតុនាពេលបច្ចុប្បន្ននេះ ?*

**៥២ សម្អាធពីមិត្តភក្ដិ និង *ពីភីស្ហ***
ដោយ គីអារ៉ា ប្លែនកូ
*ខ្ញុំបានបន្តសុំឪពុកម្ដាយខ្ញុំទៅចូលរួមកម្មវិធីជប់លៀងជាមួយមិត្តភក្ដិរបស់ខ្ញុំ ។ ទីបំផុតពួកគាត់បានអនុញ្ញាតឲ្យខ្ញុំទៅ ខ្ញុំបានអធិស្ឋានថាសូមឲ្យពួកគាត់ត្រឡប់មក ហើយយកខ្ញុំទៅវិញ ។*

**៥៤ វិទ្យាសាស្ត្រ និង ការស្រាវជ្រាវរបស់យើងរកសេចក្ដីពិត**
ដោយ អាលីសា ខេ ស្ដានថុន
*តើអ្នកមានការព្រួយបារម្ភអំពីអ្វីដែលអ្នកបានរៀននៅថ្នាក់វិទ្យាសាស្ត្រត្រូវគ្នាជាមួយនឹងដំណឹងល្អឬ ?*

**៥៨ រៀបចំខ្លួន — ហើយធ្វើកិច្ចការ**
ដោយ អែលឌើរ ហ៊ូហ្គូ អ៊ី ម៉ាទីណេ
*ផែនការរបស់ព្រះអម្ចាស់គឺថា អ្នកគឺជាអ្នកធ្វើកិច្ចការពង្សប្រវត្តិ ព្រះវិហារបរិសុទ្ធ និង កិច្ចការផ្សព្វផ្សាយសាសនា ។*

**៦០ ការចងចាំព្រះអង្គសង្គ្រោះ**
ដោយ អ៊ីរិក ប៊ី ម៉ដុក
*ពរជ័យប្រាំយ៉ាង ដែលកើតមានពីការគោរពការសន្យារបស់យើងឲ្យចងចាំព្រះយេស៊ូវគ្រីស្ទជានិច្ច ។*

**៦៤ ប័ណ្ណប្រកាស : តើមានអារម្មណ៍មិនសប់ឬ ?**

**៦៥ របៀបដែលខ្ញុំដឹង : ការរៀនធ្វើជាពន្លឺដល់ពិភពលោកនេះ**
ដោយ វិចទ័រ ឌី ដេសឺ គ្រូស វ៉ាហ្គាស




## កុមារ




**៦៦ មិនថាប្អូនគឺជានរណានោះទេ**
ដោយ លីនដា ដាវីស
*អែនឌី បានគិតថា « អូ៎ អត់ទេ ។ តើមានអ្វីនឹងកើតឡើង ប្រសិនបើខ្ញុំពុំបានផ្សារភ្ជាប់នឹងគ្រួសារខ្ញុំនោះ ? »*

**៦៨ ក្លារ៉ែន ប្រកួតនឹងកីឡាករជើងឯក**
ដោយ ឡូរី ហ្វូលើរ
*មនុស្សគ្រប់គ្នាបានមកមើលការប្រកួតរបស់ក្លារ៉ែន ហើយឃើញថា តើច្បាប់ពាក្យសម្ដីនៃប្រាជ្ញាវាងវៃនោះពិតឬទេ ។*

**៧០ កុមារដែលឈរយ៉ាងរឹងមាំ: មិត្តភក្ដិ និង សេចក្ដីជំនឿ**
ដោយ មេលីស្សា ហាត

**៧២ ចម្លើយមកពីសាវក: តើអ្នកផ្សព្វផ្សាយសាសនាត្រូវបានហៅដោយរបៀបណា ?**
ដោយអែលឌើរ អិម រ័សុល បាឡឺដ

**៧៣ ជ្រុងមួយនៃសំណួរ**
*ពេលម្ដាយ និង ឪពុកខ្ញុំឈ្លោះគ្នា ខ្ញុំមានអារម្មណ៍ព្រួយបារម្ភ និង សោកសៅ ។ តើខ្ញុំអាចធ្វើអ្វីបាន ?*

**៧៤ វីរៈបុរសក្នុងព្រះគម្ពីរមរមន: មេទ័ពមរ៉ូណៃមានចិត្តក្លាហាន**

**៧៥ ខ្ញុំអាចអានព្រះគម្ពីរមរមន**

**៧៦ រឿងចេញពីព្រះគម្ពីរមរមន: ទង់ជ័យរបស់មេទ័ពមរ៉ូណៃ**

**៧៩ តន្ត្រី: កាលខ្ញុំឮពីកុមារត្រួសត្រាយផ្លូវ**
ដោយ ជេននី ខាប ផែរី

**ខែ មិថុនា ឆ្នាំ ២០១៦ ភាគទី ៤០ លេខ ៤**
**លីអាហូណា ១៣២៨៧ 258**
ទស្សនាវដ្ដីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេស្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, អិម. រ័សុល បាឡឺដ, រ៉ូបឺត ឌី ហេល, ជែហ្វ្រី អ័រ ហូឡិន, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល ឃុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវ៉ែនសុន, ឌែល ជី រេនឡាន់

**អ្នកកែសម្រួល ៖** យ៉ូសែប ដបុលយូ. ស៊ីតាទី
**ជំនួយការអ្នកកែសម្រួល ៖** ជេមស៍ ប៊ី ម៉ាទីណូ, ខារ៉ូ អេហ្វ ម៉ាកខន់ឃី
**អ្នកប្រឹក្សា ៖** ប្រែន ខេ អាស្តុន, បែនដល ឃេ បិនណ្ណិត, ក្រេក អេ ខារដុន, ឆារិល អេ អេសព្លិន, គ្រីស្តូហ្វែល ហ្គូលឌិន, ដូហ្គ្លាស ឌី ហូលមែស, ឡែរី អរ ឡរិន, ខារ៉ូល អិម ស្ទេហ្វិន

**នាយកគ្រប់គ្រង ៖** ភីធើរ អេហ្វ អ៊ីវ៉ាន
**នាយកគ្រប់គ្រងប្រតិបត្តិការ ៖** វិនសិន អេ វ៉ូន
**នាយកគ្រប់គ្រងទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ ឡយបិហ្គ
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណុន
**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ វ៉ាល ចនសុន
**ជំនួយការការគ្រប់គ្រងផ្នែកកែសម្រួល ៖** រ៉ាយអិន ខា
**ជំនួយការបោះពុម្ព ៖** មេហ្គេន វើរហើហ្វ ស៊ីស្ស
**និពន្ធ និងកែសម្រួលដោយ ៖** ប្រ៊ិតថានី ប៊ីតធី, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវើត, ម៉ាថាយ ឌី ហ្វ៊ីតតុន, ឡរី ហ្វូលើរ, ហ្គារែត អេច ហ្គាហ្វ, ឡាប៉ែន ផតទើរ ហ្គាន, ជីល ហាកឃឹង, ឆាលទ្បិត ឡាកាបាល់, ម៉ៃយល អរ ម៉ូរីស, អ៊ីរីក ប៊ី មើរដុក សាលី ចនសុន អូដេឃីក, យ៉ូស្វេ ជេ ភីគី, ចាន ភីនបូរ៉ាហ្វ, រីឆាត អិម រ៉មនី, មីនឌី អាន សេលូ, ប៉ុល វ៉ានឌិនប៊ើហ្គ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កុត នូដសិន
**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ថែដ អ័រ ភិធើរសុន
**រចនាប្លង់ដោយ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, រ៉ាជែល ស្ម៊ីធ ស៊ី ឃីមប៊ីល ប្ញត, ថូម៉ាស ឆាល, ណាត ហ្គីនេស, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្វ្រ៊ីន, ស្កុត អិម ម៉ូយ, ម៉ាក ដបុលយូ រ៉ូប៊ីសុន, ប្រាត ធៀរ, ឃេ នីកូល វ៉ាកឃិនហូស
**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលែត នែបេឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ខន្នី បិវទួប ប្រ៊ីច, ជូលី ប៊ីដេត, ខេទី ដានខាន, ប្រែអិន ដ័បុលយូ ជីជី, ជីន្នី ជេ និលសុន, ហ្គែល ធេត រ៉ាហ៊្វីធី
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** ក្រេហ្គ ខេ សែតវីត
**នាយកផ្នែកចែកចាយ ៖** ស្ទីវិន អ័រ គ្រីស្ទានសិន

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬសាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអ៊ិនធើរណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ *Liahona*, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងហ្គារី, អាយឡែនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវេ៉, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុន្មាន គឺប្រែប្រួលទៅតាមភាសា ) ។

© 2016 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
July 2016 Vol. 15 No. 4. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# យោបល់នានាសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារបាន ។ ខាងក្រោមនេះគឺជាឧទាហរណ៍ពីរ ។*



« **ដូចជាស្ត្រីមេម៉ាយនៅសារិបតា ៖ អព្ភូតហេតុនៃដង្វាយតមអាហារ** » ទំព័រ ២៤ ៖ សូមគិតពីការអានអត្ថបទនេះជាមួយគ្នាជាគ្រួសារ ហើយបន្ទាប់មកសិក្សារឿងរបស់ស្ត្រីមេម៉ាយនៅសារិបតានៅក្នុង ពង្សាវតារក្សត្រទី ១ ១៧។ ក្រោយមកអ្នកអាចឆ្លើយសំណួរដូចតទៅនេះ ៖ តើការតមអាហារផ្តល់ពរដល់យើងម្នាក់ៗ និង គ្រួសារយ៉ាងដូចម្តេច ? តើដង្វាយតមអាហាររបស់យើងអាចជួយផ្តល់ពរដល់នរណាខ្លះ ? តើពរជ័យអ្វីខ្លះដែលយើងអាចឃើញមាននៅក្នុងគេហដ្ឋានរបស់យើង តាមរយៈការថ្វាយដង្វាយតមអាហារឲ្យកាន់តែច្រើននោះ ? អ្នកអាចពិភាក្សាពីលទ្ធភាពនៃការថ្វាយដង្វាយតមអាហារឲ្យកាន់តែច្រើន ឬ របៀបផ្សេងទៀតដែលអ្នកអាចជួយដល់ជនទ័លក្រ និង អ្នកខ្វះខាតជាមួយគ្រួសារអ្នក ។

« **ទង់ជ័យរបស់មេទ័ពម៉ូរ៉ូណៃ** » ទំព័រ ៧៦ ៖ អ្នកអាចអានអំពីមេទ័ពម៉ូរ៉ូណៃនៅក្នុងអត្ថបទនេះជាមួយគ្នាជាគ្រួសារ ។ ក្រោយមកអ្នកអាន អាលម៉ា ៤៦:១១–១៤ ហើយនិយាយអំពីអ្វីដែលបានជំរុញចិត្តឲ្យមេទ័ពម៉ូរ៉ូណៃការពារប្រជាជនរបស់លោក — « ព្រះរបស់យើង សាសនា និងសេរីភាពរបស់យើង និងសេចក្ដីសុខសាន្តរបស់យើង ភរិយារបស់យើង និងកូនចៅរបស់យើង » ។ ចំណុចទាំងនោះគឺនៅតែសំខាន់ ហើយនៅតែស្ថិតក្រោមការវាយប្រហារនាពេលបច្ចុប្បន្ននេះ ។ សូមគិតពីការបង្កើត « ទង់ឥស្សរភាព » សម្រាប់គ្រួសាររបស់អ្នកផ្ទាល់ ហើយពិភាក្សាគ្នាពីរបៀបដើម្បីការពារអ្វីៗដែលសំខាន់បំផុតចំពោះអ្នក ។

## មានធនធានជាច្រើនទៀតនៅលើអ៊ិនធើរណែត

*លីអាហូណា* និង ធនធានផ្សេងៗទៀតរបស់សាសនាចក្រ មានជាច្រើនភាសានៅលើគេហទំព័រ languages.lds.org ។ សូមមើលគេហទំព័រ facebook.com/liahona.magazine ( ដែលមានជាភាសាអង់គ្លេស ភាសាព័រទុយហ្គាល់ និង ភាសាអេស្ប៉ាញ ) ដើម្បីរកសារលិខិតដ៏បំផុសគំនិតនានា គំនិតសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ និង ឯកសារដែលអ្នកអាចចែកចាយជាមួយមិត្តភក្តិ និង គ្រួសាររបស់អ្នក ។

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយ គឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*

*ការគោរពប្រតិបត្តិ, ៨០*
*ការតមអាហារ, ២៤*
*ការបង្រៀន, ៨, ១២, ២៨, ៣០*
*ការប្រែចិត្តជឿ, ២០*
*ការពលិកម្ម, ៤*
*ការសិក្សាព្រះគម្ពីរ, ៤៤, ៤៨, ៧៥*
*ការហៅ, ៤១*
*ការអធិស្ឋាន, ២៤, ៤៨, ៦៨*
*កិច្ចការផ្សព្វផ្សាយសាសនា, ៤០, ៤៤, ៥៨, ៦៥, ៧០, ៧២*
*កិច្ចការព្រះវិហារបរិសុទ្ធ, ៣២, ៤៣, ៥០, ៥៨, ៦៦, ៧០*
*កុមារ, ៧, ៣០*
*ក្រុមគ្រួសារ, ៧, ១០, ៦៦, ៧៣, ៧៦*
*ច្បាប់ព្រហ្មចារីភាព, ៥១*
*ដង្វាយតមអាហារ, ២៤*
*ដង្វាយធួន, ១០*
*តម្លៃរបស់បុគ្គលម្នាក់ៗ, ៤២*
*ថ្នាក់សិក្ខាសាលា, ៥៨*
*និស្ស័យនៃព្រះ, ៧*
*បរិសុទ្ធភាព, ៥១*
*ផែនការនៃសេចក្ដីសង្គ្រោះ, ៦៦*
*ពង្សប្រវត្តិ, ៤២, ៤៣, ៥៨*
*ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ, ៥២, ៦៨*
*ពិធីបរិសុទ្ធ, ៣២, ៣៦, ៤៣*
*ពិធីសាក្រាម៉ង់, ៣៦, ៦០, ៦៤*
*ព្រះយេស៊ូវគ្រីស្ទ, ៤, ៣២, ៦០*
*ព្រះវរបិតាសួគ៌, ៣៦*
*ព្រះវិញ្ញាណបរិសុទ្ធ, ៤១*
*ភាពក្លាហាន, ៧៤, ៧៥*
*ភាពជាឪពុកម្ដាយ, ៧, ២៨, ៣០*
*យុវវ័យ, ២៨*
*វិទ្យាសាស្ត្រ, ៥៤*
*សម្ពាធពីមិត្តភក្តិ, ៥២*
*សេចក្ដីជំនឿ, ៤, ៤៤*
*សេចក្ដីស្រឡាញ់, ១០, ៤៤*
*សេចក្ដីសញ្ញា, ៣២, ៣៦*
*អព្ភូតហេតុ, ៥១*
*អ្នកត្រួសត្រាយ, ៤, ២០, ៧៩*

សារលិខិតគណៈប្រធានទីមួយ



ដោយ ប្រធាន
ថូម៉ាស អេស ម៉នសុន

# ស្មោះនឹងជំនឿនៃពួកបុព្វការីជនរបស់យើង

ចន លីនហ្វត មានអាយុ ៤៣ ឆ្នាំ កាលគាត់ និង ភរិយាគាត់ ម៉ារៀ ព្រមទាំងកូនប្រុសបីនាក់របស់ពួកគាត់បានសម្រេចចិត្តចាកចេញពីផ្ទះរបស់ខ្លួននៅ ហ្គ្រាវ៉េលី ប្រទេស អង់គ្លេស ដោយធ្វើដំណើរចម្ងាយរាប់ពាន់គីឡូម៉ែត្រទៅចូលរួមនឹងពួកបរិសុទ្ធនៅជ្រលងភ្នំនៃទីក្រុង សលត៍ លេក ដ៏ធំល្វឹងល្វើយ ។ ពួកគាត់បានចាកចោលកូនប្រុសទីបួនរបស់ខ្លួន ដែលកំពុងបម្រើបេសកកម្ម ហើយបានលក់ទ្រព្យសម្បត្តិខ្លួន រួចបានឡើងកប៉ាល់នៅទីក្រុង លីវើរភូលដោយជិះកប៉ាល់ឈ្មោះ *ថនតុន* ។

ការធ្វើដំណើរតាមសមុទ្រទៅកាន់ទីក្រុង នូវ យ៉ោក ហើយក្រោយមកធ្វើដំណើរតាមដីគោកទៅកាន់រដ្ឋ អៃអូវ៉ា ដែលបានបង្ហាញថាជាការធ្វើដំណើរដ៏សែនធុញថប់ណាស់ ។ ប៉ុន្តែ មិនយូរប៉ុន្មានឡើយ ក្តីអំពល់បានកើតឡើងបន្ទាប់ពីគ្រួសារ លីនហ្វត និង ពួកបរិសុទ្ធថ្ងៃចុងក្រោយដទៃទៀត ដែលបានធ្វើដំណើរតាមកប៉ាល់ *ថនតុន* ដោយចាកចេញពីទីក្រុង អៃអូវ៉ា នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៨៥៦ ដែលពួកគេគឺស្ថិតនៅក្នុងក្រុមរទេះអូស ជេមស៍ ជី វីលី ដ៏អកុសលនោះ ។

អាកាសធាតុដ៏ត្រជាក់ និង ការធ្វើដំណើរដ៏សែនលំបាកនោះបានបណ្តាលឲ្យមនុស្សជាច្រើននៅក្នុងក្រុមនោះមានជំងឺ និង ស្លាប់ ក្នុងនោះមានលោក ចន ផងដែរ ។ គាត់បានធ្លាក់ខ្លួនឈឺជាទម្ងន់ ហើយខ្សោយជាខ្លាំងរហូតដល់គេដាក់គាត់នៅលើរទេះធ្វើដំណើរនោះ ។ នៅពេលក្រុមនោះបានទៅដល់ រដ្ឋ វ៉ាយអូមីង ជំងឺរបស់គាត់កាន់តែមានសភាពធ្ងន់ធ្ងរទៅៗ ។ ក្រុមសង្គ្រោះមកពីទីក្រុង សលត៍ លេក បានមកដល់នៅថ្ងៃទី ២១ ខែ តុលា គឺគ្រាន់តែប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពី ចន បានផុតដង្ហើមលាចាកលោកនេះទៅ ។ គាត់បានចែកឋានទៅនៅព្រឹកព្រលឹមនោះនៅក្បែរច្រាំងទន្លេ ស្វីតវ៉តធើរ ។

តើ ចន សោកស្តាយឬ ដែលគាត់បានប្តូរភាពស្រណុកសុខស្រួលរបស់ខ្លួនជាមួយនឹងការលំបាក ការឈឺចាប់ និង ក្តីវេទនាដោយនាំគ្រួសាររបស់គាត់ទៅទីក្រុងស៊ីយ៉ូននោះ ?

គាត់បានប្រាប់ភរិយារបស់គាត់ពីមុនគាត់ហៀបនឹងស្លាប់ថា « ទេ បងមិនសោកស្តាយទេ ម៉ារៀ ។ បងសប្បាយចិត្តណាស់ដែលពួកយើងបានធ្វើដំណើរមកទីនេះ ។ បងនឹងមិនអាចរស់នៅរហូតដល់យើងទៅដល់ទីក្រុង សលត៍ លេកទេ ប៉ុន្តែ អូន និង កូនៗនឹងទៅដល់ទីនោះ ហើយបងគ្មានការសោកស្តាយចំពោះអ្វីៗដែលយើងបានហែលឆ្លងមកជាមួយគ្នាឡើយ ប្រសិនបើកូនៗរបស់យើងអាចធំឡើង ហើយចិញ្ចឹមគ្រួសាររបស់ពួកគេនៅក្នុងទីក្រុង ស៊ីយ៉ូននោះ » ។[១]

ម៉ារៀ និង កូនៗរបស់នាងបានទៅដល់គោលដៅនៃដំណើររបស់ខ្លួន ។ ជិត ៣០ ឆ្នាំក្រោយមកនៅពេល ម៉ារៀបានចែកឋានទៅ នាង និង ចនបានបន្សល់ទុកនូវកេរមរតកនៃសេចក្តីជំនឿ ការបម្រើ ការឧទ្ទិស និង ការបូជា ។

ដើម្បីធ្វើជាពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺត្រូវធ្វើជាអ្នកត្រួសត្រាយ ចំពោះនិយមន័យនៃពាក្យថាអ្នកត្រួសត្រាយគឺជា « មនុស្សដែលដើរទៅមុន ដើម្បីរៀបចំ ឬ បើកផ្លូវសម្រាប់មនុស្សដទៃទៀតឲ្យដើរតាម » ។[២] ហើយដើម្បីធ្វើជាអ្នកត្រួសត្រាយ គឺត្រូវតែស្គាល់ពីការបូជា ។ ទោះបីជាសមាជិកសាសនាចក្រពុំតម្រូវឲ្យចាកចេញពីផ្ទះរបស់ខ្លួន ហើយធ្វើដំណើរទៅទីក្រុង ស៊ីយ៉ូនទៀតក្តី ក៏ជារឿយៗពួកគេត្រូវតែទម្លាក់ចោលនូវទម្លាប់ចាស់ៗ សណ្តាប់ពីបុរាណ និង មិត្តភក្តិជាទីស្រឡាញ់បំផុត ។ មនុស្សមួយចំនួនបានសម្រេចចិត្តទាំងឈឺចាប់ ដើម្បីចាកចោលសមាជិកគ្រួសារខ្លួន ដែលប្រឆាំងនឹងភាពជាសមាជិកក្នុងសាសនាចក្ររបស់ពួកគេ ។ ប៉ុន្តែ ពួកបរិសុទ្ធថ្ងៃចុងក្រោយបានបន្តឆ្ពោះទៅមុខ ដោយអធិស្ឋានថាមនុស្សជាទីស្រឡាញ់ទាំងនោះនឹងយល់ ហើយទទួលយកនៅថ្ងៃណាមួយ ។

ផ្លូវរបស់អ្នកត្រួសត្រាយគ្មានភាពងាយស្រួលឡើយ ប៉ុន្តែយើងដើរតាមដាននៃអ្នកត្រួសត្រាយដ៏អស្ចារ្យបំផុត — គឺព្រះអង្គសង្គ្រោះ — ដែលទ្រង់បានយាងមុនគេ ដោយបង្ហាញដល់យើងនូវមាគ៌ាដើម្បីដើរតាម ។

ទ្រង់បានអញ្ជើញថា « ចូរមកតាមខ្ញុំ » ។[៣]

ទ្រង់បានប្រកាសថា « ខ្ញុំជាផ្លូវជាសេចក្តីពិត និង ជាជីវិត » ។[៤]



ក្រុមគ្រួសារអ្នកត្រួសត្រាយលុតជង្គង់នៅលើព្រិល ដោយ ម៉ៃឃល ធី ម៉ល

ទ្រង់បានអំពាវនាវថា « ចូរមកតាមខ្ញុំ » ។[៥]

ជាផ្លូវដែលយើងអាចសាកល្បងបាន ។ មានមនុស្សមួយចំនួនពិបាកទ្រាំទ្រនឹងសេចក្ដីចំអក និង ពាក្យសម្ដីដ៏អាក្រក់នៃជនឆោតល្ងង់ដែលចំអកដល់ព្រហ្មចារីភាព សេចក្ដីស្មោះត្រង់ និង ការគោរពប្រតិបត្តិដល់ព្រះបញ្ញត្តិនៃព្រះ ។ ពិភពលោកនេះតែងតែបន្ទាបបន្ថោកដល់ការឱបក្រសោបយកគោលការណ៍ទាំងនេះ ។ នៅពេល ណូអេ ត្រូវបានបង្គាប់ឲ្យសង់ទូកធំមួយ នោះមានពួកមនុស្សល្ងីល្ងើបានសម្លឹងមើលទៅលើផ្ទៃមេឃដ៏ស្រឡះ រួចហើយបានសើចចំអកឡុកឡឺយ — រហូតដល់ភ្លៀងបានធ្លាក់ចុះមក ។

កាលពីច្រើនសតវត្សរ៍យូរលង់ណាស់មកហើយនៅទ្វីបអាមេរិកមានមនុស្សដែលសង្ស័យ ឈ្លោះប្រកែកគ្នា ព្រមទាំងពុំគោរពតាម រហូតដល់ភ្លើងបានឆេះលេបត្របាក់ទីក្រុង សារ៉ាហិមឡា ទីក្រុងម៉ូរ៉ូណៃហាត្រូវបានលេចចុះ ហើយទឹកស្រុបពន្លិចទីក្រុង ម៉ូរ៉ូណៃ ។ ការសើចឡុកឡឺយ ការចំអកសម្ដីអាសគ្រាម និង អំពើបាបគ្មានទៀតឡើយ ។ វាត្រូវបានជំនួសដោយភាពស្ងាត់ឈឹង និង ភាពងងឹតយ៉ាងក្រាស់ ។ ការអត់ធ្មត់របស់ព្រះបានផុតកំណត់ ហើយកាលវិភាគរបស់ទ្រង់ត្រូវបានបំពេញ ។

ម៉ារៀ លីនហ្វូតពុំបោះបង់សេចក្ដីជំនឿរបស់នាងឡើយ បើទោះបីជាមានការបៀតបៀននៅក្នុងប្រទេសអង់គ្លេសក្ដី ការលំបាកនៅក្នុងការធ្វើដំណើររបស់នាងទៅកាន់ « កន្លែងដែលព្រះ . . . រៀបទុក »[៦] និង ការសាកល្បងបន្តបន្ទាប់ទៀតដែលនាងបានស៊ូទ្រាំចំពោះគ្រួសារនាង និង សាសនាចក្រ ។

នៅឆ្នាំ ១៩៣៧ ក្នុងពិធីឧទ្ទិសផ្នូរដើម្បីរំឭកចាំដល់ម៉ារៀ នោះអែលឌើរ ចច អ័លប៊ើត ស្មីធ ( ឆ្នាំ ១៨៧០–១៩៥១ ) បានសួរដល់កូនចៅរបស់នាង ៖ « តើបងប្អូនទាំងអស់គ្នា នឹងរស់នៅដោយស្មោះនឹងជំនឿនៃពួកបុព្វការីជនរបស់អ្នកដែរឬទេ ? . . . ចូរព្យាយាមឲ្យមានភាពសក្ដិសមចំពោះការបូជាទាំងអស់ដែល [ ពួកគេ ] បានធ្វើចំពោះបងប្អូន » ។[៧]

នៅពេលយើងព្យាយាមស្ថាបនាទីក្រុងស៊ីយ៉ូននៅក្នុងដួងចិត្ត គេហដ្ឋាន សហគមន៍របស់យើង និង ក្នុងប្រទេសរបស់យើង នោះយើងអាចចងចាំពីភាពក្លាហានដ៏មុតមាំ និង ការកាន់ខ្ជាប់នូវសេចក្ដីជំនឿនៃអស់អ្នកដែលផ្ដល់នូវអ្វីៗគ្រប់បែបយ៉ាង ដែលធ្វើឲ្យយើងអាចរីករាយនឹងពរជ័យនៃដំណឹងល្អដែលបានស្ដារឡើងវិញ ដោយមានសេចក្ដីសង្ឃឹម និង ការសន្យាតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ■

**កំណត់ចំណាំ**

១. សូមមើល អែនឌ្រូ ធី អូលសិន *The Price We Paid* ( ឆ្នាំ ២០០៦ ) ទំព័រ ៤៥–៤៦, ១៣៦–៣៧ ។
២. *The Compact Edition of the Oxford English Dictionary* ( ឆ្នាំ ១៩៧១ ) « pioneer » ។
៣. លូកា ១៨:២២។
៤. យ៉ូហាន ១៤:៦។
៥. យ៉ូហាន ៧:៣៧សូមមើលផងដែរ នីហ្វៃទី ៣ ៩:២២។
៦. « មកមកពួកបរិសុទ្ធ » *ទំនុកតម្កើង* លេខ ១៨ ។
៧. សូមមើល អូលសិន *The Price We Paid* ទំព័រ ២០៣-៤ ។

**ការបង្រៀនចេញពីសារលិខិតនេះ**

ប្រគិតពីការសួរដល់អស់អ្នកដែលអ្នកបង្រៀនឲ្យគិតពីមនុស្សទាំងឡាយនៅក្នុងជីវិតរបស់ពួកគេ ដែលបានរស់នៅកាលពីមុន ហើយធ្លាប់ធ្វើជាអ្នកត្រួសត្រាយសម្រាប់ពួកគេ ។ បន្ទាប់មកសួរពួកគេថា តើពេលណាពួកគេត្រូវតែធ្វើជាអ្នកត្រួសត្រាយ ហើយរៀបចំផ្លូវសម្រាប់មនុស្សដទៃ ។ សូមអញ្ជើញពួកគេឲ្យពិចារណាពីគ្រានានាដែលពួកគេត្រូវតែលះបង់ និង ពីមូលហេតុដ៏មានប្រយោជន៍នៃការលះបង់នោះ ។ បន្ទាប់មក អ្នកអាចអញ្ជើញពួកគេឲ្យកត់ទីបន្ទាល់របស់ខ្លួនអំពី « អ្នកត្រួសត្រាយដ៏អស្ចារ្យបំផុត » គឺព្រះអង្គសង្គ្រោះ ។

យុវវ័យ

## ស្មោះនឹងជំនឿ

ប្រធាន ម៉នសុន បាននិទានរឿងមួយអំពីគ្រួសារអ្នកត្រួសត្រាយម្នាក់ ហើយបានដកស្រង់ប្រសាសន៍របស់ប្រធាន ចច អ័លបើត ស្មីធ ៖ « តើបងប្អូនទាំងអស់គ្នា នឹងរស់នៅដោយស្មោះនឹងជំនឿនៃពួកបុព្វការីជនរបស់អ្នកដែរឬទេ ? . . . ចូរព្យាយាមឲ្យមានភាពសក្ដិសមចំពោះការបូជាទាំងអស់ដែល [ ពួកគេ ] បានធ្វើចំពោះបងប្អូន » ។ មិនថាអ្នកមានបុព្វការីជនដែលជាអ្នកត្រួសត្រាយ ឬ អ្នកគឺជាសមាជិកសាសនាចក្រជំនាន់ទីមួយនោះទេ តើអ្នកសម្លឹងទៅគំរូនៃសេចក្ដីជំនឿ ដើម្បីទទួលបានការណែនាំ និង កម្លាំងដែរឬទេ ? នេះជារបៀបល្អមួយដែលអ្នកចាប់ផ្ដើម ៖

១. ធ្វើបញ្ជីឈ្មោះមនុស្សដែលអ្នកគោរពកោតសរសើរ ។ ពួកគេអាចជាសមាជិកគ្រួសារផ្ទាល់របស់អ្នក ( ពីអតីតកាល ឬ បច្ចុប្បន្នកាល ) មិត្តភក្ដិ ថ្នាក់ដឹកនាំសាសនាចក្រ ឬ មនុស្សនៅក្នុងព្រះគម្ពីរ ។

២. សរសេរគុណសម្បត្តិនានាដែលអ្នកចូលចិត្តពីពួកគេ ។ តើម្ដាយរបស់អ្នកពិតជាមានការអត់ធ្មត់ឬទេ ? ប្រហែលជាមិត្តភក្ដិរបស់អ្នកមានចិត្តសប្បុរសចំពោះមនុស្សដទៃ ។ ប្រហែលជាអ្នកចូលចិត្តភាពអង់អាចក្លាហានរបស់មេទ័ព ម៉ូរ៉ូណៃ ។

៣. រើសគុណសម្បត្តិមួយមកពីបញ្ជីរបស់អ្នក ហើយសួរខ្លួនឯងថា « តើខ្ញុំអាចទទួលបានគុណសម្បត្តិនេះតាមរបៀបណា ? តើខ្ញុំត្រូវធ្វើអ្វីខ្លះ ដើម្បីអភិវឌ្ឍគុណសម្បត្តិនេះនៅក្នុងជីវិតរបស់ខ្ញុំនោះ ? »

៤. សរសេរផែនការរបស់អ្នកដើម្បីអភិវឌ្ឍគុណសម្បត្តិនេះ ហើយទុកវានៅកន្លែងណាមួយដែលអ្នកនឹងឃើញវាជារឿយៗ ដើម្បីរំឭកអ្នកពីគោលដៅរបស់អ្នក ។ អធិស្ឋានទូលសុំជំនួយពីព្រះវរបិតា ហើយពិនិត្យមើលការរីកចម្រើនរបស់អ្នកជាទៀងទាត់ ។ នៅពេលណាអ្នកមានអារម្មណ៍ថា អ្នកបានអភិវឌ្ឍគុណសម្បត្តិនោះបានគ្រប់គ្រាន់ហើយ នោះអ្នកអាចរើសយកគុណសម្បត្តិថ្មីមួយទៀតមកអភិវឌ្ឍម្ដង ។



សូមចាំថា នៅពេលយើងអភិវឌ្ឍគុណសម្បត្តិដ៏អស្ចារ្យនានានៅក្នុងខ្លួនរបស់យើង នោះយើងពុំគ្រាន់តែគោរពសេចក្ដីជំនឿ និង ការបូជារបស់បុព្វការីជនរបស់យើង ដែលពួកគាត់បានធ្វើប៉ុណ្ណោះទេ ប៉ុន្តែយើងក៏អាចក្លាយជាមនុស្សដែលជះឥទ្ធិពលល្អដល់អស់អ្នកដែលនៅជុំវិញយើងផងដែរ ។

កុមារ

## អ្នកក៏ជាអ្នកត្រួសត្រាយដែរ !

អ្នកត្រួសត្រាយគឺជាមនុស្សដែលរៀបចំផ្លូវសម្រាប់មនុស្សដទៃទៀតឲ្យដើរតាម ។

សូមគូរគំនូរ ឬ ស្វែងរករូបថតមួយនៃបុព្វការីជនរបស់អ្នក ។ តើអ្នកអាចស្វែងរករឿងមួយអំពីរបៀបដែលពួកគេបានរៀបចំផ្លូវដល់មនុស្សដទៃទៀតឲ្យដើរតាមបានទេ ? សូមសរសេរវិធីពីរយ៉ាងដែលអ្នកអាចក្លាយជាអ្នកត្រួសត្រាយនាពេលបច្ចុប្បន្ននេះ ។ អ្នកអាចចែកចាយគំនិតរបស់អ្នកនៅក្នុងកម្មវិធីរាត្រីជួបជុំក្រុមគ្រួសារសប្ដាហ៍ក្រោយរបស់អ្នក !




រូបថត © ISTOCK/THINKSTOCK

*សូមសិក្សាអត្ថបទនេះប្រកបដោយការអធិស្ឋាន ហើយព្យាយាមស្វែងរកអ្វីដែលត្រូវចែកចាយ ។ តើការយល់ដឹងពី « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » បង្កើនសេចក្ដីជំនឿរបស់អ្នកទៅលើព្រះ ហើយប្រទានពរដល់អ្នកទាំងឡាយដែលអ្នកមើលថែទាំ តាមរយៈការបង្រៀនសួរសុខទុក្ខយ៉ាងដូចម្ដេច ? សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ reliefsociety.lds.org ។*

# សក្ដានុពលរបស់យើង សម្រាប់ភាពជាឪពុកម្ដាយ



អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា « វាគឺជាការណ៍ចាំបាច់ថា កូនចៅវិញ្ញាណរបស់ព្រះមានកំណើតនៃជីវិតរមែងស្លាប់ និង មានឱកាសដើម្បីរីកចម្រើនឆ្ពោះទៅកាន់ជីវិតអស់កល្បជានិច្ច ។ នៅក្នុងពន្លឺនៃគោលបំណងដ៏អស្ចារ្យបំផុតនៃផែនការសុភមង្គលដ៏មហិមា នោះខ្ញុំជឿថា សម្បត្តិធំបំផុតលើផែនដី និងស្ថានសួគ៌គឺជាកូនចៅយើង និងពូជពង្សយើង » ។[១]

អែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ ៖

« យើងជឿលើក្រុមគ្រួសារទាំងឡាយ ហើយយើងជឿជាក់លើកូនចៅទាំងអស់ ។ . . .

‹ . . . ព្រះបានមានបន្ទូលទៅ [ អ័ដាម និង អេវ៉ា ] ថា ចូរបង្កើតកូនឲ្យចម្រើនជាច្រើនឡើង ឲ្យមានពាសពេញលើផែនដីចុះ › [ លោកុប្បត្តិ ១:២៨ ] ។ . . .

បទបញ្ញត្តិនេះពុំត្រូវបានបំភ្លេច ឬ ព្រងើយកន្តើយនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » ឡើយ ។[២]

បើទោះបីជាមនុស្សយើងទាំងអស់គ្នាពុំអាចក្លាយជាឪពុកម្ដាយនៅក្នុងជីវិតនេះក្ដី ក៏យើងអាចចិញ្ចឹមបីបាច់កូនៗគ្រប់វ័យទាំងអស់ ។ យើងរីករាយនឹងពរជ័យនៃការធ្វើជាផ្នែកមួយនៃគ្រួសាររបស់ព្រះវរបិតាសួគ៌ ហើយយើងទទួលបទពិសោធន៍នៃសេចក្ដីអំណរ ព្រមទាំងឧបសគ្គនានានៃការក្លាយជាផ្នែកមួយនៃគ្រួសារនៅលើផែនដីនេះ ។ ហើយសម្រាប់មនុស្សជាច្រើនទៀត ភាពជាឪពុកម្ដាយកំពុងរង់ចាំពួកគេនៅក្នុងភាពអស់កល្បនាពេលខាងមុខ ។

### *បទគម្ពីរបន្ថែម*

ទំនុកដំកើង ១២៧:៣; ម៉ាថាយ ១៨:៣–៥; នីហ្វៃទី ១ ៧:១; ម៉ូសេ ៥:២–៣

### *សូមពិចារណាអំពីសំណួរនេះ*

តើគ្រួសាររបស់យើងនៅលើផែនដីនេះដូចគ្នាទៅនឹងគ្រួសាររបស់យើងនៅឋានសួគ៌យ៉ាងដូចម្ដេចខ្លះ ?

**សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ**

### *រឿងពិតដែលបានកើតឡើង*

អែលឌើរ អាន់ឌើរសិន មានប្រសាសន៍ថា « សំឡេងជាច្រើននៅក្នុងពិភពលោកសព្វថ្ងៃនេះ ពង្វាងនូវសារៈសំខាន់ក្នុងការមានកូន ឬក៏ប្រាប់ថា វាជាការត្រឹមត្រូវក្នុងការពន្យាពេល ឬកំណត់ចំនួនកូននៅក្នុងក្រុមគ្រួសារ ។ ថ្មីៗនេះ កូនស្រីរបស់ខ្ញុំបានណែនាំខ្ញុំឲ្យស្គាល់គេហទំព័រមួយ ដែលសរសេរដោយម្ដាយជាគ្រីស្ទានម្នាក់ ( មិនមែននៅក្នុងព្រះវិហារយើង ) ដែលមានកូនប្រាំនាក់ ។ នាងបានអធិប្បាយ ៖ ‹ [ ការធំឡើង ] នៅក្នុងវប្បធម៌នេះ វាពិបាកណាស់ក្នុងការទទួលបាននូវទស្សនៈដែលផ្អែកលើព្រះគម្ពីរប៊ីប អំពីភាពជាម្ដាយ ។ . . . កូនៗប្រែទៅជាមិនសំខាន់ដូចទៅរៀនមហាវិទ្យាល័យទេ ។ ប្រាកដណាស់ គឺមិនសំខាន់ដូចទៅដើរលេងជុំវិញពិភពលោកទេ ។ មិនសំខាន់ដូចជាចេញទៅក្រៅពេលយប់សម្រាប់ការសប្បាយនោះទេ ។ មិនសំខាន់ដូចជាការហាត់ប្រាណរបស់អ្នកនោះទេ ។ មិនសំខាន់ដូចជាការងារដែលអ្នកអាចនឹងទទួល ឬសង្ឃឹមថានឹងទទួលនោះទេ › ។ បន្ទាប់មក នាងបន្ថែមទៀតថា ៖ ‹ ភាពជាម្ដាយពុំមែនជាការកម្សាន្តមួយនោះទេ វាជាការហៅបម្រើ ។ អ្នកពុំសន្សំទុកកូនចៅ ដោយសារអ្នកឃើញថា ពួកគេស្រស់ស្អាតជាងតែមសំបុត្រឡើយ ។ វាមិនមែនជាអ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកអាចឆ្លៀតពេលធ្វើបាននោះទេ ។ វាជាអ្វីដែលព្រះផ្ដល់ពេលវេលាដល់អ្នកដើម្បីធ្វើវា › » ។[៣]

កំណត់ចំណាំ
១. ដាល្លិន អេក អូក « The Great Plan of Happiness » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ទំព័រ ៧២, ៧៥ ។
២. នែល អិល អាន់ឌើរសិន « Children » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២៨ ។
៣. នែល អិល អាន់ឌើរសិន « Children » ទំព័រ ២៨ ។

# ការគាំទ្រសេរីភាពខាងសាសនា

មនុស្សនៅក្នុងប្រជាជាតិទាំងអស់គប្បី ធ្វើការរួមគ្នាដើម្បីជំរុញឲ្យមានសេរីភាពខាងសាសនា ថ្នាក់ដឹកនាំសាសនាចក្របានថ្លែងពីចំណុចនេះជាញឹកញាប់ ។

នៅក្នុងការប្រជុំសន្និបាតសាសនារបស់លោក ចន អេ វីដស្ដូ នៅសាកលវិទ្យាល័យ កាលីហ្វូញ៉ា ភាគខាងត្បូងនៅក្នុងទីក្រុង ឡូស អាន់ជើឡេស ទីក្រុង កាលីហ្វូញ៉ា ស.រ.អា. នៅក្នុងខែ មេសា ឆ្នាំ ២០១៥ ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ បានមានប្រសាសន៍ថា « សមាជិកសាសនាចក្រព្យាយាមបង្កើតចិត្តប្រកបដោយក្ដីសប្បុរសនៅក្នុងចំណោមប្រជាជននៃគ្រប់ជំនឿសាសនា ទស្សនៈនយោបាយ និង គ្រប់ពូជសាសន៍ទាំងអស់ » ។

ប្រធាន អុជដូហ្វបានមានប្រសាសន៍ថា « កិច្ចខិតខំដើម្បីលុបបំបាត់ទម្លាប់នៃការមិនទុកចិត្ត និង ភាពកំណាញ់ស្វិត ព្រមទាំងការយល់ពីគ្នាតាមរបៀបថ្មី — គឺការយល់ពីគ្នាថាមិនមែនជាជនចម្លែក ឬ សត្រូវឡើយ ប៉ុន្តែជាការយល់ពីគ្នាថាជាអ្នកធ្វើដំណើររួមគ្នា ជាបងប្អូនប្រុសស្រីនឹងគ្នា និង ជាកូនចៅរបស់ព្រះ — គឺជារឿងលំបាកបំផុតមួយស្របពេលជាមួយនឹងការមានបទពិសោធន៍នៃការពេញចិត្ត និង លើកស្ទួយនៃជីវិតរបស់មនុស្ស » ។ ការស្នើសុំមួយរបស់ទ្រង់ចំពោះការគោរព និង យល់ដឹងពីការណ៍នេះនោះគឺធ្វើឡើងដោយព្យាការី និង សាវកនាពេលថ្មីៗនេះ ។

នៅសន្និសីទ តុលាការ/បព្វជិត នៅឯក្រុមជំនុំ ប៊ី ណាយ អ៊ីស្រាអែល នៅក្នុងទីក្រុង សាក្រាម៉ង់តូ រដ្ឋ កាលីហ្វូញ៉ា ស.រ.អា. នៅក្នុងខែ តុលា ឆ្នាំ ២០១៥ អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា « ពុំគួរគប្បីមានសង្គ្រាមរវាងសាសនា និង រដ្ឋាភិបាលឡើយ » ។ លោកបានមានប្រសាសន៍ថា « យើងទាំងអស់គ្នានឹងចាញ់ នៅពេលមានអារម្មណ៍នៃកំហឹង ឬ ភាពជាសត្រូវ ឬ ជម្លោះកើតមានឡើង ។



*ការប្រជុំជាមួយក្រុមសមាជិកសភានៅក្នុងទីក្រុង ឡុងដ៍ ប្រទេស អង់គ្លេស អែលឌើរ ហូឡិន មានប្រសាសន៍ថា មនុស្សដែលមានជំនឿសាសនាមានអំណាចដើម្បីជំរុញលើកស្ទួយសង្គម ។*

លោកបានមានប្រសាសន៍ថា « រដ្ឋាភិបាល និង ច្បាប់របស់ខ្លួនអាចផ្ដល់នូវការការពារជាចាំបាច់សម្រាប់អ្នកមានជំនឿលើសាសនា និង អង្គការសាសនា ព្រមទាំងសកម្មភាពរបស់ពួកគេ ។ គួរកត់សម្គាល់ថាគោលការណ៍ ការបង្រៀន និង អង្គការសាសនា អាចជួយបង្កើតលក្ខខណ្ឌដែលច្បាប់សាធារណៈ និង ស្ថាប័ននានារបស់រដ្ឋាភិបាល ព្រមទាំងប្រជាពលរដ្ឋរបស់ខ្លួនអាចរីកចម្រើន ប្រយោជន៍ឲ្យមនុស្សទាំងអស់អាចរស់នៅជាមួយគ្នាដោយមានសុភមង្គល សុខដុម និង សុខសាន្ត » ។

អែលឌើរ អូក ក៏បានថ្លែងអំពីសេរីភាពខាងសាសនានៅឯការប្រជុំនៅក្នុងប្រទេស អាហ្សង់ទីន ផងដែរ ( សូមមើល « News of the Church » *Liahona,* ខែ មករា ឆ្នាំ ២០១៦ ទំព័រ ១៦ ) ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងសុន្ទរកថាដល់ក្រុមសមាជិកសភាពីគ្រប់គណបក្សទាំងអស់ស្ដីអំពីកិច្ចការបរទេសនៅក្នុងដំណាក់របស់ព្រះអម្ចាស់នៅក្នុងទីក្រុង ឡុងដ៍ ប្រទេស អង់គ្លេស កាលពីខែ មិថុនា ឆ្នាំ ២០១៥ ។ លោកបានថ្លែងថា « តាមរយៈការស្នើសុំដល់ការគោរពតម្លៃដ៏ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ សាសនា និង អង្គការសាសនានានាមានកាតព្វកិច្ចពិសេសមួយដើម្បីជំរុញមនុស្ស និង ស្របពេលគ្នានោះ បណ្ដុះឥរិយាបថនៃការអភ័យទោស ការស្រុះស្រួលនឹងគ្នា ព្រមទាំងសុឆន្ទៈព្យាយាមម្ដងទៀតសម្រាប់ឧត្តមគតិនៅក្នុងជីវិតផ្ទាល់ខ្លួនម្នាក់ និង នៅក្នុងសង្គមរបស់ពួកគេ » ។

នៅឯការប្រជុំវិហារ អ៊ីស្លាម ប្រេស៊ីល នៅក្នុងទីក្រុង សៅ ប៉ូឡូ ប្រទេស ប្រេស៊ីល កាលពីខែ មេសា ឆ្នាំ ២០១៥ អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានប្រាប់ក្រុមអន្តរជំនឿថា « សេរីភាពខាងសាសនាគឺជាថ្មសីមានៃសេចក្ដីសុខសាន្តនៅក្នុងពិភពលោក ដែលមានអ្នកប្រាជ្ញវិទូប្រកួតប្រជែងជាច្រើន » ។ លោកបានមានប្រសាសន៍ជាភាសាព័រទុយហ្គាយដល់អ្នកស្ដាប់



*នៅឯសន្និសីទសាសនានៅក្នុងរដ្ឋ កាលីហ្វូញ៉ា ស.រ.អា. អែលឌើរ អូក បានអំពាវនាវសុំឲ្យមានការគោរពគ្នារវាងសាសនាចក្រ និង រដ្ឋ ។*



*នៅឯការប្រជុំនៃអ្នកមានជំនឿសាសនានៅក្នុងប្រទេស ប្រេស៊ីល អែលឌើរ គ្រីស្តូហ្វឺសិន មានប្រសាសន៍ថា « សេរីភាពខាងសាសនាគឺជាថ្មសីមានៃភាពសុខសាន្ត » ។*



*ប្រធាន អុជដូហ្វ និង ភរិយារបស់លោក ហារៀត ជួបជាមួយថ្នាក់ដឹកនាំសាសនានានានៅក្នុងរដ្ឋ កាលីហ្វូញ៉ា ស.រ.អា. ។*





*អែលឌើរ រ៉ាសបាន ទូន្មានឲ្យនិស្សិតនៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ឲ្យធ្វើតាមការបង្រៀនរបស់ព្រះគ្រីស្ទដើម្បីស្រឡាញ់មនុស្សដូចជាទ្រង់បានស្រឡាញ់ពួកគេដែរ ។*

ដែលរួមមានពួកអ៊ីស្លាម កាតូលិក អែតវិនធីស យូដា ពួកអ៊ីវែនជែលីខល ពួកបរិសុទ្ធថ្ងៃចុងក្រោយ ពួកអ្នកគោរពវិញ្ញាណអ្នកស្រុកដើម មនុស្សដែលគ្មានជំនឿជាក់លាក់ និង មនុស្សដទៃទៀត អំឡុងពេលប្រារព្ធពិធីធ្វើការគាំទ្រឥស្សរភាពសាសនារបស់ជាតិ ។ លោកបានមានប្រសាសន៍ថា « ចូរយើងស្វែងរកភាពសុខសាន្ត តាមរយៈការធ្វើការរួមគ្នា ដើម្បីអភិរក្ស និង ការពារសិទ្ធិសេរីភាពរបស់មនុស្សទាំងអស់ ដើម្បីគាំទ្រ និង បង្ហាញពីជម្រើសសាសនាមួយ ឬ ជំនឿមួយរបស់ពួកគេ មិនថាជាបុគ្គលម្នាក់ៗ ឬ ជាសហគមន៍ជាមួយមនុស្សដទៃ នៅគេហដ្ឋាន ឬ នៅក្រៅប្រទេស នៅទីសាធារណៈ ឬ នៅកន្លែងឯកជន និង ការថ្វាយបង្គំ ការប្រតិបត្តិតាម ការអនុវត្ត និង ការបង្រៀន » ។

នៅពេលលោកថ្លែងសុន្ទរកថានៅឯការបង្រៀនពីសេរីភាពខាងសាសនាប្រចាំឆ្នាំនៅសាកលវិទ្យាល័យណូត ឌែម អូស្ត្រាលី នៅក្នុងទីក្រុង ស៊ីតនី ប្រទេសអូស្ត្រាលី កាលពីខែ ឧសភា ឆ្នាំ ២០១៥ អែលឌើរ ឃ្វីនថិន អិល ឃុក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា « មនុស្សដែលមានសេចក្តីជំនឿត្រូវតែនៅជួរមុខគេក្នុងការការពារសេរីភាពខាងសាសនា — គឺជាសេរីភាពមួយដែលធ្វើឲ្យសេរីភាពចាំបាច់ដទៃទៀតកើតឡើងបាន » ។ លោកបានមានប្រសាសន៍ថា « យើងមិនត្រឹមតែការពារសមត្ថភាពរបស់យើងដើម្បីប្រកាសពីសាសនាផ្ទាល់របស់យើងនោះទេ ប៉ុន្តែយើងត្រូវតែការពារសិទ្ធិនៃសាសនានិមួយៗ ដើម្បីចាត់ចែងគោលលទ្ធិ និង ក្រឹត្យវិន័យផ្ទាល់របស់វាផងដែរ » ។

អែលឌើរ រ៉ូណាល អេ រ៉ាសបាន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ដែលកាលនោះកំពុងបម្រើជាប្រធានច្បងគេ នៃប្រធាននៃពួកចិតសិបនាក់ នៅពេលលោកបានមានប្រសាសន៍ទៅកាន់និស្សិតនៅឯសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ នៅក្នុងទីក្រុង ប្រូវ៉ូ រដ្ឋ យូថាហ៍ ស.រ.អា. នៅក្នុងខែ កញ្ញា ឆ្នាំ ២០១៥ ។

លោកបានមានប្រសាសន៍ថា « មនុស្សមួយចំនួនដែលមានអាយុស្របាលអ្នក ងឿងឆ្ងល់ពីមូលហេតុដែលក្រុមសាសនាមានជាប់ទាក់ទិននឹងរឿងនយោបាយតាំងពីដំបូង ហើយពួកគេសង្ស័យជារឿយៗពីការជំរុញទឹកចិត្តរបស់អ្នកមានជំនឿសាសនា នៅពេលពួកគេធ្វើបែបនេះ ។ សំឡេងនៃក្រុមទាំងនេះដែលទទួលអារម្មណ៍ថា សាសនាពុំគប្បីដើរតួនៅក្នុងការពិភាក្សានយោបាយដែលបានកើនឡើងយ៉ាងខ្លាំងនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះឡើយ ដែលវាបង្កើនគ្រោះថ្នាក់នៃការបង្កើតនូវឋានៈនៃការទទួលរងគ្រោះមួយផ្សេងទៀត ៖ គឺមនុស្សដែលមានជំនឿ ដូចជារូបអ្នក និង រូបខ្ញុំ » ។

អែលឌើរ រ៉ាសបាន បានប្រាប់និស្សិតទាំងនោះថា ពិភពលោកនេះត្រូវការអ្នកជាប់ទាក់ទងយ៉ាងសកម្មចេញពីជំនាន់របស់ពួកគេស្តីពីប្រធានបទនេះ ។ « យើងត្រូវការឲ្យជំនាន់របស់អ្នកមានការយល់ដឹងជាសាកលនូវសេចក្តីមេត្តាករុណា ការគោរព និង ភាពយុត្តិធម៌ ។ យើងត្រូវការភាពសុទ្ធិដ្ឋិនិយមរបស់អ្នក និង ការប្តេជ្ញាចិត្តរបស់អ្នកដើម្បីដោះស្រាយបញ្ហាសង្គមដ៏ស្មុគស្មាញនេះ ។ លោកបានមានប្រសាសន៍ថា ចម្លើយនោះគឺត្រូវចាប់ផ្តើមជាមួយបទបញ្ញត្តិរបស់ព្រះអង្គសង្គ្រោះឲ្យ « ស្រឡាញ់ដល់គ្នាទៅវិញទៅមក ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ » ( យ៉ូហាន ១៣:៣៤ ) ។ ■

*សូមចូលទៅកាន់គេហទំព័រ news.lds.org សម្រាប់ព័ត៌មាន និងព្រឹត្តិការណ៍នានាបន្ថែមទៀតរបស់សាសនាចក្រ ។*

# ស្រឡាញ់អ្នកដទៃដែលមានគុណតម្លៃផ្សេងពីយើង

ឈ្មោះត្រូវបានដកចេញ

*ខ្ញុំបានព្យាយាមចិញ្ចឹមកូនៗរបស់ខ្ញុំឲ្យមានតម្លៃសីលធម៌ខ្ពស់ ។ ប៉ុន្តែនៅពេលមនុស្សគំរូម្នាក់របស់ពួកគេបានជ្រើសរើសធ្វើខុស នោះខ្ញុំឆ្ងល់ថា តើអ្វីៗគ្រប់យ៉ាងដែលខ្ញុំបានព្យាយាមបង្រៀននោះនឹងទៅជាយ៉ាងណា ។*

ប្អូនស្រីថ្លៃរបស់ខ្ញុំ ជេនី ( បានប្ដូរឈ្មោះ ) បានចិញ្ចឹមឲ្យធំឡើងនៅក្នុងដំណឹងល្អ ហើយគឺជាសមាជិកដែលមានការប្ដេជ្ញាចិត្តមួយរូបរបស់សាសនាចក្រ ។ បន្ទាប់ពីអាពាហ៍ពិពាហ៍ព្រះវិហារបរិសុទ្ធដ៏រីករាយរបស់នាងត្រូវបានបញ្ចប់ មនុស្សមួយចំនួននៅក្នុងសហគមន៍ដ៏តូចរបស់នាង បានចាប់ផ្ដើមនិយាយពាក្យចចាមអារាម ហើយវិនិច្ឆ័យលើរូបនាង ។ នាងបានដកខ្លួននាងចេញពីមិត្តភក្តិជាច្រើនរបស់នាង ហើយទីបំផុតនាងបានចេញពីព្រះវិហារ ។

នាងបានចាប់ផ្ដើមណាត់ជួបដើរលេងជាមួយយុវជនម្នាក់ ឈ្មោះអែនឌី ហើយមិនយូរប៉ុន្មានយុវជននោះបានប្ដូរមករស់នៅជាមួយនាង ។ ខ្ញុំបារម្ភពីអ្វីដែលត្រូវប្រាប់ដល់កូនៗរបស់ខ្ញុំ ។ កូនស្រីទាំងបីនាក់របស់ខ្ញុំស្រឡាញ់មីង ជេនីរបស់ពួកគេណាស់ ។ គ្រួសារយើងមិនគ្រាន់តែជិតស្និទ្ធនឹងនាងឡើយ ប៉ុន្តែនាងគឺជាគ្រូបង្ហាត់រាំកូនៗរបស់ខ្ញុំផងដែរ ដូច្នោះពួកគេឃើញនាងបួនប្រាំដងក្នុងមួយសប្ដាហ៍ ។

អស់រយៈពេលជាច្រើនខែ ពួកគេបានគិតថា អែនឌីបានមកលេងច្រើនដងណាស់ ប៉ុន្តែនៅទីបំផុតខ្ញុំបានប្រាប់ពួកគេថា ជេនី និង អែនឌីកំពុងតែរស់នៅជាមួយគ្នា ។ ខ្ញុំបានពន្យល់ថា ជម្រើសដែលពួកគេជ្រើសយកនោះគឺជាអំពើបាបដ៏ធ្ងន់ធ្ងរ ។ កូនស្រីរបស់ខ្ញុំហាក់ដូចជាយល់ ហើយយើងបានមានការពិភាក្សាដ៏ល្អមួយអំពីសារៈសំខាន់នៃការរស់នៅតាមគោលការណ៍នៃដំណឹងល្អ ។

ក្រោយមកមានហេតុការណ៍មួយកើតឡើង ។ ជេនីបានប្រកាសយ៉ាងរីករាយដល់គ្រួសារថា នាង និង អែនឌី កំពុងមានកូនជាមួយគ្នា ។ ជាថ្មីម្ដងទៀតខ្ញុំបារម្ភថាតើព័ត៌មាននេះប៉ះពាល់យ៉ាងណាខ្លះដល់កូនៗរបស់ខ្ញុំ ។ តើពួកគេដឹងថានេះមិនមែនជារបៀបដែលព្រះវរបិតាសួគ៌មានព្រះទ័យចង់នាំកូនចៅរបស់ទ្រង់មកកាន់ផែនដីនេះដែរឬទេ ? ប្រសិនបើពួកគេនៅក្រវល់នឹងស្ថានភាពនេះ តើពួកគេគិតថាជារឿងដែលអាចទទួលយកបាន និង ជារឿងសាមញ្ញឬទេ ?

ខ្ញុំមានក្ដីបារម្ភអស់ជាច្រើនសប្ដាហ៍ ដោយពុំចង់ប្រាប់កូនៗរបស់ខ្ញុំអំពីការអភិវឌ្ឍន៍ថ្មីបំផុតនេះ ។ មួយខែក្រោយមក ជេនី និង អែនឌីបានសម្រេចចិត្តរៀបការ ។ ហេតុអ្វីពួកគេមិនរៀបការសិន មុននឹងពួកគេប្រកាសថាពួកគេមានកូន ?

អារម្មណ៍ច្របូកច្របល់នោះបានកើតឡើងក្នុងចិត្តខ្ញុំ ។ តើខ្ញុំអាចស្រឡាញ់ជេនី ហើយមិនស្រឡាញ់



**ការប្ដេជ្ញាចិត្តចំពោះសេចក្ដីពិត**

« ការអត់ឱន និង ការគោរពរបស់យើងចំពោះអ្នកដទៃ និង ជំនឿរបស់ពួកគេពុំបណ្ដាលឲ្យយើងបោះបង់ចោលការតាំងចិត្តរបស់យើងចំពោះសេចក្ដីពិតដែលយើងយល់ និង សេចក្ដីសញ្ញាដែលយើងធ្វើនោះទេ ។ . . . យើងត្រូវតែឈរសម្រាប់សេចក្ដីពិតទោះជាពេលយើងអនុវត្តការអត់ឱន និង ការគោរពដល់ជំនឿ និង គំនិតខុសគ្នាពីខ្លួនយើង និង ដល់មនុស្សដែលកាន់វាក្ដី ។ . . .

ស្រដៀងគ្នានេះដែរជាមួយនឹងកូនចៅរបស់យើង និង អ្នកដទៃ យើងមានកាតព្វកិច្ច ដើម្បីបង្រៀនកាតព្វកិច្ចរបស់យើងចំពោះសេចក្ដីពិតគឺឧត្តម្ភណាស់ ។ ប្រាកដណាស់កិច្ចខិតខំបង្រៀនបានទទួលផលតែតាមរយៈសិទ្ធិជ្រើសរើសរបស់អ្នកដទៃប៉ុណ្ណោះ ដូច្នេះពួកគេត្រូវតែធ្វើដោយក្ដីស្រឡាញ់ ការអត់ធន់ និង ការបញ្ចុះបញ្ចូលជានិច្ច » ។

**អែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Balancing Truth and Tolerance » *Liahona,* ខែ កុម្ភៈ ឆ្នាំ ២០១៣ ទំព័រ ៣២, ៣៣ ។**



*តើខ្ញុំអាចបង្រៀនកូនៗរបស់ខ្ញុំឲ្យបន្តស្រឡាញ់មីងរបស់ពួកគេ ប៉ុន្តែកុំឲ្យស្រឡាញ់ទង្វើដែលនាងបានជ្រើសធ្វើយ៉ាងដូចម្តេច ?*

ទង្វើដែលនាងធ្វើយ៉ាងដូចម្តេច ? តើខ្ញុំអាចបង្រៀនកូនៗរបស់ខ្ញុំឲ្យបន្តស្រឡាញ់មីងរបស់ពួកគេ ប៉ុន្តែកុំឲ្យស្រឡាញ់ទង្វើដែលនាងបានជ្រើសធ្វើយ៉ាងដូចម្តេច ?

ថ្ងៃមួយ ប្អូនស្រីរបស់ខ្ញុំបានប្រាប់ខ្ញុំពីយុវនារីម្នាក់នៅក្នុងវួដរបស់នាងបានមានផ្ទៃពោះ ។ យុវនារីម្នាក់នេះបន្តទៅព្រះវិហារ ហើយហាក់បីដូចជារីករាយ ហើយរំភើបចំពោះព្រឹត្តិការណ៍ដែលនឹងកើតឡើងនៅក្នុងជីវិតរបស់នាង ។ យុវនារីផ្សេងទៀត ហាក់បីដូចជាមានអារម្មណ៍ច្របូកច្របល់ ដោយសារអ្វីដែលពួកគេបានឃើញថានោះជាអាកប្បកិរិយាដែលហាក់ដូចជាមិនសមគួរចំពោះស្ថានភាពបែបនោះ ។

ប៉ុន្តែប្អូនស្រីរបស់ខ្ញុំ ដែលជាគ្រូបង្រៀនសួរសុខទុក្ខរបស់ម្តាយនៃយុវនារីនោះ បានដឹងពីការយំយែកមិនបានដេកពួនជាច្រើនយប់របស់យុវនារីនោះ ដោយកើតទុក្ខចំពោះជម្រើសដែលនាងបានជ្រើសធ្វើរហូតឈានដល់ស្ថានភាពដ៏លំបាកនេះ ។ បន្ទាប់ពីអស់រយៈជាច្រើនសប្តាហ៍នៃការឈឺចាប់មក យុវនារីនេះបានសម្រេចចិត្តថា នាងអាចបន្តកើតទុក្ខដោយសារទង្វើរបស់នាង ឬ នាងអាចបន្តឆ្ពោះទៅមុខ ហើយមានភាពរីករាយ ។ ដោយសារពលិកម្មដ៏ធួនរបស់ព្រះគ្រីស្ទ នាងអាចទទួលយកលទ្ធផលនៃការសម្រេចចិត្តរបស់នាង ហើយជាថ្មីម្តងទៀតបានជាស្អាតស្អំតាមរយៈការប្រែចិត្ត ។

ខ្ញុំឆ្ងល់ថា តើ ជេនីបានឆ្លងកាត់ស្ថានភាពស្រដៀងនេះដែរឬទេ ។ ដោយសារតែពុំអាចប្តូរលទ្ធផលបាន តើនាងសោកស្តាយចំពោះជម្រើសរបស់នាង ហើយបានទទួលយក និង សម្រេចចិត្តបន្តឆ្ពោះទៅមុខដែរឬទេ ?

ខ្ញុំមានអារម្មណ៍ថា អៀនខ្មាសចំពោះការវិនិច្ឆ័យដ៏ឃោរឃៅរបស់ខ្ញុំ ហើយធ្វើឲ្យខ្ញុំអសមត្ថភាពដើម្បីស្រឡាញ់តាមរបៀបដែលព្រះយេស៊ូវគ្រីស្ទរំពឹងចង់ឲ្យពួកយើងស្រឡាញ់ ។ នៅពេលខ្ញុំគិតអំពីជីវិតរបស់ព្រះអង្គសង្គ្រោះ នោះខ្ញុំបានចាំថា ទ្រង់តែងតែព្យាយាមស្វែងរកមនុស្សមានបាប បង្រៀនពួកគេតាមរយៈព្រះបន្ទូល និង គំរូរបស់ទ្រង់ ហើយស្រឡាញ់ពួកគេ ។ គឺសេចក្តីស្រឡាញ់នេះហើយដែលបន្ទន់ចិត្ត និង ផ្លាស់ប្តូរមនុស្ស ។

ខ្ញុំបានដឹងថា ជារឿយៗ ខ្ញុំស្រឡាញ់មនុស្ស ដរាបណាពួកគេធ្វើទង្វើតាមអ្វីដែលខ្ញុំគិតថាពួកគេគប្បីធ្វើ ប៉ុន្តែដរាបណាពួកគេប្រព្រឹត្តិកំហុស នោះខ្ញុំវិនិច្ឆ័យពួកគេក្នុងចិត្តរបស់ខ្ញុំ ។ ខ្ញុំជាមនុស្សលាក់ពុតម្លេះហ្ន៎ ! ខ្ញុំបានដឹងថាខ្ញុំត្រូវតែប្រែចិត្ត ។ ខ្ញុំត្រូវតែរៀនស្រឡាញ់មនុស្សមានបាប ដោយពុំគាំទ្រដល់អំពើបាបឡើយ ។ ទីបំផុតខ្ញុំបានឈប់ខឹងនឹងជេនី ហើយពិតជាស្រឡាញ់នាងវិញយ៉ាងខ្លាំង ។

ខ្ញុំមានការពិភាក្សាមួយផ្សេងទៀតដ៏ល្អជាមួយកូនៗរបស់ខ្ញុំ ។ ខ្ញុំបានគូសបញ្ជាក់ពីសារៈសំខាន់នៃការរៀបអាពាហ៍ពិពាហ៍ពីមុនមានកូន ។ យើងបានទន្ទឹងចាំមើលកំណើតរបស់ទារកថ្មីម្នាក់ទៀតនៅក្នុងគ្រួសារ ។ យើងទាំងអស់គ្នាចង់គាំទ្រដល់ជេនី ហើយចែកចាយវានៅក្នុងគ្រាដ៏ពិសេសនេះនៅក្នុងជីវិតរបស់នាង ។ កូនៗរបស់យើងបានដឹងថា មីង ជេនីបានធ្វើខុស ប៉ុន្តែពួកគេនៅតែស្រឡាញ់នាង និង ពូ អែនឌី ហើយសង្ឃឹមថាថ្ងៃណាមួយគ្រួសារដ៏ល្អរបស់ពួកគេនឹងសម្រេចចិត្តត្រឡប់មកកាន់ព្រះហស្តរបស់ព្រះអង្គសង្គ្រោះរបស់យើងវិញ គឺព្រះយេស៊ូវគ្រីស្ទ ។ ■

រូបគំនូរដោយ ដូរី ជែរីស៍

# ការផ្លាស់ប្ដូរក្នុង

# ក្រុមប្រឹក្សាគ្រូបង្រៀន

*យោបល់មួយនៅក្នុងការប្រជុំក្រុមប្រឹក្សាគ្រូបង្រៀនបានផ្លាស់ប្ដូរខ្ញុំច្រើនជាងការបង្រៀនរបស់ខ្ញុំទៅទៀត ។*



*ការប្រជុំក្រុមប្រឹក្សាគ្រូបង្រៀន កំពុងជួយ សាន់ដ្រា ខាតផែល ( នៅកណ្ដាល ) កែលម្អសមត្ថភាពនៃការបង្រៀនរបស់គាត់ ។*

**ដោយ សាន់ដ្រា ខាតផែល**

ខ្ញុំមានវ័យចំណាស់ ដូច្នោះពេលខ្ញុំត្រូវបានហៅឲ្យបង្រៀនយុវនារី នោះខ្ញុំបានគិតថា « ឱម្ចាស់ថ្លៃអើយ ! ខ្ញុំងឿងឆ្ងល់ថា ហេតុអ្វីបានជាពួកគេហៅចំខ្ញុំដូច្នេះ ? »

ខ្ញុំបានខិតខំរៀបចំមេរៀនយ៉ាងខ្លាំងឲ្យសមនឹងតម្រូវការរបស់យុវនារី ហើយខ្ញុំសង្ឃឹមថាពួកគេនឹងមានឆន្ទៈចែកចាយអ្វីដែលពួកគេបានរៀន និង អ្វីដែលពួកគេបានធ្វើតាមមេរៀននៅក្នុងអំឡុងសប្ដាហ៍នោះ ។ ប៉ុន្តែជាញឹកញាប់ការសួរសំណួររបស់ខ្ញុំគឺធ្វើឲ្យមានភាពស្ងាត់ស្ងៀម ។

នៅក្នុងការប្រជុំក្រុមប្រឹក្សាគ្រូបង្រៀនលើកដំបូងរបស់វួដយើង មានគ្រូម្នាក់បាននិយាយថា គាត់កំពុងជួបការលំបាកផងដែរក្នុងការធ្វើឲ្យយុវវ័យសន្ទនាជាមួយគាត់អំឡុងពេលបង្រៀន ។ មានគ្រូបង្រៀនម្នាក់ទៀតបាននិយាយនៅក្នុងការប្រជុំនោះថា « មែនហើយ អ្នកអាចទុកឲ្យមានភាពស្ងាត់ស្ងៀមខ្លះបាន » ។ ពេលខ្លះមនុស្សត្រូវការពេលបន្តិចបន្តួចដើម្បីគិតអំពីសំណួរមួយ មុនពេលឆ្លើយតប ។

យោបល់នៅក្នុងការប្រជុំក្រុមប្រឹក្សាគ្រូបង្រៀននោះ មិនត្រឹមតែធ្វើឲ្យមានភាពខុសប្លែកទៅលើរបៀបដែលខ្ញុំបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែចំពោះសិស្សរបស់ខ្ញុំផងដែរ ។ ខ្ញុំបានគិតច្រើនអំពីយោបល់នោះ ។ នៅក្នុងមេរៀនថ្នាក់យុវនារីលើកក្រោយរបស់ខ្ញុំ ខ្ញុំបានសួរសិស្សអំពីគោលការណ៍ដំណឹងល្អ ដែលពួកគេបានអនុវត្តអំឡុងសប្ដាហ៍នោះ ។ ពួកគេពុំមាត់កអ្វីសោះដូចសព្វមួយដង ។ ប៉ុន្តែជំនួសឲ្យការប្រញាប់និយាយអ្វីទៀតពេលមានភាពស្ងាត់នោះ ខ្ញុំបានចាំពីការពិភាក្សានៅក្នុងក្រុមប្រឹក្សាគ្រូបង្រៀនរបស់យើង ហើយនិយាយដោយស្ងាត់ៗថា « កុំបង្ខំអី » ។

## ហេតុអ្វីមានការប្រជុំក្រុមប្រឹក្សាគ្រូបង្រៀន ?

ដោយសារយើងទាំងអស់គ្នាជាកូនចៅរបស់ព្រះ នោះបុគ្គលណាដែលមានឆន្ទៈរៀនសូត្រ និង រស់នៅតាមដំណឹងល្អ អាចប្រែក្លាយដូចជាព្រះវរបិតាសួគ៌របស់យើង ។ គ្រូបង្រៀនដើរតួយ៉ាងសំខាន់នៅក្នុងរបៀបដែលយើងរៀន និង រស់នៅតាមដំណឹងល្អ ។

ដើម្បីជួយគ្រូបង្រៀន គណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់បានអញ្ជើញវួដ និង សាខានៅទូទាំងសាសនាចក្រឲ្យសម្របធ្វើការប្រជុំក្រុមប្រឹក្សាគ្រូបង្រៀន ។ ការប្រជុំជាប្រចាំខែទាំងនេះ អនុញ្ញាតឲ្យគ្រូបង្រៀន និង ថ្នាក់ដឹកនាំរៀនជាមួយគ្នា នៅពេលពួកគេចែកចាយគំនិតនានាអំពីការបង្រៀន ។

ការប្រជុំទាំងនេះ គឺមានភាពថ្មីស្រឡាង ប៉ុន្តែវាបានជះឥទ្ធិពលវិជ្ជមានទៅដល់ទាំងគ្រូបង្រៀន និងសិស្សជាច្រើនរួចទៅហើយ ។ ខាងក្រោមនេះគឺជាយោបល់នានាមកពីសមាជិក ដែលមានអំណរគុណ និង រីករាយចូលរួមក្នុងការប្រជុំក្រុមប្រឹក្សាគ្រូបង្រៀននេះ ៖

- « មានការគាំទ្ររៀបចំឡើងជួយពង្រឹងដល់ខ្ញុំ ។ ពេលខ្លះ ក្នុងនាមជាគ្រូបង្រៀនយើងមានអារម្មណ៍ថា ការបង្រៀនគឺជាកិច្ចការរបស់មនុស្សតែម្នាក់ប៉ុណ្ណោះ ។ ប៉ុន្តែគំនិតនោះបានផ្លាស់ប្ដូរនៅពេលមានក្រុមប្រឹក្សានេះ ហើយមានវេទិកាចែកចាយពីការលំបាកគំនិត និង អារម្មណ៍នានា ហើយទទួលយកមតិកែលម្អពីក្រុមមួយដែលយល់អំពីការហៅបម្រើនោះ » ។ — ប្រេស្តុន ស្រ្វាតហ្វត
- « ការប្រជុំក្រុមប្រឹក្សាគ្រូបង្រៀនជួយខ្ញុំឲ្យដឹងពីសារៈសំខាន់នៃការខិតខំរបស់ខ្ញុំដើម្បីសម្របសម្រួលការបង្រៀន » ។ — ម៉ាការ៉ែត ធូលើរ
- « ខ្ញុំរីករាយទទួលយកយោបល់នានាអំពីរបៀបដែលគ្រូបង្រៀន អាចរៀន ដើម្បី ‹ បង្រៀនដល់មនុស្ស › ឲ្យបានកាន់តែប្រសើរឡើង មិនមែន ‹ បង្រៀនមេរៀន › នោះទេ » ។ — រីឆាដ ផាធី



- « ការពិភាក្សាគ្នាពីរបៀបនានាដើម្បីកែលម្អលើរបៀបដែលយើងសួរសំណួរ និងលើកទឹកចិត្តឲ្យសិស្សចូលរួមកាន់តែច្រើន ពិតជាមានប្រយោជន៍ណាស់ ។ ការដែលអាចជជែកគ្នាអំពីភាគជោគជ័យ និង ឧបសគ្គនានាដែលកើតឡើង បានផ្ដល់នូវការយល់ដឹងដល់ខ្ញុំផងដែរ » ។ — ខេន សុនណេនបើក
- « ក្រុមប្រឹក្សានេះធ្វើបានយ៉ាងល្អចំពោះជំនាញនៃការបង្រៀន ដែលនឹងធ្វើឲ្យយើងក្លាយជាគ្រូបង្រៀនកាន់តែល្អប្រសើរឡើង ។ ប្រសិនបើអ្នកមានជំនាញកាន់តែច្រើនក្នុងនាមជាគ្រូបង្រៀនម្នាក់ នោះសិស្សនៅក្នុងថ្នាក់របស់អ្នកនឹងទទួលប្រយោជន៍ជាច្រើន ។ នៅពេលដែលមានក្រុមប្រឹក្សាគ្រូបង្រៀន ខ្ញុំមានអារម្មណ៍ថាខ្ញុំមានការរីកចម្រើនខាងវិញ្ញាណផងដែរ » ។ — ប្រែន ណិលសុន
- « វាគឺជាក្ដីរីករាយមួយ ដើម្បីពង្រីកការគិតរបស់ខ្ញុំចំពោះកែលម្អការបង្រៀន » ។ — កាមីល ហ្វ្រុង

ដើម្បីរៀនបន្ថែមទៀតអំពីការប្រជុំក្រុមប្រឹក្សាគ្រូបង្រៀន និង *ការបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ* សូមចូលទៅកាន់គេហទំព័រ teaching.lds.org/**khm**។

នៅគ្រាដែលខ្ញុំបាននិយាយដូច្នោះ ការសន្ទនាគ្នាបានចាប់ផ្ដើមផ្ទុះឡើង ។ ពួកយុវនារីបានចាប់ផ្ដើមបើកដួងចិត្ត ហើយពួកគេបានចែកចាយនូវបទពិសោធន៍ដ៏ទន់ភ្លន់មួយចំនួន ។ ភ្លាមៗនោះខ្ញុំចង់ថ្លែងអំណរគុណដល់គ្រូបង្រៀន ដែលបានផ្ដល់យោបល់ដ៏សាមញ្ញនៅក្នុងការប្រជុំក្រុមប្រឹក្សាគ្រូបង្រៀនអំពីភាពស្ងាត់នោះ ។ ខ្ញុំស្ញើចសរសើរពីរបៀបដែលការអនុវត្តគោលការណ៍មួយនោះបានធ្វើឲ្យមានការផ្លាស់ប្ដូរមួយដ៏ធំយ៉ាងលឿន ។

ប៉ុន្តែខ្ញុំពុំបានដឹងភ្លាមទេ ទាល់តែក្រោយមក ទើបខ្ញុំបានឃើញពីភាពខុសប្លែកដែលគោលការណ៍នោះ និង គោលការណ៍ផ្សេងទៀតដែលខ្ញុំបានរៀនកើតមានឡើង ។ បន្ទាប់ពីចប់ម៉ោងនៅព្រះវិហារ ម្ដាយរបស់យុវនារីមួយរូបបានប្រាប់ខ្ញុំថា កូនស្រីរបស់គាត់បាននិយាយថា នាងដឹងថាខ្ញុំត្រូវបានហៅពីព្រះ ។

ខ្ញុំពុំអាចរៀបរាប់ប្រាប់អ្នកពីអារម្មណ៍ដ៏អស្ចារ្យពេលដែលស្ដាប់ឮពាក្យទាំងនោះយ៉ាងណាឲ្យអស់ទេ ។ ពេលនោះខ្ញុំបានគិតថា « តើខ្ញុំបានបង្រៀនអ្វីខ្លះដល់យុវនារីទាំងនេះ ? » ប៉ុន្តែខ្ញុំច្បាស់ជាកំពុងបង្រៀនពួកគេអ្វីមួយហើយ ។ ខ្ញុំត្រូវបានហៅដោយគោលបំណងមួយ ហើយការប្រជុំក្រុមប្រឹក្សាគ្រូបង្រៀនកំពុងជួយខ្ញុំឲ្យបំពេញគោលបំណងនោះ ។ ■

*អ្នកនិពន្ធរស់នៅប្រទេស ស្កុតឡែន ។*

ដើម្បីរៀនបន្ថែមទៀតពីរបៀបដែលអ្នកអាចជួយផ្លាស់ប្ដូរជីវិតមនុស្សជាច្រើន តាមរយៈការផ្លាស់ប្ដូររបៀបដែលអ្នកបង្រៀន សូមចូលទៅកាន់គេហទំព័រ teaching.lds.org/**khm**។

# អែលឌើរ
# ឌែល ជី រេនឡាន់ ៖
## អ្នកបម្រើដែលគោរពប្រតិបត្តិ

**ដោយ អែលឌើរ យ៉ើនធិន អិល យុក**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*



នៅទំព័របន្ទាប់ ៖ អែលឌើរ រិនឡាន់ និង បងប្អូនបង្កើតរបស់លោក ( អានីតា លីនដា និង ហ្គារី ) បានធំឡើងនៅក្នុងរដ្ឋ យូថាហ៍ និយាយភាសា ស៊ុយអែត ។ ឪពុកម្ដាយរបស់ពួកលោក អាគេ និង ម៉ារៀណា បានប្ដូរទីលំនៅពីប្រទេស ស៊ុយអែត ទៅរដ្ឋ យូថាហ៍នៅក្នុងឆ្នាំ ១៩៥០ ដើម្បីផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ដោយសារគ្មានព្រះវិហារបរិសុទ្ធនៅក្នុងស្កេនឌីណាវៀ ឬ ទ្វីបអឺរ៉ុបនៅគ្រានោះឡើយ ។ ខាងស្ដាំ ៖ អែលឌើរ និង ស៊ិស្ទើរ រេនឡាន់ ព្រមទាំងកូនស្រីរបស់ពួកលោក អាស្លី បានរស់នៅក្នុងទីក្រុង បាល់ទីម័រ រដ្ឋ ម៉ារីលែន ស. រ. អា. អស់រយៈពេលប្រាំមួយឆ្នាំ នៅទីនោះលោកបានបញ្ចប់កម្មសិក្សាផ្នែកវេជ្ជសាស្ត្ររបស់លោក និង បញ្ចប់ពីការសិក្សាផ្នែកជំងឺបេះដូងនៅមន្ទីរពេទ្យ ចន ហបឃីន ហើយនាងបានចូលរៀនសាលាច្បាប់នៃសាកលវិទ្យាល័យរដ្ឋ ម៉ារីលែន ។

ជីវិតរបស់ឌែល និង រេនឡាន់មានភាពមមាញឹកណាស់ ។ កាលអាយុ ២០ ឆ្នាំជាង ពួកគេទាំងពីនាក់បានរស់នៅ ទីក្រុង បាល់ទីម័រ រដ្ឋ ម៉ារីលែន ស. រ. អា. ។ ឌែល បានរៀនចប់ពីសាលាវេជ្ជសាស្ត្រនៅសាកលវិទ្យាល័យរដ្ឋ យូថាហ៍ ។ លោក និង រ៉ូសបានប្ដូរទីលំនៅទៅផ្នែកម្ខាងទៀតនៃប្រទេស ប្រយោជន៍ឲ្យលោកអាចចាប់ផ្ដើមចុះកម្មសិក្សាផ្នែកវេជ្ជសាស្ត្រដ៏លំបាក និង មានកិត្យានុភាពនៅក្នុងសាលាវេជ្ជសាស្ត្រ ចន ហបឃីន ។ ពួកគេមានកូនស្រីដ៏ស្រស់ស្អាតម្នាក់ឈ្មោះ អាស្លី ។ រ៉ូស ភរិយាដ៏អស្ចារ្យរបស់លោក កំពុងទទួលការព្យាបាលជំងឺមហារីក កាលឌែល បានទទួលការហៅបម្រើជាប៊ីស្សពដោយការគោរពប្រតិបត្តិ ។

នៅពេលលោកបានទៅសួរសុខទុក្ខសមាជិករួដ មានពេលខ្លះ ឌែល បានយក អាស្លីទៅជាមួយលោក ។ ថ្ងៃមួយពួកគេបានទៅសួរសុខទុក្ខសមាជិកមិនសូវសកម្មម្នាក់ ។ អែលឌើរ រេនឡាន់ ចាំថា « ខ្ញុំបានដឹងថា គ្មាននរណាម្នាក់អាចបដិសេធការសួរសុខទុក្ខរបស់ខ្ញុំជាមួយកូនស្រីដ៏គួរឲ្យស្រឡាញ់របស់ខ្ញុំ ដែលទៅជាមួយខ្ញុំឡើយ » ។ លោកបានគោះទ្វារផ្ទះបុរសម្នាក់ដែលធ្លាប់បណ្ដេញទីប្រឹក្សារបស់ប៊ីស្សព រេនឡាន់ទាំងកំហឹងកាលពីពេលមុនៗ ។

ពេលបុរសនោះបានបើកទ្វារ គាត់ជាមនុស្សមានមាឌធំ គាត់ឈរកម្ពស់នឹងក្លោងទ្វារផ្ទះគាត់ ។ គាត់បានសម្លឹងទៅប៊ីស្សព រេនឡាន់ ។ អាស្លីអាយុបួនឆ្នាំបានថ្លែងថា « តើពួកខ្ញុំអាចចូលបានឬអត់ ? »

ដោយក្ដីភ្ញាក់ផ្អើលបុរសនោះវាចាថា « មិនអីទេ ។ ចូលមក » ។

នៅពេលពួកគេអង្គុយនៅក្នុងផ្ទះ នោះបុរសនោះបានប្រាប់ប៊ីស្សព រេនឡាន់ ថា គាត់ពុំជឿថាសាសនាចក្រនេះពិតទេ ហើយគាត់ក៏មិនជឿលើព្រះយេស៊ូវគ្រីស្ទដែរ ។ គាត់បានបន្ដរ៉ាយរ៉ាប់ទាំងកំហឹង ខណៈដែលអាស្លីកំពុងលេងតុក្កតា ។ ទីបំផុតនាងបានចុះចេញពីកៅអី ហើយយកដៃខ្ទប់ត្រចៀកឪពុកនាង ហើយខ្សឹបព្មៗថា « ប៉ា សូមប្រាប់គាត់ការពិតទៅ » ។

គាត់បានប្រាប់ដូច្នោះមែន ។ ប៊ីស្សព រិនឡាន់បានថ្លែងទីបន្ទាល់របស់លោកប្រាប់បុរសនោះ ។ លោករំឭកថា « អត្តចរិតរបស់បុរសនោះបានបន្ទន់ ហើយព្រះវិញ្ញាណបានយាងចូលមកគង់នៅផ្ទះរបស់គាត់ » ។

ឥឡូវនេះក្នុងនាមជាសមាជិកម្នាក់ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ អែលឌើរ រេនឡាន់ មានឱកាសប្រាប់ពិភពលោកទាំងមូលនូវសេចក្ដីពិតនោះ ( សូមមើល គ. និង ស. ១០៧:២៣ ) ។ អែលឌើរ រេនឡាន់ មានប្រសាសន៍ថា « អំណរដ៏ធំមហិមាដែលកើតឡើងគឺការជួយនាំយកដង្វាយធួនរបស់ព្រះគ្រីស្ទទៅក្នុងជីវិតរបស់មនុស្សនៅគ្រប់ទីកន្លែង ។ ខ្ញុំគិតថាការហៅបម្រើនេះផ្ដល់ឱកាសដល់ខ្ញុំធ្វើការណ៍នេះក្នុងកម្រិតមួយកាន់តែច្រើនឡើងនៅក្នុងទីកន្លែងជាច្រើនទៀត ក្នុងនាមជាសាក្សីរបស់ព្រះគ្រីស្ទទៅកាន់ពិភពលោកទាំងមូល » ។

**ត្រូវបានចិញ្ចឹមឲ្យធំឡើងនៅក្នុងវប្បធម៌ពួកអឺរ៉ុបប៉ែកពាយព្យ**

ឌែល ហ្គាន់នើរ រេនឡាន់ បានកើតនៅក្នុងទីក្រុង សលត៍ លេក រដ្ឋ





ប្អូនស្រីរបស់អែលឌើរ រេនឡាន់ ឈ្មោះលីដា សី ម៉ាឌើរ ដែលមានអាយុតិចជាងគាត់ប្រាំពីរឆ្នាំថ្លែងថា នៅពេលកូនទាំងបួននាក់ចម្រើនវ័យធំឡើង « ពួកគេដឹងពីភាពអស្ចារ្យ និង ភាពស្មោះត្រង់ដ៏ខ្លាំងក្លារបស់ឪពុកម្ដាយខ្លួន ដែលបានប្ដូរទីលំនៅទៅទីកន្លែងថ្មីដោយពុំចេះនិយាយអង់គ្លេសសោះ ហើយមានការជួយគាំទ្រតិចតួច ប្រយោជន៍ឲ្យពួកគេទទួលបានពរជ័យនៃដំណឹងល្អ និង អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ » ។





យូថាហ៍ ស. រ. អា. នៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៥២ ។ លោក និង បងប្អូនបង្កើតរបស់លោកបានចម្រើនវ័យធំឡើងដោយនិយាយភាសាស៊ុយអែត ។ ម្ដាយរបស់ពួកលោក ម៉ារៀណា អែនឌើរសុន មកពីប្រទេស ស៊ុយអែត ហើយឪពុករបស់ពួកលោក ម៉ាត់ អាគេ រិនឡាន់ មកពីទីក្រុងដែលនិយាយភាសាស៊ុយអែតនៅក្នុងប្រទេស ហ្វាំងឡង់ ភាគខាងលិច ។ ពួកគេបានធ្វើអន្តោប្រវេសន៍មកពីប្រទេស ស៊ុយអែត ទៅទីក្រុង យូថាហ៍ នៅក្នុងឆ្នាំ ១៩៥០ ។

ឪពុកម្ដាយរបស់ ខេលបានជួបគ្នានៅព្រះវិហារនៅក្នុងទីក្រុង ស្តុកខុម ។ បន្ទាប់ពីសម្រេចចិត្តរៀបការ ពួកគេបានប្ដេជ្ញាចិត្តរៀបការនៅព្រះវិហារបរិសុទ្ធតែប៉ុណ្ណោះ ។ ដោយសារគ្មានព្រះវិហារនៅក្នុងប្រទេសនៅអឺរ៉ុបនាគ្រានោះ ( ព្រះវិហារបរិសុទ្ធ ប៊ើន ស្វីស ត្រូវបានឧទ្ទិសឆ្លងនៅក្នុងឆ្នាំ ១៩៥៥ ) ស្វាមីភរិយាគូនេះបានមកទីក្រុង យូថាហ៍ ប្រយោជន៍ឲ្យពួកគេអាចត្រូវបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ សលត៍ លេក ។

កាល ខេល អាយុ ១១ ឆ្នាំ ឪពុករបស់លោក ដែលមានជំនាញជាជាងឈើ និង អ្នកសំណង់ត្រូវបានហៅបម្រើជាអ្នកផ្សព្វផ្សាយសាសនាខាងអគារនៅក្នុងប្រទេស ស៊ុយអែតអស់រយៈពេលបីឆ្នាំ ។ គ្រួសារនេះបានចំណាយពេលរស់នៅក្នុងទីក្រុង ហេលស៊ីនគី ប្រទេស ហ្វាំងឡង់ និង ហ្គោឌិនប៊ើក ប្រទេស ស៊ុយអែត ។ ពួកលោកបានចូលរួមនៅក្នុងសាខាតូចមួយរបស់សាសនាចក្រ ហើយកូនៗបានចូលរៀននៅសាលារៀនរបស់រដ្ឋនៃប្រទេសស៊ុយអែត ។ អានីតា អិម រិនឡាន់ ប្អូនស្រីរបស់ខេល ដែលមានអាយុតិចជាងលោកមួយឆ្នាំ បានរំឭកពីរឿងដ៏លំបាកមួយនៅក្នុងដំណើរផ្លាស់ប្ដូរទីលំនៅនេះ ៖« ពីដំបូង ការប្ដូរទីលំនៅនេះជារឿងតក់ស្លុតមួយចំពោះពួកយើង ដោយសារទោះបីបើពួកខ្ញុំនិយាយភាសាស៊ុយអែតនៅផ្ទះក្ដី យើងពុំចេះវេយ្យករណ៍ ឬ ការប្រកបពាក្យនៃភាសានេះឡើយ » ។

កាលនៅតូច ខេលមានបទពិសោធន៍នូវទីបន្ទាល់រឹងមាំ បន្ទាប់ពីអានព្រះគម្ពីរមរមន ។ ប្រធានបេសកកម្មនៅក្នុងប្រទេស ស៊ុយអែត បានអញ្ជើញយុវជនបព្វជិតភាពអើរ៉ុនឲ្យអានព្រះគម្ពីរមរមន ដូច្នេះបងប្រុសរបស់ខេល ហ្គារី ដែលកាលនោះមានអាយុ ១២ ឆ្នាំ បានទទួលយកការអញ្ជើញនោះ ។ ខេលដែលមានអាយុ ១១ ឆ្នាំក៏ធ្វើតាមការអញ្ជើញនោះផងដែរ ។ បន្ទាប់ពីអានព្រះគម្ពីរមរមន លោកបានអធិស្ឋាន ហើយទូលសួរប្រសិនបើគម្ពីរនោះពិតឬទេ ។ អែលឌើរ រេនឡាន់ រំឭកថា « ខ្ញុំមានចំណាប់អារម្មណ៍ច្បាស់មួយថា ៖ ‹ ខ្ញុំបានប្រាប់អ្នក

រូបថតបានទទួលសិទ្ធិអនុញ្ញាត ពីគ្រួសាររិនឡាន់ លើកលែងតែបានកត់សម្គាល់ រូបថត © BUSATH.COM ផ្ទាំងខាងក្រោយពី ISTOCK/THINKSTOCK ។





ជាមួយភរិយា និង កូនស្រីរបស់លោក ( ខាងលើ ) អែលឌើរ រេនឡាន់ បាននិយាយថ្លែងសុន្ទរកថានៅក្នុងសន្និសីទពង្សប្រវត្តិ RootsTech ឆ្នាំ ២០១៦ នៅក្នុងទីក្រុង សលត៍ លេក ។ ទំព័រទល់មុខនេះ ៖ បានរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ សលត៍ លេក ក្នុងឆ្នាំ ១៩៧៧ អែលឌើរ និង ស៊ិស្ទើរ រេនឡាន់បានបម្រើព្រះអម្ចាស់នៅគ្រប់ទីកន្លែង និង គ្រប់ពេលវេលាដែលពួកលោកត្រូវបានហៅបម្រើ ។

យូរយារមកហើយថាគម្ពីរនេះគឺជាគម្ពីរពិត › ។ ហើយនោះគឺជាបទពិសោធន៍មួយដ៏អស្ចារ្យ » ។

ខេល និង បងប្អូនបង្កើតរបស់លោក — ហ្គារី អានីតា និង លីនដា — ចាំថានៅពេលក្រុមគ្រួសារខ្លួនបានប្ដូរទីលំនៅត្រឡប់ទៅសហរដ្ឋវិញ ពួកគេបានបន្តនិយាយ និង អធិស្ឋានជាភាសាស៊ុយអែត ។ ពួកគេក៏បានរំឭកពីការគូសបញ្ជាក់ដ៏អស្ចារ្យរបស់ឪពុកម្ដាយខ្លួនអំពីចំណេះដឹងនៃព្រះគម្ពីរផងដែរ ។ ពួកគេបាននិយាយថា « វិធីដ៏ល្អបំផុតដើម្បីពន្យល់ឪពុកម្ដាយរបស់យើងអំពីអ្វីដែលពួកយើងគិតនោះ គឺយើងប្រើព្រះគម្ពីរ » ។ អានីតានិយាយលេងថា « ការចេះខគម្ពីរនៅក្នុងគ្រួសាររបស់យើងគឺជាជំនាញដ៏សំខាន់មួយ ហើយវាពុំមែនជាជម្រើសឡើយ » ។

គួរឲ្យអស្ចារ្យណាស់ ទាំង ហ្គារី និង ខេល ត្រូវបានហៅបម្រើនៅក្នុងបេសកកម្មស៊្វីសនៅពេលតំណាលគ្នា ។ ពួកគេពុំធ្លាប់ធ្វើជាដៃគូនឹងគ្នាឡើយ ប៉ុន្តែពួកគេទាំងពីរអាចនិយាយភាសាស៊ុយអែតដើម្បីបម្រើព្រះអម្ចាស់ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាអស់រយៈពេលពីរឆ្នាំ ។ អែលឌើរ រេនឡាន់ ពិពណ៌នាពីបេសកកម្មរបស់លោកថា ជាកិច្ចការដ៏ច្រើន ប៉ុន្តែវាជាបទពិសោធដ៏អស្ចារ្យ ៖ « វាគឺជាការផ្លាស់ប្ដូរជីវិតប្រកបដោយការប្ដេជ្ញាចិត្ត និង ការសម្រេចចិត្តដើម្បីធ្វើកិច្ចការឲ្យអស់ពីសមត្ថភាព នោះបុគ្គលម្នាក់អាចក្លាយជាសិស្សរបស់ព្រះគ្រីស្ទ » ។

## ពរជ័យដ៏អស្ចារ្យបំផុត

បន្ទាប់ពីត្រឡប់មកពីបេសកកម្មរបស់លោកវិញនៅក្នុងឆ្នាំ ១៩៧៤ ខេលបានចូលរៀនសាកលវិទ្យាល័យ យូថាហ៍ ។ លោកគឺជាសិស្សដ៏ឆ្នើមមួយរូប ហើយបានទទួលបរិញ្ញាបត្រផ្នែកគីមីវិទ្យា ។ បងប្អូនបង្កើត និង មិត្តភក្ដិជិតស្និទ្ធរបស់លោកទាំងអស់បានចាំពីសមត្ថភាព ការផ្ទង់គំនិត ការឧស្សាហ៍ព្យាយាម និង ការប្ដេជ្ញាចិត្តរបស់លោកនៅក្នុងគ្រប់កិច្ចការដែលលោកបានធ្វើ — ជាបុគ្គលិកលក្ខណៈដែលលោកបន្តបង្ហាញ ។ ហ្គារី ថ្លែងថា « លោកគឺជាមនុស្សម្នាក់ដែលឧស្សាហ៍ព្យាយាមបំផុតដែលខ្ញុំធ្លាប់ជួប » ។

នៅក្នុងវួដរបស់ខ្លួន ខេលបានជួបយុវនារីម្នាក់ឈ្មោះ រ៉ូស ។ នាងគឺជាកូនស្រីរបស់គណៈប្រធានស្ដេកម្នាក់ មើរលីន អ័រលីប៊ើត ដែលក្រោយមកបានបម្រើនៅក្នុងក្រុមចិតសិប ។ ខេលចងចាំថា លោកបានតាំងចិត្តក្លាហានល្មមដើម្បីសុំ រ៉ូស ដើរលេងជាគូ ប៉ុន្តែនាងបានបដិសេធ ។ ពីរបីខែក្រោយមកពេលលោកបានព្យាយាមសុំនាងម្ដងទៀត នាងបានយល់ព្រម ។ ប៉ុន្តែរ៉ូសបានប្រាប់ខុសគ្នាបន្តិចអំពីរឿងនេះ ។ នាងចាំថា នៅពេលលោកបាននិយាយនៅក្នុងការប្រជុំសាក្រាម៉ង់អំពីបេសកកម្មរបស់លោក នាងមានការចាប់អារម្មណ៍ ។ ពួកគេបានស្គាល់គ្នាច្បាស់ជាងមុន ហើយនាងមានការភ្ញាក់ផ្អើលនៅពេលលោកបានសុំនាងដើរលេងជាគូ ប៉ុន្តែនាងជាប់រវល់ធ្វើពិធីជប់លៀងមួយដែលតម្រូវឲ្យនាងបដិសេធលោក ។ នាងមានក្ដីរីករាយដើម្បីទទួលយកការដើរលេងជាគូនោះនៅពេលគាត់បានសុំនាងម្ដងទៀត ។

ខេល និង រ៉ូស បានរៀបការនៅក្នុងឆ្នាំ ១៩៧៧ នៅក្នុងព្រះវិហារបរិសុទ្ធ សលត៍ លេក ខណៈពេលលោកកំពុងរៀននៅសាលាវេជ្ជសាស្ត្រនៅសាកលវិទ្យាល័យ យូថាហ៍ ហើយនាងកំពុងបង្រៀននៅវិទ្យាល័យ សៅហ៍ ដែលស្ថិតនៅក្នុងទីក្រុង សលត៍ លេកផងដែរ ។ អែលឌើរ រេនឡាន់ ថ្លែងប្រាប់យ៉ាងច្បាស់ថា « ក្រៅពីការសម្រេចចិត្តសកម្មនៅក្នុងសាសនាចក្រហើយនោះ ការរៀបការជាមួយរ៉ូសគឺជារឿងមួយដ៏អស្ចារ្យបំផុតនៅក្នុងជីវិតខ្ញុំ » ។ កូនស្រីរបស់ពួកលោក អាស្លី បានកើតមកមួយសប្ដាហ៍បន្ទាប់ពីអែលខេល រិនឡាន់បញ្ចប់ការសិក្សាពីសាលាវេជ្ជសាស្ត្រក្នុងឆ្នាំ ១៩៨០ ។

ក្រោយមក អែលឌើរ រេនឡាន់ ត្រូវបានគេទទួលដោយរីករាយឲ្យចូលធ្វើការនៅមន្ទីរពេទ្យ ចន ហបឃីន ដែលជាជម្រើសទីមួយរបស់លោកដើម្បីបន្តការអប់រំផ្នែកវេជ្ជសាស្ត្រ

របស់លោក ។ គ្រួសារនេះបានប្ដូរទីលំនៅទៅ ទីក្រុង បាល់ទីម័រ ម៉ារីលែន នៅទីនោះ លោកបានក្លាយជាបុគ្គលិកមន្ទីរពេទ្យ ។



**រីកចម្រើនឡើងដោយឆ្លងកាត់ការសាកល្បង**

នៅក្នុងខែ តុលា ឆ្នាំ ១៩៨១ សិស្ទើរ រេនឡាន់ ត្រូវបានធ្វើរោគវិនិច្ឆ័យដឹងថា កើតជំងឺមហារីកអុជីរ ។ នាងបានទទួលការវះកាត់ពីរដង ហើយព្យាបាលដោយប្រើថ្នាំគីមីអស់រយៈពេលប្រាំបួនខែ ។ ដោយមានការលំបាកក្នុងការថែទាំ រ៉ូស និង កូនស្រីលោក អែលឌើរ រេនឡាន់ រំឭកថា « ខ្ញុំមានការឈឺចាប់ ហើយវាហាក់បីដូចជាការអធិស្ឋានរបស់ខ្ញុំពុំបានឮដល់ឋានសួគ៌សោះ » ។

ពេលលោកបានយក រ៉ូសពីមន្ទីរពេទ្យទៅផ្ទះវិញ នាងមានភាពទន់ខ្សោយ ប៉ុន្តែពួកគេចង់អធិស្ឋានជាមួយគ្នា ។ លោកបានសុំឲ្យសិស្ទើរ រេនឡាន់ អធិស្ឋាន ។ « ពាក្យអធិស្ឋានដំបូងរបស់នាងនោះគឺ ‹ ឱព្រះវរបិតាដែលគង់នៅឋានសួគ៌ ពួកទូលបង្គំមានអំណរគុណចំពោះអំណាចបព្វជិតភាព ដែលយើងមានទោះបីជាមានរឿងអ្វីកើតឡើងក្ដី យើងអាចនៅជាមួយគ្នាជារៀងរហូត › » ។

នៅគ្រានោះ លោកមានអារម្មណ៍នៃភាពជិតស្និទ្ធជាពិសេសជាមួយកិរិយាលោក និង ព្រះ ។ អែលឌើរ រេនឡាន់មានប្រសាសន៍ថា « កាលពីមុនខ្ញុំយល់ពីគ្រួសារអស់កល្បជានិច្ចនៅក្នុងគំនិតរបស់ខ្ញុំ តែឥឡូវនេះខ្ញុំយល់នៅក្នុងដួងចិត្តរបស់ខ្ញុំវិញ » ។ « ជំងឺរបស់រ៉ូសបានផ្លាស់ប្ដូរដំណើរជីវិតរបស់យើង » ។

ដើម្បីចៀសវាងពីការគិតពីជំងឺរបស់ខ្លួន សិស្ទើរ រេនឡាន់ បានសម្រេចចិត្តចូលរៀនសាលាច្បាប់ ។ សិស្ទើរ រេនឡាន់ និយាយថា « ខ្ញុំគ្រាន់តែគិតថា ‹ នេះគឺជាបទពិសោធន៍ដ៏ឈឺចាប់មួយ បើសិនយើងមិនធ្វើអ្វីមួយពីបទពិសោធន៍នេះទេនោះ › » ។ « វាពុំមែនជាផែនការរបស់យើង ដើម្បីឲ្យខ្ញុំមានជំងឺមហារីកទាំងវ័យក្មេង ហើយមានកូនតែម្នាក់នោះទេ ។ ហើយខ្ញុំគិតថាខ្ញុំនឹងមិនទាំងរស់ផង ។ ប៉ុន្តែពួកខ្ញុំគិតថា ការចូលរៀនសាលាច្បាប់គឺជារឿងត្រឹមត្រូវមួយ » ។

នាងបានបន្តការសិក្សា ទោះបីជានៅពេលនាងកំពុងបន្តព្យាបាលជំងឺរបស់នាង ហើយស្វាមីរបស់នាងកំពុងបន្តកម្មសិក្សារបស់លោកក្ដី ។



**បីស្សពនៃទីក្រុង បាល់ទីម័រដែលមានមនុស្សកុះករ**

នៅពេលអែលឌើរ រេនឡាន់ កំពុងស្ថិតក្នុងការផ្លាស់ប្ដូរពីបុគ្គលិកវេជ្ជសាស្ត្ររយៈពេលបីឆ្នាំទៅជានិស្សិតពេទ្យរៀនខាងបេះដូង នោះលោកត្រូវបានសម្ភាសធ្វើជាបីស្សពនៅវួដ បាល់ទីម័រ ។ ប្រែន ពេធី ដែលជាទីប្រឹក្សាទីមួយនៅក្នុងស្ដេក បាល់ទីម័រ ម៉ារីលែន កាលគ្រានោះ ចាំពីការសម្ភាសន៍នោះ ។ ទាំងគាត់ និង ប្រធានស្ដេក ស្ទេផាន ភី ស៊្បីពគ្លី ទទួលអារម្មណ៍ « យ៉ាងខ្លាំងពីព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ » នៅពេលពួកគេសម្ភាសលោក ។

បងប្រុស ពេធីរំឭកថា « លោកបានបង្ហាញខ្លួនលោកថាជាបីស្សពដ៏អស្ចារ្យម្នាក់ » ទោះបីជាមួយនឹងវិជ្ជាជីវៈ និង ឧបសគ្គគ្រួសារដែលលោកបានកំពុងជួបប្រទះក្ដី ។ ពេលអែលឌើរ រិនឡាន់បានទទួលការហៅរបស់លោកមកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់កាលពីឆ្នាំមុន បងប្រុស ពេធីសម្គាល់ឃើញថា សមាជិកនៃវួដ បាល់ទីម័រ ព្រមទាំងសហការីខាងវេជ្ជសាស្ត្ររបស់អែលឌើរ រិនឡាន់ដែលពួកគេភាគច្រើនពុំមែនជាពួកបរិសុទ្ធថ្ងៃចុងក្រោយនោះ មានក្ដីរីករាយជាខ្លាំង ។ ពួកគេបានបង្ហាញសេចក្ដីស្រឡាញ់ដល់លោក និង ការកោតសរសើរចំពោះការបម្រើ និង អត្តចរិតដ៏មានសីលធម៌បំផុតរបស់លោក ។

**វិជ្ជាជីវៈដ៏មានកិត្តិយស**

ក្នុងឆ្នាំ ១៩៨៦ បន្ទាប់ពីសិស្ទើរ រិនឡាន់បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យច្បាប់ ម៉ារីលែន ហើយអែលឌើរ រិនឡាន់បានបញ្ចប់កម្មសិក្សាផ្នែកវេជ្ជសាស្ត្ររបស់លោករយៈពេលបីឆ្នាំ និង បីឆ្នាំពីការសិក្សាផ្នែកបេះដូង នោះពួកគេបានត្រឡប់ទៅរស់នៅយូថាហ៍វិញ ។ សិស្ទើរ រិនឡាន់បានចាប់ផ្ដើមធ្វើការផ្នែកច្បាប់នៅការិយាល័យមេធាវីនៃអគ្គនាយករដ្ឋ យូថាហ៍ ហើយអែលឌើរ រិនឡាន់បានក្លាយជាសាស្ត្រាចារ្យផ្នែកវេជ្ជសាស្ត្រនៅសាកលវិទ្យាល័យយូថាហ៍ ។ អស់រយៈពេល ១៨ ឆ្នាំលោកគឺជានាយកផ្នែកវេជ្ជសាស្ត្រនៃកម្មវិធីការប្ដូរសរីរាង្គបេះដូងនៃមន្ទីរពេទ្យប្ដូរសរីរាង្គរដ្ឋ យូថាហ៍ ។

ខាងឆ្វេង ៖ រូបថត ដោយ គ្រីស្ទីន រ៉ម្សី *DESERET NEWS* រូបថតមង្គលការ © NEWMAN PHOTOGRAPHY

អែលឌើរ រិនឡាន់ បានចាកចោលពីវិជ្ជាជីវៈវេជ្ជសាស្ត្រដ៏ជោគជ័យរបស់លោក ក្នុងនាមជាអ្នកឯកទេសខាងបេះដូង ដើម្បីទទួលការហៅបម្រើជាពួកអ្នកមានសិទ្ធិអំណាចទូទៅ ការចាត់តាំងដំបូងឲ្យធ្វើជាគណៈប្រធានតំបន់អាហ្វ្រិកភាគអាគ្នេយ៍ ។ ទំព័រទល់មុខនេះ ៖ អែលឌើរ រិនឡាន់ បានជ្រើសយកគំនូររបស់ព្រះអង្គសង្គ្រោះ ដែលគូរដោយ ហៀនរីច ហូហ្វមែន ដាក់ព្យួរក្នុងការិយាល័យរបស់លោក បន្ទាប់ពីវាបានទាក់ចិត្តលោក ពេលលោកបានឃើញរូបគំនូរនោះនៅក្នុងការិយាល័យប្រធាន ម៉នសុន ។

ក្នុងឆ្នាំ ២០០០ លោកក៏បានធ្វើជានាយកនៃកម្មវិធី ការបង្កា និង ការព្យាបាលជំងឺខ្សោយបេះដូងនៅមជ្ឈមណ្ឌលសុខភាព អ៊ីនធើរម៉ោនធេននៅក្នុងទីក្រុង សលត៍ លេក ។ កម្មវិធីនោះរួមមានការវះកាត់ដេរភ្ជាប់នូវឧបករណ៍ច្របាច់ឈាមទៅនឹងបេះដូង ព្រមទាំងការប្ដូរដាក់បេះដូងសប្បនិមិត្ត ។ លោកវេជ្ជបណ្ឌិត ដូណាល់ ប៊ី ដូទី ជាវេជ្ជបណ្ឌិតវះកាត់បេះដូងដ៏ល្បីល្បាញនៅលើឆាកអន្តរជាតិ គឺជាសហការី និង មិត្តភក្តិរបស់វេជ្ជបណ្ឌិត រិនឡាន់នៅមន្ទីរពេទ្យ អិល. ឌី. អេស ។ វេជ្ជបណ្ឌិត ដូទីបាននិយាយថា « ការបំពាក់បំប៉នរបស់លោកគឺអស្ចារ្យណាស់ មានការយកចិត្តទុកដាក់ ការចាត់ចែងកម្មវិធីដ៏មានប្រសិទ្ធភាព និង មានមេត្តាធម៌ជាខ្លាំង » ។

វេជ្ជ. អេ ជី ហ្វូរី ជាអ្នកជំនឿខាងកាតូលិកដែលបានធ្វើការយ៉ាងជិតស្និទ្ធជាមួយវេជ្ជ. រិនឡាន់អស់រយៈពេលជាច្រើនឆ្នាំថ្លែងថា វេជ្ជ. រិនឡាន់ គឺជាប្រធាននៃអ្នកឯកទេសវះកាត់ប្ដូរបេះដូងនៅក្នុងតំបន់ « ដែលគ្មានគូប្រៀប មានសេចក្ដីថ្លៃថ្នូរ បន្ទាបខ្លួន និង មានចិត្តមេត្តា » ។ គាត់និយាយថា វេជ្ជ. រិនឡាន់ « ជួយមនុស្សផ្សេងទៀតឲ្យក្លាយជាមនុស្សកាន់តែប្រសើរបំផុត ។ លោកបានធ្វើវាដោយមិនចេញមុខមាត់ឡើយ ។ លោកពូកែស្ដាប់ និង មានការយកចិត្តទុកដាក់ ហើយលោកចាប់អារម្មណ៍យ៉ាងខ្លាំងលើជោគជ័យនៃអស់អ្នកដែលធ្វើការជាមួយលោក » ។ វេជ្ជ. រិនឡាន់បានដឹកនាំគេដោយស្ងៀមស្ងាត់តាមរយៈគំរូ ហើយមានការគិតគូរពីគ្រួសារនៃសហការីរបស់លោក ។

ជាពិសេសវេជ្ជ. ហ្វូរី បានកត់សម្គាល់ឃើញជាពិសេសពីក្ដីអាណិតអាសូររបស់វេជ្ជ. រិនឡាន់ ចំពោះអ្នកជំងឺ ។ ឧទាហរណ៍ ប្រសិនបើអ្នកជំងឺគ្មានមធ្យោបាយធ្វើដំណើរនោះវេជ្ជ. រិនឡាន់នឹងទៅដឹកអ្នកជំងឺពីផ្ទះរបស់ពួកគេដែលនៅឆ្ងាយ សែងអ្នកជំងឺដាក់ឡានលោក ហើយបន្ទាប់មកដឹកអ្នកជំងឺទៅមន្ទីរពេទ្យវិញ ។ វេជ្ជ. ហ្វូរីបាននិយាយថា នេះគឺរឿងអស្ចារ្យណាស់ ។

**ការបម្រើនៅក្នុងពួកចិតសិបនាក់**

បន្ទាប់ពីបម្រើជាប្រធានស្តេកអស់រយៈពេលប្រាំឆ្នាំនៅក្នុងស្តេកទីមួយនៃសាកលវិទ្យាល័យ សលត៍ លេក អែលឌើរ រិនឡាន់ ត្រូវបានហៅនៅក្នុងឆ្នាំ ២០០០ ឲ្យបម្រើជាពួកចិតសិបនាក់ប្រចាំតំបន់នៅក្នុងតំបន់យូថាហ៍ ។ ក្រោយមកនៅក្នុងខែ មេសា ឆ្នាំ ២០០៩ លោកត្រូវបានហៅបម្រើជាពួកចិតសិបនាក់ដែលមានសិទ្ធិអំណាចទូទៅ ។ ការចាត់តាំងដំបូងរបស់លោក គឺបម្រើនៅក្នុងគណៈប្រធានតំបន់អាហ្វ្រិកភាគអាគ្នេយ៍ ជាតំបន់មួយដែលមានអង្គភាពជាច្រើននៅក្នុងប្រទេស ២៥ ផ្សេងគ្នា ។







ស៊ិស្ទើរ រិនឡាន់ បានចែកចាយចម្លើយរបស់ពួកគេចំពោះការហៅបម្រើនោះ ៖ « ពិតណាស់ វាជារឿងភ្ញាក់ផ្អើលមួយ ។ ហើយមនុស្សជាច្រើនបាននិយាយថា ‹ អ្នកចាកចេញពីវិជ្ជាជីវៈអ្នក ខណៈដែលអ្នកកំពុងនៅលើចំណុចកំពូលនៃភាពជោគជ័យរបស់អ្នក › ។ ហើយនោះប្រហែលជាការពិត ។ ប៉ុន្តែប្រសិនបើព្រះអម្ចាស់ត្រូវការចំណុចកំពូលនៃភាពជោគជ័យលើវិជ្ជាជីវៈរបស់យើង ហើយនោះគឺជាពេលដែលយើងអាចបម្រើ អញ្ចឹងវាគឺដល់ពេលត្រូវទៅបម្រើហើយ » ។

ដោយមានប្រសាសន៍ពីភរិយាលោកថាជាវីរៈនារីរបស់លោក នោះអែលឌើរ រិនឡាន់មានប្រសាសន៍ថា





« នាងបានលះបង់យ៉ាងធំធេង » ។ ស៊ិស្ទើរ រិនទ្លាន់បានចាកចោលការងាររបស់គាត់ជាប្រធាននៃក្រុមហ៊ុនច្បាប់ និង ចាកចោលមុខតំណែងជាច្រើននៃក្រុមប្រឹក្សាដ៏មានមុខមាត់ ដើម្បីទៅបម្រើជាមួយលោក ។ អែលឌើរ រិនទ្លាន់មានប្រសាសន៍ថា « យើងត្រូវបានបញ្ជូនទៅប្រទេសអាហ្រ្វិក ហើយបានរៀនពីពួកបរិសុទ្ធនៅទីនោះអំពីអ្វីដែលសំខាន់បំផុត » ។

នាថ្ងៃអាទិត្យមួយនៅក្នុងទីក្រុង កុងហ្គោ លោកបានសួរសមាជិកថា តើពួកគេកំពុងជួបនូវឧបសគ្គអ្វីខ្លះ ប៉ុន្តែពួកគេពុំអាចគិតឃើញថាមានឧបសគ្គអ្វីសោះ ។ លោកបានសួរម្ដងទៀត ។ ទីបំផុត មានបុរសចំណាស់ម្នាក់នៅខាងក្រោយបន្ទប់ បានក្រោកឡើង ហើយនិយាយថា « អែលឌើរ រិនទ្លាន់ តើយើងអាចមានឧបសគ្គយ៉ាងដូចម្ដេច ? យើងមានដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ » ។ ដោយគិតពីបទពិសោធន៍នោះ អែលឌើរ រិនទ្លាន់ ពន្យល់ ៖ « ខ្ញុំចង់ក្លាយដូចជាពួកបរិសុទ្ធ កុងហ្គោទាំងនេះ ដែលអធិស្ឋានទូលសុំអាហាររាល់ថ្ងៃ មានអំណរគុណរាល់ថ្ងៃចំពោះអាហារ មានអំណរគុណចំពោះគ្រួសាររបស់ពួកគេ ។ ពួកគេគ្មានអ្វីឡើយ ប៉ុន្តែពួកគេដូចជាមានអ្វីៗគ្រប់យ៉ាងអញ្ចឹង » ។

ការបម្រើនៅក្នុងគណៈប្រធានតំបន់អស់រយៈពេលប្រាំឆ្នាំ អែលឌើរ រិនទ្លាន់បានធ្វើដំណើររាប់ពាន់គីឡូម៉ែត្រ ឆ្លងកាត់តំបន់អាហ្វ្រិកភាគអាគ្នេយ៍ដ៏ធំល្វឹងល្វើយ សួរសុខទុក្ខសមាជិក និង អ្នកផ្សព្វផ្សាយសាសនា ។ លោកបានសិក្សាភាសាបារាំង ដោយសារប្រជាជននៃប្រទេសទាំងនោះនិយាយភាសានេះ ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ដែលជាសមាជិកនៃពួកដប់ពីរនាក់បានចាត់តាំងឲ្យធ្វើការជាមួយគណៈប្រធានតំបន់អាហ្វ្រិកភាគអាគ្នេយ៍នៅគ្រានោះ បានមានប្រសាសន៍អំពីអែលឌើរ រិនទ្លាន់ ៖ « គ្មាននរណាម្នាក់លះបង់ខ្លួនឯងនៅក្នុងតំបន់នេះ និង ចំពោះប្រជាជននេះព្រមទាំងសេចក្ដីត្រូវការរបស់ពួកគេច្រើនជាងអែលឌើរ រិនទ្លាន់បានធ្វើឡើយ ។ លោកបានធ្វើការដោយមិនឈប់ឈរ ដើម្បីស្គាល់ប្រជាជននេះ ស្រឡាញ់វប្បធម៌របស់ពួកគេ ហើយជួយជំរុញពួកបរិសុទ្ធឲ្យឆ្ពោះទៅរកពន្លឺនៃការប្រោសលោះ » ។

**ត្រូវបានហៅបម្រើឲ្យធ្វើជាសាក្សីពិសេស**

នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ លោកបានទទួលទូរសព្ទដោយពុំបានរំពឹងទុកជាមុនមកពីការិយាល័យគណៈប្រធានទីមួយ ។ នៅឯអគាររដ្ឋបាលសាសនាចក្រ « ប្រធាន ថូម៉ាស អេស ម៉នសុន និងទីប្រឹក្សាទាំងពីររូបរបស់លោកបានស្វាគមន៍ខ្ញុំយ៉ាងកក់ក្ដៅ ។ បន្ទាប់ពីយើងបានអង្គុយមក ប្រធាន ម៉នសុន បានមើលមុខខ្ញុំ ហើយមានប្រសាសន៍ថា ‹ ប្អូនប្រុស រិនទ្លាន់ យើងហៅប្អូនប្រុសឲ្យបម្រើជាសមាជិកម្នាក់ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ › » ។

អែលឌើរ រិនទ្លាន់មានភាពស្រឡាំងកាំង ។ លោកបានបន្ទាបខ្លួនទទួលយកការហៅបម្រើនោះ ហើយរំឭកថា « ខ្ញុំគិតថាប្រធាន ម៉នសុន បានដឹងថា ខ្ញុំមានចិត្តសាប់សល់ ដូច្នោះលោកបានមើលមុខខ្ញុំ ហើយលោកបានមានប្រសាសន៍ថា ‹ ព្រះបានហៅប្អូនប្រុស ហើយព្រះអម្ចាស់បានឲ្យខ្ញុំដឹងពីរឿងនេះ › » ។

អែលឌើរ រិនទ្លាន់ បានត្រឡប់ទៅការិយាល័យរបស់លោកវិញ បិទទ្វារ ហើយលុតជង្គង់ចុះអធិស្ឋាន ។ បន្ទាប់ពីសម្រួលអារម្មណ៍របស់លោកហើយនោះ លោកបានហៅភរិយារបស់លោកមក ។ លោកមានប្រសាសន៍ថា « ប្រតិកម្មរបស់នាងចំពោះរឿងនេះគឺភ្ញាក់ផ្អើលណាស់ ប៉ុន្តែវាជាការប្ដេជ្ញាចិត្តយ៉ាងច្បាស់លាស់ចំពោះព្រះអម្ចាស់ សាសនាចក្រទ្រង់ និង ចំពោះខ្ញុំ » ។

កូនស្រីរបស់ពួកគេ អាស្លី ទទួលស្គាល់ថា « ប៉ារបស់ខ្ញុំមានភាពស្ទាត់ជំនាញដោយសារពរជ័យពីឋានសួគ៌ ហើយត្រូវបានរៀបចំពេញមួយជីវិតនៃការបម្រើសម្រាប់ការបម្រើនេះ ។ លោកមានដួងចិត្តនៃសេចក្ដីស្រឡាញ់ធំធេង និង ពេញលេញ » ។

ដូចគ្នានេះផងដែរ បងប្រុសរបស់អែលឌើរ រិនទ្លាន់ ឈ្មោះ ហ្គារី បាននិយាយថា អែលឌើរ រិនទ្លាន់ « ត្រូវបានរៀបចំតាំងពីយូរយារណាស់មកហើយ ទាំងឧបសគ្គ និង ការបម្រើចំពោះការបម្រើនេះដែលលោកបានទទួល ។ នេះគឺជាផ្នែកមួយនៃផែនការដ៏ធំដែលបានកើតឡើង ហើយវាមានភាពងាយស្រួលដល់ខ្ញុំដើម្បីគាំទ្រលោក » ។

ដោយគិតពីការបម្រើដ៏អស្ចារ្យនេះ អែលឌើរ រិនទ្លាន់មានប្រសាសន៍ថា « ខ្ញុំគ្មានអារម្មណ៍ថាខ្ញុំមានសមត្ថភាពឡើយ លើកលែងតែខ្ញុំដឹងថាព្រះយេស៊ូវគ្រីស្ទ គឺជាព្រះអង្គសង្គ្រោះនៃពិភពលោកប៉ុណ្ណោះ ។ ខ្ញុំអាចធ្វើជាសាក្សីនៃការមានព្រះជន្មរស់ពិតរបស់ទ្រង់ ថាទ្រង់គឺជាអង្គសង្គ្រោះរបស់ខ្ញុំ និង របស់បងប្អូន ។ ខ្ញុំដឹងថា រឿងនោះគឺជាការពិត » ។ ■

ខាងឆ្វេង ៖ រូបថតនៅក្នុងការិយាល័យ ដោយ ជុំ ស្កុត DESERET NEWS រូបថតជាមួយស្ត្រីដោយ ចយ ចាស

# ការធ្វើដំណើររបស់ខ្ញុំ

## ក្នុងនាមជាអ្នកត្រួសត្រាយម្នាក់មកពីប្រទេសឥណ្ឌា





ខ្ញុំបានងាកក្រោយមើលពីដំណើរជីវិតរបស់ខ្ញុំកាលពី « ក្មេងរស់នៅក្នុងព្រៃស្បាត » នៅក្នុងតំបន់ដាច់ស្រយាលមួយនៅក្នុងប្រទេសឥណ្ឌា មកក្លាយជាមនុស្សម្នាក់ដែលជារូបខ្ញុំនាបច្ចុប្បន្ននេះ នោះខ្ញុំដឹងថាជីវិត និង សេចក្ដីជំនឿរបស់ខ្ញុំគឺពិតជាអព្ភូតហេតុ ។






ដោយ មែនហ្គាល ដែន ឪពធី ដូចដែលបានប្រាប់ ចន សានតូស្ស មូរ៉ាឡា

ខ្ញុំបានកើតនៅក្នុងភូមិតូចមួយក្នុងព្រៃស្បាតប្រទេសឥណ្ឌាដែលមានជួរភ្នំហាត់ អេស្ទើននៅព័ទ្ធជុំវិញ ។ កាលខ្ញុំអាយុ ១៨ ខែ យើងបានប្ដូរទីលំនៅទៅភូមិ ខែងហ្រ្គាប៉ាលីនៅត្រើយម្ខាងនៃទន្លេកូលាប ។ ឪពុកម្ដាយខ្ញុំដាក់ខ្ញុំក្នុងកន្ត្រក អំឡុងពេលពួកគាត់ធ្វើដំណើរ ។ ក្នុងភូមិនោះមាន ២០ ទៅ ២៥គ្រួសារដែលរស់នៅក្នុងខ្ទមតូចៗដោយគ្មានភ្លើងអគ្គីសនីឡើយ ។ យើងគ្មានសាលារៀន មន្ទីរពេទ្យ ឬ ស្ថានីយ៍រថយន្តក្រុងឡើយ ។ យើងដីកដីនៅបាតទន្លេដើម្បីបានទឹកមកប្រើប្រាស់ ។ កាលនៅកុមារភាពខ្ញុំលេងនៅក្នុងព្រៃស្បាត និង ទីវាលទាំងនោះដោយដើរលើកំណល់ឈើដែលដាក់នៅក្នុងវាលភក់ និង ហែលទឹកទន្លេ ។

បុព្វការីជនរបស់ខ្ញុំគឺជាសង្ឃនៅព្រះវិហារ ហិនឌូ ក្រោមការគ្រប់គ្រងរបស់មហារាជ ( ស្ដេច ) នៃវាំង បាស្តារ នៃទីក្រុង ចាហ្គដាលពរ ។ ប៉ុន្តែនៅពេលស្ថានភាពនយោបាយដែលគ្មានស្ថេរភាពបានប្រែកាន់តែគ្រោះថ្នាក់ នោះជីតារបស់ខ្ញុំ និង គ្រួសារលោកបានគេចខ្លួនទៅទីក្រុង ឧតជាត ។ ពួកគេបានទទួលទីជម្រកសម្រាប់ជនភៀសខ្លួននៅបេសកកម្ម អាល្លីម៉ង់ លូធើរែន នៅទីនោះគាត់បានធ្វើជាគ្រូពេទ្យ និង បម្រើការនៅក្នុង អាយូវេដា ( ជាផ្នែកមើមថ្នាំបុរាណ ) ។ នៅទីនោះហើយដែលជីតារបស់ខ្ញុំបានជ្រើសរើសប្រែចិត្តជឿលើសាសនាគ្រិស្ត ។

ឪពុករបស់ខ្ញុំបានបន្តជំនឿលើសាសនាគ្រិស្ត ដោយជ្រើសរើសធ្វើជាអ្នកផ្សាយដំណឹងល្អ និង ជាមេដឹកនាំសាសនា ( គ្រូបង្រៀន ) ។ ពេលខ្ញុំកើត ខ្ញុំត្រូវបានដាក់ឈ្មោះឲ្យថា មែនហ្គាល ដែន ឪពធី ( មានន័យថា « ល្អ » « អំណោយ » និង « ពន្លឺ » ) ដោយទទួលមរតកនូវទំនៀមទម្លាប់នៃជំនឿសាសនាគ្រិស្ត ។

កាលខ្ញុំនៅក្មេង ខ្ញុំបានចូលរួមព្រះវិហារ អាល្លីម៉ង់ លូធើរែនជាទៀងទាត់ ។ យើងបានទៅលើភ្នំដើម្បីអធិស្ឋានជាមួយគ្នាជាញឹកញាប់ ។ នៅថ្ងៃមួយដែលមានភ្លៀងធ្លាក់ គ្រប់គ្នាដែលនៅក្នុងក្រុមអធិស្ឋាននោះបានទទឹកខ្លួនជោក ហើយមានម្នាក់ដែលជាគ្រូផ្សាយដំណឹងល្អបានផ្ដល់ការអធិស្ឋានដ៏ស្មោះអស់ពីចិត្ត ទូលសុំព្រះអម្ចាស់បញ្ឈប់ភ្លៀង ។ វាគួរឲ្យអស្ចារ្យណាស់ ភ្លៀងបានឈប់មែន ។ នោះគឺជាការចាប់ផ្ដើមនូវសេចក្ដីជំនឿរបស់ខ្ញុំលើព្រះ និង ការអធិស្ឋាន ។

### តើពួកមរមនគឺជាពួកគ្រិស្តសាសនិកឬទេ ?

បន្ទាប់ពីចប់ថ្នាក់ទីប្រាំបី ខ្ញុំពុំបានបន្តការសិក្សានៅសាលាទៀតឡើយ ដោយត្រូវចូលរៀនថ្នាក់សិក្ខាសាលាខាងសាសនាវិទ្យារយៈពេលបីឆ្នាំនៅ ឧតជាត ហើយត្រូវបានតែងតាំងជាអ្នកផ្សាយដំណឹងល្អ ដូចដែលឪពុករបស់ខ្ញុំធ្លាប់បានធ្វើ ។

រូបថតក្មេងប្រុសដែលបានរចនា ដោយ វីនឌី ហ្គីប ខឹលើរ រូបថតនៃ តាយ ម៉ាហាល ដែលមានរចនាជាចម្លាក់នៅផ្ទៃខាងក្រោយ តែមសំបុត្រ © ISTOCK/THINKSTOCK ហេមើរ៉ា/THINKSTOCK

បន្ទាប់ពីដឹកនាំការប្រជុំនៅក្នុង និង ជុំវិញទីក្រុង ខុកជាតអស់រយៈពេលពីរបីឆ្នាំមក ខ្ញុំបានប្ដូរទៅរស់នៅភាគខាងជើងប្រទេសឥណ្ឌា នៅទីនោះខ្ញុំបានចាប់ផ្ដើមលក់សៀវភៅនានាមកពីអ្នកនិពន្ធអំពីសង្គមអ្នកផ្សព្វផ្សាយសាសនាគ្រិស្ដ ។ ខ្ញុំបានឃើញសៀវភៅមួយក្បាលដែលមានចំណងជើងថា *តើពួកមរមនគឺជាពួកគ្រិស្ដសាសនិកឬទេ ?* មានអ្វីមួយនៅក្នុងសៀវភៅនេះបានទាក់ទាញចិត្តខ្ញុំ ហើយខ្ញុំបានសម្រេចចិត្តអានសៀវភៅនោះ ។

សៀវភៅនោះមានពាក្យរិះគន់ជាច្រើនទៅលើពួកមរមន និង ជំនឿរបស់ពួកគេ ។ ទោះជាយ៉ាងណាក៏ដោយ ផ្នែកជាច្រើនទៀតនៅក្នុងសៀវភៅនោះបានទាក់អារម្មណ៍ខ្ញុំជាខ្លាំង ជាពិសេសសិក្ខាបទរបស់ពួកគេអំពីក្រុមព្រះ សមាសភាគនៃការថ្វាយបង្គំរបស់ពួកគេ ព្រមទាំងប្រវត្តិអំពីពហុពន្ធភាព ។ ប៉ុន្តែ អ្វីមួយដែលខ្ញុំចាប់ចិត្តខ្លាំងបំផុតនោះគឺថាសាសនាចក្ររបស់ពួកគេបានដាក់ឈ្មោះតាមព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំអន្ទះសាចង់ដឹងបន្ថែមទៀតជាខ្លាំង ។

ថ្ងៃមួយពេលខ្ញុំកំពុងអធិស្ឋាន ខ្ញុំមានអារម្មណ៍បំផុសគំនិតឲ្យទៅសើបអង្កេតពីព្រះវិហារពួកមរមន ។ ខ្ញុំបានដឹងថាទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍គឺជាទីស្នាក់ការកណ្ដាលរបស់សាសនាចក្រ ។ ខ្ញុំបានសម្រេចចិត្តសរសេរសំបុត្រមួយ ហើយចារលើខ្នងសំបុត្រនោះផ្ញើជូនទៅកាន់ « អ្នកដែលគ្រប់គ្រងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍ ស.រ.អា. » ។

## ការរៀនសូត្រពីសាវក

នៅក្នុងឆ្នាំ ១៩៥៩ បងប្រុស ឡាម៉ា វិល្លាម មកពីនាយកដ្ឋានអ្នកផ្សព្វផ្សាយសាសនារបស់សាសនាចក្របានផ្ញើទីបន្ទាល់របស់យ៉ូសែប ស្ម៊ីធ មាត្រានៃសេចក្ដីជំនឿ និង ព្រះគម្ពីរមរមនមកឲ្យខ្ញុំ ដែលជាការឆ្លើយតបចំពោះសំបុត្ររបស់ខ្ញុំនោះ ។ ខ្ញុំបានសិក្សាសម្ភារទាំងអស់នោះ ហើយខ្ញុំបានប្រែចិត្តជឿដោយសារតែសេចក្ដីពិតពេញលេញដែលមាននៅក្នុងសម្ភារទាំងនោះ ។ ប៉ុន្តែ គ្មានអ្នកផ្សព្វផ្សាយសាសនា ឬ សមាជិកបង្រៀនខ្ញុំនៅក្នុងប្រទេសឥណ្ឌាឡើយ ។

ក្រោយមកនៅក្នុងខែ មករា ឆ្នាំ ១៩៦១ អែលឌើរ ស្ពែនសើរ ដបុលយូ឴ ឃឹមបឹល ( ឆ្នាំ ១៨៩៥–១៩៨៥ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានធ្វើទស្សនកិច្ចមកទីក្រុង ដេលី ។ ខ្ញុំបានចំណាយពេលបីថ្ងៃធ្វើដំណើរជាមួយលោកទៅវិហារ តាយម៉ាហាល នៅ អាក្រា និង ទៅ ដាម៉ាស្សាឡា ។ លោកបានបង្រៀនមេរៀនដំណឹងល្អជាច្រើន ហើយខ្ញុំស្ដាប់គាត់នាប់យល់ដូចជាអេប៉ុងជក់ទឹកអញ្ចឹង ។ នៅថ្ងៃចុងក្រោយនៃទស្សនកិច្ចរបស់លោក ខ្ញុំបានត្រៀមខ្លួនរួចរាល់ដើម្បីជ្រមុជទឹក ។ នៅថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៦១ អែលឌើរ ឃឹមបឹល បានជ្រមុជទឹកឲ្យខ្ញុំនៅទន្លេ យ៉ាមូណា សីស្ទើរ ឃឹមបឹល គឺជាសាក្សីផ្លូវការម្នាក់ ទោះបីជាមានអ្នកមើលដ៏សំខាន់ៗជាច្រើននាក់ទៀតក៏ដោយ ។ ខ្ញុំបានទទួលការបញ្ជាក់នាពេលល្ងាចនោះ ។

ពេលសាវករបស់ព្រះអម្ចាស់បានបង្រៀនខ្ញុំរយៈពេលបីថ្ងៃដោយគ្មានអ្វីមករំខាន នោះគឺជាពេលវេលាដ៏អស្ចារ្យបំផុតនៅក្នុងជីវិតរបស់ខ្ញុំ ។ អ្វីមួយដែលសោកស្ដាយនោះគឺថាលោកបានក្លាយជាមិត្តភក្ដិមរមនដ៏ពិសេសរបស់ខ្ញុំ ។



## ចំណង់ចង់ក្លាយជាពួកបរិសុទ្ធ

បន្ទាប់ពីអែលឌើរ ឃឹមបឹល បានចាកចេញទៅ ខ្ញុំបានចែកចាយបទពិសោធន៍នៃការប្រែចិត្តជឿរបស់ខ្ញុំជាមួយមិត្តភក្ដិរបស់ខ្ញុំ ហើយពួកគេបានសើចចំអកឲ្យខ្ញុំ ។ ប៉ុន្តែ ខ្ញុំបានដឹងថាដំណឹងល្អគឺជាការពិត ហើយខ្ញុំពុំអាចបដិសេធបានឡើយ ដូច្នោះខ្ញុំបានសម្រេចចិត្តស្វែងរកវគ្គបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈផ្សេងមួយទៀត ។ ខ្ញុំបានចាប់ផ្ដើមអាជីវកម្មដេរខោអាវដូចឪពុករបស់ខ្ញុំបានធ្វើ ។ ដោយសន្សឹមៗ ខ្ញុំបានដឹងថាខ្ញុំពុំអាចរីកចម្រើនឡើយ លុះត្រាខ្ញុំមានការអប់រំបន្ថែមទៀត ។ ខ្ញុំមានអាយុជាង ២០ ឆ្នាំ ហើយគំនិតដែលថាត្រូវត្រឡប់ទៅរៀនវិញនោះគឺជាគំនិតញញួរមួយ ប៉ុន្តែខ្ញុំបានចំណាយពេលប្រាំបួនឆ្នាំក្រោយមកដើម្បីទទួលយកការអប់រំ ។ ខ្ញុំបានធ្វើអាជីវកម្មរបស់ខ្ញុំពេលព្រឹក ហើយទៅរៀននៅពេលល្ងាច ។ ខ្ញុំបានចំណាយប្រាក់ដែលខ្ញុំរកបានទាំងអស់ទៅលើការសិក្សា ។ ខ្ញុំបានប្ដេជ្ញាចិត្ត ហើយអធិស្ឋានសូមជំនួយពីព្រះ ។ ខ្ញុំបានបន្តរៀនរហូតទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែក ចិត្តវិទ្យា សង្គមវិទ្យា និង សិល្បៈមកពីសាកលវិទ្យាល័យអាក្រា ។ ទីបំផុត ខ្ញុំបានចូលរៀននៅសាកលវិទ្យា មីរ៉ុត ដើម្បីសិក្សាយកសញ្ញាបត្រផ្នែកច្បាប់ ។

អំឡុងពេលដំបូងៗនៃប្រាំបួនឆ្នាំនោះ មានគ្រួសារមួយនៃពួកបរិសុទ្ធថ្ងៃចុងក្រោយនៅទីក្រុង ដេលី គឺគ្រួសារ ស្មុតលែហ្វ ដែលបានធ្វើការនៅក្នុងស្ថានទូតសហរដ្ឋ ។ ខ្ញុំបានធ្វើដំណើរទៅទីក្រុង ដេលី ដើម្បីចូលរួមពិធីសាក្រាម៉ង់នៅក្នុងផ្ទះរបស់ពួកគេ ។ នៅក្នុងឆ្នាំ ១៩៦២ អែលឌើរ រីឆាដ អិល អ៊ីវ៉ាន ( ឆ្នាំ ១៩០៦–៧១ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានជួបជាមួយពួកយើង ហើយនៅក្នុងឆ្នាំ ១៩៦៤ អែលឌើរ ហ្គរដុន ប៊ី ហ៊ិងគ្លី ( ឆ្នាំ ១៩១០–២០០៨ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមកផងដែរ ។ ខ្ញុំចាំពីការបំពាក់កម្រងផ្កាឲ្យអែលឌើរ ហ៊ិងគ្លី និង បានប្រគល់ឆ្នាំងមួយដែលមានដង្វាយមួយភាគក្នុងដប់ដែលខ្ញុំបានសន្សំទុក គឺបានសន្សំទុកអស់ពេលជាច្រើនឆ្នាំមកហើយ ។

ជាអកុសល គ្រានៃការរាប់អានបែបនេះ — ដែលមានន័យបំផុត — កម្រកើតឡើងណាស់ ហើយដង្ហើយទៅវិញនៅក្នុងប្រទេសឥណ្ឌា ខ្ញុំគ្មានការរាក់ទាក់ជាប់ជានិច្ចពីពួកបរិសុទ្ធដទៃទៀតឡើយ ។ ការណ៍នេះបានកក្កូនដួងចិត្តខ្ញុំយ៉ាងខ្លាំង ។ នៅឆ្នាំបន្តបន្ទាប់ទៀតមក ភាពឯកោតែឯងបានចាប់ផ្ដើមជះឥទ្ធិពលអវិជ្ជមានដល់រូបខ្ញុំ ហើយខ្ញុំឃើញថាគ្មានអនាគតចំពោះខ្ញុំឡើយនៅក្នុងប្រទេសឥណ្ឌា ។ ខ្ញុំចង់បានបព្វជិតភាព ហើយរស់នៅក្នុងចំណោមពួកបរិសុទ្ធខ្លាំងណាស់ ។

## ក្លាយជាអ្នកត្រួសត្រាយ

នៅពេលខ្ញុំមានអារម្មណ៍ថា វាដល់ពេលដែលខ្ញុំត្រូវខិតឲ្យកាន់តែជិតនឹងពួកបរិសុទ្ធ នោះខ្ញុំបានឈប់រៀននៅសាលាច្បាប់ ហើយធ្វើអន្តោប្រវេសន៍ទៅប្រទេសកាណាដា ។ នៅពេលយន្តហោះបានចុះចតនៅអែតម៉ុនថុន អាល់ប៊ើតា ខ្ញុំបានទៅវួដមួយដែលនៅក្បែរនោះបំផុត ។ ខ្ញុំបានជួបជាមួយប៊ីស្សព ហារី ស្មីធ ហើយភ្លាមនោះខ្ញុំបានមានអារម្មណ៍ថាជាកម្មសិទ្ធិ និង មានការរាប់អាននៅក្នុងវួដនោះ ។ ខ្ញុំបានទៅទស្សនាព្រះវិហារបរិសុទ្ធ ខាតស្តុន អាល់ប៊ើតា ទោះបីជាខ្ញុំពុំទាន់អាចទទួលអំណោយទានពិសិដ្ឋរបស់ខ្ញុំក្ដី ។

រូបថតដែលបានទទួលសិទ្ធិអនុញ្ញាតពីមែនហ្វ្រេន ដែន ឌីពី និង បណ្ណាល័យការប្រវត្តិ ប៊ី.វ៉ាយ.យូ. ។




*ខាងលើ ៖ បងប្រុស ឌីពធី កាលជានិស្សិតនៅប្រទេសឥណ្ឌា ។ ខាងក្រោម ៖ បងប្រុស ឌីពធី ( ខាងឆ្វេង ) ជាមួយ ប៉ុល ទ្រីស្សូវ៉ាដាស ជាអ្នកត្រួសត្រាយម្នាក់ផ្សេងទៀតដែលជាសមាជិកសាសនាចក្រមកពីប្រទេសឥណ្ឌា នៅវិសាលដ្ឋាននៃព្រះវិហារបរិសុទ្ធក្នុងទីក្រុងសលត៍ លេក ។ ខាងឆ្វេង ៖ ប្រធាន ស្ពែនសើរ ដបុលយូ ឃីមបឹល បានដើរតួយ៉ាងសំខាន់នៅក្នុងដំណើរត្រួសត្រាយរបស់បងប្រុសឌីពធី ។*

ខ្ញុំចង់ទៅទស្សនាទីក្រុង សលត៍ លេក ហើយធ្វើឲ្យមិត្តភក្តិរបស់ខ្ញុំ អែលឌើរ ឃីមបឹល និង បងប្រុសឡាម៉ា វិល្លាមមានការភ្ញាក់ផ្អើល ។ ទីបំផុតនៅក្នុងរដូវផ្ការីក ឆ្នាំ ១៩៦៩ ប្រាំបីឆ្នាំបន្ទាប់ពីខ្ញុំបានជ្រមុជទឹក ខ្ញុំបានទៅទស្សនាទីក្រុង សលត៍ លេក ហើយបានជួបអែលឌើរ ឃីមបឹល ។ លោកមានក្តីរីករាយណាស់ ហើយបានចំណាយពេលពេញមួយថ្ងៃជាមួយខ្ញុំ ។

កាលនៅទីក្រុង សលត៍ លេក ខ្ញុំបានទៅហាងមួយដើម្បីកាត់សក់ ។ ខ្ញុំបានចែកចាយទីបន្ទាល់របស់ខ្ញុំជាមួយនឹងជាងកាត់សក់នោះ ដែលគាត់ក៏ជាអ្នកប្រែចិត្តជឿដោយខ្លួនឯងដែរ ។ មានសុភាពបុរសម្នាក់កំពុងរង់ចាំកាត់សក់ ដែលស្តាប់ឮខ្ញុំដោយចៃដន្យ ហើយបានប្រាប់ខ្ញុំពីការធ្វើដំណើររបស់គាត់ទៅប្រទេសឥណ្ឌា ។ គាត់បានចេញថ្លៃកាត់សក់ឲ្យខ្ញុំ អញ្ជើញខ្ញុំទៅបរិភោគអាហារពេលល្ងាច ហើយបានបើកឡាននាំខ្ញុំទៅសាកលវិទ្យាល័យ ព្រិកហាំយ៉ង់ ។ ខ្ញុំមានការភ្ញាក់ផ្អើលដោយឃើញបរិវេណសាកលវិទ្យាល័យនោះ ។ ខ្ញុំបាននិយាយថា ខ្ញុំចង់បន្តការសិក្សារបស់ខ្ញុំនៅទីនេះ ប៉ុន្តែខ្ញុំគ្មានប្រាក់គ្រប់គ្រាន់ដើម្បីរៀនទេ ។ បុរសម្នាក់នោះបានសុំបង់ប្រាក់ ១000 ដុល្លារសម្រាប់ថ្លៃសិក្សារបស់ខ្ញុំ ។ ខ្ញុំមានចិត្តរំភើប និង មានអំណរគុណយ៉ាងខ្លាំង ។

ខ្ញុំបានចូលរួមកម្មវិធីកិច្ចការសង្គមនៅសាកលវិទ្យាល័យ ប៊ី. វ៉ាយ. យូ ។ នៅក្នុងឆ្នាំ ១៩៧២ បន្ទាប់ពីបញ្ចប់ការសិក្សាសពីសាកលវិទ្យាល័យ ប៊ី. វ៉ាយ.យូ ខ្ញុំបានប្តូរទៅរស់នៅទីក្រុង សលត៍ លេក ដើម្បីបន្តរៀនយកសញ្ញាបត្រអនុបណ្ឌិតមកពីសាកលវិទ្យាយូថាហ៍ ។ ក្រោយមកខ្ញុំបានប្តូរទៅនៅរដ្ឋ កាលីហ្វូញ៉ា ស.រ.អា. នៅទីនោះខ្ញុំបានរៀនថ្នាក់បណ្ឌិតផ្នែកពិនិត្យ និង ព្យាបាលខាងចិត្តវិទ្យា បានបង្រៀនវគ្គសិក្សាស្តីពីរបៀបដើម្បីបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ ហើយបាននិពន្ធសៀវភៅមួយក្បាល ។ ឥឡូវនេះខ្ញុំបានចូលនិវត្តន៍ ហើយរស់នៅជាមួយភរិយារបស់ខ្ញុំ វីនឌីនៅរដ្ឋ ណារ៉ាដា ស.រ.អា. ។



មានគ្រាមួយដែលខ្ញុំបានឆ្លងកាត់នូវការលំបាក ឧបសគ្គ និង សេចក្តីទុក្ខលំបាកផ្ទាល់ខ្លួនជាច្រើន ។ ការផ្តោតចិត្តទុកដាក់របស់ខ្ញុំលើដំណឹងល្អ និង ពរជ័យនៃព្រះវិហារបរិសុទ្ធបានជួយខ្ញុំឲ្យយកឈ្នះលើឧបសគ្គជាច្រើននៃជីវិតនេះ ។

**ផែនការរបស់ទ្រង់គឺអស្ចារ្យណាស់**

ជារឿយៗ ខ្ញុំបានងាកក្រោយមើលពីដំណើរជីវិតរបស់ខ្ញុំកាលពី « ក្មេងរស់នៅក្នុងព្រៃស្បាត » នៅក្នុងតំបន់ដាច់ស្រយាលមួយនៅក្នុងប្រទេសឥណ្ឌា មកក្លាយជាមនុស្សម្នាក់ដែលជារូបខ្ញុំនាបច្ចុប្បន្ននេះ នោះខ្ញុំដឹងថាជីវិត និង សេចក្តីជំនឿរបស់ខ្ញុំគឺពិតជាអព្ភូតហេតុ ។ ការរៀបចំរបស់ព្រះអម្ចាស់សម្រាប់ជីវិតរបស់ខ្ញុំគឺវាអស្ចារ្យជាងអ្វីដែលខ្ញុំរពឹងគិតទៅទៀត ។ វាជាការអស្ចារ្យអ្វីម្ល៉េះ ដែលមានព្យាការី ស្ពែនសើរ ដបុលយូ ឃីមបឹល ជាអ្នកដែលព្រះអម្ចាស់តាំងឡើង បង្រៀនខ្ញុំ ហើយដើរជាមួយខ្ញុំនៅក្នុងគ្រាសំខាន់ៗនៅក្នុងដំណើរជីវិតរបស់ខ្ញុំ ។

ជារឿយៗ ខ្ញុំគិតងាកទៅគ្រាដែលខ្ញុំមានជាមួយប្រធាន ឃីមបឹល ។ លោកបានអញ្ជើញខ្ញុំឲ្យទៅដំណើរកម្សាន្តបោះជំរុំ ពិចនិច និង បុណ្យថ្លែងអំណរគុណ ព្រមទាំង បុណ្យគ្រីស្ទម៉ាស់ជាមួយគ្រួសារលោក ។ រហូតមកដល់ឥឡូវនេះ ខ្ញុំបានដឹងថាលោកគឺពិតជាសាវក និង ជាព្យាការីរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទមែន ។

ខ្ញុំបានជួបប្រធាន ឃីមបឹល លើកចុងក្រោយអំឡុងពេលលោកឈឺជាទម្ងន់ ប៉ុន្តែលោកនៅតែញញឹម ហើយឱបខ្ញុំ ។ លោកគឺជាពួកអិល. ឌី. អេស. ដំបូងគេដែលខ្ញុំទាក់ទង ហើយខ្ញុំបានដឹងថាលោកនឹងមិនដែលបំភ្លេចខ្ញុំនោះឡើយ ។

ខ្ញុំមានអំណរគុណចំពោះព្រះសម្រាប់ព្យាការីរបស់យើង និង ដំណឹងល្អដែលបានស្តារឡើងវិញ ។ សាសនាចក្ររបស់យើងគឺជាសាសនាចក្រគំរូរបស់ព្រះដែលពិភពលោកត្រូវការនាសម័យនេះ ។ ដោយសារសាសនាចក្រ ខ្ញុំអាចទទួលបានការអប់រំ ហើយរីកចម្រើនជាពលរដ្ឋម្នាក់ ។ ខ្ញុំមានអំណរគុណចំពោះថ្ងៃនោះ នៅពេលខ្ញុំបានដឹងថាការអធិស្ឋានគឺជាការពិត ហើយថាខ្ញុំមានឆន្ទៈស្តាប់នូវសំឡេងតូចរហៀង ហើយព្យាយាមស្វែងរកសាសនាចក្រ ។ ខ្ញុំមានអំណរគុណដែលខ្ញុំបានអនុញ្ញាតឲ្យព្រះអម្ចាស់រៀបចំខ្សែជីវិតរបស់ខ្ញុំ ។ ខ្ញុំដឹងថា ប្រសិនបើយើងស្វែងរកនគររបស់ទ្រង់ នោះអ្វីៗគ្រប់យ៉ាងទៀតនឹងប្រទានមកយើងថែមទៀតផង ( សូមមើល ម៉ាថាយ ៦:៣៣) ។ ■

*អ្នកនិពន្ធមកពីតេលែនហ្គាណា ប្រទេស ឥណ្ឌា ។*



## ដូចជាស្ត្រីមេម៉ាយនៅសារិបតា ៖

# អព្ភូតហេតុនៃដង្វាយតមអាហារ

*នៅពេលយើងគិតពីការថ្វាយដង្វាយតមអាហារឲ្យកាន់តែមានចិត្តទូលាយជាងមុន នោះយើងបានចាំថា មនុស្សម្នាក់ថ្វាយរបស់តូចមួយដល់ព្រះអម្ចាស់ នោះទ្រង់នឹងប្រទានពរជ័យដ៏ធំដល់អ្នកនោះវិញ ។*

**ដោយ ប៉ូ នៀន ( ហ្វេលីព ) ជូ និង ពេត្រា ជូ**

គ្រួសារជាច្រើននៅទូទាំងពិភពលោកនេះជួបនូវការលំបាកផ្នែកហិរញ្ញវត្ថុ ជាពិសេសអំឡុងពេលមានវិបត្តិសេដ្ឋកិច្ច ។[១] ឥទ្ធិពលនៃវិបត្តិបែបនេះធ្លាប់កើតមានឡើងនៅក្នុងវួដក្នុងតំបន់របស់យើងកាលពីច្រើនឆ្នាំកន្លងទៅ នៅពេលយើងបានឃើញគ្រួសារជាច្រើនត្រូវការជំនួយ ។ នៅដើមឆ្នាំនោះ ប៊ីស្សពរបស់យើងបានចែកចាយដល់យើងអំពីការអញ្ជើញរបស់ប្រធានស្តេករបស់យើងឲ្យថ្វាយដង្វាយតមអាហារដោយចិត្តទូលាយ ដើម្បីជួយដល់អស់អ្នកដែលខ្វះខាត ។

ទោះបីជាថ្នាក់ដឹកនាំរបស់ពួកយើងបានសុំឲ្យយើងក្រឡេកមើលពីស្ថានភាពរៀងខ្លួនយើង ហើយពិចារណាប្រសិនបើយើងអាចមានចិត្តកាន់តែទូលាយជាងមុនជាមួយនឹងដង្វាយតមអាហាររបស់យើង ក៏ពួកលោកពុំបានបញ្ជាក់ជាក់លាក់ថាតើយើងគួរបង់ប៉ុន្មាននោះឡើយ ។ ប៉ុន្តែ ព្រះវិញ្ញាណបានរំឭកពួកយើងពីដំបូន្មានរបស់ប្រធានម៉ារ៉ុន ជី រ៉មនី ( ឆ្នាំ ១៨៩៧–១៩៨៨ ) ជាទីប្រឹក្សាទីមួយនៃគណៈប្រធានទីមួយ ដែលបានប្រាប់កាលពីច្រើនឆ្នាំមកហើយ ។ លោកបានមានប្រសាសន៍ ៖ « ខ្ញុំជឿជាក់យ៉ាងមុតមាំថា អ្នកពុំអាចផ្តល់ដល់សាសនាចក្រ និង ស្ថាបនានគរព្រះ ហើយប្រែជាកាន់តែខ្វះខាតខាងហិរញ្ញវត្ថុនោះទេ ។ . . . មនុស្សម្នាក់ថ្វាយរបស់តូចមួយដល់ព្រះអម្ចាស់ នោះទ្រង់នឹងប្រទានពរជ័យដ៏ធំដល់អ្នកនោះវិញ ។ នោះគឺជាបទពិសោធន៍របស់ខ្ញុំ ។ ប្រសិនបើសមាជិកសាសនាចក្រនឹងបរិច្ចាគដង្វាយតមអាហារគុណនឹងពីរ នោះជីវភាពខាងវិញ្ញាណនៅក្នុងសាសនាចក្រនឹងកើនឡើងគុណនឹងពីរដែរ ។ យើងត្រូវតែចាំរឿងនេះនៅក្នុងចិត្ត ហើយមានចិត្តទូលាយនៅក្នុងការបរិច្ចាគរបស់យើង » ។[២]

ប្រគ័ន្ធដោយ ស៊្រ ដាតុប ដាល

យើងដឹងថាវាគឺជាការលះបង់មួយចំពោះគ្រួសាររបស់យើង ដើម្បីបង្កើនថវិកាទៅក្នុងដង្វាយតមអាហាររបស់យើង ប៉ុន្តែយើងបានពិចារណាពីការបង្រៀន និង ការសន្យារបស់ប្រធាន រ៉មនី យ៉ាងយកចិត្តទុកដាក់ ។ យើងបានទទួលពរជ័យយ៉ាងក្រាស់ក្រែ ហើយយើងទទួលអារម្មណ៍ដ៏ខ្លាំងក្លាដើម្បីបង្កើនថវិកាសម្រាប់ថ្វាយដង្វាយតមអាហាររបស់យើងជាមួយគ្រួសារ ។

ជាងនេះទៅទៀត យើងចង់ឲ្យគ្រួសាររបស់យើងយកឈ្នះលើទំនោរចិត្តនៃភាពអាត្មានិយម ។ ដោយសារយើងរស់នៅក្នុងសង្គមដែលផ្តោតចិត្តលើអ្វីៗដែលយើងទទួលបាន និង ការបំពេញតែចំណង់ចង់បានរបស់ខ្លួនយើងផ្ទាល់ នោះយើងបានបារម្ភថាកូនៗរបស់យើងនឹងមានភាពអាត្មានិយមច្រើនឡើង ។ ប៉ុន្តែយើងមានសង្ឃឹមលើប្រសាសន៍របស់ប្រធាន ស្ពែនសើរ ដបុលយូ឴ ឃីមបឹល ( ឆ្នាំ ១៨៩៥–១៩៨៥ ) ៖ « តាមរយៈការអនុវត្តតាមក្រឹត្យវិន័យនៃការតមអាហារ នោះមនុស្សម្នាក់នឹងឃើញប្រភពនៃអំណាចផ្ទាល់ខ្លួនមួយដើម្បីយកឈ្នះលើការធ្វើតាមចិត្តខ្លួនឯង និង ភាពអាត្មានិយម » ។[៣]

នៅអំឡុងពេលបីខែដំបូងនៃការថ្វាយដង្វាយតមអាហារដោយចិត្តទូលាយ យើងចាប់ផ្តើមឃើញមានពរជ័យជាច្រើន ។ យើងអាចចំណាយតិចលើគ្រឿងទេស ហើយសាំងឡានរបស់យើងហាក់បីដូចជានៅពេញជិះបានយូរជាងមុន ។ កូនៗរបស់យើងបានសុំរបស់របរផ្សេងៗតិចជាងមុន ហើយភាពអាត្មានិយមនៅក្នុងគេហដ្ឋានរបស់យើងស្ទើរតែរលត់បាត់អស់ ។

ឧទាហរណ៍ នៅពេលយើងបានបរិច្ចាគឲ្យទៅក្រុមបរិច្ចាគអាហារនៅក្នុងមូលដ្ឋាន នោះកូនៗរបស់យើងបានចាប់ផ្តើមលើកទឹកចិត្តយើងឲ្យបរិច្ចាគកាន់តែច្រើនទៀត ។ នៅពេលយើងធ្វើការរាប់សន្និធិនៃការផ្គត់ផ្គង់អាហារប្រចាំឆ្នាំរបស់យើង នោះយើងបានឃើញថាយើងពិតជាមានអាហារស្មើនឹងតម្លៃអាហារសម្រាប់រយៈពេលពីរឆ្នាំ ។ លើសពីនោះទៀត កាលពីមុនយើងចំណាយអង្ករ ២២.៧ គីឡូក្រាមក្នុងមួយខែ ។ ឥឡូវនេះអង្ករទម្ងន់ដដែលនោះយើងអាចប្រើបានដល់ទៅពីរខែ ។ វាហាក់ដូចជាឃ្លាំងស្តុកទុកអាហាររបស់យើងកំពុងតែកើនឡើង ។

យើងនឹកចាំពីរឿងនៃស្ត្រីមេម៉ាយនៅសារិបតា ។ អំឡុងគ្រាមានភាពទុរភិក្ស ព្យាការី អេលីយ៉ា បានអំពាវនាវដល់ស្ត្រីមេម៉ាយម្នាក់ ដែលគ្មានអ្វីនឹងផ្តល់ជាអាហារដល់លោក បានសុំឲ្យស្ត្រីនោះផ្តល់ទឹក និង នំបុ័ងដល់លោក ។ នាងឆ្លើយថា « ខ្ញុំស្បថដោយនូវព្រះយេហូវ៉ា ជាព្រះនៃអ្នកដ៏មានព្រះជន្មរស់នៅថា ខ្ញុំគ្មាននំមួយដុំឡើយ មានតែម្សៅមួយក្តាប់នៅក្នុងខាប់ និងប្រេងបន្តិចបន្តួចនៅដបប៉ុណ្ណោះ មើលនែ ខ្ញុំកំពុងតែរើសអំកាច់ឈើពីរនេះ ដើម្បីចូលទៅចម្អិនសម្រាប់ខ្ញុំ និងកូន យើងនឹងបរិភោគតែប៉ុណ្ណោះ រួចស្លាប់ទៅ » ( ពង្សាវតារក្សត្រទី ១ ១៧:១២ ) ។

ព្យាការីបានសន្យានឹងនាងថា « ម្សៅក្នុងខាប់នោះនឹងមិនដែលផុតទៅ ហើយប្រេងក្នុងដបក៏មិនដែលរលោះឡើយ ។ . . .

ដូច្នេះ នាងក៏ទៅធ្វើតាមបង្គាប់របស់អេលីយ៉ា រួចទាំងនាង និងលោក ព្រមទាំងកូននាង គ្រប់គ្នាបានបរិភោគតមកជាយូរថ្ងៃ » ( ពង្សាវតារក្សត្រទី ១ ១៧:១៤–១៥ ) ។ ម្សៅរបស់នាង ដែលមានគ្រប់គ្រាន់សម្រាប់តែអាហារមួយពេលសម្រាប់គ្រួសាររបស់ខ្លួននោះបានកើនឡើង ដែលធ្វើឲ្យគ្រួសាររបស់នាង និង មនុស្សដទៃទៀតបរិភោគបានតមកជាយូរថ្ងៃ ។ អព្ភូតហេតុដូចគ្នាបែបនេះ — ដោយផ្អែកលើដង្វាយផ្ទាល់ខ្លួនរបស់យើង — កំពុងតែកើតមានឡើងនៅក្នុងគ្រួសាររបស់យើង ។

អំឡុងពេលដែលមានការលំបាកនៅក្នុងផ្នែកហិរញ្ញវត្ថុ ការថ្វាយដង្វាយតមអាហារដោយចិត្តទូលាយ និង ជួយខ្វល់ខ្វាយដល់អ្នកដែលខ្វះខាតអាចជាការពិបាក ជាពិសេសនៅពេលយើងស្ថិតក្នុងស្ថានភាព — ដូចជាស្ត្រីមេម៉ាយនៅសារិបតា — ក្នុងចំណោមអ្នកខ្វះខាត ។ ការថ្វាយដង្វាយតមអាហារដោយចិត្តទូលាយ ដោយមិនគិតពីបរិមាណទឹកប្រាក់ តម្រូវឲ្យមានជំនឿលើព្រះអម្ចាស់ និង ការសន្យារបស់ទ្រង់ដើម្បីថែទាំយើង ។ ប៉ុន្តែ ព្រះអម្ចាស់បំពេញការសន្យារបស់ទ្រង់ ហើយបទពិសោធន៍របស់គ្រួសារយើងបានបង្រៀនយើងថា ដរាបណាយើងមានឆន្ទៈចែករំលែក ដរាបនោះយើងនឹងកាន់តែទទួលពរជ័យ ។

ដូចប្រធាន រ៉មនី បានមានប្រសាសន៍ ៖ « សូមកុំផ្តល់ ដើម្បីគ្រាន់តែជាប្រយោជន៍ដល់អ្នកក្រីក្រឡើយ ប៉ុន្តែផ្តល់ដើម្បីសុខុមាលភាពផ្ទាល់ខ្លួនអ្នកផងដែរ ។ ចូរថ្វាយឲ្យគ្រប់គ្រាន់ ប្រយោជន៍ឲ្យអ្នកអាចឲ្យខ្លួនអ្នកចូលទៅក្នុងនគរព្រះ តាមរយៈការញែកមធ្យោបាយ និង ពេលវេលារបស់អ្នក » ។[៤] ការថ្វាយដង្វាយតមអាហារដោយចិត្តកាន់តែទូលាយ ជួយគ្រួសាររបស់យើងឃើញក្តីអំណរនៅក្នុងការមើលថែដល់ជនក្រីក្រ ហើយពង្រឹងសុខុមាលភាពខាងវិញ្ញាណរបស់យើងផ្ទាល់ ។

ឆន្ទៈរបស់យើងដើម្បីថ្វាយរបស់តូចមួយបានប្រទានពរជ័យជាច្រើនដល់យើងវិញ ។ ឆន្ទៈរបស់យើងដើម្បីថ្វាយដង្វាយតមអាហារដោយចិត្តទូលាយ បានប្រទានអាហារនៅក្នុងឃ្លាំងរបស់យើងឡើងទ្វេដង ។ ពិតណាស់ ព្រះចេស្តានៃព្រះអម្ចាស់ដើម្បីបង្កើននំបុ័ងប្រាំដុំ និង ត្រីពីរ សម្រាប់បុរស ៥០០០ នាក់ ឥតរាប់ពួកស្រីៗ និងក្មេងៗទេ បានបរិភោគឆ្អែតហើយប្រមូលចំណិតដែលនៅសល់ដាក់បាន ១២ កន្ត្រក ( សូមមើល ម៉ាថាយ ១៤:១៦–២១ ) គឺជាព្រះចេស្តាដូចគ្នាទៅនឹងការបំពេញម្សៅដល់ស្ត្រីមេម៉ាយនៅសារិបតា និង បានបង្កើនអាហារនៅក្នុងឃ្លាំងនៃគ្រួសារយើង ។ មិនត្រឹមតែប៉ុណ្ណោះឡើយ ពរជ័យដ៏មហិមាបំផុតរបស់យើងពុំបានកើតឡើងដូចជាការបង្កើនអាហារនោះទេ ប៉ុន្តែវាបានកាត់បន្ថយភាពអាត្មានិយម ហើយបង្កើនជីវភាពខាងវិញ្ញាណនៅក្នុងគេហដ្ឋានរបស់យើង ។

វាជាទីបន្ទាល់របស់យើងថា នៅពេលយើងបរិច្ចាគដោយចិត្តទូលាយទៅក្នុងមូលនិធិដង្វាយតមអាហាររបស់សាសនាចក្រ ទោះបីជាមធ្យោបាយរបស់យើងមានកំណត់ក្តី នោះព្រះអម្ចាស់នឹងបង្កើនការខិតខំរបស់យើង ហើយប្រទានពរដល់យើងហួសពីអ្វីដែលយើងអាចយល់បាន ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*

កំណត់ចំណាំ

១. សូមមើល ឧទាហរណ៍ ហិនរី បី អាវរិង « Is Not This the Fast That I Have Chosen ? » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ២២–២៥ ។
២. ម៉ារ៉ុន ជី រ៉មនី Welfare Agricultural Meeting ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៩៧១ ទំព័រ ១ ។
៣. ស្ពែនសើរ ដបុលយូ ឃីមបឹល « Becoming the Pure in Heart » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៧៨ ទំព័រ ៨០ ។
៤. ម៉ារ៉ុន ជី រ៉មនី « The Blessings of the Fast » *Ensign,* ខែ កក្កដា ឆ្នាំ ១៩៨២ ទំព័រ ៤ ។

នំប៉័ង និង ត្រី ដោយ វ៉ែស ផាតុប ផាល





**ការតមអាហារ ៖ ចូរឲ្យតម្លៃដល់ឯកសិទ្ធិដ៏ពិសិដ្ឋនោះ**

« ខ្ញុំសូមថ្លែងទីបន្ទាល់អំពីអព្ភូតហេតុទាំងខាងវិញ្ញាណ និងខាងសាច់ឈាមដែលកើតមានចំពោះជន ដែលរស់នៅតាមច្បាប់តមអាហារ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ពីអព្ភូតហេតុដែលកើតមានដល់រូបខ្ញុំ ។ ពិតណាស់ ដូចជាអេសាយបានកត់ត្រា ខ្ញុំបានស្រែកអំពាវនាវនៅក្នុងការតមអាហារជាច្រើនដង ហើយពិតណាស់ព្រះបានឆ្លើយតប ‹ យើងនៅឯណេះហើយ › ( អេសាយ ៥៨:៩ ) ។ ចូរឲ្យតម្លៃដល់ឯកសិទ្ធិដ៏ពិសិដ្ឋនោះ យ៉ាងហោចណាស់មួយខែម្ដង ហើយមានចិត្តទូលាយទៅតាមលទ្ធភាពនៅក្នុងដង្វាយតមអាហាររបស់អ្នក និងដង្វាយមនុស្សធម៌ ការអប់រំ និងអ្នកផ្សាយសាសនាផ្សេងទៀត ។ ខ្ញុំសូមសន្យាថា ព្រះនឹងមានព្រះទ័យសប្បុរសចំពោះអ្នក ហើយជនដែលទទួលបានជំនួយពីអ្នក នឹងហៅឈ្មោះអ្នកថាមានពរជារៀងរហូត » ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមពួកសាវកដប់ពីរនាក់ « **Are We Not All Beggars ?** » ***Liahona,*** ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៤២ ។

# ការយល់ចិត្ត
## យុវវ័យដែលអ្នកបង្រៀន

*ការខិតខំរៀនពីយុវវ័យដែលអ្នកបង្រៀនអាចចាក់សោបើកទ្វារឆ្ពោះទៅរកការប្រែចិត្តជឿរបស់ពួកគេ ។*

សមាជិកវ័យក្មេងជាច្រើនមានការរំភើប និង ចិត្តស្វាហាប់ ដែលអាចធ្វើឲ្យការបង្រៀន និង ការប្រឹក្សាដល់ពួកគេជាទីរីករាយចិត្ត ។ ប៉ុន្តែមនុស្សមួយចំនួនក៏អាចប្រឈមមុខនឹងឧបសគ្គនានានៅពេលពួកគេធំឡើង និង មានភាពចាស់ទុំ — គឺអ្វីៗគ្រប់យ៉ាងមកពីការសម្របសម្រួលទៅរកការផ្លាស់ប្ដូររាងកាយរបស់ពួកគេ ភាពតានតឹងចិត្តនៅឯសាលារៀន ការគាបសង្កត់នៃវប្បធម៌ដែលព្យាយាមបញ្ចុះបញ្ចូលពួកគេកុំឲ្យរស់នៅតាមដំណឹងល្អ ។ យុវវ័យត្រូវការគ្រូបង្រៀនដែលយល់ចិត្តពួកគេ ហើយខ្វាយខ្វល់ពីពួកគេ ។ ពួកគេត្រូវការអ្នកប្រឹក្សាដែលជំរុញឲ្យមានបរិយាកាសសុវត្ថិភាពមួយសម្រាប់ពួកគេ ដើម្បីរៀន និង អនុវត្តតាមអ្វីដែលពួកគេបានរៀន ។

នេះជាចំណុចមួយចំនួនដែលអាចជាប្រយោជន៍ដើម្បីដឹងអំពីយុវវ័យ នៅពេលអ្នកដាក់ផែនការ រៀបចំ និង បង្រៀនពួកគេតាមរបៀបរបស់ព្រះអម្ចាស់ ៖

១. *យុវវ័យមានចិត្តចង់ ហើយត្រូវការរៀនគោលលទ្ធិ ។* នៅក្នុងពិភពលោកដែលងាកចេញបន្តិចម្ដងៗពីបទដ្ឋាននៃដំណឹងល្អនេះ យុវវ័យកំពុងស្រេកឃ្លាននូវសេចក្ដីពិតអស់កល្បជានិច្ច ។ ពួកគេចង់រៀនពី « រឿងទាំងឡាយ តាមដែលមាននៅពេលនេះ ហើយអំពីរឿងទាំងឡាយតាមដែលមាននៅពេលខាងមុខ » ( យ៉ាកុប ៤:១៣ ) ។ រឿងទាំងនោះគឺមាននៅក្នុងគោលលទ្ធិនៃដំណឹងល្អ ។ នៅពេលអ្នកបង្រៀន សូមផ្ដោតទៅលើគោលលទ្ធិដែលមាននៅក្នុងព្រះគម្ពីរ ការបង្រៀនរបស់ពួកព្យាការី និងពួកសាវកនៅរស់ ព្រមទាំងឯកសារជាផ្លូវការដទៃផ្សេងទៀតរបស់សាសនាចក្រ ។ សូមលើកទឹកចិត្តយុវវ័យឲ្យសិក្សាធនធានទាំងនេះដោយខ្លួនឯង ។ គោលលទ្ធិមានប្រសិទ្ធិភាពយ៉ាងខ្លាំងក្លា ( សូមមើល អាលម៉ា ៣១:៥ ) ។

២. *យុវវ័យកំពុងស្ថាបនាអត្តសញ្ញាណរបស់ខ្លួន ។* ពួកគេកំពុងតែស្វែងយល់ថាពួកគេគឺជានរណា ហើយថាពួកគេចង់ប្រែក្លាយទៅជានរណា ។ នៅពេលពួកគេរៀបចំខ្លួនសម្រាប់តួនាទីនាពេលអនាគត នោះពួកគេអាចងឿងឆ្ងល់ពីអ្វីដែលព្រះអម្ចាស់បានមានផែនការសម្រាប់ពួកគេ ហើយថាតើពួកគេអាចនឹងធ្វើនូវកិច្ចការទាំងអស់ដែលបានរំពឹងទុកពីពួកគេដែរឬទេ ។ ក្នុងនាមជាឪពុកម្ដាយ ឬ គ្រូបង្រៀនអ្នកអាចបំផុសឲ្យមានទំនុកចិត្តអំពីអនាគត និង ផ្ដល់ការណែនាំក្នុងការរៀបចំខ្លួនសម្រាប់វា ។ ជួយពួកគេឲ្យកាន់តែខិតជិតព្រះ ហើយស្ថាបនាជីវិតរបស់ពួកគេលើបទដ្ឋាននៃដំណឹងល្អ ។ បង្រៀនពួកគេពីសារៈសំខាន់នៃព្រះវិហារបរិសុទ្ធ និងតួនាទីរបស់ពួកគេក្នុងការស្ថាបនានគរព្រះ ។

៣. *យុវវ័យដឹងនៅពេលអ្នកខ្វល់ខ្វាយពីពួកគេ ។* ដើម្បីឲ្យយុវវ័យពិតជាចុះប្រទូ្បកយ៉ាងសកម្មក្នុងការរៀនសូត្រដំណឹងល្អ នោះពួកគេត្រូវតែដឹងថាអ្នក



ស្រឡាញ់ពួកគេ ហើយអ្នកចាប់អារម្មណ៍ពីពួកគេម្នាក់ៗ ។ ស្ដាប់ពួកគេ ។ រកមើលលក្ខណៈវិជ្ជមានដែលពួកគេមាន ហើយស្ថាបនាពួកគេចេញពីចំណុចនោះមក ។ បង្ហាញទំនុកចិត្តរបស់អ្នកលើពួកគេ ហើយផ្ដល់ការធានាអះអាងថាពួកគេមានតម្លៃ និង មានគេត្រូវការ ។

៤. *យុវវ័យមានចំណាប់អារម្មណ៍ជាច្រើន* ។ យុវវ័យម្នាក់ៗមាននូវលក្ខណៈពិសេសរៀងៗខ្លួន ។ ព្យាយាមស្គាល់ពីចំណាប់អារម្មណ៍ តម្រូវការ និង ឧបសគ្គផ្ទាល់ខ្លួនរបស់ពួកគេ ។ ចំណុចនេះអាចតម្រូវឲ្យជួយដល់ពួកគេ លើសពីកាលវិភាគប្រជុំ ថ្នាក់រៀន និង សកម្មភាពទៀងទាត់នានាទៅទៀត ។ តាមរយៈការព្យាយាមស្គាល់ពួកគេ នោះអ្នកអាចទទួលបានការយល់ដឹង និង បំផុសគំនិតតាមរយៈព្រះវិញ្ញាណបរិសុទ្ធអំពីតម្រូវការរបស់ពួកគេ ដែលអាចជះឥទ្ធិពលលើរបៀបដែលអ្នកបង្រៀនពួកគេ ។ នៅពេលយុវវ័យដឹងពីចំណាប់អារម្មណ៍ដ៏ស្មោះសររបស់អ្នកនៅក្នុងជីវិតរបស់ពួកគេ នោះដួងចិត្តរបស់ពួកគេនឹងបើកទទួលយកការបង្រៀន និង ទីបន្ទាល់របស់អ្នក ។

៥. *យុវវ័យអាចរកឃើញចម្លើយចំពោះសំណួររបស់ខ្លួន* ។ អ្នករៀនគ្រប់វ័យទាំងអស់រីករាយនឹងស្វែងយល់ពីចំណេះដឹងនៃដំណឹងល្អ ប៉ុន្តែវាសំខាន់ជាពិសេសចំពោះមនុស្សវ័យជំទង់ នៅពេលពួកគេអភិវឌ្ឍគុណតម្លៃ និង ជំនឿរបស់ពួកគេ ។ មេរៀនដំណឹងល្អដែលមានឥទ្ធិពលយូរអង្វែង នៅពេលពួកគេរៀនដោយខ្លួនឯងផ្ទាល់ — ហើយរស់នៅតាមមេរៀននោះ ។ ជំនួសឲ្យការផ្ដល់ចម្លើយដល់យុវវ័យ អ្នកអាចប្រើវិធីសាស្ត្របង្រៀន ដែលអញ្ជើញ និង បំផុសគំនិតពួកគេឲ្យស្វែងរកចម្លើយចំពោះសំណួរផ្ទាល់ខ្លួន ។ ការណ៍នេះនឹងនាំទៅរកការផ្លាស់ប្រែចិត្តជឿកាន់តែជ្រាលជ្រៅ — ដែលជាគោលដៅចម្បងបំផុតនៃការណែនាំទាំងអស់នៃដំណឹងល្អ ។



៦. *យុវវ័យអាចបង្រៀនគ្នាទៅវិញទៅមក* ។ យុវវ័យមានចំណាប់អារម្មណ៍ក្នុងការផ្ដល់យោបល់អំពីអ្វីដែលបានបង្រៀន ហើយរំភើបចែកចាយអ្វីដែលពួកគេដឹង ។ តាមរយៈគំរូ និង ការណែនាំរបស់អ្នក នោះអ្នកអាចជួយពួកគេរៀនបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ ។ ដោយមានការណែនាំពីអ្នក នោះពួកគេអាចចាប់ផ្ដើមដោយការបង្រៀនផ្នែកណាមួយនៃមេរៀន ឬ ដឹកនាំការពិភាក្សាខ្លីៗ ។ នៅពេលពួកគេទទួលបទពិសោធន៍ ហើយមានទំនុកចិត្ត នោះពួកគេអាចមានឱកាសយូរៗម្ដងបង្រៀនមេរៀនទាំងមូល ។ នៅពេលយុវវ័យរៀនពីគ្នាទៅវិញទៅមក នោះពួកគេជួយពង្រឹងគ្នាទៅវិញទៅមកទប់ទល់នឹងសម្ពាធពីអស់អ្នកដែលពុំមានគុណតម្លៃដូចពួកគេ ។

៧. *យុវវ័យកំពុងរៀនពីភាពជាអ្នកដឹកនាំ* ។ គណៈប្រធានថ្នាក់ និង គណៈប្រធានកូរ៉ុមមានការហៅបម្រើដ៏ពិសិដ្ឋដើម្បីដឹកនាំក្រុមរបស់ខ្លួនដែលមានអាយុស្របាលគ្នា ។ ប៉ុន្តែ ទោះបីជាពួកគេមានបទពិសោធន៍នៃភាពជាអ្នកដឹកនាំក្ដី ពួកគេនៅតែត្រូវការការណែនាំពីអ្នកស្ដីអំពីរបៀបដើម្បីដឹកនាំការប្រជុំ ជួយអ្នកដទៃឲ្យរៀន និង បម្រើ ។ ឱកាសនៃភាពជាអ្នកដឹកនាំផ្សេងៗទៀតអាចកើតមាននៅក្នុងគេហដ្ឋាន នៅពេលយុវវ័យត្រូវបានផ្ដល់ឲ្យនូវការទទួលខុសត្រូវនានាដ៏មានន័យ ។

៨. *យុវវ័យរៀនពីឪពុកម្ដាយ និង មនុស្សពេញវ័យដ៏គំរូផ្សេងៗទៀត* ។ ផ្នែកមួយនៃការទទួលខុសត្រូវរបស់អ្នកក្នុងនាមជាគ្រូបង្រៀន គឺត្រូវជួយពង្រឹងទំនាក់ទំនងរវាងយុវវ័យជាមួយនឹងថ្នាក់ដឹកនាំ និង ឪពុកម្ដាយរបស់ពួកគេ ។ អ្នកអាចជួយយុវវ័យស្វែងរកចម្លើយចំពោះសំណួរជាច្រើនរបស់ពួកគេ ប៉ុន្តែសំណួរមួយចំនួនរបស់ពួកគេនឹងមានចម្លើយកាន់តែប្រសើរ ប្រសិនបើឪពុកម្ដាយ ឬ ថ្នាក់ដឹកនាំរបស់ពួកគេជាអ្នកឆ្លើយ ។ សូមដឹកនាំតម្រែតម្រង់យុវវ័យឲ្យទៅរកឪពុកម្ដាយរបស់ពួកគេ ហើយលើកទឹកចិត្តពួកគេឲ្យពង្រឹងចំណងមិត្តភាពក្រុមគ្រួសារ ។ សូមនិយាយជាមួយឪពុកម្ដាយឲ្យបានទៀងទាត់ អំពីអ្វីដែលអ្នកកំពុងសិក្សានៅក្នុងថ្នាក់ ហើយចែកចាយទេពកោសល្យ ការរីកចម្រើន និង ការរួមចំណែកជាវិជ្ជមានដែលអ្នកសង្កេតឃើញនៅក្នុងកូនប្រុសស្រីរបស់ពួកគេ ។ សូមសួរពួកគេពីអ្វី ដែលអ្នកអាចធ្វើបានដើម្បីជួយពួកគេ នៅពេលដែលពួកគេបង្រៀនកូនៗរបស់ខ្លួន ។

ការជួយយុវវ័យឲ្យប្រែចិត្តជឿ ត្រូវការការខិតខំប្រឹងប្រែងរួមគ្នាពីឪពុកម្ដាយ អ្នកដឹកនាំ អ្នកប្រឹក្សាយោបល់ និង គ្រូបង្រៀន រួមទាំងគ្រូបង្រៀនថ្នាក់សិក្ខាសាលាផងដែរ ។ ពេលអ្នកធ្វើការជាមួយគ្នា នោះអ្នកអាចបង្កើតបទពិសោធន៍នៃការរៀនសូត្រឲ្យកាន់តែមានឥទ្ធិពលខ្លាំងឡើង សម្រាប់យុវវ័យជាងអ្នកធ្វើវាតែឯកឯង ។ ■

*សម្រាប់យោបល់បន្ថែមទៀត សូមមើល « **Teach the Youth** » នៅក្នុងសៀវភៅសិក្សាថ្មីគឺសៀវភៅ* Teaching in the Savior’s Way *( នៅលើអ៊ិនធើរណែតនៅគេហទំព័រ **teaching.lds.org/khm** )* ។

# « មើលន៏កូនតូចៗរបស់អ្នករាល់គ្នា »

## ការរៀនបង្រៀនកុមារ

*« [ ព្រះយេស៊ូវ ] បានយកកូនក្មេងរបស់ពួកគេ ម្តងម្នាក់ៗ ហើយបានប្រទានពរដល់ពួកវា ហើយបានអធិស្ឋានដល់ព្រះវរបិតាសម្រាប់ពួកគេ ។ . . . ហើយទ្រង់មានបន្ទូលទៅហ្វូងមនុស្សថា មើលន៏ ! កូនតូចៗរបស់អ្នករាល់គ្នា » ( នីហ្វៃទី ៣ ១៧:២១, ២៣ ) ។*

ប្រសិនបើអ្នកជាឪពុកម្តាយ ឬ ត្រូវបានហៅឲ្យបង្រៀនកុមារ នោះអ្នកត្រូវបានប្រទានឲ្យនូវអំណោយទានដ៏មហិមាមួយ ។ អែលឌើរ អិម រ័សុល បាឡឺដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « [ អ្នក ] គឺជាមនុស្សម្នាក់ដែលព្រះតែងតាំងឲ្យឱបក្រសោបដល់កុមារតូចៗ នាសព្វថ្ងៃនេះដោយក្តីស្រឡាញ់ និងដោយភ្លើងនៃសេចក្តីជំនឿ និងការយល់ដឹងអំពីអត្តសញ្ញាណថា ពួកគេជានរណា » ។[១]

កុមារនឹងនាំមកនូវក្តីអំណរ ហើយបំផុសគំនិតអ្នកឲ្យធ្វើជាគំរូល្អ ។ នៅពេលដែលអ្នកទទួលស្គាល់ភាពស្មោះត្រង់ សេចក្តីស្រឡាញ់ ការជឿទុកចិត្ត និងសេចក្តីសង្ឃឹមរបស់កុមារ នោះអ្នកនឹងខិតកាន់តែជិតព្រះអម្ចាស់ និងយល់កាន់តែច្បាស់ពីព្រះបញ្ញត្តិរបស់ទ្រង់ ដើម្បី « ត្រឡប់ដូចជាកូនតូច » ( ម៉ាថាយ ១៨:៣ ) ។

នេះជាចំណុចទាំងប្រាំបីដែលត្រូវចងចាំអំពីកុមារ នៅពេលអ្នកព្យាយាមស្រឡាញ់ និង បង្រៀនពួកគេតាមរបៀបរបស់ព្រះសង្គ្រោះធ្វើ ។

១. *កុមារមានតែជំនឿ ។* ពួកគេងាយទទួលយកសេចក្តីពិត ។ សូមបង្រៀនពួកគេនូវគោលលទ្ធិត្រឹមត្រូវដែលសាមញ្ញ និងឲ្យច្បាស់ៗ ដោយប្រើភាសា និងឧទាហរណ៍ដែលពួកគេអាចយល់បាន ។

២. *កុមារអាចទទួលស្គាល់ឥទ្ធិពលនៃព្រះវិញ្ញាណ ។* សូមបង្រៀនពួកគេថា អារម្មណ៍នៃសេចក្តីសុខសាន្ត សេចក្តីស្រឡាញ់ និង ក្តីអំណរដែលពួកគេមាននៅពេលដែលពួកគេនិយាយ ឬច្រៀងពីព្រះយេស៊ូវគ្រីស្ទ និង ដំណឹងល្អរបស់ទ្រង់ កើតមានមកពីព្រះវិញ្ញាណបរិសុទ្ធ ។ សូមជួយពួកគេឲ្យយល់ថា អារម្មណ៍ទាំងនេះជាផ្នែកមួយនៃទីបន្ទាល់ ។

៣. *កុមារយល់ពីការនិយាយត្រង់ៗ ។* ការប្រៀបធៀបស្មុគស្មាញអាចធ្វើឲ្យពួកគេភាន់ច្រឡំ ។ ពេលអ្នកបង្រៀន សូមនិយាយពីព្រឹត្តិការណ៍ និង សកម្មភាពនានាដែលពួកគេធ្លាប់ស្គាល់ដូចជា ៖ គេហដ្ឋាន ក្រុមគ្រួសារ និងពិភពលោកនៅជុំវិញខ្លួនពួកគេ ។

៤. *កុមារមានចិត្តចង់រៀនជាខ្លាំង ។* ពួកគេចូលចិត្តការរៀនសូត្រតាមរយៈបទពិសោធន៍ផ្សេងៗ និង ការយល់ដឹងជាច្រើន ។ ពួកគេឆ្លើយតបបានយ៉ាងល្អ និង សកម្មក្នុងមេរៀននៅពេលប្រើរូបភាព ។ សូមអនុញ្ញាតឲ្យពួកគេបញ្ចេញចលនា រុករក និងសាកល្បងអ្វីថ្មីៗ ។

៥. *កុមារមានចិត្តចង់ចែកចាយ និង ជួយជាខ្លាំង ។* ពួកគេមានអ្វីៗជាច្រើនដែលអាចបង្រៀនគ្នាទៅវិញទៅមក និង បង្រៀនអ្នកផងដែរ ។ សូមឲ្យពួកគេចែកចាយអ្វីដែលពួកគេកំពុងរៀន ។ សូមផ្តល់ឱកាសឲ្យពួកគេអានព្រះគម្ពីរ កាន់រូបភាព ឆ្លើយសំណួរ ឬ សរសេរអក្សរលើក្តារខៀន ។

៦. *កុមារមានក្តីស្រឡាញ់ ហើយចង់បានក្តីស្រឡាញ់ ។* សូមរកមើលឱកាសដើម្បីជំរុញឲ្យមានអាកប្បកិរិយានៃក្តីសប្បុរស និងគួរឲ្យស្រឡាញ់ ដែលកើតឡើងពីធម្មជាតិចំពោះពួកគេ ។ សូមកសាងទំនុកចិត្តរបស់ពួកគេ ដោយការបង្ហាញក្តីស្រឡាញ់ និង អំណរគុណរបស់អ្នក ព្រមទាំងស្តាប់យ៉ាងយកចិត្តទុកដាក់ចំពោះអ្វីដែលពួកគេនិយាយ ។

៧. *កុមារធ្វើតាមគំរូរបស់អ្នក ។* អ្នកកំពុងតែបង្រៀនជានិច្ច ទោះជាពេលដែលអ្នកមិនដឹងខ្លួនក៏ដោយ ។ កុមារនឹងកត់សម្គាល់ពីរបៀបដែលអ្នករស់នៅតាមគោលការណ៍ទាំងឡាយដែលអ្នកបង្រៀន ។ គំរូដ៏សុចរិតរបស់អ្នកអាចជះឥទ្ធិពលយ៉ាងខ្លាំងលើការរីកចម្រើនឡើងនៃទីបន្ទាល់របស់ពួកគេ ។

៨. *កុមារតូចៗមានពេលយកចិត្តទុកដាក់ខ្លី ។* អាកប្បកិរិយាដែលមិនយកចិត្តទុកដាក់អាចមានន័យថា ពួកគេនឿយហត់ ឬឃ្លាន ឬពួកគេមិនយល់ពីអ្វីដែលអ្នកបាននិយាយ ឬថាពួកគេត្រូវការរត់លេង ឬក៏ពួកគេមានការធុញទ្រាន់ ។ ពួកគេចូលចិត្តការរៀនសូត្រតាមរយៈ ការថាឡើងវិញច្រំដែលៗ វិធីសាស្ត្រខុសៗគ្នា រឿងនិទានងាយៗ បទចម្រៀង និងសកម្មភាពនានា ។ សូមលើកទឹកចិត្តពួកគេឲ្យចូលរួមក្នុងមេរៀន ។ ■

### ធនធានមេរៀន

តើអ្នកត្រូវការរឿង រូបភាព ឬ វីដេអូ ដើម្បីធ្វើឲ្យមេរៀនថ្នាក់អង្គការបឋមសិក្សា ឬ រាត្រីជួបជុំក្រុមគ្រួសារក្លាយជាមេរៀនកាន់តែប្រសើរឡើង ប៉ុន្តែមិនដឹងទៅរកនៅទីណាឬ ? សូមមើលគេហទំព័រ **lessonhelps.lds.org!**

សម្រាប់យោបល់បន្ថែមទៀត សូមមើល « Teach the Children » នៅក្នុងសៀវភៅសិក្សាថ្មីគឺ សៀវភៅ *Teaching in the Savior's Way* ( នៅលើអ៊ិនធើរណែតនៅគេហទំព័រ teaching.lds.org/khm ) .

កំណត់ចំណាំ

១. អិម រ័សុល បាឡឺដ « Great Shall Be the Peace of Thy Children » *Ensign,* ខែ មេសា ឆ្នាំ ១៩៩៤ ទំព័រ ៦០ ។



« ចូរឲ្យសំឡេងសើចក្អាកក្អាយរបស់ក្មេងៗធ្វើឲ្យដួងចិត្តយើងរីករាយ ។ ចូរឲ្យសេចក្ដីជំនឿរបស់ក្មេងៗលួងលោមព្រលឹងរបស់យើង ។ ចូរឲ្យសេចក្ដីស្រឡាញ់របស់ក្មេងៗបំផុសគំនិតឲ្យយើងមានសកម្មភាពនានា » ។

ប្រធាន ថូម៉ាស អេស ម៉នសុន
« **Precious Children — A Gift from God** » ***Ensign,*** ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ទំព័រ ៧០ ។



**ដោយ អែលឌើរ**
**ម៉ារីអុន ឌី ហាងស៍**
**( ឆ្នាំ ១៩២១–២០១១ )**
បានបម្រើជាសមាជិក
នៃពួកចិតសិបនាក់ពីឆ្នាំ
១៩៥៣ ដល់ ១៩៩២

# ការថ្វាយបង្គំនៅព្រះវិហារបរិសុទ្ធ

## គន្លឹះដើម្បីស្គាល់ព្រះ

*នៅក្នុងព្រះវិហារបរិសុទ្ធយើងអាចរៀនរស់នៅដូចជាព្រះគ្រីស្ទបានរស់នៅលើផែនដីនេះ ហើយរៀបចំខ្លួនដើម្បីរស់នៅដូចទ្រង់ ព្រមទាំងព្រះវរបិតាកំពុងមានព្រះជន្មរស់នាពេលបច្ចុប្បន្ននេះ ។*

ខ្ញុំចាំយ៉ាងច្បាស់ពីការសន្ទនាមួយមុនដំបូងគេដ៏អន្ទះសា និង ស្មោះអស់ពីចិត្តជាមួយអ្នកចូលរួមព្រះវិហារបរិសុទ្ធ បន្ទាប់ពីខ្ញុំបានចាប់ផ្ដើមការបម្រើរបស់ខ្ញុំជាប្រធានព្រះវិហារបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ សលត៍ លេក ។ យុវនារីដ៏ចេះគិតគូរម្នាក់បានអានចំខគម្ពីរដែលទាក់ទងទៅនឹងមុខងារនៃព្រះវិហារបរិសុទ្ធថាជាគេហដ្ឋាននៃការរៀនសូត្រ និង ការណែនាំ ។ នាងបានមានភាពឈ្លាសវៃល្មមគ្រប់គ្រាន់ដើម្បីដឹងថា ដើម្បីស្គាល់ព្រះ និង ព្រះគ្រីស្ទ « ជាព្រះពិតតែមួយ និងព្រះយេស៊ូវគ្រីស្ទដែលទ្រង់បានចាត់ឲ្យមកផង គឺជាជីវិតដ៏នៅអស់កល្បជានិច្ច » ( យ៉ូហាន ១៧:៣ ) ។ នាងក៏បានដឹងផងដែរថា យើងរៀនស្គាល់ព្រះវរបិតារបស់យើង ហើយទីបំផុតត្រឡប់ទៅកាន់ទ្រង់វិញតាមរយៈព្រះគ្រីស្ទ ។

ទីបន្ទាល់របស់ខ្ញុំចំពោះនាងនោះគឺថា សម្រាប់ខ្ញុំអ្វីៗគ្រប់យ៉ាងនៅក្នុងព្រះវិហារបរិសុទ្ធចង្អុលបង្ហាញជាចម្បងទៅលើព្រះគ្រីស្ទ និង ព្រះវរបិតារបស់យើង ។ ភាពសក្តិសិទ្ធិនៃពិធីបរិសុទ្ធ និង សេចក្ដីសញ្ញាគឺនៅក្នុងសេចក្ដីស្រឡាញ់ និងសិទ្ធិអំណាចដែលបានផ្ទេរដ៏ធួនរបស់ទ្រង់ — គឺជាសិទ្ធិអំណាច « បព្វជិតភាពដ៏បរិសុទ្ធ តាមរបៀបនៃព្រះរាជបុត្រានៃព្រះ » ( គ. និង ស. ១០៧:៣ ) ។ ប៉ុន្តែនាងពុំទាន់បានធ្វើការទាក់ទងច្បាស់លាស់នៅក្នុងគំនិត និង ចិត្តផ្ទាល់ខ្លួនរបស់នាងនៅឡើយទេ នូវរបៀបដែលការថ្វាយបង្គំនៅព្រះវិហារបរិសុទ្ធអាចក្លាយជាគន្លឹះសំខាន់ដើម្បីស្គាល់ព្រះអម្ចាស់ ។ . . .

### ព្រះគ្រីស្ទ ព្រះគម្ពីរ ព្រះវិហារបរិសុទ្ធ គេហដ្ឋាន

ព្រះវិហារបរិសុទ្ធគឺមានសារៈសំខាន់បំផុតនៅក្នុងការផ្ដល់នូវគំរូសម្រាប់ការបន្សុទ្ធ ហើយការញែកខ្លួនយើងឲ្យទៅជាបរិសុទ្ធ ដែលនៅពេលយើងរៀនអំពីព្រះគ្រីស្ទ អាចនាំយើងទៅរកចំណេះដឹងផ្ទាល់ខ្លួនអំពីទ្រង់ ហើយឈរជាសាក្សីអំពីទ្រង់ដែលនាំទៅរកអំណោយទាននៃជីវិតដ៏មានតម្លៃបំផុត ។

ការសិក្សា និង ការថ្វាយបង្គំនៅព្រះវិហារបរិសុទ្ធអាចក្លាយជាសាកលវិទ្យាល័យនៃជីវិតអស់កល្បជានិច្ចតាមរយៈព្រះយេស៊ូវគ្រីស្ទ ។ នៅក្នុងការអធិស្ឋាននៃការឧទ្ទិសនៅឯទីក្រុង ខឺតឡង់ ការទូលអង្វរនេះត្រូវបានធ្វើឡើងដល់ព្រះអម្ចាស់ ៖ « ហើយព្រះវរបិតាដ៏បរិសុទ្ធអើយ សូមព្រះអង្គអនុញ្ញាតឲ្យអស់អ្នកណា ដែលនឹងថ្វាយបង្គំនៅក្នុងដំណាក់នេះ អាចបានទទួលការបង្រៀនពីពាក្យសម្ដីនៃប្រាជ្ញាវាងវៃ . . .

« ហើយសូមឲ្យពួកគេអាចបានធំឡើងក្នុងទ្រង់ ហើយទទួលនូវភាពពោរពេញនៃព្រះវិញ្ញាណបរិសុទ្ធ » ( គ. និង ស. ១០៩:១៤–១៥ ) ។

តើការណ៍នេះអាចសម្រេចទៅបានតាមរយៈពិធី និង ទម្លាប់ទាំងនេះឬ ? មែនហើយ វាអាចសម្រេចបាននូវផ្នែកខ្លះ ប្រសិនបើយើងយល់ពីគោលបំណងនិមិត្តសញ្ញា គឺដូចជាអ័ដាម និង អេវ៉ាបាននាំឲ្យយល់វានៅក្នុងគ្រាដំបូងៗបង្អស់នៃជីវិតរមែងស្លាប់នេះ ។ ប៉ុន្តែជាទូទៅ យើងរៀនតាមរយៈខ្លឹមសារនៃសារលិខិតគោលការណ៍នានានៃសេចក្ដីរីកចម្រើនដ៏នៅអស់កល្បជានិច្ច នៃជីវិតដ៏នៅអស់កល្បជានិច្ច ។ វានៅជុំវិញគោលការណ៍មួយចំនួនដែលយើងធ្វើសេចក្ដីសញ្ញាជាមួយព្រះអម្ចាស់ ។ សូមចាំពីសេចក្ដីថ្លែងការណ៍របស់ប៉ុលទៅកាន់ពួកសាសន៍រ៉ូមថា យើងត្រូវស្រុះស្រួលនឹងព្រះតាមរយៈការសុគតរបស់ព្រះគ្រីស្ទ ហើយបានសង្គ្រោះ « ដោយទ្រង់មានព្រះជន្មរស់ឡើងវិញ » ( រ៉ូម ៥:១០ ) ។ ចំពោះខ្ញុំការនេះមានន័យថា គោលការណ៍នានានៃព្រះជន្មដ៏បរិសុទ្ធរបស់ទ្រង់នាំយើងទៅកាន់សេចក្ដីសង្គ្រោះដ៏ពេញលេញនោះដែលហៅថា ភាពតម្កើងឡើង — សេចក្ដីស្រឡាញ់ ការរៀនសូត្រ

រូបព្រោកឡើង ហើយផើបចុះ ដោយ បារី អែនឌើរសិន



ការបម្រើ ការរីកចម្រើន ដោយបង្កើតនូវជីវិតដែលមានកម្រិតមួយនៃភាពជាព្រះ ជាមួយមនុស្សជាទីស្រឡាញ់ ជាមួយព្រះវរបិតា និង ព្រះរាជបុត្រា ។ នៅក្នុងព្រះវិហារបរិសុទ្ធយើងអាចរៀនរស់នៅដូចជាព្រះគ្រីស្ទបានរស់នៅលើផែនដីនេះ ព្រមទាំងដូចជាទ្រង់ និងព្រះវរបិតាកំពុងមានព្រះជន្មរស់ផងដែរ ។

**គោលការណ៍សំខាន់ៗនៃព្រះជន្មរបស់ព្រះគ្រីស្ទ**

តើគោលការណ៍ទាំងនោះមានអ្វីខ្លះ ដែលវាសំខាន់នៅក្នុងព្រះជន្មទ្រង់ ដែលបានបង្រៀននៅក្នុងព្រះវិហារបរិសុទ្ធ ហើយថាវាទាក់ទងនឹងសេចក្ដីសញ្ញាដែលយើងបានធ្វើជាមួយព្រះអម្ចាស់យ៉ាងដូចម្ដេច ? . . .

ទ្រង់បានមានក្ដីស្រឡាញ់តាមរបៀបមួយដែលប្រហែលមានតែទ្រង់ និង ព្រះវរបិតាទេដែលពិតជាយល់ពីក្ដីស្រឡាញ់នោះ ។ ប៉ុន្តែយើងនៅលើផែនដីនេះដើម្បីរៀនពីក្ដីស្រឡាញ់នោះ ដើម្បីរៀនស្រឡាញ់ឲ្យល្អមគ្រប់គ្រាន់នឹងចែករំលែកវាបាន ។ នៅលើសមរភូមិ និង នៅក្នុងបន្ទប់មន្ទីរពេទ្យ ព្រមទាំងនៅក្នុងកាលៈទេសៈដ៏អង់អាចក្លាហាននៃការបូជាដោយមិនគិតពីខ្លួនឯងចំពោះឪពុកម្ដាយ ឬ កូន វាបានបង្ហាញចំពោះខ្ញុំថា មានមនុស្សដែលពិតជាបានរៀនស្រឡាញ់ និង លះបង់តាមរបៀបរបស់ទ្រង់ ។

នៅពេលយើងជ្រើសរើស និង ធ្វើតាមផ្លូវនៃការផ្ដល់ឲ្យ ការខ្វល់ខ្វាយ ក្ដីមេត្តា និង សប្បុរស នោះយើងនឹងយល់ថានេះគឺពុំមែនជាជម្រើសនៃដំណឹងល្អឡើយ វាគឺជាចំណុចសំខាន់នៃដំណឹងល្អ ។ សុភាវធម៌ និង កិត្តិយស ភាពមិនអាត្មានិយម អត្តចរិតល្អ និង បទពិសោធន៍ល្អគឺត្រូវបានរំពឹងពីរូបយើង ។ អ្វីដែលសំខាន់បំផុតបន្ទាប់ពីអ្វីផ្សេងទៀតទាំងនោះគឺថាតើយើងជាមនុស្សបែបណា តើយើងមានឆន្ទៈផ្ដល់ឲ្យគេប៉ុណ្ណា ។ . . . នេះជាអ្វីដែលយើងសម្រេចចិត្តរាល់ថ្ងៃ គ្រប់នាទី នៅពេលយើងរៀន ហើយទទួលយកការណែនាំពីព្រះអម្ចាស់ ។

បន្ទាប់ពីការឆ្កាង ការរស់ឡើងវិញ និង ការយាងឡើងលើវិញរបស់ព្រះអង្គសង្គ្រោះ នោះមានអ្វីមួយបានកើតឡើងចំពោះសាវកដែលនៅរស់ដែលដឹកនាំដោយពេត្រុស ដែលបានបំបាក់ព្រះទ័យរបស់ទ្រង់ នៅក្នុងគ្រានៃការតានតឹង ។ បុណ្យថ្ងៃទីហាសិបបានកើតឡើង — ការយាងមកនៃព្រះវិញ្ញាណ — ហើយអស់អ្នកដែលមានការស្ទាក់ស្ទើរបានមានទីបន្ទាល់ ហើយថ្លែងទីបន្ទាល់យ៉ាងរឹងមាំ ។ ជំពូកទី ១ រហូតដល់ជំពូក៥ នៃគម្ពីរកិច្ចការប្រាប់ពីដំណើររឿងនេះ ។ ខគម្ពីរប៉ុន្មានចុងក្រោយនៃជំពូក ៥ មានឥទ្ធិពលយ៉ាងខ្លាំង ។ លោកកាម៉ាលាលបានចូលរួមជាមួយក្រុមរបស់លោក ដើម្បីផ្ដល់ឱកាសម្ដងទៀតគឺពេលបន្ថែមបន្តិចទៀតដល់ពួកសិស្ស ។ ដូច្នេះពួកគេត្រូវបានព្រមានជាថ្មីម្ដងទៀតឲ្យឈប់បង្រៀន និង ផ្សាយអំពីព្រះគ្រីស្ទ ពួកគេត្រូវបានវាយដំជាថ្មីម្ដងទៀត ហើយដោះលែងវិញ ។ កំណត់ត្រានោះបាននិយាយថា ពួកគេបានចាកចេញពីទីនោះដោយអរសប្បាយ ពីព្រោះពួកគេត្រូវបានឃើញថាគួរនឹងទ្រាំដោយព្រោះព្រះនាមព្រះគ្រីស្ទ ។ បន្ទាប់មក « អ្នកទាំងនោះចេះតែបង្រៀន ព្រមទាំងប្រាប់ដំណឹងល្អពីព្រះយេស៊ូវគ្រីស្ទ នៅក្នុងព្រះវិហារ ហើយនៅអស់ទាំងផ្ទះរាល់តែថ្ងៃជានិច្ច » ( កិច្ចការ ៥:៤២ ) ។

នៅក្នុងលក្ខណៈដូចគ្នានេះអ្វីមួយគួរកើតឡើងចំពោះយើង នៅពេលយើងចាកចេញពីព្រះវិហារបរិសុទ្ធនៅក្នុងស្មារតីនៃ នីហ្វៃទី ៣ ១៧:៣ ៖ « ហេតុដូច្នោះហើយ ចូរអ្នករាល់គ្នាត្រឡប់ទៅផ្ទះវិញចុះ ហើយពិចារណាគិតអំពីរឿងទាំងឡាយដែលយើងបាននិយាយ ហើយចូរសូមដល់ព្រះវរបិតា ដោយនូវនាមយើង ដើម្បីឲ្យអ្នករាល់គ្នាអាចយល់ ហើយប្រុងប្រៀបចិត្តគំនិតរបស់អ្នក ចាំថ្ងៃស្អែកហើយយើងនឹងយាងមកជួបអ្នកទៀត » ។

**អំណាចដ៏បរិសុទ្ធនៃការថ្វាយបង្គំនៅព្រះវិហារបរិសុទ្ធ**

ដោយបានស្គាល់តាមរបៀបពិសេសមួយក្នុងពេលនេះនូវផ្លូវ និង ពន្លឺដែលបានធ្វើតាមព្រះអម្ចាស់ — និង ស្រឡាញ់ទ្រង់ — នោះស្មារតីនៃភាពបរិសុទ្ធអាចធ្វើឲ្យយើងជាមនុស្សថ្មី អនុវត្តក្ដីស្រឡាញ់ និង ភាពជាបងប្អូន រួមគ្នាធ្វើតាមព្រះឆន្ទៈព្រះអម្ចាស់ បម្រើ ចែកចាយ ស្រឡាញ់ ស្មោះត្រង់ចំពោះបទដ្ឋានត្រឹមត្រូវ ស្វែងរកនគរព្រះជាមុនសិន ។

យើងត្រូវតែធ្វើឲ្យជីវិតគ្រួសាររបស់យើងមានភាពបរិសុទ្ធ ហើយធ្វើឲ្យគេហដ្ឋានរបស់យើងជាកន្លែងដែលយើង « បង្រៀន ហើយផ្សាយ » ពីព្រះយេស៊ូវគ្រីស្ទរាល់ថ្ងៃ ប៉ុន្តែធ្វើតាមទ្រង់ជានិច្ច ។ គេហដ្ឋាន គ្រួសារ ជីវិតផ្ទាល់ខ្លួនរបស់យើងគប្បីផ្ដោតសំខាន់លើការរៀនសូត្រ ផ្ដោតសំខាន់លើភាពមិនអាត្មានិយម និង ការបម្រើ ។ នៅក្នុងសម្ដីរបស់ រ៉ូហ្វាស ចូនស៍ ថា « ពួកបរិសុទ្ធពុំត្រូវបានមើលឃើញដូចជាទេវតា ហេតុនោះទេ ហើយក៏ពុំត្រូវបានបំផុសនូវគោរពភាពហួតដែរ ។ ពួកគេត្រូវបានបង្កើតឡើងជាចំណុចផ្ដោតចិត្តទុកដាក់នៃពន្លឺ និង អំណាច ។ ពួកបរិសុទ្ធពិតនោះគឺជាម្ដាយ អ្នកជិតខាងល្អ ជាបុគ្គលដែលធ្វើឲ្យសង្គមបានប្រសើរឡើង ជាបុគ្គលដែលបង្កើតបរិយាកាសដ៏រីករាយ និង ជាពរជ័យ ។ ពួកបរិសុទ្ធពិតគឺជាពួកគ្រីស្ទានដែលស្វាហាប់ម្នាក់ ដែលបង្ហាញពីចំណុចច្បាស់លាស់នៃជីវិតដែលដឹងយ៉ាងពេញលេញនៅក្នុងឋានសួគ៌ » ។[១]

ចំពោះខ្ញុំ អ្វីដែលចាត់ទុកថាជាគន្លឹះដ៏ច្បាស់ និង មានប្រសិទ្ធិភាពចំពោះអត្ថន័យនៃព្រះវិហារបរិសុទ្ធ និង ការថ្វាយបង្គំនៅព្រះវិហារបរិសុទ្ធ ។ ព្រះអម្ចាស់



រូបថត ព្រះវិហារបរិសុទ្ធម៉ានីល ហ្វីលីពីន ស្រ្តីសាសន៍ចាក់ ដោយ ហាវី អែនដឺស៊ីន

បានបើកសម្ដែងដល់ព្យាការី យ៉ូសែប ស្ម៊ីធ ក្នុងឆ្នាំ ១៨៣៦ នៅក្នុងការអធិស្ឋានដែលបានធ្វើឡើងនៅឯការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ខឺតឡង់ ។ ការអធិស្ឋាននោះក្លាយជាកណ្ឌទី ១០៩ នៃគោលលទ្ធិ និងសេចក្ដីសញ្ញា ។ មនុស្សដែលមានចិត្តចង់យល់ដោយស្មោះសរពីអត្ថន័យគ្រឹះនៃព្រះវិហារបរិសុទ្ធ អាចអានវាយ៉ាងល្អម្ដងហើយម្ដងទៀត ជាពិសេសខគម្ពីរទាំងម្ភៃប្អូនដំបូងដ៏ជក់ចិត្ត និង មានអំណាចនោះ ។ ខទី ៥ គឺជាសេចក្ដីថ្លែងដ៏ល្អដែលសមនឹងផ្ដោតចិត្តទុកដាក់យ៉ាងខ្លាំង ៖ « ដ្បិតព្រះអង្គជ្រាបថាទូលបង្គំទាំងអស់គ្នាបានសម្រេចកិច្ចការនេះ តាមរយៈការវេទនាដ៏ខ្លាំង ហើយចេញពីភាពក្រខ្សត់របស់ទូលបង្គំទាំងអស់គ្នា នោះទូលបង្គំទាំងអស់គ្នាបានថ្វាយរបស់របរនៃទូលបង្គំទាំងអស់គ្នា ដើម្បីសង់ដំណាក់មួយដល់ព្រះនាមរបស់ទ្រង់ *ប្រយោជន៍ឲ្យកូនមនុស្សអាចមានកន្លែងមួយ ដើម្បីសម្ដែងអង្គទ្រង់ដល់រាស្ត្ររបស់ទ្រង់* » ( គ. និង ស. ១០៩:៥ការសង្កត់បញ្ជាក់ត្រូវបានបន្ថែម ) ។

តើទ្រង់សម្ដែងអង្គទ្រង់ដល់មនុស្សនៅក្នុងព្រះវិហារបរិសុទ្ធយ៉ាងដូចម្ដេច ?

ជាពិសេសខ្ញុំជឿថា តាមរយៈសម្រស់ និង អានុភាពដ៏ខ្លាំងក្លានៃគោលការណ៍ពិធីបរិសុទ្ធ និង សេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធ តាមរយៈការថ្វាយបង្គំនៅព្រះវិហារបរិសុទ្ធ — តាមរយៈវិញ្ញាណនៃវិវរណៈ និង ពរជ័យផ្សេងទៀតនៃព្រះវិញ្ញាណដែលមានសម្រាប់អស់អ្នកដែលមានគំនិត និង ដួងចិត្តដែលត្រូវគ្នា និង ដែលមានក្ដីអំណត់ ហើយមានចិត្តអន្ទះសាចង់រៀន និង បន្តជីវិតរបស់ខ្លួនទៅរកឧត្តមគតិដូចជាព្រះគ្រីស្ទ ( សូមមើល នីហ្វៃទី ៣ ២៧:២១, ២៧ ) ។

ឧទាហរណ៍មួយអាចបង្ហាញឲ្យឃើញច្បាស់ពីកម្លាំងខាងវិញ្ញាណ ដែលកើតឡើងចំពោះអស់អ្នកដែលខិតខំនៅក្នុងការបម្រើរបស់ព្រះអម្ចាស់នៅក្នុងព្រះវិហារបរិសុទ្ធ ។ នាព្រឹកមួយ ខ្ញុំបានទៅព្រះវិហារបរិសុទ្ធនៅម៉ោងប្រហែល ៤:៣០ ព្រឹក ដោយអំណរគុណខ្ញុំអាចធ្វើដំណើរយ៉ាងលំបាកឆ្លងកាត់ព្រិលយ៉ាងក្រាស់ពីផ្ទះរបស់យើងទៅកាន់ទីនោះ ។ នៅក្នុងបន្ទប់ស្វាត់នោះ ខ្ញុំបានជួបមិត្តភក្ដិម្នាក់ដែលអង្គុយសញ្ជឹងគិតនៅពេលគាត់បានទ្រោបទៅមុខដោយប្រើឈើច្រត់របស់ខ្លួន ដែលជាមិត្តចាស់យូរមកហើយ ដែលខ្ញុំកោតសរសើរជាខ្លាំង ។ ដូចជាខ្ញុំដែរ គាត់ស្លៀកពាក់សដែលជាសម្លៀកបំពាក់អ្នកធ្វើការនៅព្រះវិហារបរិសុទ្ធ ។ ខ្ញុំបានស្វាគមន៍គាត់ដោយក្ដីរីករាយ ហើយបានសួរថាគាត់កំពុងធ្វើអ្វីនៅទីនោះនាព្រឹកនោះ ។

គាត់បាននិយាយថា « ប្រធាន ហាងស៍ លោកដឹងហើយថាខ្ញុំកំពុងធ្វើអ្វីនៅទីនេះ ។ ខ្ញុំគឺជាអ្នកធ្វើពិធីបរិសុទ្ធនៅទីនេះដើម្បីបំពេញការចាត់តាំងរបស់ខ្ញុំ » ។

ខ្ញុំបាននិយាយថា « ខ្ញុំដឹងហើយ ប៉ុន្តែខ្ញុំកំពុងឆ្ងល់ថាតើអ្នកបានមកដល់ទីនេះដោយធ្វើដំណើរឆ្លងកាត់ព្យុះព្រិលនោះយ៉ាងដូចម្ដេចបាន ។ ខ្ញុំទើបតែបានឮតាមវិទ្យុថា ជ្រលងភ្នំ ផាលីត្រូវបានបិទផ្អាកគ្រប់ចរាចរណ៍ធ្វើដំណើរទាំងអស់ ដោយសារមានឧបសគ្គរាំង ។

គាត់បាននិយាយថា « ខ្ញុំមានរថយន្តល្អដែលអាចធ្វើដំណើរឡើងដើមឈើក៏បានដែរ » ។

ខ្ញុំបាននិយាយថា « ខ្ញុំក៏អញ្ចឹងដែរ ឬ បើមិនអញ្ចឹងទេខ្ញុំពុំអាចមកដល់ទីនេះឡើយ ហើយខ្ញុំរស់នៅតែពីរបីគីឡូម៉ែត្រតែប៉ុណ្ណោះពីទីនេះ » ។

ក្រោយមកខ្ញុំបានសួរគាត់ ថាតើគាត់ធ្វើយ៉ាងដូចម្ដេចទើបអាចឆ្លងកាត់របាំងនោះ ដែលព័ត៌មានទើបតែប្រកាសថាវានៅក្នុងជ្រលងភ្នំនោះ ។ ចម្លើយរបស់គាត់នោះគឺធម្មតាដូចជាកសិករ និង ប្រធានស្ដេកដែលខ្ញុំបានជួបដំបូងដែលរឹងមាំ ជាបុរសដ៏ខ្លាំងម្នាក់ដែលជិះសេះ កាលខ្ញុំចំណាយពេលមួយរសៀលជាមួយលោកកាលពីមុនការប្រជុំសន្និសីទស្ដេក ។ ជំងឺរលាកសន្លាក់ និង ភាពចាស់ជរាពិតជាធ្វើឲ្យលោកទ្រុឌទ្រោម ហើយនឹងឆក់យកជីវិតគាត់ក្នុងពេលឆាប់ៗនេះ ។ លោកមានការឈឺចាប់ក្នុងការធ្វើចលនា ។ ចម្លើយរបស់គាត់នៅព្រឹកនោះគឺថា « ឥឡូវនេះ ប្រធាន ហាងស៍ ខ្ញុំបានស្គាល់មន្ត្រីជាច្រើននៅផ្លូវនោះ តាំងតែពីពួកគេកើតមកម្ល៉េះ ។ ពួកគេដឹងថាខ្ញុំត្រូវឆ្លងកាត់ផ្លូវនោះ ហើយថាប្រសិនបើចាំបាច់ខ្ញុំអាចព្យាយាមវាងផ្លូវទៅ ! ពួកគេក៏បានស្គាល់ពីឡាន និង បទពិសោធន៍របស់ខ្ញុំ ហើយពួកគេគ្រាន់តែរំកិលរបាំងនោះប្រសិនបើពួកគេចាំបាច់ត្រូវតែធ្វើវា » ។



គាត់បាននៅទីនោះដោយស្មោះត្រង់ ហើយទៀងត្រង់នៅព្រឹកនោះ ហើយចាប់ផ្ដើមកិច្ចការពិសិដ្ឋរបស់គាត់ ។ ព្រះវិហារបរិសុទ្ធជួយអភិវឌ្ឍបុគ្គលដែលមានសេចក្ដីជំនឿ និង ការបូជាបែបនេះ ។ ■

*ដកស្រង់ចេញពីសុន្ទរកថាដែលបានចែកចាយនៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៩៣ នៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ អត្ថបទទាំងមូលបានបោះពុម្ពនៅក្នុង* Temples of the Ancient World *បានបោះពុម្ព ដូណាល ដបុលយូ ផារី ( ឆ្នាំ ១៩៩៤ ) ។*

កំណត់ចំណាំ

១. *Rufus Jones Speaks to Our Time* ( ឆ្នាំ ១៩៦១ ) ទំព័រ ១៩៩ ។




ដោយអែលឌើរ
**យ៉ូសែប ដបុលយូ ស៊ីតាទី**
នៃពួកចិតសិបនាក់


# ការគោរពព្រះ

## តាមរយៈការគោរពសេចក្ដីសញ្ញារបស់យើង

*ពរជ័យដ៏អស្ចារ្យនៃសេចក្តីជំនឿលើព្រះ កើតមានដោយការគោរពប្រតិបត្តិទ្រង់តាមរយៈ ការគោរពតាមសេចក្តីសញ្ញាទាំងឡាយរបស់យើង ។*

ក្នុងឆ្នាំ ១៩៨៥ ស៊ីស្ទើរ ស៊ីតាទី និង ខ្ញុំ បានជួបបុរសម្នាក់ឈ្មោះ រ៉ចជើរ ហូវដ នៅទីក្រុង ណៃរ៉ូប៊ី ប្រទេស កេនយ៉ា ។ គាត់ និង ភរិយាគាត់ឈ្មោះ អ៊ីលីន កំពុងបម្រើជាអ្នកផ្សព្វផ្សាយសាសនាវ័យចំណាស់ ។ ពួកគាត់បានអញ្ជើញយើងឲ្យចូលរួមក្នុងក្រុមជំនុំតូចមួយ ដែលធ្វើឡើងក្នុងផ្ទះរបស់ពួកគាត់ ។ វាជាគ្រាដំបូង ដែលយើងបានចូលរួមការប្រជុំរបស់សមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ យើងមានអារម្មណ៍ពីព្រះវិញ្ញាណនៅក្នុងការប្រជុំដំបូងនោះ ហើយចាប់តាំងពីពេលនោះមក យើងបានចូលរួមសាសនាចក្រជារៀងរាល់ថ្ងៃអាទិត្យ ។

ប៉ុន្មានខែក្រោយមក រ៉ចជើរ បានធ្វើបុណ្យជ្រមុជទឹកឲ្យយើង រួមទាំងកូនប្រុសអាយុប្រាំបួនរបស់យើងដែរ ។ មិនយូរប៉ុន្មាន រ៉ចជើរ និង អេលែន បានត្រឡប់ទៅផ្ទះវិញ នៅពេលបញ្ចប់បេសកកម្មរបស់ពួកគាត់ ។ ពីរបីឆ្នាំម្ដង យើងបានឮដំណឹងពីពួកគាត់ ។

ទីបំផុត នៅដើមឆ្នាំ ២០១០ ស៊ីស្ទើរ ស៊ីតាទី និង ខ្ញុំបានជួប រ៉ចជើរ ម្តងទៀត ។ ឥឡូវនេះគាត់មានអាយុ ៩០ ឆ្នាំហើយ ។ ដោយមានអាយុចាស់ ហើយសុខភាពកាន់តែខ្សោយ គាត់មានការពិបាកក្នុងការដើរយ៉ាងខ្លាំង ។ នៅពេលយើងឈរទល់មុខគ្នាជាលើកដំបូង បន្ទាប់ពីបានបែកគ្នាអស់រយៈពេលច្រើនឆ្នាំមកហើយនោះ យើងមានសេចក្តីអំណរចំពោះគ្នាទៅវិញទៅមក ដែលពុំអាចថ្លែងបានឡើយ ។ ទឹកភ្នែកបានហូរស្រក់មកកាលយើងឱបគ្នាដោយភាពទន់ភ្លន់ ។ យើងមានអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគ្នាទៅវិញទៅមក និង ចំពោះអំណោយទានដ៏អស្ចារ្យនៃដំណឹងល្អ ។ យើងបានរួបរួមគ្នាក្នុងសេចក្តីជំនឿ ក្នុងនាមជារាស្ត្រនៃនគរព្រះ ។

កាលខ្ញុំគ្រេកអរនៅខណៈពេលនោះ បទគម្ពីរមួយបានលេចឡើងក្នុងគំនិតខ្ញុំថា ៖ « ចូរចាំចុះ តម្លៃនៃព្រលឹងទាំងឡាយ គឺមហិមាណាស់ចំពោះព្រះនេត្រនៃព្រះ . . .

« ហើយបើសិនជាអ្នកត្រូវធ្វើការអស់មួយជីវិតអ្នក ដោយស្រែកប្រាប់ពីការប្រែចិត្តដល់ប្រជាជននេះ ហើយគ្រាន់តែនាំព្រលឹងមួយគត់មករកយើង នោះអ្នកនឹងមានសេចក្តីអំណរដ៏មហិមាជាមួយអ្នកនោះនៅក្នុងនគរនៃព្រះវរបិតារបស់យើង ! » ( គ. និង ស. ១៨:១០, ១៥ ) ។

ពរជ័យដ៏ធំៗមួយចំនួនរបស់ព្រះ ត្រូវបានសន្យាទៅដល់អស់អ្នកណាដែលនាំព្រលឹងចូលក្នុងនគរព្រះ ។ ព្រះអង្គសង្គ្រោះបានប្រាប់ថា « មិនមែនអ្នករាល់គ្នាដែលបានរើសខ្ញុំទេ គឺខ្ញុំទេតើ ដែលរើសអ្នករាល់គ្នាវិញ ទាំងតាំងអ្នករាល់គ្នាឲ្យទៅបង្កើតផល ហើយថាឲ្យផលរបស់អ្នករាល់គ្នាបាននៅជាប់ផង ដើម្បីឲ្យព្រះវរបិតាបានប្រោសប្រទានឲ្យអ្នករាល់គ្នាបានអ្វីៗ ដែលនឹងសូមពីទ្រង់ដោយនូវឈ្មោះខ្ញុំ » ( យ៉ូហាន ១៥:១៦ ) ។

ក្រោយមកនៅឆ្នាំដដែលនោះ រ៉ចជើរ បានទទួលមរណភាព ។ ខ្ញុំដឹងយ៉ាងច្បាស់ថា គាត់គឺជាបុរសម្នាក់ដែលរកឃើញភាពសុខសាន្តនៅជាមួយព្រះ ។ គាត់បានមានឥទ្ធិពលលើជីវិតរបស់យើងតាមរយៈការចែកចាយដំណឹងល្អ ។ គំរូនៃការបម្រើដ៏ស្មោះត្រង់របស់គាត់ចំពោះមនុស្សដែលគាត់ស្គាល់ អមជាមួយនឹងអ្នកផ្សព្វផ្សាយសាសនាវ័យក្មេង និង អ្នកផ្សព្វផ្សាយសាសនាជាប្ដីប្រពន្ធជាច្រើននាក់ ដែលកំពុងបម្រើក្នុងសាសនាចក្រ ឆ្លុះបញ្ចាំងពីរបៀបមួយដែលយើងគោរពប្រតិបត្តិព្រះ ។

### ទំនាក់ទំនងខាងសេចក្តីសញ្ញារបស់យើងជាមួយព្រះ

ដោយសារយើងគឺជាសមាជិករបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នោះយើងម្នាក់ៗមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះវរបិតាសួគ៌តាមរយៈសេចក្តីសញ្ញាទាំងឡាយ ។ សេចក្តីសញ្ញានីមួយៗត្រូវបានបញ្ជាក់ដោយពិធីបរិសុទ្ធមួយដែលយើងទទួលយកដោយស្ម័គ្រចិត្ត ហើយតាំងចិត្តរក្សាសេចក្តីសញ្ញានោះ ។ តាមរយៈដង្វាយធួនរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ អាចធ្វើឲ្យយើងបំពេញនូវកាតព្វកិច្ចទាំងឡាយរបស់យើងក្នុងសេចក្តីសញ្ញានីមួយៗ នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើទ្រង់ ។



យើងគោរពប្រតិបត្តិព្រះវរបិតាសួគ៌នៅពេលយើងធ្វើឲ្យទំនាក់ទំនងយើងជាមួយទ្រង់កាន់តែស៊ីជម្រៅ ដោយការធ្វើ ហើយរក្សាសេចក្ដីសញ្ញា និង ពិធីបរិសុទ្ធនៃការសង្គ្រោះ ។ ទ្រង់ប្រទានពរដល់អស់អ្នកទាំងឡាយណា ដែលរក្សាសេចក្ដីសញ្ញារបស់ខ្លួន ដោយមានព្រះវិញ្ញាណបរិសុទ្ធដឹកនាំ និង ពង្រឹងពួកគេ ។ ខាងក្រោមនេះគឺជាទំនាក់ទំនងនៃសេចក្ដីសញ្ញាដ៏សំខាន់បំផុត ដែលយើងអាចបង្កើតជាមួយព្រះវរបិតាសួគ៌ ។

### សេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក

ពិធីបុណ្យជ្រមុជទឹកនាំយើងឲ្យចូលក្នុងទំនាក់ទំនងសេចក្ដីសញ្ញាដំបូងជាមួយព្រះ ។ យើងសក្ដិសមចំពោះពិធីបរិសុទ្ធនោះនៅពេលយើង « បន្ទាបខ្លួន [ យើង ] ចំពោះព្រះ . . . មកដោយចិត្តសង្រេង និង វិញ្ញាណទន់ទាប ហើយធ្វើបន្ទាល់នៅចំពោះសាសនាចក្រថា [ យើង ] ប្រាកដជាបានប្រែចិត្តចំពោះអំពើបាបរបស់ [ យើង ] ទាំងអស់ . . . ហើយប្រាកដជាសម្ដែងដោយកិច្ចការទាំងឡាយរបស់ [ យើង ] ថា [ យើង ] បានទទួលពីព្រះវិញ្ញាណនៃព្រះគ្រីស្ទចំពោះការផ្ដាច់បាបទាំងអស់របស់ [ យើង ] » ( គ. និង ស. ២០:៣៧ ) ។

ពេលយើងសម្ដែងចេញតាមរយៈទង្វើថា យើងពិតជា « លើកដាក់មកលើខ្លួន [ យើង ] នូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ដោយប្ដេជ្ញាថានឹងបម្រើទ្រង់ដល់ចុងបំផុត » ( គ. និង ស. ២០:៣៧ ) « ទទួលបន្ទុកគ្នាទៅវិញទៅមក ដើម្បីឲ្យបន្ទុកនោះបានស្រាល . . . ទួញយំជាមួយនឹងអ្នកណាដែលទួញយំ . . . ហើយកម្សាន្តទុក្ខដល់អស់អ្នកណាដែលត្រូវការការកម្សាន្តទុក្ខ ហើយឈរជាសាក្សីដល់ព្រះនៅគ្រប់ពេល និង គ្រប់សេចក្ដី និង គ្រប់ទីកន្លែងដែល [ យើង ] រាល់គ្នាបានទៅ រហូតដល់ពេលស្លាប់ » ( ម៉ូសាយ ១៨:៨–៩ ) នោះគឺយើងរក្សាសេចក្ដីសញ្ញាហើយ ។

ជាការតបស្នង ព្រះបង់ថ្លៃដល់យើងដោយនូវអំណោយទានព្រះវិញ្ញាណបរិសុទ្ធដែលតាមរយៈអំណោយទាននោះ យើងទទួលបានភាពជាដៃគូនឹងព្រះវិញ្ញាណបរិសុទ្ធ ដែលប្រទានដល់យើងនូវការណែនាំ និង ការបង្ហាញផ្លូវក្នុងគ្រប់កិច្ចការទាំងអម្បាលម៉ានរបស់យើង ដោយដឹកនាំយើងទៅរកជីវិតដ៏នៅអស់កល្បជានិច្ច ( សូមមើល ម៉ូសាយ ១៨:៩–១០ ) ។

ខ្ញុំស្គាល់ពីសេចក្ដីអំណរដ៏មហិមា និង ពីការពោរពេញទៅដោយព្រះវិញ្ញាណបន្ទាប់ពីពិធីបុណ្យជ្រមុជទឹក ដែលខ្ញុំបានបន្តដកពិសោធ ជាពិសេសដរាបណាដែលខ្ញុំនៅជិតព្រះ ។

### សម្បថ និង សេចក្ដីសញ្ញានៃបព្វជិតភាព

បុរសដែលរក្សាសេចក្ដីសញ្ញាបុណ្យជ្រមុជទឹក មានគុណសម្បត្តិដើម្បីចូលក្នុងសម្បថ និង សេចក្ដីសញ្ញានៃបព្វជិតភាព ។ យើងទទួលបានវា តាមរយៈពិធីបរិសុទ្ធនៃការដាក់ដៃលើក្បាល ។ សេចក្ដីសញ្ញានៃបព្វជិតភាពគឺជាសេចក្ដីសញ្ញាមួយនៃការបម្រើសម្រាប់សេចក្ដីសង្គ្រោះនៃកូនចៅរបស់ព្រះ ។ យើងគោរពប្រតិបត្តិព្រះនៅពេលយើងតម្កើងការហៅរបស់យើង ( សូមមើល គ. និង ស. ៨៤:៣៣ ) ហើយ « បម្រើទ្រង់ឲ្យអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំង [ របស់យើង ] » ( គ. និង ស. ៤:២ ) ហើយដោយ « សេចក្ដីជំនឿ សេចក្ដីសង្ឃឹម សេចក្ដីសប្បុរស និង សេចក្ដីស្រឡាញ់ ដោយភ្នែកស្មោះត្រង់ទាំងស្រុងចំពោះសិរីល្អនៃព្រះ » ( គ. និង ស. ៤:៥ ) ។

ពរជ័យរបស់ព្រះអម្ចាស់ដែលកើតមានចំពោះពួកអ្នកកាន់បព្វជិតភាពដ៏ស្មោះត្រង់រួមមានការញែកជាបរិសុទ្ធ « ដោយសារព្រះវិញ្ញាណ ចំពោះការសាងរូបកាយរបស់ពួកគេជាថ្មី » ( គ. និង ស. ៨៤:៣៣ ) ។ ពួកគេត្រឡប់ជាអ្នកទទួលបានមរតកជាពរជ័យនៃលោកម៉ូសេ និង លោកអ័ប្រាហាំ ( សូមមើល គ. និង ស. ៨៤:៣៤ ) ។ ពួកព្យាការី និង សាវកថ្ងៃចុងក្រោយ គឺជាគំរូដ៏ប្រពៃនៃអ្នកដែលតម្កើងបព្វជិតភាពខ្លួន ។ ជីវិតរបស់ពួកលោកគឺជាទីបន្ទាល់ ដែលព្រះអម្ចាស់បង់ថ្លៃសម្រាប់ពួកលោក ។

### ពិធីបរិសុទ្ធ និងសេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធ

បុរសដែលកាន់បព្វជិតភាពជាន់ខ្ពស់ដោយសក្ដិសម និង ស្ត្រីដែលមានភាពសក្ដិសម អាចទទួលពិធីបរិសុទ្ធនានា ហើយធ្វើសេចក្ដីសញ្ញាពិសិដ្ឋនៅក្នុងព្រះវិហារបរិសុទ្ធ ។ តាមរយៈពិធីបរិសុទ្ធ និង សេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធ យើងសិក្សាស្វែងយល់ពីគោលបំណងនៃជីវិតនេះ និង ដើម្បីត្រៀមជាស្រេចសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ។ យើងទទួលពិធីបរិសុទ្ធ ហើយចូលក្នុងសេចក្ដីសញ្ញានៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច និង ការផ្សារភ្ជាប់ជាមួយក្រុមគ្រួសារយើង ។ យើងតាំងចិត្តថ្វាយជីវិតរបស់យើងទៅដល់ព្រះ និង ចំពោះកិច្ចការនៃសេចក្ដីសង្គ្រោះសម្រាប់កូនចៅព្រះទាំងអស់ ។ ការរក្សាសេចក្ដីសញ្ញាទាំងនេះដោយស្មោះត្រង់នាំឲ្យយើងទទួលបានការដឹកនាំខាងវិញ្ញាណ និង អំណាចដើម្បីយកឈ្នះលើការសាកល្បងទាំងឡាយនៃជីវិតមែងស្លាប់ និង ដើម្បីទទួលបានភាពតម្កើងឡើងដែលជាពរជ័យដ៏មហិមាដែលព្រះប្រទានដល់កូនចៅទ្រង់ ( សូមមើល គ. និង ស. ១៤:៧ ) ។ ភាពតម្កើងឡើង ឬ ជីវិតដ៏នៅអស់កល្បជានិច្ច មានន័យថា អរសប្បាយជាក្រុមគ្រួសារដែលជាកម្រិតរស់នៅដែលមានសភាពដូចជាព្រះវរបិតាសួគ៌ដែរ ។

### ពិធីសាក្រាម៉ង់

សម្រាប់សមាជិកសាសនាចក្រ ការទទួលទានសាក្រាម៉ង់ដោយមានភាពសក្ដិសមជារៀងរាល់ថ្ងៃអាទិត្យគឺជាការចាំបាច់ ។ តាមរយៈពិធីបរិសុទ្ធនេះ យើងបញ្ជាក់ពីការបន្តឆន្ទៈដើម្បីលើកដាក់ព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ហើយបន្តការតាំងចិត្តរបស់យើង ដើម្បីរក្សាសេចក្ដីសញ្ញាទាំងអស់ដែលយើងបានធ្វើ ។ យើងប្រើប្រាស់ព្រះចេស្ដានៃដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ដើម្បីជួយយើងកាន់ខ្ជាប់ដរាបដល់ចុងបំផុតក្នុងសេចក្ដីសុចរិត ។ នៅពេលយើងធ្វើដូច្នេះ យើងមានគុណសម្បត្តិសម្រាប់ពរជ័យទាំងអស់នៃសេចក្ដីសញ្ញានានាដែលយើងបានធ្វើ ។

### បំណងប្រាថ្នាដ៏សុចរិត

ការល្មើសសេចក្ដីសញ្ញាធ្វើឲ្យព្រះអន់ព្រះទ័យ ហើយពរជ័យដែលបានសន្យាពុំកើតមានឡើងឡើយ ( សូមមើល គ. និង ស. ៨២:១០ ) ។



*តាមរយៈដង្វាយធួនរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ អាចធ្វើឲ្យយើងបំពេញនូវកាតព្វកិច្ចទាំងឡាយរបស់យើងក្នុងសេចក្ដីសញ្ញានីមួយៗ នៅពេលយើងអនុវត្តសេចក្ដីជំនឿទៅលើទ្រង់ ។*

នៅក្នុង សាំយូអែលទី ១ ២:១២–១៧, ២២–៣៤ យើងរៀនពីសេចក្ដីអាក្រក់ដែលបានប្រព្រឹត្តដោយពួកកូនប្រុសរបស់អេលី ដែលជាសង្ឃ ។ ដោយសំអាងទៅលើតំណែងរបស់ឪពុកខ្លួន ពួកគេបានរំលងនឹងសេចក្ដីសញ្ញានៃបព្វជិតភាព ។ ពួកគេព្យាយាមបំពេញតាមចំណង់តណ្ហាខ្លួន កាលគេប្រព្រឹត្តទទឹងច្បាប់ក្រមសីលធម៌ជាមួយស្រីៗអ្នកមកថ្វាយបង្គំ ហើយកាលគេយកសាច់ដង្វាយរបស់រាស្ត្រអ៊ីស្រាអែល ទុកសម្រាប់ខ្លួនគេផ្ទាល់យ៉ាងថោកទាបបំផុត ។ ព្រះអម្ចាស់បានចេញដីការកាត់ទោសកូនប្រុសទាំងឡាយរបស់អេលី និង អេលីខ្លួនគាត់ផ្ទាល់សម្រាប់ការដែលលោកពុំបានហាមឃាត់ពួកគេ ។

ចំណង់ខាងកាមគុណដូចនោះ អាចយកឈ្នះបានតាមរយៈការតាំងចិត្តរក្សាសេចក្ដីសញ្ញាជាមួយព្រះ ដូចបានបង្ហាញដោយយ៉ូសែបនៅអេស៊ីព្ទ កាលលោកត្រូវប្រឈមមុខនឹងអ្នកមិនមានជំនឿ អសីលធម៌ម្នាក់ ( សូមមើល លោកុប្បត្តិ ៣៩:៩, ១២ ) ។ ព្រះបានតម្កើងដល់យ៉ូសែប ហើយបានជួយលោកយកឈ្នះលើគ្រប់ទម្រង់នៃសេចក្ដីអាក្រក់ទាស់នឹងលោក ។ លោកបានធំឡើងក្លាយទៅជាបុរសដែលមានអំណាចធំជាងគេទីពីរនៅប្រទេសអេស៊ីព្ទ ហើយជាឧបករណ៍មួយក្នុងព្រះហស្តព្រះ ដើម្បីការពារវង្សអ៊ីស្រាអែល ( សូមមើល លោកុប្បត្តិ ៤៥:៧–៨ ) ។

ប្រសិនបើការល្បួងបានឈ្នះលើយើងហើយ នោះបំណងប្រាថ្នាដើម្បីស្ដារទំនាក់ទំនងយើងជាមួយព្រះវរបិតាសួគ៌នឹងនាំយើងទៅរកការប្រែចិត្តដ៏ស្មោះ ។ បន្ទាប់មក ដង្វាយធួនរបស់ព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ជួយយើងឲ្យប្រែក្លាយជាមានភាពសក្ដិសមសារជាថ្មី ។

**ការធ្វើតាមពួកព្យាការី**

នៅពេលព្រះគ្រីស្ទបានស្ថាបនាសាសនាចក្រទ្រង់ ទ្រង់បានរើសពួកសាវក ព្យាការី អ្នកផ្សាយដំណឹងល្អ គ្រូគង្វាល និង គ្រូបង្រៀន « សម្រាប់ការស្អាងរូបកាយព្រះគ្រីស្ទឡើង ៖

« ទាល់តែយើងរាល់គ្នាបានរួបរួមខាងឯសេចក្ដីជំនឿរួចជាស្រេច ហើយបានស្គាល់ព្រះរាជបុត្រានៃព្រះដូចគ្នាទាំងអស់ គឺបានដល់ពេញជាមនុស្ស ហើយដល់ខ្នាតកម្ពស់នៃសេចក្ដីពោរពេញផងព្រះគ្រីស្ទ » ( អេភេសូរ ៤:១២–១៣ ) ។

ព្យាការី និង សាវកដែលកំពុងរស់នៅរបស់យើងបង្រៀនថា « សុភមង្គលនៅក្នុងជីវិតគ្រួសារអាចកើតមានឡើងបាននៅពេលធ្វើតាមការបង្រៀនរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ អាពាហ៍ពិពាហ៍ និង គ្រួសារ ដែលមានជោគជ័យ គឺស្ថាបនា និង រក្សាលើគោលការណ៍នៃសេចក្ដីជំនឿ ការអធិស្ឋាន ការប្រែចិត្ត ការអភ័យទោស ការគោរពគ្នា សេចក្ដីស្រឡាញ់ សេចក្ដីមេត្តាករុណា ការងារ និង កម្មវិធីកម្សាន្តល្អៗទាំងឡាយ » ( « ក្រុមគ្រួសារ ៖ សេចក្ដីប្រកាសដល់ពិភពលោក » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៩ ) ។

គេហដ្ឋាន និង ក្រុមគ្រួសារយើង ផ្ដល់នូវគ្រឹះសម្រាប់បង្កើតទំនាក់ទំនងរឹងមាំជាមួយព្រះដោយផ្អែកទៅលើសេចក្ដីសញ្ញាទាំងឡាយ ។ ការធ្វើតាមការបង្រៀនដ៏បំផុសគំនិតនៃពួកព្យាការីដែលកំពុងរស់នៅ នឹងជួយយើងឲ្យមានក្រុមគ្រួសារដ៏រឹងមាំ ផ្ដល់ឲ្យយើងនូវអំណាចដើម្បីរក្សាសេចក្ដីសញ្ញានានារបស់យើង ព្រមទាំងធានានូវពរជ័យដ៏អស្ចារ្យបំផុតនៃសេចក្ដីជំនឿរបស់យើង ។ ■

# សូមអរគុណចំពោះការណែនាំខ្ញុំឲ្យស្គាល់ដំណឹងល្អ

កាលពីដើមទសវត្សរ៍ឆ្នាំ ១៩៨០ គ្រួសាររបស់ខ្ញុំបានរស់នៅក្នុងប្រទេស អាល្លឺម៉ង់ ភាគខាងលិច ហើយយើងគឺជាសមាជិកនៅស្ដេក ទាហានខាយសើរស្លោធើន អាល្លឺម៉ង់ ។ នៅគ្រានោះ ថ្នាក់ដឹកនាំក្នុងមូលដ្ឋានរបស់យើងបានសង្កត់ធ្ងន់លើ កិច្ចការផ្សព្វផ្សាយសាសនា ។ ពួកលោកបានប្រាប់ យើងថានៅក្នុងរង្វង់មិត្តភក្តិរបស់យើង ព្រះអម្ចាស់បាន ដាក់កូនវិញ្ញាណជម្រើសរបស់ទ្រង់មួយចំនួន ដែល ស្វែងរកដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។

ភរិយាខ្ញុំ ជេនី និង រូបខ្ញុំបានជឿថានោះគឺជាការពិត ។ ថ្នាក់ដឹកនាំរបស់យើងបានលើកទឹកចិត្ត យើងម្នាក់ៗ ឲ្យកត់សម្គាល់ពីមិត្តភក្តិមិនមែនជា សមាជិក ដែលយើងគិតថាចាប់អារម្មណ៍ស្ដាប់ដំណឹង ល្អ ។ យើងបានធ្វើបញ្ជីឈ្មោះមនុស្សប្រហែល ១០ នាក់ ហើយបន្ទាប់មកបានតមអាហារ និង អធិស្ឋាន អំពីបញ្ជីឈ្មោះរបស់មិត្តភក្តិយើង ហើយបាន សម្រេចចិត្តថាអ្នកណាដែលយើងទៅជួបមុនគេ ។ យើងបានសម្រេចចិត្តទាក់ទងបុរសពីរនាក់ដែលជា សហការីនៅក្នុងការិយាល័យរបស់ខ្ញុំ ។ ដំបូងខ្ញុំបាន និយាយជាមួយយុវមជ្ឈិមវ័យម្នាក់ឈ្មោះ គ្រីស្ទ ប៉ុន្តែ គេបានបង្ហាញចំណាប់អារម្មណ៍តិចតួចនៅពេល នោះ ។ ក្រោយមកយើងបានសម្រេចចិត្តថា ខ្ញុំនឹងទៅ ជួប ប្រ៊ូស ហាំប៊ី ជាមនុស្សម្នាក់ដែលល្អ និង មានចិត្ត សប្បុរសដែលទើបតែមានគ្រួសារថ្មោងថ្មី ។

ប៉ុន្តែបួនប្រាំថ្ងៃបានកន្លងផុតទៅ ខ្ញុំបានឃើញថាខ្ញុំ ភ័យខ្លាចក្នុងចិត្តពុំហ៊ាននិយាយដំណឹងល្អប្រាប់គាត់ ឡើយ ។ ទីបំផុត នៅថ្ងៃមួយ ជេនី បានទូរសព្ទមកខ្ញុំ ពេលខ្ញុំនៅការិយាល័យ ហើយបានសួរខ្ញុំថា « តើបង បាននិយាយជាមួយ ប្រ៊ូស ហើយឬនៅ ? » ខ្ញុំបាន និយាយថា « ទេ បង មិនទាន់បាននិយាយជាមួយ គេនៅឡើយទេ ប៉ុន្តែបងនឹងនិយាយជាមួយគេឆាប់ៗ នេះ » ។ ក្រោយមកនាងបានសួរថា តើប្រ៊ូស នៅក្នុង ការិយាល័យទេថ្ងៃនេះ ហើយខ្ញុំបាននិយាយថា បាទ គាត់នៅ ។ នៅពេលនោះនាងបាននិយាយថា « ស្កុត សូមដាក់ទូរសព្ទចុះ ។ អូននឹងនៅចាំ ពេលបង និយាយជាមួយគាត់ ! »

ខ្ញុំបានដាក់ទូរសព្ទចុះ ហើយបានដើរទៅរក ប្រ៊ូស ទាំងភ័យក្នុងចិត្ត ហើយសួរថា « ប្រ៊ូស តើអ្នកដឹងថា ខ្ញុំជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃ ពួកបរិសុទ្ធថ្ងៃចុងក្រោយមែនទេ ?» គាត់បាននិយាយ ថា បាទខ្ញុំដឹង ហើយខ្ញុំបាននិយាយថា « តើអ្នកចាប់ អារម្មណ៍រៀនបន្ថែមទៀតអំពីសាសនាចក្រនេះឬ ទេ ? » គាត់បានឆ្លើយថា « បាទខ្ញុំចង់រៀន » ។

រំលងជាពីរបីសប្ដាហ៍ក្រោយមក ប្រ៊ូស ភរិយារបស់ គាត់ អ៊ីឡា និង កូនស្រីរបស់ពួកគេ ថានយ៉ា បាន មកផ្ទះរបស់យើងបរិភោគអាហារពេលល្ងាច ហើយ បានជួបជាមួយអ្នកផ្សព្វផ្សាយសាសនា ។ ពួកគេ បានរៀនមេរៀន ចូលរួមការប្រជុំសាសនាចក្រជាមួយ យើង បានទទួលដំណឹងល្អ ហើយបានជ្រមុជទឹក ។ វាគឺជាថ្ងៃដ៏នក្ខត្តឫក្ស និង រីករាយបំផុត ។ ប្រ៊ូស មាន អំណរគុណដែលយើងបានណែនាំគ្រួសាររបស់គាត់ឲ្យ ស្គាល់ដំណឹងល្អ ។ សូម្បីតែ គ្រីស្ទ ជាយុវវជននៅក្នុង ការិយាល័យរបស់យើងបានចូលរួមបុណ្យជ្រមុជទឹក ហើយមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ ក្រោយមក ប្រ៊ូស និង អ៊ីឡា បានទៅជួប គ្រីស្ទប្រាប់អំពីដំណឹង ល្អ ។ ដោយការរាប់អានរបស់ពួកគេ នោះគ្រីស្ទបាន រៀនដំណឹងល្អពីអ្នកផ្សព្វផ្សាយសាសនា ហើយបាន ចូលរួមសាសាចក្រផងដែរ ។ ■

ស្កុត់ អេឌហ្គា រដ្ឋ យូថាហ៍ ស.រ.អា.

ភរិយារបស់ខ្ញុំបាននិយាយថា « ស្កុត សូមដាក់ទូរសព្ទចុះ ។ « អូននឹងនៅចាំ ពេលបងនិយាយ ប្រាប់ប្រ៊ូសអំពីដំណឹងល្អ ! » ។



រូបគំនូរដោយ ស្ទេន ហ្វែលូ



ខ្ញុំមានការភ្ញាក់ផ្អើល ដោយបានជួបស្ត្រីមិនសូវសកម្មម្នាក់ នៅតាមផ្លូវក្នុងអគារដែលត្រូវការការលួងលោម និង ជំនួយ ។

# ខ្ញុំមានអារម្មណ៍ថាខ្វះសមត្ថភាព

កាលខ្ញុំត្រូវបានហៅឲ្យបម្រើជាប្រធានសមាគមសង្គ្រោះទូទៅ ខ្ញុំជាម្ដាយវ័យក្មេងដ៏រវល់ម្នាក់ ។ ខ្ញុំបានចម្រើនវ័យធំឡើង ហើយរស់នៅស្រមតាមការបង្រៀនរបស់សាសនាចក្រ ប៉ុន្តែខ្ញុំបានដឹងថា ខ្ញុំគ្មានភាពល្អឥតខ្ចោះ ហើយមានអារម្មណ៍ព្រួយបារម្ភអំពីសមត្ថភាពរបស់ខ្ញុំ ក្នុងការជួយដល់បងប្អូនស្ត្រីនៅក្នុងវួដរបស់ខ្ញុំដែលជួបប្រទះការលំបាក ។

នាថ្ងៃអាទិត្យមួយនៅព្រះវិហារ ខ្ញុំមានអារម្មណ៍ថាបាក់ទឹកចិត្តជាខ្លាំង ។ បងប្អូនស្ត្រីដែលត្រូវការជំនួយពីខ្ញុំបានមកជួបខ្ញុំពេញមួយថ្ងៃ ។ ស្ត្រីខ្លះត្រូវការជំនួយខាងសុខុមាលភាព ហើយខ្លះទៀតគ្រាន់តែត្រូវការឲ្យខ្ញុំស្ដាប់ពួកគេប៉ុណ្ណោះ ។ បន្ទាប់មក ព្រះវិញ្ញាណបានបំផុសគំនិតខ្ញុំមិនឲ្យទៅការប្រជុំពិធីសាក្រាម៉ង់ឡើយនៅពេលចាប់ផ្ដើមនោះ ហើយខ្ញុំមានការភ្ញាក់ផ្អើលដោយបានជួបស្ត្រីមិនសូវសកម្មម្នាក់ នៅតាមផ្លូវក្នុងអគារដែលត្រូវការការលួងលោម និង ជំនួយ ហើយពុំអាចចាំបានរហូតដល់ចប់ម៉ោងប្រជុំ ។

នៅពេលចប់ម៉ោងនៅព្រះវិហារ ខ្ញុំអស់កម្លាំងណាស់ ! ខ្ញុំបានយំនៅលើឡានតាមផ្លូវរហូតដល់ផ្ទះ ។ ខ្ញុំឮក្នុងខួរក្បាលរបស់ខ្ញុំនូវពាក្យបែបនេះ ៖ « និយាយជាមួយប៊ីស្សព ! » ខ្ញុំមានអារម្មណ៍ថាប៊ីស្សពមានយោបល់ដ៏ឈ្លាសវៃប្រាប់ខ្ញុំអំពីរបៀបដែលខ្ញុំអាចមានអារម្មណ៍ធូរស្បើយពីបន្ទុកនៃការហៅបម្រើរបស់ខ្ញុំ ប៉ុន្តែខ្ញុំពុំចង់រំខានគាត់បន្ទាប់ពីម៉ោងនៃការប្រជុំដ៏យូរនៅព្រះវិហារទៀតឡើយ ។ ខ្ញុំបានសម្រេចចិត្តពន្យាពេលទូរសព្ទទៅគាត់ តែក្រោយមកទូរសព្ទបានរោទ៍ឡើង ។ ប៊ីស្សពបានទូរសព្ទមករកខ្ញុំ ។ គាត់បានទទួលអារម្មណ៍បំផុសគំនិតឲ្យទូរសព្ទមកខ្ញុំ ។

ខ្ញុំបានប្រាប់ប៊ីស្សពថាតើវាមានការនឿយហត់ខ្លាំងប៉ុណ្ណាចំពោះខ្ញុំ នៅពេលមានកិច្ចការជាច្រើនដែលចាំបាច់ត្រូវដោះស្រាយក្នុងពេលតែមួយ ហើយថាតើខ្ញុំកើតទុក្ខខ្លាំងប៉ុណ្ណាដែលខ្ញុំពុំអាចជួយបងប្អូនស្ត្រីជាច្រើនទៀត ។ គាត់បានស្ដាប់ដោយអំណត់ ។ យើងក៏ធ្លាប់បានពិភាក្សានូវសំណួរសុខុមាលភាពមួយចំនួនដែលខ្ញុំបានលើកឡើងមកនិយាយនាថ្ងៃនោះ ហើយខ្ញុំបានមានអារម្មណ៍ល្អប្រសើរឡើង ។

នៅពេលនិយាយគ្នាចប់ ខ្ញុំបាននិយាយថា « ខ្ញុំបានគិតថា ប៊ីស្សពនឹងមានយោបល់ឈ្លាសវៃដើម្បីប្រាប់ខ្ញុំ ថាតើត្រូវធ្វើដូចម្ដេចដើម្បីកុំឲ្យមានអារម្មណ៍ថាមានបន្ទុកធ្ងន់ធ្ងរនោះ » ។ គាត់បានឆ្លើយថា គាត់ចង់មានយោបល់ល្អបែបនោះនិយាយប្រាប់ដែរ ប៉ុន្តែគួរឲ្យសោកស្ដាយណាស់គាត់គ្មានយោបល់អ្វីឡើយ ។

ទោះបីជាខ្ញុំពុំទទួលបានចម្លើយក្ដី ខ្ញុំមានអារម្មណ៍រីករាយបន្ទាប់ពីខ្ញុំដាក់ទូរសព្ទចុះវិញ ។ ខ្ញុំមានអារម្មណ៍ថា ព្រះអម្ចាស់បានឆ្លើយតបចំពោះសេចក្ដីត្រូវការរបស់ខ្ញុំដើម្បីទទួលបានការណែនាំ និង គាំទ្រ ។

អំឡុងពេលប៉ុន្មានសប្ដាហ៍ក្រោយមក អារម្មណ៍នៃការខ្វះសុវត្ថិភាពនោះបានកើតមានក្នុងចិត្តខ្ញុំទៀត ហើយខ្ញុំបានអធិស្ឋានដើម្បីយល់ពីអ្វីដែលត្រូវធ្វើ ដើម្បីធ្វើជាប្រធានសមាគមសង្គ្រោះម្នាក់ដែលកាន់តែប្រសើរឡើង ។ ថ្ងៃមួយ នៅពេលខ្ញុំបានស្ដាប់សន្និសីទទូទៅ ខ្ញុំបានចាប់អារម្មណ៍ពាក្យមួយចំនួន ហើយព្រះវិញ្ញាណបានមានបន្ទូលមកកាន់ដួងចិត្តខ្ញុំយ៉ាងខ្លាំង ។ ខ្ញុំបានយល់ថា ហេតុផលដែលខ្ញុំមានអារម្មណ៍ថាខ្វះសមត្ថភាពនោះគឺដោយសារខ្ញុំខ្វះសមត្ថភាពរបស់ខ្ញុំផ្ទាល់ ។

តាមរយៈបទពិសោធន៍របស់ខ្លួន ប៊ីស្សពរបស់ខ្ញុំបានបង្ហាញខ្ញុំ ថាតើវាសំខាន់ប៉ុណ្ណាដើម្បីស្ដាប់តាមព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះវិញ្ញាណមានសារៈសំខាន់ចំពោះការហៅបម្រើរបស់យើងនៅក្នុងសាសនាចក្រ ពុំមែនទេពកោសល្យ ឬ ជំនាញផ្ទាល់ខ្លួនយើងឡើយ ។ លើកដំបូងបង្អស់ក្នុងរយៈពេលមួយដ៏យូរហើយ ដែលខ្ញុំមានអារម្មណ៍សុខសាន្ត និង ការធានាអះអាង ។

ខ្ញុំនៅតែខ្វះបទពិសោធន៍ ហើយខ្ញុំនៅតែមានភាពមមាញឹកជាមួយគ្រួសាររបស់ខ្ញុំដូចពីមុន ប៉ុន្តែខ្ញុំពុំជឿតទៅទៀតឡើយថា ខ្ញុំត្រូវតែធ្វើឲ្យការហៅរបស់ខ្ញុំសម្រេចបានលទ្ធផលល្អឥតខ្ចោះនោះ ។ ព្រះវរបិតាសួគ៌អាចប្រទានដល់ខ្ញុំនូវកិច្ចការនានាដែលខ្ញុំចាំបាច់ត្រូវសម្រេចឲ្យបាននូវព្រះឆន្ទៈរបស់ទ្រង់ ហើយអាចតម្កើងកិច្ចខិតខំរបស់យើង ដរាបណាយើងគោរពបទបញ្ញត្តិទ្រង់ ។ ■

ឈ្មោះត្រូវបានដកចេញ ស្ដុកខូម ស៊ុយអែត

រូបគំនូរដោយ អេលែន ហ្គាន់ស៍

# ការស្វែងរកជីដូន

ខ្ញុំមានការសោកស្ដាយមួយ ដែលខ្ញុំពុំធ្លាប់អង្គុយជាមួយជីដូនខាងឪពុកខ្ញុំ ដើម្បីនិយាយគ្នាពីជីវប្រវត្តិរបស់គាត់ ហើយកត់ត្រាពីអនុស្សាវរីយ៍របស់គាត់សម្រាប់ពូជពង្សខ្ញុំ ។ បន្ទាប់ពីជីដូនខ្ញុំបានចែកឋានទៅ ឪពុក និង ឪពុកមារបស់ខ្ញុំបានប្រាប់ខ្ញុំពីរបៀបដែលជីដូនខ្ញុំគ្មានការភ្ញាក់ផ្អើលចំពោះអ្វីដែលខ្លួនគាត់មានឡើយ ហើយមានពេលមួយនោះ គាត់ថែមទាំងបានសួរថា « ហេតុអ្វីគេចង់ដឹងពីរូបខ្ញុំ ? »

បញ្ហាខាងហិរញ្ញវត្ថុបានជំរុញឲ្យគ្រួសារខ្ញុំប្ដូរទៅរស់នៅផ្ទះចាស់របស់ជីដូនខ្ញុំ មានអនុស្សាវរីយ៍ដ៏រីករាយ និង គួរឲ្យស្ដាយជាច្រើនបានកើតឡើងក្នុងចិត្តខ្ញុំ ។ នាយប់មួយនោះ ប៉ុន្មានថ្ងៃបន្ទាប់ពីប្ដូរទៅនៅទីនោះ ខ្ញុំបានមើលសៀវភៅរូបថតចាស់ៗ និង ប្រអប់អនុស្សាវរីយ៍របស់ជីដូនខ្ញុំជាច្រើន ដែលមានទាំងសំបុត្រចាស់ៗដែលឪពុកមាបានសរសេរ បណ្ណ័ចូលព្រះវិហារបរិសុទ្ធចាស់ៗ ព្រមទាំងកម្មវិធីក្រដាសកម្មវិធីបុណ្យសពរបស់ជីតាខ្ញុំផងដែរ ។ បន្ទាប់ពី មើលវត្ថុអនុស្សាវរីយ៍នេះ ខ្ញុំឆ្ងល់ថាតើវាមានអ្វីថែមទៀតទេ ។

ខ្ញុំមានអារម្មណ៍បំផុសគំនិតឲ្យរកមើលនៅលើធ្នើ ហើយភ្លាមនោះខ្ញុំបានឃើញថង់មួយ ដែលមានប្រអប់ដាក់ឯកសារពណ៌ខៀវដែលមើលទៅដូចជាត្រូវបោះចោល ។ នៅក្នុងប្រអប់ឯកសារនោះ ខ្ញុំបានឃើញដំណើរជីវប្រវត្តិតាំងពីដើមដំបូងរបស់ជីដូនរបស់ខ្ញុំដែលបានសរសេរកាលពី ៣០ ឆ្នាំមុននោះ ។ ក្រោយមកដោយក្ដីអស្ចារ្យខ្ញុំបានដឹងថា គ្មាននរណាម្នាក់នៅក្នុងគ្រួសាររបស់ខ្ញុំបានដឹងថាមានសៀវភៅនេះឡើយ ។ ឪពុក និង ឪពុកមារបស់ខ្ញុំមានប្រសាសន៍ត្រឹមត្រូវណាស់ — គឺថាជីដូនខ្ញុំគ្មានការភ្ញាក់ផ្អើលជាមួយនឹងខ្លួនគាត់ឡើយ ដែលគាត់ពុំបានប្រាប់នរណាម្នាក់ថាគាត់បានចាប់ផ្ដើមសរសេរពីជីវប្រវត្តិរបស់គាត់ឡើយ !

នៅយប់នោះ ខ្ញុំបានអានគ្រប់ពាក្យទាំងអស់ដែលមាននៅលើប្រាំបីទំព័រនោះ ហើយនៅពេលខ្ញុំបានអានវា ខ្ញុំបានរៀនជាច្រើនពីជីដូនរបស់ខ្ញុំ — ពីជីវិតរបស់គាត់កាលនៅវិទ្យាល័យ ថាតើគាត់បានជួបជីតាខ្ញុំតាមរបៀបណា ហើយថាតើវាលំបាកខ្លាំងប៉ុណ្ណាសម្រាប់គាត់ ដើម្បីបិទរោងភាពយន្តដែលគាត់ និង ជីតារបស់ខ្ញុំបានបើកជាមួយគ្នា ។

ខ្ញុំមានអារម្មណ៍ថាគាត់មានវត្តមាននៅទីនោះនៅពេលខ្ញុំអានសៀវភៅនេះ គឺហាក់ដូចជាគាត់កំពុងប្រាប់ខ្ញុំថាកុំបារម្ភតទៅទៀតអំពីការមិនបំពេញបញ្ចប់នូវប្រវត្តិផ្ទាល់មាត់ដែលខ្ញុំមានបំណងដើម្បីធ្វើវានោះ ។ ការអានពីជីវប្រវត្តិរបស់ជីដូនខ្ញុំដែលសរសេរដោយដៃគាត់ផ្ទាល់គឺមានតម្លៃពុំអាចកាត់ថ្លៃបាន ហើយខ្ញុំបានកាត់បន្ថយនូវអារម្មណ៍នៃការសោកស្ដាយដែលខ្ញុំបានមានជាយូរមកហើយ ។ វាគឺជាការធានាអះអាងពីសេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់ និង ជាសក្ខីភាពថាពង្សប្រវត្តិគឺពុំមែនគ្រាន់តែជាការស្វែងរកបុព្វការីជនដែលយើងពុំស្គាល់នៅក្នុងជីវិតនេះតែប៉ុណ្ណោះទេ ។ វាថែមទាំងជាការស្វែងរកបន្ថែមទៀតនូវអស់អ្នកដែលយើងស្រឡាញ់ជាខ្លាំង និង ជាមួយអស់អ្នកដែលយើងបានចំណាយពេលដ៏មានតម្លៃបំផុតនៅលើផែនដីនេះ ។

នៅពេលខ្ញុំអង្គុយចុះជាមួយសមាជិកផ្សេងទៀតនៃគ្រួសារ ដើម្បីសរសេរប្រវត្តិរបស់ពួកគេ ហើយពួកគេសួរខ្ញុំពីមូលហេតុដែលថាហេតុអ្វីមានគេចង់ដឹងពីខ្លួនពួកគេ នោះខ្ញុំបានបញ្ជាក់ប្រាប់ពួកគេថា ប្រវត្តិរបស់ពួកគេគឺមានតម្លៃដើម្បីប្រាប់ដល់មនុស្សដទៃ ហើយថាពូជពង្សរបស់ពួកគេនឹងមានអំណរគុណចំពោះពួកគេ គឺដូចជារូបខ្ញុំមានអំណរគុណចំពោះជីដូនរបស់ខ្ញុំ ដែលបានបន្សល់ទុកនូវដំណើររឿងដ៏មានតម្លៃបំផុតរបស់គាត់ ។ ■

រូប៊ីន វ៉ាដស្វើ រដ្ឋ យូថាហ៍ ស.រ.អា.



រូបគំនូរដោយ អេលែន ហ្គានស៍

# ព្រះវិហារបរិសុទ្ធនៅផ្នែកម្ខាងទៀតនៃពិភពលោក

អំឡុងពេលវ័យជំទង់ ខ្ញុំបានចូលរួមសាសនាចក្រ ដែលវាផ្ទុយពីបំណងប្រាថ្នារបស់គ្រួសារខ្ញុំ ។ កាលខ្ញុំមានអាយុខ្ទង់ ២០ ឆ្នាំប្លាយ ខ្ញុំបានចាប់ផ្ដើមធ្វើពង្សប្រវត្តិរបស់គ្រួសារខ្ញុំ បន្ទាប់ពីលោកឪពុកខ្ញុំបានចែកឋានទៅ ។ មិនយូរប៉ុន្មានក្រោយមក ខ្ញុំបានរៀបការ ហើយមានភាពមមាញឹកក្នុងនាមជាភរិយា និង ម្ដាយដែលចិញ្ចឹមបីបាច់កូនតូចៗ ហើយបានឈប់ធ្វើកិច្ចការពង្សប្រវត្តិ ។

ដោយសារខ្ញុំគ្មានគ្រួសារនៅក្នុងសាសនាចក្រ នោះខ្ញុំមានបំណងស្វែងរកពង្សប្រវត្តិរបស់គ្រួសារខ្ញុំជាខ្លាំង ។ ខ្ញុំចូលចិត្តធ្វើកិច្ចការនេះ ហើយមានបំណងចំណាយពេលឲ្យបានច្រើនថែមទៀតដើម្បីធ្វើវា ។

កាលខ្ញុំអាយុ ៣៣ ឆ្នាំជីវិតរបស់ខ្ញុំបានជួបនឹងបញ្ហាដែលពុំបានព្រៀងទុក ពេលសុខភាពរបស់ខ្ញុំបានចាប់ផ្ដើមធ្លាក់ចុះទ្រុឌទ្រោម ។ វាជាគ្រាដ៏លំបាកដែលខ្ញុំមិនអាចឡើងភ្នំជាមួយគ្រួសាររបស់ខ្ញុំ ការដើរកម្សាន្តនៅជុំវិញផ្ទះក្លាយជាការលំបាក ។ ខ្ញុំពុំអាចសម្អាតផ្ទះរយៈពេលពីរម៉ោងនៅថ្ងៃសៅរ៍ទៀតឡើយ ហើយខ្ញុំរីករាយណាស់ ប្រសិនបើខ្ញុំគ្រាន់តែអាចបូមធូលីបាននោះ ។ ខ្ញុំធ្លាប់មានមិត្តភក្តិជាច្រើន តែឥឡូវនេះខ្ញុំមានមិត្តភក្តិតែពីរបីនាក់ប៉ុណ្ណោះ ដោយសារខ្ញុំពុំអាចធ្វើអ្វីៗសម្រាប់ពួកគេដូចកាលពីមុនឡើយ ។

គឺនៅពេលនោះហើយ ដែលខ្ញុំបានចាប់ផ្ដើមធ្វើកិច្ចការពង្សប្រវត្តិរបស់គ្រួសារខ្ញុំម្ដងទៀត ។ កូនស្រីរបស់ខ្ញុំបានចាប់ផ្ដើមស្វែងរកពង្សប្រវត្តិខាងឪពុករបស់នាង ហើយតែមួយល្ងាចប៉ុណ្ណោះបានបញ្ចប់កិច្ចការដែលខ្ញុំចំណាយពេលធ្វើអស់ជាច្រើនឆ្នាំ ។ ខ្ញុំបានបញ្ចប់បួនប្រាំជំនាន់នៅក្នុងផ្នែករបស់ខ្ញុំ ហើយបានបញ្ជូនឈ្មោះទៅកាន់ព្រះវិហារបរិសុទ្ធ ដើម្បីធ្វើកិច្ចការនោះឲ្យបានចប់សព្វគ្រប់ ។ ខ្ញុំចង់ទៅព្រះវិហារបរិសុទ្ធ ហើយធ្វើពិធីទាំងនោះសម្រាប់សមាជិករបស់ខ្ញុំដោយផ្ទាល់ ប៉ុន្តែសុខភាព និង ចម្ងាយផ្លូវទៅព្រះវិហារបរិសុទ្ធមិនអំណោយផលដល់ខ្ញុំឡើយ ។



ខ្ញុំមានអារម្មណ៍បំផុសគំនិតឲ្យរកមើលនៅលើធ្នើ ហើយភ្លាមនោះខ្ញុំបានឃើញថង់មួយ ដែលមើលទៅដូចជាត្រូវបោះចោល ។

បន្ទាប់ពីបញ្ជូនឈ្មោះទាំងនោះហើយ ខ្ញុំបានចាប់ផ្ដើមយំដោយ មានអារម្មណ៍ថា ខ្ញុំបានធ្វើឲ្យសមាជិកគ្រួសាររបស់ខ្ញុំពិបាកចិត្ត ដោយសារខ្ញុំពុំអាចនៅទីនោះជាមួយពួកគេ នៅថ្ងៃធ្វើពិធីបរិសុទ្ធដ៏ពិសេសនោះសម្រាប់ពួកគេ ។ មួយសប្ដាហ៍ក្រោយមក នៅពេលខ្ញុំបានចុះឈ្មោះទៅក្នុងគេហទំព័រ FamilySearch.org ដើម្បីពិនិត្យមើលពីការរីកចម្រើននៃកិច្ចការព្រះវិហារបរិសុទ្ធរបស់ពួកគេ នោះខ្ញុំបានឃើញអ្វីមួយដ៏អស្ចារ្យ ។ មិនត្រឹមតែកិច្ចការទាំងអស់បានធ្វើចប់សព្វគ្រប់ប៉ុណ្ណោះទេ ប៉ុន្តែសមាជិកនៅក្នុងព្រះវិហារបរិសុទ្ធ អាក្រា ហ្គាណា បានធ្វើកិច្ចការទាំងនោះ ! ខ្ញុំមានក្តីរំភើបដោយឃើញសមាជិកនៅផ្នែកម្ខាងទៀតនៃពិភពលោកនេះ បានធ្វើកិច្ចការព្រះវិហារបរិសុទ្ធបានចប់សព្វគ្រប់សម្រាប់គ្រួសារដ៏តូចរបស់ខ្ញុំនេះ ។ ខ្ញុំបានយំជាខ្លាំង ដោយគិតពីការលះបង់របស់ប្រជាជននៅក្នុងប្រទេស ហ្គាណា នៅពេលពួកគេបានធ្វើដំណើរទៅព្រះវិហារបរិសុទ្ធដើម្បីគ្រួសាររបស់ខ្ញុំ ។ ខ្ញុំមានអំណរគុណជាខ្លាំង ចំពោះសមាជិកនៃមណ្ឌលព្រះវិហារបរិសុទ្ធ អាក្រា ហ្គាណា បានធ្វើកិច្ចការដែលខ្ញុំពុំអាចធ្វើវាបាន ៖ គឺចូលទៅព្រះវិហារបរិសុទ្ធ ហើយផ្ដល់ពរជ័យនៃពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធសម្រាប់គ្រួសាររបស់ខ្ញុំ ។ ■

រុបប៊ីន អ៊ីស្តាប្រ៊ូក រដ្ឋ វើរជិនញ៉ា ស.រ.អា.

# ការដោះស្រាយបញ្ហាជាមួយ នឹងការត្រឡប់មក ផ្ទះវិញមុនកំណត់

**ដោយ ដេនី រ៉ូលីន**

ខ្ញុំពុកខ្ញុំមិននៅផ្ទះឡើយដោយសារគាត់ជាប់ធ្វើដំណើរផ្នែកជំនួញ ដូច្នោះមានតែម្ដាយខ្ញុំម្នាក់គត់ដែលបានទៅស្វាគមន៍ខ្ញុំនៅពេលខ្ញុំបានចុះពីយន្តហោះពីបេសកកម្មរបស់ខ្ញុំ ។ គាត់បានឱបខ្ញុំ ហើយពួកយើងបានយំ ។

ខ្ញុំបានធ្វើតេស្តវេជ្ជសាស្ត្រជាច្រើនតាមដែលអាចធ្វើបាន ប៉ុន្តែវេជ្ជបណ្ឌិតពុំអាចស្វែងរកឃើញបញ្ហាអ្វីឡើយ ។ ការដោះស្លាកឈ្មោះអ្នកផ្សព្វផ្សាយសាសនារបស់ខ្ញុំចេញ ប្រាំបួនខែមុនកំណត់គឺជារឿងដ៏លំបាកបំផុតដែលខ្ញុំបានជួប ។ ខ្ញុំមានអារម្មណ៍ថាវាគឺជាភាពបរាជ័យមួយ ដែលខ្ញុំមិនបានបញ្ចប់បេសកកម្ម ។

> **ការត្រឡប់មកពីបេសកកម្មវិញមុនកំណត់ ដោយសារតែហេតុផលសុខភាពក្ដី ក៏អាចជាបទពិសោធន៍មួយដ៏បាក់ទឹកចិត្តខ្លាំងបំផុត ។ វាបានកើតឡើងចំពោះខ្ញុំ ។ ប៉ុន្តែអ្នកអាចធ្វើវាឲ្យរីកចម្រើនទៅមុខ មិនមែនអន់ថយទៅក្រោយឡើយ ។**

## ពិតជាមានន័យណាស់ ដើម្បីធ្វើជាអ្នកផ្សព្វផ្សាយសាសនាមួយរូប

ការធ្វើជាអ្នកផ្សព្វផ្សាយសាសនា គឺជាគោលដៅរបស់ខ្ញុំជានិច្ច ។ ពេលបងប្រុសរបស់ខ្ញុំបានចេញបម្រើបេសកកម្ម នោះខ្ញុំបានស្លៀកពាក់ដោយមានពាក់ស្លាកឈ្មោះដែលធ្វើដោយខ្លួនឯង ដើម្បីលាគាត់នៅប្រលានយន្តហោះ ។ ពេលអាយុបម្រើបេសកកម្មបានផ្លាស់ប្ដូរកាលពីឆ្នាំ ២០១២ នោះខ្ញុំមានអាយុ ១៩ ឆ្នាំ ហើយខ្ញុំបានដឹងថាការប្រកាសនោះគឺជាចម្លើយចំពោះការអធិស្ឋានរបស់ខ្ញុំ ។ ខ្ញុំបានរាំក្នុងបន្ទប់ បំពេញទម្រង់បែបបទបម្រើរបស់ខ្ញុំនៅថ្ងៃនោះ ណាត់ជួបពេទ្យពិនិត្យសុខភាព ហើយបានដាក់បញ្ជូនទម្រង់បែបបទបម្រើរបស់ខ្ញុំនៅក្នុងសប្ដាហ៍នោះតែម្ដង ។ ពីរសប្ដាហ៍ក្រោយមក ខ្ញុំបានទទួលការបម្រើទៅបេសកកម្មកាលីហ្វូញ៉ា អាណាហៀម ហើយត្រូវទៅមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនារយៈពេលពីរខែបន្ទាប់ពីនោះ ។

ពេលខ្ញុំបានទៅក្នុងតំបន់បេសកកម្ម ខ្ញុំមានអារម្មណ៍ « ពុះកញ្ជ្រោល » ធ្វើកិច្ចការនេះ ហើយពុំចង់បង្អង់កិច្ចការនេះឡើយ ។ អ្នកបំពាក់បំប៉នខ្ញុំ និងរូបខ្ញុំពិតជាខិតខំរៀនមេរៀនមួយចំនួនយ៉ាងលឿនដោយសារយើងរំភើបចិត្តដើម្បីបង្រៀនខ្លាំងណាស់ ។ សម្រាប់ខ្ញុំ ការធ្វើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង គឺជារឿងសាមញ្ញបំផុតនៅលើលោកនេះ ។ ជួនកាលខ្ញុំមានការលំបាក និងស្មុគស្មាញ ប៉ុន្តែចំពោះខ្ញុំគ្មានអ្វីដែលអស្ចារ្យជាងការធ្វើជាអ្នកផ្សព្វផ្សាយសាសនាឡើយ ។

អំឡុងពេលប្រាំបីខែនៅក្នុងបេសកកម្មរបស់ខ្ញុំ ដៃគូខ្ញុំ និង រូបខ្ញុំត្រូវជិះកង់ផ្សព្វផ្សាយដោយសារគ្មានឡានគ្រប់គ្រាន់ឡើយ ។ ខ្ញុំខានជិះកង់យូរមកហើយ ហើយពុំដឹងថាជិះកង់ទាំងស្លៀកសំពត់យ៉ាងដូចម្ដេចនោះទេ ប៉ុន្តែខ្ញុំមានក្ដីរំភើបណាស់ ។ ប៉ុន្តែបន្ទាប់ពីពីរបីសប្ដាហ៍ក្រោយមក ខ្ញុំបានចាប់ផ្ដើមឈឺនៅចំហៀងខ្លួនដែលវាឈឺបាត់ៗ ។ ខ្ញុំមិនខ្វល់ខ្វាយនឹងការឈឺចាប់នោះទេ ហើយបន្តខិតខំធ្វើការ ។

ការឈឺនោះបានប្រែកាន់តែញឹកញាប់ ហើយខ្លាំងឡើងៗ រហូតដល់យប់មួយដៃគូរបស់ខ្ញុំបានយកខ្ញុំទៅបន្ទប់សង្គ្រោះបន្ទាន់ ។ ខ្ញុំបានធ្វើតេស្តវេជ្ជសាស្ត្រជាច្រើន ប៉ុន្តែវេជ្ជបណ្ឌិតពុំអាចស្វែងរកឃើញប្រភពនៃការឈឺចាប់នោះឡើយ ។

នៅប៉ុន្មានសប្ដាហ៍ក្រោយមក ខ្ញុំបានអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ ទូលសុំឲ្យការឈឺចាប់នោះបានរសាយបាត់ទៅ ហើយទទួលការប្រសិទ្ធពរបព្វជិតភាពបួនប្រាំដង ប៉ុន្តែវាកាន់តែឈឺខ្លាំងឡើងៗ ។ ខ្ញុំមានការឈឺចាប់គ្រប់ពេលទោះបីដេក ដើរ ឈរ អង្គុយក្ដី ការឈឺចាប់នោះមានជាប់ជានិច្ច ។ ប៉ុន្តែខ្ញុំបានសម្រេចចិត្តថា ខ្ញុំអាចទម្លាប់នឹងការឈឺចាប់នោះ ហើយបន្តធ្វើការទៀត ។




រចនាលម្អរូបថតដោយ ខូលីន លីហ្គើតវ៉ូដ



នាថ្ងៃមួយខ្ញុំបានដួលសន្លប់នៅលើចិញ្ចើមថ្នល់ ហើយពុំអាចធ្វើចលនាអ្វីទៀតបានឡើយ ។ ខ្ញុំត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ដើម្បីធ្វើតេស្តផ្សេងៗ ប៉ុន្តែម្តងនេះនៅតែគ្មានលទ្ធផលអ្វីឡើយ ។ ខ្ញុំបានព្យាយាមសម្រាកបន្តិច ហើយអង្គុយលើកៅអីរង់ចាំរថយន្តក្រុងជាមួយដៃគូខ្ញុំ ហើយបង្រៀនមនុស្សកាលពួកគេកំពុងរង់ចាំឡានក្រុង ។ ខ្ញុំបានអង្គុយរហូតដល់បង្រៀនចប់ ដោយខាំមាត់អត់ទ្រាំនឹងការឈឺចាប់ ។ ទីបំផុតខ្ញុំបានធ្វើឲ្យខ្លួនឯងកាន់តែដុនដាបខ្លាំងឡើង ហើយក្រោយមកខ្ញុំត្រូវបានបញ្ជូនទៅមន្ទីរពេទ្យសារជាថ្មីម្តងទៀត ។ ខ្ញុំបានដឹងថាខ្ញុំអាចធ្វើបាបខ្លួនឯងជាអចិន្ត្រៃយ៍ ប្រសិនបើខ្ញុំបន្តនៅបម្រើបេសកកម្មរបស់ខ្ញុំទៀតនោះ ។ បន្ទាប់ពីអធិស្ឋានជាច្រើនដងមក ខ្ញុំបានទទួលចម្លើយថា ខ្ញុំគួរតែត្រឡប់ទៅផ្ទះវិញ ដើម្បីដោះស្រាយបញ្ហាសុខភាពរបស់ខ្ញុំសិន ។



*ដរាបណាអ្នកព្យាយាមរស់នៅដោយសុចរិតយ៉ាងអស់ពីចិត្ត នោះវាគឺជាជំហាននៃការរីកចម្រើនមួយ ។*

**ជំហាននៃការរីកចម្រើន**

ពេលខ្ញុំបានដឹងថា ខ្ញុំបានមកផ្ទះវិញជារៀងរហូត នោះខ្ញុំមានការបាក់ទឹកចិត្តយ៉ាងខ្លាំង ។ ប៉ុន្តែខ្ញុំបានព្យាយាមអស់ពីសមត្ថភាពរបស់ខ្ញុំ ដើម្បីបន្តសេចក្ដីជំនឿរបស់ខ្ញុំ និង សិក្សាព្រះគម្ពីរ ។ គ្រួសាររបស់ខ្ញុំបានប្រព្រឹត្តិយ៉ាងល្អចំពោះខ្ញុំ ប៉ុន្តែមនុស្សដទៃទៀតដែលនៅជុំវិញខ្ញុំពុំដឹងច្បាស់ ថាតើត្រូវប្រព្រឹត្តិបែបណាចំពោះស្ថានភាពរបស់ខ្ញុំឡើយ ។ ពួកគេបន្តសួរសំណួរខ្ញុំ ហើយខ្ញុំមានការពិបាកនឹងគ្រប់គ្រងអារម្មណ៍សោកសៅរបស់ខ្ញុំណាស់ ។ ប៉ុន្តែ មានបុរសម្នាក់បានទូរសព្ទមកខ្ញុំដោយពុំរំពឹងទុក ហើយបានប្រាប់ខ្ញុំថា កូនប្រុសរបស់គាត់បានត្រឡប់មកផ្ទះវិញមុនកំណត់ពីបេសកកម្មរបស់គាត់យូរយារណាស់មកហើយ ។ គាត់បានប្រាប់ខ្ញុំថា ការសាកល្បងនេះមានសក្តានុពលអាចបំផ្លាញសេចក្តីជំនឿ និង សុភមង្គលរបស់ខ្ញុំបាន ហើយថាជាញយៗវាបំផ្លាញដល់អ្នកត្រឡប់ពីបេសកកម្មមុនកំណត់ជាច្រើននាក់មកហើយ ។ គាត់បាននិយាយថា « អ្វីដែលអ្នកត្រូវចងចាំនោះគឺថា ដរាបណាអ្នកព្យាយាមរស់នៅដោយសុចរិតយ៉ាងអស់ពីចិត្ត នោះវាគឺជាជំហាននៃការរីកចម្រើនមួយ មិនថាមានអ្វីកើតឡើងនោះឡើយ » ។

វាបានក្លាយជាបាវចនារបស់ខ្ញុំ ហើយខ្ញុំបានពឹងផ្អែកលើវាយ៉ាងខ្លាំងសម្រាប់ឆ្នាំបន្ទាប់ទៀត ។ អស់រយៈពេលប្រាំបីខែ ខ្ញុំអាចដើរបានតិចៗ ប៉ុន្តែមនុស្សផ្សេងនៅតែវិនិច្ឆ័យខ្ញុំ ពេលពួកគេបានដឹងថាខ្ញុំបានត្រឡប់មកផ្ទះវិញមុនកំណត់ ។ ពួកគេបាននិយាយថា មានមនុស្សជាច្រើនដែលបានឈឺធ្ងន់ជាងនេះទៀត ប៉ុន្តែពួកគេបានបម្រើរហូតដល់ចប់ ។ ពួកគេពុំយល់ពីមូលហេតុដែលខ្ញុំពុំអាចនៅបន្តរហូតដល់ចប់ឡើយ ទោះបីជាមានជំងឺយ៉ាងណាក្តី ។ ខ្ញុំមានការឈឺចាប់ណាស់ដែលបានឮរឿងនេះ ដោយសារខ្ញុំស្រឡាញ់បេសកកម្មរបស់ខ្ញុំជាខ្លាំង ប៉ុន្តែខ្ញុំមានសេចក្តីជំនឿថា ព្រះវរបិតាសួគ៌មានព្រះរាជបំណងមួយចំពោះការសាកល្បងរបស់ខ្ញុំ ហើយវាអាចជាជំហាននៃការរីកចម្រើន ។

ខ្ញុំបានចាប់ផ្តើមចូលរៀនវិញម្តងទៀត ហើយបានចាប់ផ្តើមដើរលេងជាគូ ។ ខ្ញុំអាចឃើញថាខ្ញុំមានការរីកចម្រើន ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ខ្ញុំមើលទៅបេសកកម្មរបស់ខ្ញុំគឺជារឿងដ៏ជូរចត់មួយជានិច្ច ។ ក្រោយមកមិត្តម្នាក់របស់ខ្ញុំបានរំឭកខ្ញុំថា ដង្វាយធួនរបស់ព្រះអង្គសង្គ្រោះអាចព្យាបាលគ្រប់ការឈឺចាប់ និង ភាពជូរចត់គ្រប់បែបយ៉ាង ។ ដោយមានជំនួយពីទ្រង់ ខ្ញុំអាចសប្បាយចិត្តនៅពេលគិតអំពីបេសកកម្មរបស់ខ្ញុំ ។

ខ្ញុំបានលុតជង្គង់ ហើយអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌របស់ខ្ញុំ ។ ខ្ញុំបានទូលប្រាប់ទ្រង់ពីការឈឺចាប់ និង កិច្ចខិតខំរបស់ខ្ញុំដើម្បីបានជាសះស្បើយ ហើយបានការល្បួងលោម ។ ខ្ញុំបានទូលសុំ ប្រសិនបើទ្រង់អាចដកយកភាពជូរចត់ដែលខ្ញុំបានមានអារម្មណ៍នោះចេញ ។ បន្ទាប់ពីការអធិស្ឋានរបស់ខ្ញុំ ព្រះអម្ចាស់បានធ្វើឲ្យខ្ញុំឃើញពីបេសកកម្មរបស់ខ្ញុំ ដែលចេញមកពីទស្សនវិស័យរបស់ទ្រង់ ។ ទាំងការបម្រើ និង ការត្រឡប់មកផ្ទះវិញមុនកំណត់របស់ខ្ញុំគឺជាផ្នែកមួយនៃផែនការរបស់ព្រះអម្ចាស់ដើម្បីជួយឲ្យខ្ញុំដើរលើផ្លូវដែលទ្រង់មានព្រះទ័យចង់ឲ្យខ្ញុំប្រែក្លាយ ។ ខ្ញុំអាចឃើញអព្ភូតហេតុនានា ដែលទ្រង់បានប្រទានឲ្យ តាំងពីខ្ញុំមកដល់ផ្ទះវិញ ។ វាគឺជាផ្លូវមួយដ៏លំបាក ប៉ុន្តែឥឡូវនេះខ្ញុំអាចក្រឡេកមើលទៅការត្រឡប់មកផ្ទះវិញមុនកំណត់របស់ខ្ញុំទាំងក្តីសុខសាន្ត ដោយដឹងថាព្រះមានព្រះទ័យចង់ថ្វាយអ្វីដែលល្អបំផុតសម្រាប់ខ្ញុំ ។

## សម្រាប់អ្នកត្រឡប់ពីបេសកកម្មវិញ ៖ វិធី ៦យ៉ាងដើម្បីដោះស្រាយនឹងការត្រឡប់មកផ្ទះវិញមុនកំណត់

ការត្រឡប់មកផ្ទះវិញគឺលំបាកណាស់ ប៉ុន្តែដោយមានការខិតខំ នោះអ្នកអាចធ្វើឲ្យការត្រឡប់មកផ្ទះវិញមុនកំណត់របស់អ្នក ក្លាយជាជំហាននៃការរីកចម្រើនដោយកិត្តិយស និង មានប្រយោជន៍ ។ ទាំងនេះគឺជាចំណុចដែលបានជួយខ្ញុំ ៖

**មកឯព្រះគ្រីស្ទ ។** មិនថាមានបញ្ហាអ្វីដែលបណ្ដាលឲ្យអ្នកត្រឡប់មកផ្ទះវិញឡើយ ព្រះគ្រីស្ទអាចជួយអ្នកឲ្យដោះស្រាយវាបាន ។ ដង្វាយធួនគឺមិនគ្រាន់តែសម្រាប់ប្រែចិត្តឡើយ វាក៏សម្រាប់លួងលោម យល់ចិត្ត និង ព្យាបាលផងដែរ ។

**សូមចាំថាវាគឺជាជំហាននៃការរីកចម្រើន ។** ដរាបណាអ្នករស់នៅដោយសក្ដិសមនឹងព្រះវិញ្ញាណ ហើយធ្វើអស់ពីសមត្ថភាពរបស់អ្នក នោះកាលៈទេសៈដែលជាថ្មជំពប់ដួលអាចធ្វើឲ្យអ្នកមានការរីកចម្រើន ។

**បន្តទម្លាប់សិក្សាព្រះគម្ពីរ ។** ព្រះមានបន្ទូលតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលដឹងរឿងផ្សេងទៀត ដោយការសិក្សា និង អនុវត្តខគម្ពីរដោយស្មោះសរ ។ អ្នកអាចឃើញថា ព្រះបានប្រទាននូវជំពូកទាំងមូលដើម្បីឲ្យអ្នកទទួលបានការលួងលោមចិត្ត ។

**បន្តមានភាពមមាញឹក ។** ដំណើរផ្លាស់ប្ដូរពីការដាក់វិន័យតឹងរឹង និង មានភាពមមាញឹកនៃជីវិតជាអ្នកផ្សព្វផ្សាយសាសនា ទៅជាការពុំធ្វើអ្វីសោះ អាចជាពេលទំនេរច្រើនដើម្បីសោកស្ដាយចំពោះខ្លួនឯង និង មានអារម្មណ៍ថាខ្លួនខ្វះចន្លោះ និង កើតទុក្ខ ជាអ្វីមួយដែលសាតាំងចង់បាន ។ ព្រះមានព្រះទ័យចង់ឲ្យអ្នក « ឧស្សាហ៍ចូលរួម » ក្នុងប្រយោជន៍ល្អ ( សូមមើល គ. និង ស. ៥៨:២៧ ) ដោយសារវានឹងជួយអ្នកឲ្យមានភាពរីករាយ ។

**អធិស្ឋានសុំជំនួយ ។** ព្រះវរបិតាសួគ៌កំពុងរង់ចាំជាមួយនឹងពរជ័យនៃការលួងលោម និង ណែនាំ ។ អ្វីទាំងអស់ដែលអ្នកត្រូវធ្វើនោះគឺទូលសុំ ។ ការយកឈ្នះលើការសាកល្បងណាក៏ដោយតម្រូវឲ្យមានជំនួយពីព្រះអម្ចាស់ ។

**សូមគិតថា មនុស្សទូទៅមានបំណងចិត្តល្អ ។** វាងាយនឹងឃើញពីហេតុផលដែលធ្វើឲ្យអាក់អន់ស្រពន់ចិត្ត ដោយមនុស្សដែលពិតជាខ្វល់ខ្វាយអំពីអ្នក ប៉ុន្តែពួកគេពុំអាចដឹងថាតើត្រូវប្រព្រឹត្តិយ៉ាងដូចម្ដេចចំពោះស្ថានភាពរបស់អ្នក ។ ផ្ដោតយកចិត្តទុកដាក់លើមនុស្សដែលចង់ឲ្យអ្នកទទួលបានជោគជ័យ ហើយអភ័យទោសដល់អស់អ្នកដែលវិនិច្ឆ័យអ្នក ។

## សម្រាប់អស់អ្នកដែលស្រឡាញ់ដល់អ្នកដែលត្រឡប់មកផ្ទះមុនកំណត់ ៖ វិធី ៥យ៉ាងដើម្បីជួយអ្នកផ្សព្វផ្សាយសាសនាដែលត្រឡប់មកផ្ទះវិញមុនកំណត់

នៅពេលខ្ញុំបានមកដល់ផ្ទះវិញ ខ្ញុំបានឃើញថា មនុស្សពុំបានដឹងថាតើត្រូវប្រព្រឹត្តិយ៉ាងដូចម្ដេចចំពោះខ្ញុំឡើយ ។ នេះគឺជាយោបល់មួយចំនួនដែលខ្ញុំចង់ឲ្យមនុស្សទូទៅបានដឹង ៖

**សូមកុំវិនិច្ឆ័យឡើយ ។** អ្នកដែលត្រឡប់មកផ្ទះវិញមុនកំណត់ កំពុងនៅក្នុងដំណើរការមួយនៃការព្យាបាល ឬ កែលម្អអ្វីមួយ មិនថាជាបញ្ហាមកពីរូបកាយ គំនិត ស្មារតី ឬ សូម្បីតែគ្រួសាររបស់ពួកគេឡើយ ។ សូមមានចិត្តសប្បុរសចំពោះអស់អ្នកដែលកំពុងព្យាយាម និង ពុះពារ ។

**ឈប់សួរសំណួរផ្សេងៗ ។** ពិតណាស់វាជាការល្អដែលមានមនុស្សខ្វល់ខ្វាយដោយចិត្តស្មោះសរចំពោះយើង តែការសួរសំណួរផ្ទាល់ខ្លួនមួយចំនួនអាចបណ្ដាលឲ្យមានការឈឺចាប់ ។ ទោះបីជាអ្នកមានបំណងល្អក្តី សូមកុំជជីកសួរដល់អ្នកផ្សព្វផ្សាយសាសនាដែលត្រឡប់មកផ្ទះវិញមុនកំណត់ឡើយ ។ សូមបង្ហាញសេចក្ដីស្រឡាញ់របស់អ្នកតាមរយៈការគាំទ្រដ៏សប្បុរសផ្សេងទៀត ។

**ជួយពួកគេឲ្យបន្តមានភាពមមាញឹក ។** វាមានការលំបាកដើម្បីកែលម្រួលពីកិច្ចការ និង សកម្មភាពនៃបេសកកម្មទៅជាពេលវេលាដែលទំនេរជាងមុន និង មានជម្រើសថ្មីនៅផ្ទះ ។ ជួយពួកគេឲ្យស្វែងរកអ្វីដែលជាកិច្ចការសកម្ម សប្បាយរីករាយ និង កម្សាន្តដើម្បីធ្វើ ។



**ទុកឲ្យពួកគេទទួលវិវរណៈផ្ទាល់ខ្លួនពួកគេ ។** ទោះបីជា អ្នកផ្សព្វផ្សាយសាសនាជ្រើសត្រឡប់ទៅបម្រើវិញ ឬ មិនទៅវិញក្តី វាគឺជារឿងរវាងពួកគេនឹងព្រះវរបិតាសួគ៌ ។ សូមលើកទឹកចិត្តពួកគេឲ្យស្វែងរកព្រះឱវាទសួគ៌ា ហើយទុកចិត្តពួកគេឲ្យទទួលចម្លើយផ្ទាល់របស់ខ្លួន ។

**ធ្វើជាមិត្តភក្តិនឹងពួកគេ ។** ភាគច្រើន វានឹងក្លាយជាការសាកល្បងមួយដ៏លំបាកបំផុតនៅក្នុងជីវិតរបស់អ្នកផ្សព្វផ្សាយសាសនាដែលត្រឡប់មកផ្ទះវិញមុនកំណត់ ។ ពួកគេជាច្រើននឹងមានមន្ទិលសង្ស័យចំពោះជំនឿរបស់ខ្លួន ។ នោះពុំមែនមានន័យថាពួកគេមិនអាចសប្បាយរីករាយ ឬ រីកចម្រើនឡើយ ប៉ុន្តែពួកគេត្រូវការមិត្តម្នាក់ដែលមានឆន្ទៈស្រឡាញ់ពួកគេដោយឥតលក្ខខណ្ឌ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*

# បន្តរឹងប៉ឹងនៅក្នុង ប្រទេសបារាំង

**ដោយ មីនឌី អាន សេលូ**
ទស្សនាវដ្ដីសាសនាចក្រ

ការបំពាក់បំប៉នធ្វើជាអ្នកបើកឧទ្ធម្ភាគចក្រគឺជាឱកាសដ៏កម្របំផុតសម្រាប់មនុស្សទូទៅ ។ ប៉ុន្តែនៅពេលផ្ទៃ អូ អាយុ ២៤ ឆ្នាំ បានសម្រេចចិត្តទៅចុះឈ្មោះបម្រើកងទ័ពបារាំង គាត់បានទទួលឱកាសនោះ ។ ឥឡូវនេះនៅក្នុងឆ្នាំទីពីររបស់គាត់នៃការបំពាក់បំប៉នបួនឆ្នាំ ផ្ទៃ កំពុងតែប្រឹងអស់ពីសមត្ថភាពរបស់ខ្លួន ដើម្បីរស់នៅធ្វើជាគំរូមួយនៃពួកអ្នកជឿ ទោះបីជាបរិយាកាសជុំវិញខ្លួនរបស់គាត់យ៉ាងណាក៏ដោយ ។

ដោយត្រូវឈរជើងនៅក្នុងស្ថានីយមួយកន្លែងដែលត្រូវចំណាយពេលប្រហែលជាមួយម៉ោងកន្លះពីទីក្រុង បរដូរ នៅភាគនិរតី ប្រទេសបារាំង ផ្ទៃនៅឆ្ងាយពីមិត្តភក្តិ គ្រួសារ និង ស្រុកកំណើតខ្លួននៅ វិនណៃស ។ សាលាប្រជុំដែលនៅជិតបំផុតគឺមានចម្ងាយផ្លូវមួយម៉ោង នោះមានន័យថា គាត់ពុំសូវមានទំនាក់ទំនងច្រើនឡើយជាមួយសមាជិកអំឡុងពេលនៃសប្ដាហ៍ ។ ផ្ទៃ និយាយថា « វាគ្មានភាពងាយស្រួលសោះដើម្បីធ្វើជាសមាជិកសាសនាចក្រនៅក្នុងជួរកងទ័ព ដោយសារមានការល្បួងជាច្រើន ហើយពិតណាស់វាគឺជាពិភពពីរផ្សេងគ្នា ។ អ្នកត្រូវបានគេវិនិច្ឆ័យជាច្រើននៅក្នុងជួរកងទ័ព ដោយមិនផ្អែកលើអ្វីដែលអ្នកធ្វើឡើយ ប៉ុន្តែផ្អែកលើបុគ្គលិកលក្ខណៈរបស់ខ្លួនអ្នក » ។ ផ្ទៃចង់ឲ្យអស់អ្នកដែលនៅជុំវិញខ្លួនគាត់ឃើញថា គាត់ពុំផឹងគ្រឿងស្រវឹង ជក់ថ្នាំជក់ មើលការណ៍អាសគ្រាម ឬ ចូលរួមពិធីជប់លៀងឡើយ — ជាសកម្មភាពដែលគេធ្វើច្រើនបំផុតនៅក្នុងជួរកងទ័ព — ដោយសារគាត់គឺជា ៖ សមាជិកសាសនាចក្រ ។ អំឡុងពេលគាត់ពុះពារ ដើម្បីឲ្យអស់អ្នកដែលនៅជុំវិញគាត់គោរពដល់គាត់ នោះការអធិស្ឋាន និង ការសិក្សាព្រះគម្ពីរជួយរក្សាឲ្យទីបន្ទាល់របស់គាត់មានភាពរឹងប៉ឹង ។ គាត់បានពន្យល់ថា « ខ្ញុំមិនចូលដេកឡើយប្រសិនបើខ្ញុំមិនបានអានព្រះគម្ពីរជាមុនសិននោះ ហើយខ្ញុំព្យាយាមអធិស្ឋាននៅគ្រប់ពេលដែលខ្ញុំអាចអធិស្ឋានបាន » ។

ផ្ទៃ ពន្យល់ថា « ការអានព្រះគម្ពីរ និង ការអធិស្ឋានបានជួយខ្ញុំយ៉ាងខ្លាំងអំឡុងពេលសិក្សារបស់ខ្ញុំ ដើម្បីដឹងថា ព្រះមានពិតមែន ថាទ្រង់គង់នៅឋានសួគ៌ — ទោះបីជាគាត់ពុំទាន់យល់អស់នូវដំណឹងល្អក្ដី ។ ខ្ញុំគ្រាន់តែដឹងថាព្រះពិតជាគង់នៅទីនោះ ការណ៍នេះធ្វើឲ្យខ្ញុំបន្តដើរនៅលើផ្លូវត្រូវ » ។

មូលដ្ឋានគ្រឹះនៃការសិក្សាព្រះគម្ពីរនោះហើយដែលបានជួយ ផ្ទៃឲ្យហែលឆ្លងកាត់ថ្នាក់រៀនទាំងអស់របស់គាត់ ហើយសូម្បីតែឥឡូវនេះជួយគាត់ឲ្យឆ្លងកាត់ការបំពាក់បំប៉នជាកងទ័ព ។ ពីមុនចុះឈ្មោះបម្រើកងទ័ព ផ្ទៃ បានបម្រើបេសកកម្មនៅក្នុងទីក្រុងម៉ុនត្រេល ហ្គូប៊ែក ប្រទេសកាណាដា នៅទីនោះទីបន្ទាល់ និង ការយល់ដឹងរបស់គាត់អំពីដំណឹងល្អបានរឹងមាំឡើង ។

**នៅក្នុងនាមជាសមាជិកនៃសាសនាចក្រនៅក្នុងជួរកងទ័ពបារាំង ផ្ទៃ ពឹងផ្អែកលើការអធិស្ឋាន និង ការសិក្សាព្រះគម្ពីរ ដើម្បីធ្វើជាគំរូនៃសេចក្ដីជំនឿរបស់គាត់ ។**

គាត់និយាយថា « ព្រះគម្ពីរគឺជាមធ្យោបាយដ៏ជាក់ស្ដែងបំផុតដែលព្រះវរបិតាសួគ៌ឆ្លើយសំណួរមកកាន់យើង » ។

តាមរយៈការអធិស្ឋាន និង ការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន ផ្ទៃមិនត្រឹមតែទទួលបានការបំផុសគំនិតប៉ុណ្ណោះទេ ប៉ុន្តែការធ្វើបែបនេះក៏ជាគំរូមួយដល់អស់អ្នកដែលនៅជុំវិញគាត់នៅក្នុងអង្គភាពកងទ័ពរបស់គាត់ផងដែរ ។ ដោយសារតែគាត់ និង មិត្តភក្តិរួមថ្នាក់របស់គាត់គ្មានអ្វីដែលដូចគ្នា ក្រៅពីពានរង្វាន់ថ្នាក់ជាតិ នោះផ្ទៃដឹងថា តាមរយៈការធ្វើតាមការបង្រៀននៃព្រះគម្ពីរនោះគាត់អាចក្លាយជាមនុស្សម្នាក់ដែលពួកគេអាចគោរពដោយសារជំនឿរបស់គាត់ ហើយពុំមែនមិនគោរពដោយសារសេចក្ដីជំនឿរបស់គាត់ឡើយ ។ ■

## ព័ត៌មានបន្ថែមអំពី ផ្ទៃ

***តើអ្នកចូលចិត្តបរិភោគអ្វីខ្លះ ?***

ខ្ញុំចូលចិត្តម្ហូប ប្រេតុង ( ម្ហូបម្យ៉ាងដូចជានំពុម្ពដែលមានប្រភពដើមមកពីប្រទេសបារាំងភាគខាងលិច ) ។ ខ្ញុំក៏ចូលចិត្តនំប៉ុង ធីស សាច់ក្រក និង សាច់ចិញ្ច្រាំ ។

***តើអ្នកធ្វើអ្វីខ្លះនៅពេលទំនេរ ?***

ខ្ញុំចូលចិត្តដើរលេងជាមួយមិត្តរបស់ខ្ញុំ ។ ពេលខ្លះយើងគ្រាន់តែទៅបរិភោគអាហារ ហើយជជែកគ្នាលេង ។ ខ្ញុំចូលចិត្តដើរទិញឥវ៉ាន់ជាមួយភរិយារបស់ខ្ញុំ ឬ ទៅមើលខ្សែភាពយន្ត ។ ខ្ញុំក៏ចូលចិត្តអានអត្ថបទអំពីកីឡា ហើយក៏លេងកីឡាផងដែរ ។ ជាពិសេសខ្ញុំក៏ចូលចិត្តរត់ និង ហែលទឹក ។

***តើការណាត់ជួបជាគូមានលក្ខណៈយ៉ាងដូចម្ដេចដែរនៅក្នុងប្រទេសបារាំង ?***

វាមានការលំបាកណាស់ដើម្បីដើរលេងជាមួយនារីម្នាក់ដែលចាត់ទុកត្រឹមតែជាមិត្តនោះ លុះត្រាតែនារីនោះយល់ពីរបៀបដែលមនុស្សនៅសហរដ្ឋណាត់ជួបជាគូ ៖ ការដើរលេងជាមួយគ្នាគឺដើម្បីស្គាល់ ហើយក្លាយជាមិត្ត ។ ថ្នាក់ដឹកនាំសាសនាចក្រព្យាយាមបង្កើតសកម្មភាពយុវមជ្ឈិមវ័យជាច្រើនដោយសារវាធ្វើឲ្យពួកយើងជួបគ្នា ហើយមានការណាត់ជួបជាគូដ៏ធំមួយ — ហើយនោះគឺជារបៀបដែលភរិយាខ្ញុំ និង រូបខ្ញុំបានជួបគ្នា ។

## សាសនាចក្រនៅក្នុងប្រទេសបារាំង

ពួកបរិសុទ្ធថ្ងៃចុងក្រោយ ៣៧៨១២ នាក់
វួដ និង សាខា ១០៧
មជ្ឈមណ្ឌលពង្សប្រវត្តិ ៦៧ កន្លែង
បេសកកម្ម ២
ព្រះវិហារបរិសុទ្ធ ១ ( កំពុងសាងសង់ )

## ប្រទេសបារាំង ៖ ចំនួនជាតួលេខ

ប្រជាជន ៦៦ លាននាក់ ( ការប៉ាន់ប្រមាណគិតត្រឹមឆ្នាំ ២០១៥ )
អគារស្រស់ប្រណិត ៤០០០០ ( ប្រាសាទបុរាណ គេហដ្ឋានស្តុកស្តម វាំង )
ភ្ញៀវទេសចរណ៍ ៨០ លាននាក់ទស្សនាប្រទេសបារាំងរៀងរាល់ឆ្នាំ — គឺជាប្រទេសដែលមានភ្ញៀវទេសចរណ៍ច្រើនជាងគេបំផុតនៅលើពិភពលោក ។








ចម្លើយមកពីថ្នាក់ដឹកនាំនៃសាសនាចក្រ



ដោយ អែលឌើរ
រ៉ូណល អេ រ៉ាសបាន
ក្នុងកូរ៉ុមនៃពួកសាវក
ដប់ពីរនាក់

# របៀប ទទួលបាននូវពរជ័យ នៃព្រះវិហារបរិសុទ្ធ

ព្រះវិហារបរិសុទ្ធគឺជាដំណាក់របស់ព្រះអម្ចាស់ ជាកន្លែងដែលការបង្រៀនរបស់ព្រះអង្គសង្គ្រោះរបស់យើងត្រូវបានបញ្ជាក់ជាថ្មីតាមរយៈពិធីបរិសុទ្ធពិសិដ្ឋនានា ដូចជាបុណ្យជ្រមុជទឹក និង អាពាហ៍ពិពាហ៍សម្រាប់មរណជន ដែលចងភ្ជាប់ក្រុមគ្រួសារអស់កល្បជានិច្ច ។

ខ្ញុំផ្តល់អនុសាសន៍ដល់អ្នកថា ការថ្វាយបង្គំនៅព្រះវិហារបរិសុទ្ធគឺជាលំនាំសំខាន់មួយដែលយើងម្នាក់ៗត្រូវដាក់គោលដៅ — ផ្ទាល់ខ្លួន និង ជាគ្រួសារ — នៅពេលអ្នកពិចារណាពីការផ្តោតចិត្ត និង ការយកចិត្តទុកដាក់លើខ្លួនអ្នក នៅពេលអ្នក ដាក់គ្រឹះយ៉ាងរឹងមាំនៅក្នុងជីវិតផ្ទាល់របស់អ្នក ។ ខ្ញុំដឹងថាអ្នកទាំងអស់គ្នាភាគច្រើនបានធ្វើកិច្ចការនេះហើយ ហើយដោយសារកិច្ចការនេះយើងមានអំណរគុណចំពោះអ្នកជាខ្លាំង ។

គណៈប្រធានទីមួយបានចេញនូវការអញ្ជើញមួយដល់សមាជិកទាំងអស់នៃសាសនាចក្រ ដែលវាពិតជាអនុវត្តចំពោះអ្នក និង រូបខ្ញុំ ៖ « នៅពេលណា និង កាលៈទេសៈណាដែលអំណោយផល សមាជិកត្រូវបានលើកទឹកចិត្តឲ្យ ធ្វើកិច្ចការបម្រើនៅក្នុងព្រះវិហារបរិសុទ្ធជាជាងទៅធ្វើសកម្មភាពកម្សាន្តមួយចំនួន » ។

យើងក៏គប្បី ពិចារណាពីពរជ័យដែលបានសន្យា ដោយព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈនៅពេលយើងស្មោះត្រង់ក្នុងការចូលរួមព្រះវិហារបរិសុទ្ធ ។ ប្រធាន ថូម៉ាស អេស ម៉នសុន បានសន្យា ៖ « ចូរមកព្រះវិហារបរិសុទ្ធ ហើយទម្លាក់បន្ទុករបស់អ្នកនៅចំពោះព្រះភ័ក្រព្រះអម្ចាស់ ហើយអ្នកនឹង ពោរពេញដោយស្មារតី និង ទំនុកចិត្តថ្មីនាពេលអនាគត ។ ចូរទុកចិត្តលើព្រះអម្ចាស់ ហើយប្រសិនបើអ្នកធ្វើដូច្នោះ នោះទ្រង់នឹងឱបក្រសោប និង បីត្រកងអ្នក ហើយដឹកនាំអ្នកមួយជំហានម្តងៗឲ្យដើរនៅលើផ្លូវនោះ ដែលនាំទៅរកនគរសេឡេស្ទាលនៃព្រះ » ។[១]

ពរជ័យនៃការលួងលោមមួយផ្សេងទៀតនៃការថ្វាយបង្គំក្នុងព្រះវិហារបរិសុទ្ធ គឺជាការធានាអះអាងនៃការការពារ និង ភាពសុខសាន្តពីព្យុះដែលបោកបក់មកលើយើងនាសម័យនេះ ។ កន្លែងសុវត្ថិភាពមួយចំនួនដែលព្រះវរបិតាសួគ៌បានបង្កើតឡើងសម្រាប់ប្រមូលផ្តុំប្រជារាស្ត្ររបស់ទ្រង់នោះគឺក្នុងព្រះវិហារបរិសុទ្ធនៃព្រះអម្ចាស់ ។

ឃ្លាមួយនៅគ្រប់ជញ្ជាំងខាងក្រៅព្រះវិហារបរិសុទ្ធទាំងអស់មានសរសេរ ៖ « បរិសុទ្ធដល់ព្រះអម្ចាស់/ដំណាក់នៃព្រះអម្ចាស់ » ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថាព្រះវិហារបរិសុទ្ធទាំងអស់នៃព្រះអម្ចាស់គឺជាដំណាក់ដ៏ឧដុងឧត្តមរបស់ទ្រង់នៅលើផែនដីនេះ ។ ខ្ញុំសូមអញ្ជើញអ្នកទាំងអស់គ្នាឲ្យ ចូលរួមកាន់តែញឹកញាប់ ទៅតាមកាលៈទេសៈអំណោយផលដល់អ្នក ហើយ ទទួលយកពរជ័យ និង ការការពាររបស់ខ្លួន ដែលបានសន្យាដល់អ្នកដោយព្យាការីរបស់ព្រះ ។ ■

*ដកស្រង់ចេញពីសុន្ទរកថានៃការប្រជុំធម្មនិដ្ឋានដែលបានថ្លែងនៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់ ប្រព្រឹត្តិទៅនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ។ សម្រាប់អត្ថបទទាំងមូលជាភាសាអង់គ្លេស សូមចូលទៅកាន់គេហទំព័រ speeches.byu.edu។*



រូបថតបន្ទប់សេឡេស្ទាលនៅក្នុងព្រះវិហារបរិសុទ្ធ គិលបឺត អារីហ្សូណា ។

## តើអ្នកបានអនុវត្តគោលការណ៍នេះដោយរបៀបណា ?

អ្វីមួយដែលជួយខ្ញុំជាខ្លាំងថាព្រះវិហារបរិសុទ្ធគឺជាដំណាក់របស់ព្រះអម្ចាស់នៅក្នុងចិត្តខ្ញុំ នោះគឺជាភាពសុខសាន្តដែលខ្ញុំបានទទួលគ្រប់ពេលដែលខ្ញុំទៅព្រះវិហារបរិសុទ្ធ ។ ដោយសារគ្រួសាររបស់ខ្ញុំនៅក្នុងជួរកងទ័ព នោះខ្ញុំបានទៅព្រះវិហារបរិសុទ្ធជាច្រើននៅជុំវិញពិភពលោក ហើយមានអារម្មណ៍ — នៃភាពសុខសាន្ត ការលួងលោម និង ព្រះវិញ្ញាណដូចគ្នាគ្រប់ព្រះវិហារបរិសុទ្ធទាំងនោះ ។ ភាពសុខសាន្តនៃព្រះវិហារបរិសុទ្ធបានជួយខ្ញុំឲ្យយល់កាន់តែច្បាស់ថែមទៀតពីតួនាទីរបស់ខ្ញុំនៅក្នុងជីវិតនេះ និង របៀបកែប្រែជីវិតរបស់ខ្ញុំឲ្យបានកាន់តែប្រសើរឡើង ។ វាក៏បានបង្កើននូវសមត្ថភាពរបស់ខ្ញុំដើម្បីដោះស្រាយនឹងភាពតានតឹងនៃជីវិតប្រចាំថ្ងៃនេះ ។

ជែននីសឺ ប៊ី រដ្ឋ យូថាហ៍ ស.រ.អា.

កំណត់ចំណាំ

១. ថូម៉ាស អេស ម៉នសុន បានដកស្រង់នៅក្នុង ឌែល វ៉ាន អ័ឌិន « San Diego Temple: 45th House of the Lord Dedicated in ‹ Season for Temple Building › » *Church News*, ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ១៩៩៣ ទំព័រ ១២ ។

# ចំទៅនឹងគោលដៅ

**ហេតុអ្វីព្រះបានប្រទាននូវ អារម្មណ៍ប្រតិព័ទ្ធ រវាងគ្នា នឹងគ្នាដល់យើង អស់ពេល ជាយូរ ពីមុនយើង រៀបការ ជាមួយ គ្នា?**

ពិតណាស់ អារម្មណ៍នៃការប្រតិព័ទ្ធគឺមិនអាក្រក់ឡើយ ហើយទីបំផុតវាគឺជាគោលបំណងដ៏ទេវភាពនៅក្នុងអាពាហ៍ពិពាហ៍ ។ ប៉ុន្តែ ហេតុអ្វីបានជាយើងមានអារម្មណ៍ទាំងនេះ អស់រយៈពេលជាច្រើនឆ្នាំពីមុនយើងអាចប្រព្រឹត្តិវាដោយសមរម្យនោះ ?

មែនហើយ ជីវិតនេះគឺជាការសាកល្បងនូវការគោរពប្រតិបត្តិតាម ហើយច្បាប់ព្រហ្មចារីភាពគឺជាច្បាប់ដ៏សំខាន់បំផុតដើម្បីគោរពតាម ។ ការសាកល្បងនេះកាន់តែពិបាកឡើងៗ បន្ទាប់ពីមានភាពពេញវ័យ នៅពេលអ័រម៉ូន ( និង វប្បធម៌ដែលអនុមតិខាងផ្លូវភេទ ) កំពុងជំរុញពួកយើងថា « ប្រព្រឹត្តិតាមអារម្មណ៍ទាំងនោះទៅ » ប៉ុន្តែ ពន្លឺនៃព្រះគ្រីស្ទ និង ព្រះវិញ្ញាណបរិសុទ្ធ ( ព្រមទាំងព្រះគម្ពីរ ព្យាការី ឪពុកម្ដាយ និង ថ្នាក់ដឹកនាំ ) កំពុងប្រាប់យើងឲ្យ « ចូររង់ចាំសិន » ។ នៅពេលយើងស្ដាប់តាមសារលិខិតថាឲ្យរង់ចាំសិន នោះយើងបង្ហាញពីភាពសក្ដិសមរបស់យើង ហើយបង្ហាញពីភាពចាស់ទុំ និង វិន័យនៃសីលធម៌របស់យើង ដែលជា « ការអនុវត្តជាប់ជានិច្ចនូវសិទ្ធិសេរីភាពជ្រើសរើសត្រឹមត្រូវដោយសារវាជារឿងត្រឹមត្រូវ ទោះបីជាវាលំបាកក្ដី » ( ឌី ថត គ្រីស្ដូហ្វឺសិន « Moral Discipline » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ១០៥ ) ។

ដូចជាការសាកល្បងជាច្រើននៅក្នុងជីវិតនេះ ការសាកល្បងនេះធ្វើឲ្យយើងបង្ហាញថាខ្លួនយើងសក្ដិសម នឹងពរជ័យដ៏អស្ចារ្យដែលកើតមានឡើង — រួមមានការផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធសម្រាប់ពេលនេះ និង និង ពេលដ៏អស់កល្បជានិច្ច ។ ■



**ហេតុអ្វី អព្ភូតហេតុ ពុំកើតមានឡើង សព្វថ្ងៃនេះ ដូច វាបានកើតឡើងកាលនៅ សម័យព្រះគ្រីស្ទ?**

អព្ភូតហេតុរបស់ព្រះអង្គសង្គ្រោះគឺជា « សកម្មភាពដ៏ទេវភាព » ព្រមទាំងជា « ផ្នែកនៃការបង្រៀនដ៏ទេវភាព » ( Bible Dictionary « Miracles » ) ។ ការជាសះស្បើយ និង អព្ភូតហេតុផ្សេងទៀតមាននៅក្នុងសាសនាចក្រសព្វថ្ងៃនេះ ទោះបីជាអព្ភូតហេតុទាំងនោះវាមិនជារឿងរំភើប និង និយាយដោយមហាជនជានិច្ចក្ដី នោះគឺដោយសារអស់អ្នកដែលមានបទពិសោធន៍ទាំងនោះចាត់ទុកថាអព្ភូតហេតុនោះពិសិដ្ឋ ។ អ្នកអាចស្វែងរកអព្ភូតហេតុនានានៅក្នុងជីវិតរបស់អ្នក ឬ សមាជិកគ្រួសាររបស់អ្នក ឬ ជីដូនជីតារបស់អ្នក ។ ទោះបីជាយើងមានបំណងចង់បានអព្ភូតហេតុក្ដី យើងគប្បីចាំថាព្រះវរបិតាសួគ៌ឆ្លើយតបមកយើង តាមពេលវេលា និង តាមរបៀបរបស់ទ្រង់ ។

អព្ភូតហេតុគឺជាផ្នែកនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ វាគឺជាទីសម្គាល់មួយថា សេចក្ដីជំនឿគឺមាននៅលើផែនដីនេះ ( សូមមើល អេធើរ ១២:១២ ) ហើយវាគឺជាអំណោយទាននៃព្រះវិញ្ញាណ ( សូមមើល គ. និង ស. ៤៦:២១ ) ។ ■

# សម្ពាធពីមិត្តភក្តិពីភ័ស្តូ

*ទីបំផុតខ្ញុំបានទៅពិធីជប់លៀងមួយជាមួយមិត្តភក្តិទាំងអស់របស់ខ្ញុំ ប៉ុន្តែពួកគេទាំងអស់គ្នាផឹកគ្រឿងស្រវឹង ។*





**មិត្តភក្តិដ៏ល្អគឺសំខាន់ណាស់**

« ចូររាប់អានអស់អ្នកដែលដូចជាខ្លួនអ្នក ដែលកំពុងដាក់ផែនការសម្រាប់កិច្ចការដែលមានសារៈសំខាន់បំផុត — គឺគោលដៅអស់កល្បជានិច្ច » ។

ប្រធាន ថូម៉ាស អេស ម៉នសុន « **Decisions Determine Destiny** » ( ការប្រជុំធម្មនិដ្ឋានសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ) ទំព័រ ៤ **speeches.byu.edu** ។

**ដោយ គីអារ៉ា ប្លែនកូ**

កាលខ្ញុំអាយុ ១២ ឆ្នាំ មានស្រីៗនៅក្នុងសាលាថ្មីរបស់ខ្ញុំបានអញ្ជើញខ្ញុំទៅពិធីជប់លៀងខួបកំណើត ។ វាគឺជាពិធីជប់លៀងដំបូងជាមួយមិត្តភក្តិនៅសាលាដែលពួកគេបានអញ្ជើញខ្ញុំ ។ ពេលខ្ញុំបានសុំឪពុកម្ដាយខ្ញុំប្រសិនបើខ្ញុំអាចទៅពិធីជប់លៀងនោះ ពួកលោកបានឆ្លើយថា មិនឲ្យខ្ញុំទៅឡើយ ដោយសារពិធីជប់លៀងនោះចាប់ផ្ដើមយប់ពេក ។

មិនយូរប៉ុន្មានក្រោយមក ខ្ញុំបានទទួលការអញ្ជើញមួយផ្សេងទៀត ។ ខ្ញុំបានសុំឪពុកម្ដាយខ្ញុំម្ដងទៀត ប៉ុន្តែពួកគេបានបដិសេធម្ដងទៀត ហើយខ្ញុំខឹងនឹងពួកគាត់ ។ តើខ្ញុំពុំអាចមានភាពសប្បាយខ្លះទេឬ ?

បន្ទាប់មកមានមិត្តភក្តិស្និទ្ធស្នាលខ្ញុំម្នាក់បានរៀបចំពិធីជប់លៀងមួយ ។ ខ្ញុំគឺជាមនុស្សដំបូងគេដែលនាងបានអញ្ជើញ ។ ពិធីជប់លៀងនោះចាប់ផ្ដើមមុនម៉ោងជាងពិធីជប់លៀងផ្សេងទៀត ។ វាជាពិធីជប់លៀងឯកជនមួយ ហើយធ្វើឡើងនៅក្បែរផ្ទះរបស់ខ្ញុំ ។ ខ្ញុំបានសុំការអនុញ្ញាតពីឪពុកម្ដាយខ្ញុំទៅចូលរួម ហើយពួកលោកបានយល់ព្រម ។ ខ្ញុំរំភើបខ្លាំងណាស់ !

ថ្ងៃនោះបានមកដល់ ។ នៅពេលឪពុកម្ដាយរបស់ខ្ញុំបានដឹកខ្ញុំទៅទីនោះ ពួកគាត់បាននិយាយថា ពួកគាត់នឹងមកទទួលខ្ញុំនៅម៉ោង ១០ យប់ នៅពេលខ្ញុំទៅពិធីជប់លៀងនោះ ខ្ញុំបានឃើញមិត្តស្រីៗរបស់ខ្ញុំ ។ ម្ភៃនាទីក្រោយមក ខ្ញុំនៅតែមិនទាន់ឃើញយុវនារីដែលជាម្ចាស់ខួបកំណើតនោះសោះ ។

មួយសន្ទុះក្រោយមក យុវជនម្នាក់បានដើរមករកពួកយើង ហើយសួរថា « តើអ្នកនាងបានយកប្រាក់មកទិញ *ភីស្តូ*ទេ ? » គាត់ធ្វើសញ្ញាមួយដែលធ្វើឲ្យខ្ញុំដឹងថា « ភីស្តូ » នោះគឺជាស្រាបៀរ ។ មិត្តស្រីៗរបស់ខ្ញុំនោះបានបង់ប្រាក់ឲ្យគាត់ ។ ខ្ញុំគ្មានប្រាក់ឡើយ ដូច្នោះខ្ញុំបានសម្រេចចិត្តដើរទៅជាមួយយុវនារីផ្សេងទៀត ខណៈដែលពួកគេទាំងនេះកំពុងទិញស្រាបៀរផឹក ។

ទីបំផុត យុវនារីដែលជាម្ចាស់ខួបកំណើតនោះបានមកដល់—គឺមួយម៉ោងក្រោយមក ។ ខ្ញុំបានជូនពរដល់នាង ហើយខណៈដែលយើងកំពុងជជែកគ្នានោះ មានឡានធំមួយបានបើកមកដល់ ។ បុរសប្រាំនាក់បានចុះពីឡាន ហើយដាក់ស្រាបៀរពីរធុងចុះពីឡាន ។ មនុស្សគ្រប់គ្នាបានទៅរោមជុំទីនោះ ហើយចាប់ផ្ដើមចែកស្រាបៀរគ្នាផឹក ។ មិត្តស្រីៗរបស់ខ្ញុំបានចេញទៅយកស្រាបៀរនោះ ហើយខ្ញុំនៅតែឯង មើលពួកយុវវ័យទាំងនោះប្រជ្រៀតគ្នាទៅយកស្រាបៀរផឹក ។

មិត្តស្រីៗរបស់ខ្ញុំបានដើរមករកខ្ញុំ ហើយឲ្យស្រាបៀរខ្ញុំផឹក ។ ខ្ញុំបានប្រាប់ពួកគេថា « អត់ទេ អរគុណហើយ » ។ ពួកគេបានទទូចឲ្យខ្ញុំផឹកម្ដងទៀត ។ ខ្ញុំនិយាយថា អត់ទេ ជាថ្មីម្ដងទៀត ។ បេះដូងខ្ញុំបានចាប់ផ្ដើមលោតខុសចង្វាក់ ហើយខ្ញុំមានអារម្មណ៍ថាចម្លែក គឺដូចជានៅក្នុងខ្សែភាពយន្តដ៏ថប់បារម្ភមួយ ដែលមានខ្ញុំគឺជាតួឯក ហើយខ្ញុំត្រូវបានជាប់អន្ទាក់នៅកន្លែងដ៏ចម្លែក ។ បន្ទាប់មកខ្ញុំបានស្ដាប់ឮសម្លេងឡានសីផ្លេរ—គឺជាឪពុកម្ដាយរបស់ខ្ញុំ ! ខ្ញុំបានចេញទៅដោយលើកដៃលាពួកគេ ហើយបានរត់ទៅកាន់ឡាន ។

ខ្ញុំបានចូលក្នុងឡាន ហើយដកដង្ហើមទាំងថប់បារម្ភ ។ ខ្ញុំបានចាប់ផ្ដើមគិតពីបរិយាកាសដ៏តឹងតែងមួយដែលខ្ញុំបានមាននៅទីនោះ ។ ម្ដាយខ្ញុំបានសួរថាតើខ្ញុំមានកើតអ្វីទេ ។ ខ្ញុំបានតបថា « ចាស៎ ម៉ាក់ ប៉ុន្តែមានអ្វីមួយធ្វើឲ្យខ្ញុំមានការភ្ញាក់ផ្អើល » ។

ឪពុកខ្ញុំបានសួរថា « តើមានអ្វីដែលធ្វើឲ្យកូនភ្ញាក់ផ្អើលនោះ ? » ។

មិត្តភក្តិរបស់ខ្ញុំទាំងអស់កំពុងផឹកគ្រឿងស្រវឹង ហើយខ្ញុំនៅទីនោះដោយក្ដីបារម្ភ ដោយរង់ចាំថាមានអ្វីមួយដែលល្អនឹងកើតឡើង ។ ខ្ញុំបានបួងសួងយ៉ាងខ្លាំងឲ្យម៉ាក់ និង ប៉ាមកទីនេះឲ្យបានលឿន ហើយឥឡូវនេះខ្ញុំនៅទីនេះ » ។ ខ្ញុំបានមើលនាឡិកាឡានវាមិនទាន់ម៉ោង ១០ យប់នៅឡើយទេ ។

ម្ដាយខ្ញុំមានប្រសាសន៍ថា « នោះហើយជារបៀបជប់លៀងនៅក្នុងលោកិយនេះ ។ នោះជាមូលហេតុដែលប៉ា និង ម៉ាក់មិនអនុញ្ញាតឲ្យកូនទៅពិធីជប់លៀងមុនៗ » ។

នាយប់នោះពេលខ្ញុំបានអធិស្ឋាន ខ្ញុំបានទូលថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌របស់ខ្ញុំ ដែលបានឲ្យឪពុកម្ដាយខ្ញុំទៅដល់ទីនោះមុនម៉ោង ។

យើងជាសមាជិកសាសនាចក្រយើងរស់នៅក្នុងលោកិយ ប៉ុន្តែមិនមែនដូចជាលោកិយឡើយ ។ ខ្ញុំបានរៀនថា ប្រសិនបើខ្ញុំបន្តចូលរួមពិធីជប់លៀងបែបនោះទៀត ខ្ញុំអាចធ្លាក់ទៅក្នុងការរំលោភលើច្បាប់ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ និង ច្បាប់ព្រហ្មចារីភាពផងដែរ ។ មនុស្សដែលខ្ញុំស្គាល់ជាច្រើននាក់បានធ្លាក់ចូលក្នុងអន្លង់នេះ ភាគច្រើនពួកគេមិនមែនជាសមាជិកសាសនាចក្រទេ ប៉ុន្តែសមាជិកសាសនាចក្រក៏អាចឈានដល់ចំណុចនៃការធ្លាក់នេះ ប្រសិនបើពួកគេមិនបន្តរឹងមាំនោះ ។

ខ្ញុំមានភាពរីករាយចំពោះការសម្រេចចិត្តដែលខ្ញុំមិនបានផឹកគ្រឿងស្រវឹង ។ ខ្ញុំគិតថា គេនឹងសើចចំអកដាក់ខ្ញុំបន្ទាប់ពីនោះ ប៉ុន្តែមិត្តភក្តិរបស់ខ្ញុំបានមានការគោរពកាន់តែច្រើនឡើងចំពោះខ្ញុំ ដោយសារពួកគេដឹងពីបទដ្ឋានរបស់ខ្ញុំ ។ បន្ទាប់ពីនោះមកខ្ញុំគ្មានក្ដីបារម្ភ ដើម្បីនិយាយថាទេចំពោះអ្វីដែលខ្ញុំដឹងថា នឹងមានបញ្ហាដល់ខ្ញុំឡើយ ។ ■

*អ្នកនិពន្ធរស់នៅទីក្រុង សាលទីឡូ ប្រទេសម៉ិកស៊ិក ។*

រូបថតដោយ ក្រេក ហ្វ៊ីល

# វិទ្យាសាស្ត្រ

## និង ការស្រាវជ្រាវរបស់យើងរក

# សេចក្ដីពិត



*គ្មានអ្វីដែលត្រូវបារម្ភឡើយ ប្រសិនបើវាហាក់បីដូចជាមានជម្លោះរវាងការយល់ដឹងរបស់អ្នកអំពីដំណឹងល្អ និង អ្វីដែលអ្នករៀនតាមរយៈវិទ្យាសាស្ត្រនោះ ។*

**ដោយ អាលីសា ខេ ស្ដានថុន**

តើអ្នកអាចស្រមៃពីការទៅជួបវេជ្ជបណ្ឌិតឯកទេសផ្នែកស្បែក ដោយសារអ្នកមានជំងឺកើតមុនធ្ងន់ធ្ងរ ហើយគាត់ប្រាប់អ្នកថាការព្យាបាលនឹងត្រូវបូមឈាមមួយចំនួនចេញពីខ្លួនអ្នកនោះ ? ការណ៍នេះអាចចម្លែកចំពោះអ្នក ប៉ុន្តែវាមិនមែនជារឿងដែលពិបាកជឿនោះទេកាលពីពីរសតវត្សរ៍កន្លងទៅ ។ កាលនោះ ការបូមឈាមមួយចំនួនចេញពីខ្លួន គឺត្រូវបានចាត់ទុកថាជាការព្យាបាលដែលមានបទដ្ឋាន ចំពោះជំងឺស្ទើរតែគ្រប់លក្ខខណ្ឌ រួមមាន ការពិបាករំលាយអាហារ ជំងឺឆ្កួត និង សូម្បីតែជំងឺកើតមុន ។ គ្មាននរណាមានមន្ទិលសង្ស័យពីការណ៍នោះឡើយ ។ ហេតុអ្វីពួកគេគួរតែមានមន្ទិលចំពោះរឿងនោះ ? ក្រោយមក ការបូមឈាមមួយចំនួនចេញពីខ្លួនត្រូវបានប្រើប្រាស់អស់រយៈពេលរាប់ពាន់ឆ្នាំទៅតាមវប្បធម៌ផ្សេងៗជាច្រើន ។

គ្មានមន្ទិលឡើយ រហូតដល់វេជ្ជបណ្ឌិតបានចាប់ផ្ដើមគិតអំពីថ្នាំមកពីទស្សននៃវិទ្យាសាស្ត្រ ទើបមានមនុស្សបានមានមន្ទិលពីការព្យាបាលបែបនោះ ។ ទីបំផុតនៅពេលការបូមឈាមត្រូវបានពិនិត្យកាន់តែច្រើនទៅៗ នោះវេជ្ជបណ្ឌិតបានឈប់ប្រើវិធីសាស្ត្រនេះចំពោះជំងឺទាំងអស់ហើយ ប៉ុន្តែប្រើវាតែចំពោះជំងឺជាក់លាក់មួយចំនួនប៉ុណ្ណោះ ។[១]

តាមរយៈឧទាហរណ៍ជាប្រវត្តិសាស្ត្រមួយនេះ យើងឃើញថា ដោយសារការជឿត្រូវបានទទួលយកយ៉ាងទូលំទូលាយ ឬ ត្រូវបានអនុវត្តអស់ពេលជាច្រើនឆ្នាំ វាពុំមែនមានន័យថាវាពិតនោះទេ ។ ហើយយើងឃើញថាវិទ្យាសាស្ត្រអាចជាឧបករណ៍មួយដ៏អស្ចារ្យក្នុងការបើកបង្ហាញនូវសេចក្ដីពិត ។

សម្រាប់ពួកបរិសុទ្ធថ្ងៃចុងក្រោយ នោះគឺជាគោលការណ៍សំខាន់ណាស់ ។ ការស្គាល់សេចក្ដីពិតពុំមែនគ្រាន់តែផ្ដល់ដល់យើងនូវគ្រឹះដ៏ប្រសើរក្នុងការធ្វើការសម្រេចចិត្តនោះទេ ( « អត់ទេ ថ្ងៃនេះ ខ្ញុំនឹងមិនឲ្យគេបូមឈាមខ្ញុំទេ អរគុណ ! » ) ប៉ុន្តែវាថែមទាំងបន្ថែមនូវការយល់ដឹងរបស់យើងចំពោះដំណឹងល្អថែមទៀតផង ។ ដូចប្រធាន ព្រិកហ្គាំ យ៉ង់ ( ឆ្នាំ ១៨០១–៧៧ ) បានបង្រៀនថា « គ្មានសេចក្ដីពិតណា ដែលមិនមែនជារបស់ដំណឹងល្អឡើយ ។ . . . ប្រសិនបើអ្នកអាចស្វែងរកសេចក្ដីពិតនៅឋានសួគ៌ [ ឬ ] ផែនដី . . . វាគឺជាកម្មសិទ្ធិរបស់គោលលទ្ធិយើងហើយ » ។[២]

## មូលហេតុ និង របៀប

ពិតណាស់នៅពេលយើងនិយាយអំពីរបៀបដែលវិទ្យាសាស្ត្ររួមចំណែកនៅក្នុងសេចក្ដីពិតដែលយើងដឹង នោះត្រូវប្រាកដថាយើងយល់ថា សេចក្ដីពិតបែបណាដែលវិទ្យាសាស្ត្រអាចបង្ហាញបាន — ហើយអ្វីដែលវាមិនអាចបង្ហាញបាន ។ របៀបមួយដើម្បីមើលឃើញវានោះ គឺត្រូវសួរសំណួរនានាដែលវិទ្យាសាស្ត្រអាចឆ្លើយបាន និង មិនអាចឆ្លើយបាន ។

ស៊ិស្ទើរ អែឡិន មែនហ្វ្រុម ដែលបានសិក្សាផ្នែកវិស្វករគីមីវិទ្យានៅវិទ្យាស្ថានពហុបច្ចេកទេស រ៉េនសៀលើរ នៅក្នុងទីក្រុង នូវ យ៉ោក ស.រ.អា. ពន្យល់វាតាមរបៀបនេះ ៖ « វិទ្យាសាស្ត្រពន្យល់ពីរបៀបធ្វើ ។ ប៉ុន្តែវាមិនអាចពន្យល់ពីមូលហេតុឡើយ » ។ គាត់បន្ថែមថា សាសនាគឺជាអ្វីដែលពន្យល់ពីមូលហេតុ ដូចជាមូលហេតុដែលផែនដីនេះត្រូវបានបង្កើតឡើង និង មូលហេតុដែលយើងត្រូវបានដាក់នៅលើផែនដីនេះ ។

អ្នករូបវិទ្យាដ៏ល្បីល្បាញឈ្មោះ អាលប៊ើត អ៊ីនស្ទែនក៏ជឿផងដែរថាសាសនា និង វិទ្យាសាស្ត្រមានគោលបំណងខុសគ្នា តែពឹងពាក់គ្នាទៅវិញទៅមក ។

លោកបានសរសេរថា « វិទ្យាសាស្ត្រគ្រាន់តែអាចបង្ហាញថាវាជាអ្វីប៉ុណ្ណោះ ប៉ុន្តែមិនអាចបង្ហាញថាវាគួរតែជាអ្វីឡើយ ។ ក្រៅពីតំបន់ត្រួតត្រារបស់ [ វិទ្យាសាស្ត្រ ] តម្លៃនៃការវិនិច្ឆ័យលើរឿងទាំងអស់គឺនៅតែចាំបាច់បំផុត » ។[៣]

តើការណ៍នោះមានន័យយ៉ាងណាចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយ ? ទីមួយ យើងដឹងថាការយល់ដឹងផ្នែកវិទ្យាសាស្ត្រនឹងបន្តមានការផ្លាស់ប្ដូរ ។ ក្រៅពីនោះទៀត វិទ្យាសាស្ត្រគឺជាអ្វីៗទាំងអស់ដែលព្យាយាមស្វែងរករបៀបកាន់តែប្រសើរ ដើម្បីយល់ពី « របៀប » នានានៃពិភពលោកនៅជុំវិញខ្លួននេះ ។ ដោយការដឹងពីរឿងនេះ នោះយើងពុំត្រូវការពិនិត្យមើលពីការសិក្សាថ្មីៗបំផុត ចំពោះការយល់ដឹងពី « មូលហេតុ » ឬ « ភាពគួរតែ » នៃជីវិតឡើយ ។ យើងអាចពឹងផ្អែកលើដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ដែលគ្មានការផ្លាស់ប្ដូរ ដើម្បីជួយយើងឲ្យធ្វើការសម្រេចចិត្តរវាងការណ៍ត្រឹមត្រូវ និង ខុសឆ្គង ។



រូបគំនូរ © ISTOCK/THINKSTOCK



## វាត្រូវរ៉ូវគ្នា

ប្រធាន រ័សុល អិម ណិលសុន ប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ និង ជាគ្រូពេទ្យវះកាត់បេះដូងដ៏ល្បីល្បាញមួយរូប បាននិយាយអំពីរបៀបដែលសាសនា និង វិទ្យាសាស្ត្រត្រូវរ៉ូវគ្នា ។

លោកបានមានប្រសាសន៍ថា « គ្មានជម្លោះរវាងវិទ្យាសាស្ត្រ និង សាសនាឡើយ ។ ជម្លោះនឹងកើតឡើងមកពីការយល់ដឹងមិនពេញលេញនៃវិទ្យាសាស្ត្រ ឬ សាសនា ឬក៏ទាំងពីរ ។ . . . មិនថាសេចក្តីពិតបានមកពីមន្ទីរពិសោធន៍វិទ្យាសាស្ត្រ ឬ ដោយវិវរណៈមកពីព្រះនោះទេ វាត្រូវរ៉ូវគ្នា » ។[៤]

ដូច្នេះប្រសិនបើអ្នកមានសំណួរ ថាតើអាយុរបស់ផែនដី ឬ សត្វដៃណូសើរ ឬ ការវិវឌ្ឍន៍នានា ឬ អ្វីផ្សេងទៀត ដែលអ្នកមាននៅក្នុងថ្នាក់វិទ្យាសាស្ត្រត្រូវគ្នានឹងដំណឹងល្អ នោះវាជារឿងអស្ចារ្យណាស់ ! វាពិតជាត្រូវរ៉ូវគ្នា ប៉ុន្តែវានៅតែមានសំណួរជាច្រើន ដោយសារវានៅតែមានអ្វីៗជាច្រើនដែលយើងកំពុងរៀន ។ បងប្រុស ប្រាយអិន ដោាន អ្នកវិទ្យាសាស្ត្រផ្នែកឱសថនៅទីក្រុង ឃ្វីប៊ិច ប្រទេស កាណាដា បាននិយាយថា គាត់ទន្ទឹងរង់ចាំដល់ពេលដែលអ្វីៗគ្រប់យ៉ាងនឹងត្រូវបានបើកសម្តែងដល់ពួកយើង ( សូមមើល គ. និង ស. ១០១:៣២–៣៤ ) ។

គាត់និយាយថា នៅពេលនេះ « សមត្ថភាពរបស់យើងនៅមានដែនកំណត់ដើម្បីយល់ដឹងពីអាថ៌កំបាំងទាំងអស់នៃពិភពលោកជុំវិញពួកយើងនេះ តាមរយៈការខ្នះខ្នែងរកខាងវិទ្យាសាស្ត្រ ។ ដូចគ្នានេះផងដែរ យើងក៏មានដែនកំណត់ក្នុងការយល់ដឹងរបស់យើងអំពីអាថ៌កំបាំងរបស់ព្រះ និង ការតាក់តែងដ៏មហិមារបស់ទ្រង់ចំពោះកូនចៅរបស់ទ្រង់ផងដែរ » ។

បន្ទាប់ពីនោះគ្មានអ្វីដែលត្រូវបារម្ភឡើយ ប្រសិនបើវាហាក់បីដូចជាមានជម្លោះរវាងការយល់ដឹងរបស់អ្នកអំពីដំណឹងល្អ និង អ្វីដែលអ្នករៀនតាមរយៈវិទ្យាសាស្ត្រ ។ ភាពពិតនោះគឺថា គ្មានអ្វីដែលវិទ្យាសាស្ត្របើកបង្ហាញអាចបង្ហាញថាជំនឿរបស់អ្នកខុសឡើយ ។

ដូច្នេះប្រសិនបើអ្នកចូលចិត្តវិទ្យាសាស្ត្រ សូមរៀននូវវិស័យនានាទាំងអស់ដែលអ្នកចាប់អារម្មណ៍ ! សេចក្តីជំនឿរបស់អ្នកអាចផ្តល់ប្រយោជន៍ដល់អ្នក ។ បងប្រុស រីឆាដ ហ្គាដនើរ សាស្ត្រាចារ្យបរិញ្ញាបត្ររងនៃមុខវិជ្ជាជីវវិទ្យានៅសាកលវិទ្យាល័យ វើរជីញ៉ា ភាគខាងត្បូង និយាយថា សេចក្តីជំនឿរបស់គាត់លើដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទគឺជាជំនួយមួយដ៏ធំចំពោះគាត់ ។

គាត់និយាយថា « ជួនកាលនៅពេលការស្រាវជ្រាវមានការលំបាក ហើយការងារហាក់បីដូចជាមិនដំណើរការ — ការស្រាវជ្រាវគឺមានលក្ខណៈបែបនេះច្រើនណាស់ — នោះការមានទស្សនវិស័យលើពរជ័យនៃដំណឹងល្អបានជួយខ្ញុំឲ្យធ្វើកិច្ចការនោះបាន » ។

បងប្រុស ដោាន ក៏មានអារម្មណ៍ថាសេចក្តីជំនឿរបស់គាត់បានជួយគាត់ក្នុងកិច្ចការវិទ្យាសាស្ត្ររបស់គាត់ផងដែរ ។

គាត់និយាយថា « ខ្ញុំធ្វើការដោយសេចក្តីជំនឿជានិច្ចថា មានភាពសមហេតុផល និង របៀបរៀបរយនៅក្នុងអ្វីៗគ្រប់យ៉ាង ហើយថាប្រសិនបើខ្ញុំស្រាវជ្រាវនូវសំណួរដែលវែងអន្លាយ ហើយលំបាក នោះព្រះវរបិតាសួគ៌នឹងបើកដួងចិត្តខ្ញុំទទួលយកចម្លើយនោះ » ។

## រីករាយក្នុងការរកឃើញរបស់វិទ្យាសាស្ត្រ

សេចក្តីជំនឿរបស់យើងលើព្រះគ្រីស្ទ និង ដំណឹងល្អរបស់ទ្រង់អាចជួយយើងឲ្យបន្ទាបខ្លួន ហើយទទួលសេចក្តីពិតដែលយើងកំពុងស្វែងរក បើទោះវាជាខាងវិទ្យាសាស្ត្រ ឬ ខាងវិញ្ញាណក្តី ។

សាស្ត្រាចារ្យ ហ្គាដនើរ មានប្រសាសន៍ថា « មានអ្វីៗជាច្រើនដែលយើងមិនដឹងក្នុងផ្នែកវិទ្យាសាស្ត្រ ហើយមានអ្វីជាច្រើនអំពីព្រះដែលទ្រង់ពុំទាន់បានបើកសម្តែងនៅឡើយ ។ ដូច្នេះវាចាំបាច់ថាត្រូវបន្តបើកដួងចិត្តទទួលព័ត៌មានឲ្យកាន់តែច្រើនដល់យើង ហើយនឹងមិនព្រួយបារម្ភនៅក្នុងពេលនេះឡើយ » ។

ឧទាហរណ៍ មនុស្សមួយចំនួនជឿលើព្រះ គ្រាន់តែដោយសារពួកគេពុំបានឃើញពីការពន្យល់ផ្សេងទៀតចំពោះការអង្កេតរបស់ខ្លួននៃពិភពលោកនេះឡើយ ។ នេះគឺត្រូវបានហៅថាជាការជឿលើ « ព្រះនៃចម្លើយចំពោះចន្លោះខ្វះខាត » ហើយវាអាចធ្វើឲ្យមនុស្សមានអារម្មណ៍ភ័យខ្លាចអំពីការរកឃើញរបស់វិទ្យាសាស្ត្រ ។ សាស្ត្រាចារ្យ ហ្គាដនើរផ្តល់ឧទាហរណ៍មួយ ៖

« មនុស្សមួយចំនួនបានជឿលើព្រះ ដោយសារតែគ្មានភស្តុតាងពេញលេញនៅក្នុងកំណត់ត្រាហ្វូស៊ីលដើម្បីបញ្ជាក់ ( ចំពោះពួកគេ មានន័យថា ដំណើរការប្រែប្រួលជាលំដាប់នោះមិនអាចពន្យល់ឲ្យគ្រប់គ្រាន់នូវរបៀបដែលយើងមកកាន់ផែនដីនេះ ) ។ ប៉ុន្តែតើមានអ្វីកើតឡើងចំពោះសេចក្តីជំនឿរបស់យើង នៅពេលភស្តុតាងមិនពេញលេញនេះត្រូវបានបំពេញដោយការរកឃើញនៃហ្វូស៊ីលថ្មីនោះ ? ផ្ទុយទៅវិញ យើងត្រូវការទទួលបាននូវភស្តុតាងពិតអំពីព្រះ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ហើយតមកយើងអាចរីករាយនៅក្នុងការរុករកឃើញរបស់វិទ្យាសាស្ត្រ ច្រើនជាងបារម្ភពីវា » ។

នៅពេលយើងធ្វើតាមវិធីសាស្ត្រនេះ នោះយើងចងចាំថាទាំងវិទ្យាសាស្ត្រ និង សាសនាអាចជួយយើងនៅក្នុងការស្រាវជ្រាវរកសេចក្តីពិតរបស់យើង ហើយដែលការពិតទាំងនោះគឺកើតឡើងមកពីប្រភពតែមួយ ៖ គឺព្រះ ។

សាស្ត្រាចារ្យ ហ្គាដនើរ មានប្រសាសន៍ថា « ព្រះអាចបើកសម្តែងអ្វីៗគ្រប់យ៉ាងដែលទ្រង់មានព្រះទ័យ រួមទាំងសេចក្តពិតខាងវិទ្យាសាស្ត្រផងដែរ ។ ហើយពិតណាស់ ទ្រង់បានបំផុសគំនិតដល់អ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ និង

វិស្វករ — ប៉ុន្តែទ្រង់ពុំផ្ដល់ចម្លើយទាំងអស់ដល់ពួកគេឡើយ ។ ទ្រង់ចង់ឲ្យពួកគេ និង យើងប្រើប្រាស់ខួរក្បាលរបស់យើង ដូច្នោះទ្រង់ឲ្យយើងស្វែងយល់ពីវិទ្យាសាស្ត្រ និង វិវរណៈរបស់ទ្រង់ចំពោះសាសនាចក្រច្រើនជាងអំពីរបៀបរៀបចំសាសនាចក្រ ហើយជាពិសេសរបៀបដែលយើងអាចមកកាន់ព្រះគ្រីស្ទ ហើយបានសង្គ្រោះ ។

« វិវរណៈផ្ទាល់របស់ព្រះអង្គចំពោះពួកយើងអាចជាប្រធានបទណាមួយ ប៉ុន្តែជាពិសេសធ្វើឲ្យយើងដឹងថាទ្រង់មានព្រះជន្មរស់ ហើយស្រឡាញ់យើងថាព្រះគ្រីស្ទបានធ្វើឲ្យផែនការនៃសេចក្ដីសង្គ្រោះកើតមានឡើង ថាយើងមានព្យាការីដែលរស់នៅសព្វថ្ងៃថាយើងអាចធ្វើតាមផែនការព្រះ ហើយថាវាគឺសក្ដិសមណាស់ដើម្បីធ្វើបែបនោះ » ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*

**កំណត់ចំណាំ**

១. សូមមើល ឧទាហរណ៍ ខេ ខូឌែល និង បាបារ៉ា អ័រ ខាធើរ *Childbed Fever: A Scientific Biography of Ignaz Semmelweis* ( ឆ្នាំ ១៩៩៤ ) ។
២. *Teachings of Presidents of the Church: Brigham Young* ( ឆ្នាំ ១៩៩៧ ) ទំព័រ ១៦ ។
៣. អាលប៊ើត អ៊ីស្ទិន នៅក្នុង « Science and Religion » នៅក្នុង Ken Wilber *Quantum Questions: Mystical Writings of the World's Greatest Physicists* ( ឆ្នាំ ១៩៨៤ ) ។
៤. វ៉េសុល អិម ណិលសុន នៅក្នុង Marianne Holman Prescott « Church Leaders Gather at BYU's Life Sciences Building for Dedication » *Church News,* ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៥ គេហទំព័រ LDS.org ។







# សំ & បំ

**ជាមួយវេជ្ជ. រីឆាដ ហ្គាដនើរ ជាជីវវិទូផ្នែកម៉ូលេគុល**
*និង កោសិកា*

***តើលោកចាប់អារម្មណ៍លើវិទ្យាសាស្ត្រយ៉ាងដូចម្ដេច ?***

ឪពុករបស់ខ្ញុំជារុក្ខវិទូ ដូច្នោះវាធ្វើឲ្យខ្ញុំចាប់អារម្មណ៍លើវិទ្យាសាស្ត្រ ។ អំឡុងពេលធំឡើង ខ្ញុំធ្លាប់លេងកែវពង្រីក និង ឧបករណ៍ពិសោធន៍ផ្សេងៗទៀតរបស់គាត់ ហើយឮគាត់និយាយពីរុក្ខជាតិ និង ពួកផ្សិត ។ ហើយឪពុករបស់លោកជាវិទ្យាវិទូសិក្សាពីស្បែន បានឲ្យសត្វល្អិតមួយចំនួនមកខ្ញុំសិក្សាពីពួកវាកាលខ្ញុំអាយុប្រហែលប្រាំបួនឆ្នាំ ។ ខ្ញុំបានរៀននូវមុខវិជ្ជាវិទ្យាសាស្ត្រទាំងអស់ដែលខ្ញុំអាចរៀនបាននៅវិទ្យាល័យ ជាពិសេសរីករាយនឹងកិច្ចការលំហាត់ឲ្យបង្កើតនូវក្រុមសត្វល្អិតនានា ។ ខ្ញុំបានសម្រេចចិត្ត តាំងពីខ្ញុំនៅក្មេងថានឹងយកសញ្ញាបត្របណ្ឌិតនៅក្នុងផ្នែកវិទ្យាសាស្ត្រ ដោយសារខ្ញុំចូលចិត្តដឹងពីដំណើរការរបស់អ្វីៗគ្រប់យ៉ាង ហើយខ្ញុំចូលចិត្តការរៀនសូត្រ ។

***តើការខិតខំរៀនផ្នែកវិទ្យាសាស្ត្ររបស់អ្នកជួយពង្រឹងសេចក្ដីជំនឿរបស់អ្នកយ៉ាងដូចម្ដេចដែរ ?***

កាលណាខ្ញុំកាន់តែរៀនអំពីភាពស្មុគស្មាញនៅក្នុងកោសិកា នោះខ្ញុំកាន់តែមានការអស្ចារ្យ ។ ខ្ញុំមានរូបប័ណ្ណប្រកាសធំពីរនៅក្នុងក្រដាសបោះពុម្ពតូចមួយ ដែលភាគច្រើនគឺអំពីប្រតិកម្មគីមីនៅក្នុងកោសិកាសាមញ្ញមួយ ប្រតិកម្មទាំងអស់នេះត្រូវគ្រប់គ្រងដោយប្រុងប្រយ័ត្ន ។ មានពេលមួយនោះ ខ្ញុំបានបង្ហាញវានៅក្នុងថ្នាក់បព្វជិតភាពដែលខ្ញុំបានបង្រៀន ។ ខ្ញុំបានរំឭកពួកគេអំពី រូបចម្លាក់ព្រះគ្រីស្ទ នៅវិសាលដ្ឋាននៃព្រះវិហារបរិសុទ្ធ និង នៅតាមមជ្ឈមណ្ឌលទស្សនាផ្សេងទៀតរបស់ អិល.ឌី.អេស. ។ នៅពីក្រោយរូបចម្លាក់នោះមានគំនូរផាត់ពណ៌នៃរូបសាកលលោក ហើយមានសារថ្លែងបញ្ជាក់ថា « នេះគឺជាអង្គបង្កបង្កើតអ្វីៗទាំងអស់នេះ ! » ប៉ុន្តែខ្ញុំសូមផ្ដល់យោបល់ថា ចូរដាក់ប័ណ្ណប្រកាសនេះនៅពីក្រោយរូបចម្លាក់នេះផងដែរ ។ ប័ណ្ណប្រកាសនេះមិនស្អាតដូចជារូបគំនូរសាកលលោកឡើយ ប៉ុន្តែទ្រង់បានបង្កើតកោសិកាគីមីនេះផងដែរ ហើយយល់ទាំងអស់ពីវាយ៉ាងលម្អិត !

***តើសេចក្ដីជំនឿរបស់អ្នកបានជួយអ្នកនៅក្នុងការសិក្សាផ្នែកវិទ្យាសាស្ត្ររបស់អ្នកយ៉ាងដូចម្ដេច ?***

កាលខ្ញុំនៅធ្វើការស្រាវជ្រាវ ហើយឥឡូវនេះភាគច្រើនខ្ញុំបង្រៀនពីវិទ្យាសាស្ត្រ នោះសេចក្ដីជំនឿរបស់ខ្ញុំគឺសំខាន់ណាស់ចំពោះខ្ញុំ ដោយសារខ្ញុំពុំអាចយល់ពីវិទ្យាសាស្ត្រទាំងស្រុងឡើយប្រសិនបើគ្មានសេចក្ដីជំនឿនោះ ។ ការរៀនអំពីរបៀបដែលកោសិកាធ្វើការ ប៉ុន្តែពុំរៀនពីមូលហេតុអ្វីដែលកោសិកា ឬ ពួកយើងមកនៅលើផែនដីនេះ នោះនឹងធ្វើឲ្យខ្ញុំគ្មានការពេញចិត្តឡើយ ។



**អែលឌើរ ហ៊ូហ្គូ អ៊ី ម៉ាទីណេ**
នៃពួកចិតសិបនាក់

# រៀបចំខ្លួន — ហើយធ្វើកិច្ចការ

*ការរៀបចំខ្លួនរបស់អ្នក ហើយធ្វើកិច្ចការរបស់ព្រះអម្ចាស់នឹងផ្លាស់ប្តូរជីវិតរបស់អ្នក ។*

ខ្ញុំជាគ្រូបង្រៀនថ្នាក់សិក្ខាសាលារយៈពេលប្រាំមួយឆ្នាំ ។ យើងជួបគ្នារៀងរាល់ថ្ងៃនៅម៉ោង ៦ ព្រឹក នៅក្នុងផ្ទះរបស់យើងនៅក្នុងទីក្រុង ព័រតូ រីកូ ។ វាជាកិច្ចការដែលត្រូវរៀបចំមេរៀនជាច្រើនរៀងរាល់ថ្ងៃ ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ។ ប៉ុន្តែខ្ញុំរីករាយនឹងធ្វើកិច្ចការនេះណាស់ ហើយវាបានជួយខ្ញុំឲ្យអភិវឌ្ឍនូវសេចក្តីស្រឡាញ់កាន់តែច្រើនឡើងចំពោះពួកយុវវ័យនៃសាសនាចក្រ ។

## ចូរមកដោយមានចិត្តចង់រៀនសូត្រ

ខ្ញុំកត់សម្គាល់ឃើញថា ភាគច្រើនអ្វីដែលកូនសិស្សបានទទួលមកពីថ្នាក់សិក្ខាសាលានោះ គឺអាស្រ័យនឹងការរៀបចំខ្លួនរបស់ពួកគេ ។ ដូច្នោះ ប្រសិនបើអ្នកចង់ចេះកាន់តែច្រើនពីមេរៀនថ្នាក់សិក្ខាសាលា នោះខ្ញុំសូមអញ្ជើញអ្នកឲ្យសិក្សាមេរៀននោះជាមុន ហើយពិចារណាពីវា ។ មកថ្នាក់រៀនដោយមានអារម្មណ៍ស្រេកឃ្លាននូវចំណេះដឹង ។ ចូរមកដូចជាកូនតូច ដែលមានចិត្តចង់រៀនសូត្រជានិច្ច ។ ចូររៀបចំខ្លួនដើម្បីចូលរួម ប្រយោជន៍ឲ្យអ្នកអាចបង្រៀនគ្នាទៅវិញទៅមក ។ ហើយយើងមករៀនដោយមានសំណួរ ។ មួយទៀតយុវជនអើយ ការសិក្សាព្រះគម្ពីរ ឬ ប្រហែលជាយោបល់របស់គ្រូបង្រៀនអាចឆ្លើយនឹងសំណួររបស់អ្នកបាន ។

ការណែនាំដ៏ល្អបំផុតអំឡុងពេលរៀន ឬ ការប្រជុំនានានៅក្នុងសាសនាចក្រកើតមានឡើង នៅពេលអ្នករៀបចំខ្លួន ហើយអ្នកទទួលការបំផុសគំនិតខាងវិញ្ញាណដែលកើតឡើងជាគំនិត ។ ចូរសរសេរគំនិតទាំងនោះទុក ហើយក្រោយមកអនុវត្តវា ។ ចូររកមើលយោបល់នានាពីព្រះគម្ពីរ ឬ សុន្ទរកថាសន្និសីទទូទៅ ឬ អត្ថបទនានាមកពីទស្សនាវដ្ដីសាសនាចក្រឲ្យកាន់តែច្រើនឡើង ។ ចូរពិចារណាអំពីយោបល់ទាំងនោះនៅក្នុងគំនិត និង ដួងចិត្តរបស់អ្នក ហើយត្រៀមខ្លួនរួចជាស្រេចដើម្បីបម្រើ ដោយសារនៅពេលណាអ្នកមានសេចក្តីពិតទាំងនេះនៅក្នុងខ្លួនអ្នក នោះព្រះអម្ចាស់នឹងប្រើអ្នកឲ្យជួយអ្នកដទៃ ។

ក្រោយមក កាលខ្ញុំបម្រើជាប្រធានបេសកកម្មជាមួយភរិយារបស់ខ្ញុំ ខ្ញុំបានដឹងថាថ្នាក់សិក្ខាសាលាគឺជាកន្លែងរៀបចំខ្លួនដ៏អស្ចារ្យបំផុតសម្រាប់ការបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ អស់ពេលជាច្រើនឆ្នាំ ខ្ញុំបានឃើញព្រះចេស្ដាដ៏មហិមានៃដំណឹងល្អប្រទានពរដល់សិស្សដែលស្មោះត្រង់ចូលរៀនថ្នាក់សិក្ខាសាលា ។ ពួកគេបានអនុវត្តអ្វីដែលពួកគេបានរៀននៅក្នុងមេរៀនទាំងនោះ នៅក្នុងឧបសគ្គធំៗនៅក្នុងជីវិតរបស់ពួកគេ ហើយបានហែលឆ្លងកាត់ឧបសគ្គនានា សូម្បីតែជាការត្រឡប់មកកាន់ព្រះវិហារវិញបន្ទាប់ពីមិនសូវសកម្មមួយរយៈ ។

## រៀបចំខ្លួនដើម្បីចូលរួម

ប្អូនៗទាំងអស់គ្នាសំខាន់ណាស់ចំពោះព្រះអម្ចាស់ ។ ប្អូនៗពិតជាសំខាន់ខ្លាំងណាស់ ។ កិច្ចការរបស់ពួកយុវវ័យគឺត្រូវរៀបចំខ្លួនធ្វើកិច្ចការអ្នកផ្សព្វផ្សាយសាសនា ហើយបន្ទាប់មកធ្វើកិច្ចការអ្នកផ្សព្វផ្សាយសាសនា ។ ឥឡូវនេះអ្នកត្រូវតែយល់ថា នៅពេលអ្នកបន្តធ្វើកិច្ចការអ្នកផ្សព្វផ្សាយសាសនា ហើយនៅពេលអ្នកបន្តរៀបចំខ្លួន ការណ៍នេះនឹងជំរុញព្រមទាំងនាំឲ្យអ្នកមានការរីកចម្រើននាពេលអនាគតក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនារបស់ព្រះអម្ចាស់ ។ អ្នកពុំត្រូវការស្លាកឈ្មោះនៃអ្នកផ្សព្វផ្សាយសាសនាដើម្បីធ្វើកិច្ចការផ្សព្វផ្សាយសាសនានោះឡើយ ដោយសារអ្នកពាក់ព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទដែលបានចារនៅក្នុងដួងចិត្តរបស់អ្នក ដោយសារសេចក្តីសញ្ញារបស់អ្នក ។

## ប្អូនៗអាចធ្វើកិច្ចការនេះបាន ។

ការណ៍នេះក៏ពិតចំពោះកិច្ចការពង្សប្រវត្តិ និងកិច្ចការព្រះវិហារបរិសុទ្ធផងដែរ ។ ឧទាហរណ៍ នៅក្នុងតំបន់ ការីប៊ៀន ជាកន្លែងដែលខ្ញុំបម្រើ ស្តេកជាច្រើនប្រើពួកយុវវ័យឲ្យធ្វើជាអ្នកផ្តល់ប្រឹក្សាខាងពង្សប្រវត្តិ បានធ្វើឲ្យមានសមាជិកដែលស្វែងរកឈ្មោះសម្រាប់កិច្ចការព្រះវិហារបរិសុទ្ធ និង ធ្វើកិច្ចការពង្សប្រវត្តិនោះកើនចំនួនឡើង ។ នៅក្នុងស្តេកមួយមានពួកយុវវ័យ ២០ នាក់ដែលត្រូវបានហៅជាអ្នកផ្តល់ប្រឹក្សាខាងពង្សប្រវត្តិ រយៈពេលមួយឆ្នាំពីមុនពួកគេមានអាយុគ្រប់ទៅបេសកកម្ម ។ នៅពេលពួកគេសួរសុខទុក្ខសមាជិកនៅតាមផ្ទះរបស់ពួកគេ ដើម្បី



បង្ហាញសមាជិកពីរបៀបធ្វើពង្សប្រវត្តិរបស់ខ្លួន នោះពួកគេនិយាយជាមួយមនុស្សនៅតាមផ្លូវ ហើយប្រាប់ពួកគេអំពីពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធ ។ នោះគឺជាកិច្ចការផ្សព្វផ្សាយសាសនាហើយ !

ខ្ញុំសង្ឃឹមថានៅពេលពួកគេបម្រើបេសកកម្ម នោះពួកគេមានអារម្មណ៍ពីព្រះវិញ្ញាណរួចស្រេចក្នុងរបៀបមួយដ៏មានព្រះចេស្ដា — ពោរពេញដោយសេចក្ដីសង្ឃឹមនៅក្នុងគេហដ្ឋានរបស់ពួកគេ ប៉ុន្តែប្រសិនបើគ្មានទេ នោះពួកគេនឹងមាននៅពេលពួកគេធ្វើកិច្ចការពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធ ។ បន្ទាប់មកនៅពេលពួកគេចូលទៅក្នុងមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា ខ្ញុំសង្ឃឹមថា គ្មាននរណាម្នាក់ប្រាប់ខ្ញុំថា « ខ្ញុំមានព្រះវិញ្ញាណបរិសុទ្ធខ្លាំងនៅទីនេះ ជាងពេលណាៗទាំងអស់នៅក្នុងជីវិតរបស់ខ្ញុំ » ។ ពួកគេគួរតែទទួលអារម្មណ៍នៃព្រះចេស្ដារបស់ទ្រង់ដ៏ខ្លាំងនេះតាំងតែពីមុនមកម្ល៉េះ ។

> វានឹងប្រទានពរ ព្រមទាំងផ្លាស់ប្ដូរជីវិតរបស់ប្អូន ។

ព្រះអម្ចាស់ស្រឡាញ់ប្អូនៗ ។ ទស្សនវិស័យរបស់ទ្រង់គឺថា អ្នកគឺជាអ្នកធ្វើកិច្ចការពង្សប្រវត្តិ ព្រះវិហារបរិសុទ្ធ និង កិច្ចការផ្សព្វផ្សាយសាសនា ។ ប្អូនៗទាំងអស់គ្នាមានជំនាញ និង ចំណេះដឹង ។ នៅពេលប្អូនៗរៀបចំខ្លួនបានល្អ នោះប្អូនៗអាចធ្វើកិច្ចការនេះ ។ វានឹងប្រទានពរ ព្រមទាំងផ្លាស់ប្ដូរជីវិតរបស់ប្អូន ។ ■





# ការចងចាំ ព្រះអង្គសង្គ្រោះ

ដោយ **អ៊ីរិក ប៊ី ម៉ុដុក**
ទស្សនាវដ្ដីសាសនាចក្រ

រៀងរាល់សប្ដាហ៍ យើងមានពរឲ្យមានឱកាសទទួលទានសាក្រាម៉ង់នៅពេលចូលរួមព្រះវិហារ ។ ពិតណាស់ វាគឺជាមូលហេតុចម្បងមួយដែលពួកយើងទៅព្រះវិហារនៅថ្ងៃអាទិត្យ ។ ប៉ុន្តែតើអ្នកដឹងទេថាពិធីសាក្រាម៉ង់មានសារៈសំខាន់ប៉ុណ្ណានោះ ? មានកិច្ចការមួយដែលយើងសន្យានឹងធ្វើ ដែលធ្វើឲ្យវាក្លាយជាពិធីបរិសុទ្ធដ៏សំខាន់ និង ពិសិដ្ឋបំផុតនៅក្នុងសាសនាចក្រ ៖ ចងចាំព្រះយេស៊ូវគ្រីស្ទ ។

ចូរគិតពីរឿងនេះ ៖ ចងចាំព្រះអង្គសង្គ្រោះគឺជាផ្នែកដ៏សំខាន់មួយនៃការអធិស្ឋានសាក្រាម៉ង់ ។ នៅក្នុងការអធិស្ឋាននោះ យើងសន្យាថាយើងនឹង « ចងចាំទ្រង់ជានិច្ច » ( គ. និង ស. ២០:៧៧, ៧៩ ) ពុំមែនគ្រាន់តែថ្ងៃអាទិត្យឡើយ ប៉ុន្តែ *ជានិច្ច* ។



នៅពេលយើងចងចាំព្រះអង្គសង្គ្រោះជានិច្ច នោះជីវិតរបស់យើងនឹងគិតពីបទដ្ឋាន និង ការបង្រៀនរបស់ទ្រង់ ហើយយើងនឹងឃើញផងដែរពីព្រះចេស្ដា និង ឥទ្ធិពលគាំទ្រនៅក្នុងជីវិតរបស់យើងផងដែរ ។

## របៀបដែលការចងចាំបានជួយយុវជនមួយរូប

ឧទាហរណ៍ នៅពេលទេវតានៃព្រះបានហៅ អាលម៉ាជាកូនឲ្យប្រែចិត្ត នោះអាលម៉ាបានដួលទៅលើដី ហើយពុំអាចនិយាយ ឬកម្រើកអស់ជាច្រើនថ្ងៃ ។ អំឡុងគ្រានោះ លោកត្រូវញាំញីដោយសេចក្ដីទុក្ខវេទនាដោយការនឹកឃើញដល់អំពើបាបរបស់ខ្លួន ប៉ុន្តែក្រោយមកលោកបាន « នឹកឃើញ . . . ពីការព្យាករបស់ឪពុក [ លោក ] . . . អំពីការយាងមកនៃព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះដើម្បីមកធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សលោក » ។ ក្រោយមកលោកមានប្រសាសន៍ ៖ « ឥឡូវនេះ នៅពេលដែលឪពុកនឹកគិតទៅលើរឿងនេះ នោះឪពុកបានយំនៅក្នុងចិត្ត ៖ ឱព្រះយេស៊ូវអើយ ព្រះអង្គជាព្រះរាជបុត្រានៃព្រះ សូមព្រះអង្គមានសេចក្ដីមេត្តាករុណាមកលើទូលបង្គំផង ដែលជាអ្នកនៅក្នុងប្រមាត់ល្វីងជូរចត់ ហើយកំពុងតែទ្បោមព័ទ្ធទៅដោយច្រវាក់ដ៏អស់កល្បជានិច្ចនៃសេចក្ដីស្លាប់ ។ ហើយឥឡូវនេះ មើលចុះ នៅពេលដែលឪពុកកំពុងតែគិតយ៉ាងនេះ នោះឪពុកក៏ឈប់នឹកឃើញការឈឺចាប់ទៀតមែនហើយ ឪពុកក៏អស់កើតទុក្ខដោយការនឹកឃើញអំពើបាបរបស់ខ្លួនទៀតទៅ » ( អាលម៉ា ៣៦:១៧–១៩ ) ។

តាមរយៈការគិតពីព្រះគ្រីស្ទ បាននាំអាលម៉ាឲ្យអធិស្ឋានទូលសុំក្ដីមេត្តាករុណា ដកយកអារម្មណ៍ខុសឆ្គង បន្ធូរការឈឺចាប់របស់លោក ហើយជួយលោកឲ្យប្រែចិត្ត ។ ដូចជាអាលម៉ាដែល យើងអាចបង្វែរជីវិតរបស់យើងទៅកាន់ព្រះគ្រីស្ទ ហើយមានបទពិសោធន៍នៃក្ដីអំណរដែលកើតឡើងពីការរស់នៅតាមដំណឹងល្អ ។ ដំណើរការនេះចាប់ផ្ដើមដោយជម្រើសរបស់យើងដើម្បីចងចាំព្រះយេស៊ូវគ្រីស្ទ និង អំណាចនៃដង្វាយធួនរបស់ទ្រង់ ។



*ពរជ័យដ៏មហិមាកើតមានឡើងនៅពេលយើងចងចាំព្រះយេស៊ូវគ្រីស្ទ តាមរយៈពិធីសាក្រាម៉ង់ ។*

រូបគំនូរដោយ ខាវៃ រ៉េល



នេះគឺជាពរជ័យប្រាំបន្ថែមទៀត ដែលកើតមានពីការគោរពការសន្យារបស់យើងឲ្យចងចាំព្រះអង្គសង្គ្រោះជានិច្ច ។

**១. ព្រះវិញ្ញាណទ្រង់នឹងគង់នៅជាមួយយើង**

នៅពេលអ្នកទទួលទានសាក្រាម៉ង់នៅថ្ងៃអាទិត្យ នោះអ្នករំឭកការសន្យាដែលថា ប្រសិនបើអ្នកចងចាំព្រះគ្រីស្ទ គោរពព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ហើយលើកដាក់លើខ្លួនអ្នកនូវព្រះនាមទ្រង់ នោះអ្នកនឹងមានព្រះវិញ្ញាណរបស់ទ្រង់គង់ជាមួយយើងជាដរាប ។ នៅក្នុងពិភពលោកដែលពោរពេញដោយឧបសគ្គនេះ វាងាយស្រួលនឹងវង្វេង ។ ប៉ុន្តែប្រសិនបើអ្នកមានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយអ្នកនោះ « ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះអ្នករាល់គ្នាអាចស្គាល់សេចក្ដីពិតនៃគ្រប់ការណ៍ទាំងអស់ » ( ម៉ូរ៉ូណៃ ១០:៥ ) ។ ព្រះវិញ្ញាណនៃព្រះអម្ចាស់អាចធ្វើជាអ្នកនាំផ្លូវអ្នក ហើយប្រទានពរដល់អ្នកនូវការប្រាប់ផ្លូវ ការណែនាំ និង ការការពារ ។

**២. ទ្រង់អាចប្រទានកម្លាំងដល់យើងដើម្បីទប់ទល់នឹងការល្បួងនានា**

ការការពារទប់ទល់នឹងការល្បួងដែលល្អ និង សំខាន់បំផុតនោះគឺជាសេចក្ដីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ ( សូមមើល អាលម៉ា ៣៧:៣៣ ) ។ នៅពេលយើងផ្ដោតចិត្តរបស់យើងលើព្រះគ្រីស្ទ នោះយើងអាចស្គាល់ការកុហករបស់សាតាំង ហើយចាប់យកការប៉ុនប៉ងរបស់វាដើម្បីបោកប្រាស់យើង ។ ដោយសារព្រះយេស៊ូវបានជួបនឹងការល្បួង ប៉ុន្តែពុំដែលចុះចាញ់ការល្បួងឡើយ យើងអាចពឹងផ្អែកលើទ្រង់ នៅពេលយើងជួបនឹងការល្បួង ។ នីហ្វៃបានបង្រៀនថា អស់អ្នកណាដែល « តោងជាប់តាម [ ព្រះបន្ទូលនៃព្រះ ] នោះនឹងមិនត្រូវវិនាសឡើយ សូម្បីតែការល្បួងទាំងឡាយ និងព្រួញភ្លើងទាំងឡាយរបស់មារសត្រូវក៏មិនអាចឈ្នះលើពួកគេដែរ » ( នីហ្វៃទី ១ ១៥:២៤ ) ។ នៅពេលយើងចងចាំព្រះអង្គសង្គ្រោះ និង ការបង្រៀនរបស់ទ្រង់ នោះទ្រង់អាចលើកយើងឡើង ហើយពង្រឹងយើងទប់ទល់នឹងការល្បួង ។

**៣. គំរូរបស់ទ្រង់នឹងដឹកនាំយើង**

ព្រះយេស៊ូវពុំគ្រាន់តែប្រាប់យើងពីកន្លែងដែលត្រូវទៅដើម្បីទទួលបានជីវិតអស់កល្បជានិច្ចឡើយ ទ្រង់បានដឹកនាំផ្លូវទៀតផង ។ ទ្រង់បានមានព្រះបន្ទូលថា « ទ្រង់គឺជាផ្លូវ សេចក្ដីពិត និងជីវិត » ( យ៉ូហាន ១៤:៦ ) ។ ព្រះគ្រីស្ទគឺជាគំរូដ៏ល្អឥតខ្ចោះរបស់យើង ។ អំឡុងពេលនៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ នោះព្រះយេស៊ូវបានបង្រៀន និង ធ្វើជាគំរូអំពីសេចក្ដីស្រឡាញ់ ភាពទន់ទាប ការបន្ទាបខ្លួន និង សេចក្ដីអាណិតអាសូរ ។ ទ្រង់បានចំណាយពេលវេលារបស់ទ្រង់ចំពោះការបង្រៀន ការបម្រើ និង ការស្រឡាញ់អ្នកដទៃ ។

### សម្រាប់ព័ត៌មានបន្ថែមអំពីពិធីសាក្រម៉ង់

*ដើម្បីរៀនបន្ថែមទៀតអំពីព្រះអង្គសង្គ្រោះ និង ពិធីសាក្រាម៉ង់ នោះអ្នកអាចអាន ៖*

- *ជែហ្វ្រី អ័រ ហូឡិន « This Do in Remembrance of Me »* Ensign, *ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ៦៧ ។*
- *ឆារិល អេ អេសព្លិន, « The Sacrament— a Renewal for the Soul »* Liahona, *Nov. ២០១៤, ១២ ។*



គ្រប់កិច្ចការទាំងអស់ដែលទ្រង់បានធ្វើ គឺទ្រង់គោរពតាមព្រះឆន្ទៈរបស់ព្រះវរបិតាទ្រង់ ( សូមមើល យ៉ូហាន ៥:៣០ ) ។ ព្រះអង្គសង្គ្រោះបានធ្វើជាគំរូនៅក្នុងគ្រប់កិច្ចការទាំងអស់ ដូចជារបៀបដែលយើងគប្បីរស់នៅ ហើយទ្រង់អញ្ជើញយើងទាំងអស់គ្នាឲ្យធ្វើតាមគំរូទ្រង់ ។

ប្រសិនបើអ្នកធ្លាប់រកឃើញថាអ្នកពុំដឹងថាត្រូវទៅទីណា ឬ ត្រូវធ្វើអ្វី ចូរចងចាំព្រះអង្គសង្គ្រោះ ។ ទ្រង់មានបន្ទូលថា « ខ្ញុំជាពន្លឺលោកីយ៍ អ្នកណាដែលតាមខ្ញុំ នោះមិនដែលដើរក្នុងសេចក្ដីងងឹតឡើយ គឺនឹងមានពន្លឺនៃជីវិតវិញ » ( យ៉ូហាន ៨:១២ ) ។

## ៤. ទ្រង់អាចជួយយើងបម្រើមនុស្សដទៃ

ព្រះយេស៊ូវបានដាក់សេចក្ដីត្រូវការរបស់មនុស្សដទៃលើសេចក្ដីត្រូវការផ្ទាល់ខ្លួនរបស់ទ្រង់ជានិច្ច ។ ទ្រង់ « បានយាងចុះឡើងធ្វើកិច្ចការល្អ » ( កិច្ចការ ១០:៣៨ ) ។ ទ្រង់បានព្យាបាលអ្នកឈឺ ហើយបានជួយអស់អ្នកដែលនៅជុំវិញទ្រង់ ។ នៅពេលយើងចងចាំព្រះយេស៊ូវ នោះយើងចងចាំទង្វើនៃការបម្រើដោយមិនគិតពីខ្លួនឯងដែលបង្ហាញពីព្រះជន្មរបស់ទ្រង់ ។ យើងក៏ចងចាំដែរថា ទ្រង់បានសុំយើងឲ្យបម្រើទ្រង់ តាមរយៈការបម្រើមនុស្សដទៃ ។ « កាលណាអ្នករាល់គ្នានៅក្នុងការបម្រើដល់មនុស្សទូទៅ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបម្រើ ដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ » ( ម៉ូសាយ ២:១៧ ) ។

ព្រះអម្ចាស់នឹងបើកភ្នែករបស់អ្នកឲ្យមើលឃើញអស់អ្នកដែលនៅជុំវិញអ្នក ដែលអ្នកអាចជួយពួកគេ ។ អ្នកនឹងត្រូវបានដឹកនាំក្នុងរបៀបដែលអ្នកអាចបម្រើពួកគេដោយអស់ពីសមត្ថភាព ។ ជីវិតរបស់អ្នកនឹងកាន់តែសប្បាយ ហើយកាន់តែពេញលេញ នៅពេលអ្នកធ្វើការបម្រើតូចតាច និងសាមញ្ញ ។ ការបម្រើមនុស្សដទៃនឹងនាំឲ្យមានអារម្មណ៍នៃភាពសុខសាន្ត និង សេចក្ដីអំណរទៅក្នុងជីវិតរបស់អ្នក ។

## ៥. យើងអាចប្រែចិត្តបាន

យើងទាំងអស់គ្នាបរាជ័យក្នុងការកាន់តាមបទបញ្ញត្តិពេញលេញតាមអ្វីដែលរំពឹងទុក ទោះបីយើងព្យាយាមដោយស្មោះសរក្ដី ប៉ុន្តែដោយសារព្រះជន្ម និង បេសកកម្មរបស់ព្រះយេស៊ូវគ្រីស្ទ នោះមានផ្លូវដើម្បីត្រឡប់មកវិញ ។

ការចងចាំព្រះយេស៊ូវគ្រីស្ទរំឭកយើងពីអំណោយទាននៃការប្រែចិត្ត ដែលបានប្រទានមកតាមរយៈដង្វាយធួនរបស់ទ្រង់ ។ ព្រះយេស៊ូវអញ្ជើញយើងទាំងអស់គ្នាឲ្យប្រែចិត្ត ហើយយើងមានបទពិសោធន៍នៃក្ដីអំណរនៅពេលយើងបែរចេញឆ្ងាយពីអំពើបាប ហើយងាកទៅរកទ្រង់ ។ នៅពេលយើងមានបំណងស្មោះសរដើម្បីផ្លាស់ប្ដូរ ហើយរក្សាបទបញ្ញត្តិ នោះព្រះអម្ចាស់សន្យាថា « អ្នកណាដែលប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួន អ្នកនោះឈ្មោះថាបានអត់ទោសឲ្យហើយ ហើយយើងជាព្រះអម្ចាស់ មិនចាំពីអំពើបាបទាំងនោះទៀតទេ » ( គ. និង ស. ៥៨:៤២ ) ។

ពេលអ្នកទទួលទានសាក្រាម៉ង់ អ្នកធ្វើការតាំងចិត្តដើម្បីចងចាំព្រះអង្គសង្គ្រោះជានិច្ច ។ ដរាបណាអ្នកទុកព្រះគ្រីស្ទនៅក្នុងគំនិតអ្នក ដរាបនោះទ្រង់នឹងក្លាយជាអង្គដ៏សំខាន់នៃជីវិតរបស់អ្នក ហើយដរាបនោះទ្រង់នឹងដឹកនាំ ព្រមទាំងណែនាំអ្នកឲ្យទៅដល់សក្ដានុពលដ៏ពោរពេញរបស់អ្នក ។ ការចងចាំព្រះអង្គសង្គ្រោះជានិច្ច នឹងប្រទានពរជ័យដល់អ្នកជាដរាប ។ ■



# ការរក្សាថ្ងៃឈប់សម្រាករបស់ខ្ញុំ

ដោយ ម៉ាខេនស៊ី ប្រោន

ខ្ញុំយឺតហើយ ! ខ្ញុំបានស្លៀកសម្លៀកបំពាក់ដ៏ស្រស់ស្អាត យកកៅស៊ូចងសក់ បើកឡានទៅព្រះវិហារ ចតឡាន ហើយប្រញាប់ចូលទៅក្នុងអគារ ។ ហ៊ឺ ! ខ្ញុំរកកៅអីអង្គុយនៅលើវេទិកា គឺចំពេលដែលប៊ីស្សពក្រោកឡើងដើម្បីចាប់ផ្ដើមការប្រជុំសាក្រាម៉ង់ ។

ខ្ញុំត្រូវឡើងនិយាយនៅថ្ងៃអាទិត្យនោះ ដូច្នោះខ្ញុំបានមើលការកត់ចំណាំរបស់ខ្ញុំយ៉ាងលឿន ដើម្បីប្រាកដថាខ្ញុំមិនភ្លេចអ្វីឡើយ ។ មិនយូរប៉ុន្មាន វាហាក់បីដូចជាពិធីសាក្រាម៉ង់បានចប់ ហើយខ្ញុំបានទៅថ្នាក់សាលាថ្ងៃអាទិត្យ ។ មានពិធីសាក្រាម៉ង់ជោគជ័យមួយទៀតហើយ !

តើវាជាពិធីសាក្រាម៉ង់ជោគជ័យទេ ?

អាទិត្យក្រោយមក ខ្ញុំបានចាប់ផ្ដើមឆ្ងល់ ។ មួយអាទិត្យទៀតបានកន្លងទៅ ហើយនៅពេលខ្ញុំអង្គុយនៅក្នុងការប្រជុំសាក្រាម៉ង់ ដោយពិចារណាពីអត្ថន័យនៃពិធីសាក្រាម៉ង់ចំពោះខ្ញុំ នោះមានគំនិតមួយបានផុសឡើងចំពោះខ្ញុំ ៖ ខ្ញុំបានតាំងចិត្តជាថ្មីរាល់សប្ដាហ៍ដើម្បីចងចាំព្រះយេស៊ូវគ្រីស្ទជានិច្ច ប៉ុន្តែតើខ្ញុំយកចិត្តទុកដាក់ធ្វើបែបនោះបានកម្រិតណា ?

ខ្ញុំចង់ផ្លាស់ប្ដូរ ដូច្នោះខ្ញុំបានសម្រេចចិត្តធ្វើផែនការប្រចាំសប្ដាហ៍ ។

- អំឡុងពេលនៃសប្ដាហ៍ ខ្ញុំចង់ចំណាយពេលពិចារណាពីឥរិយាបថរបស់ខ្ញុំ ហើយទូលសុំការអភ័យទោសពីអំពើបាបរបស់ខ្ញុំ ។ ខ្ញុំក៏ធ្វើឲ្យប្រាកដថាខ្ញុំទៅព្រះវិហារមុនម៉ោង ដើម្បីខ្ញុំអាចស្ដាប់តន្ត្រីពីមុនការប្រជុំ ហើយមានអារម្មណ៍ពីព្រះវិញ្ញាណ ។
- អំឡុងពិធីសាក្រាម៉ង់ ខ្ញុំនឹងចងចាំព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធួនរបស់ទ្រង់ ។ ខ្ញុំនឹងពិចារណាមើលឡើងវិញពីអ្វីដែលខ្ញុំបានធ្វើត្រូវ និង អ្វីដែលខ្ញុំបានធ្វើខុស ។ ខ្ញុំនឹងសួរខ្លួនឯងថា « ព្រះអម្ចាស់អើយ តើខ្ញុំនៅខ្វះអ្វីទៀត ? » ( សូមមើល ម៉ាថាយ ១៩:២០ ) ។
- រៀងរាល់ថ្ងៃបន្ទាប់ពីពិធីសាក្រាម៉ង់ ខ្ញុំនឹងអធិស្ឋានសុំជំនួយដើម្បីកែលម្អ ហើយចងចាំព្រះគ្រីស្ទ ។

នៅពេលខ្ញុំបានធ្វើតាមផែនការរបស់ខ្ញុំ នោះខ្ញុំពិតជាស្រឡាញ់ពិធីសាក្រាម៉ង់កាន់តែខ្លាំងឡើង ។ ខ្ញុំចូលចិត្តអធិស្ឋានទៅព្រះវរបិតាសួគ៌ ហើយនិយាយជាមួយទ្រង់អំពីជីវិតរបស់ខ្ញុំ ។ ដោយមិនគិតពីឥរិយាបថរបស់ខ្ញុំកាលពីអាទិត្យមុន ខ្ញុំមានអំណរគុណជានិច្ចចំពោះដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និង ឱកាសដើម្បីផ្លាស់ប្ដូរ ហើយកែប្រែខ្លួនឲ្យបានប្រសើរឡើង ។ ឥឡូវនេះខ្ញុំដឹងថាពិធីសាក្រាម៉ង់គឺពុំមែនគ្រាន់តែសម្រាប់តែថ្ងៃអាទិត្យប៉ុណ្ណោះទេ វាគឺ *រៀងរាល់* ថ្ងៃ ។

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*

រចនាលម្អរូបថតដោយ ដាវីឌ ស្ដូឃី

# តើមានអារម្មណ៍មិនស៊ីប់ឬ ?

« តើអ្នកបានគិតល្អិតល្អន់អំពីព្រះអង្គសង្គ្រោះ និងការពលិកម្មដ៏ធួនរបស់ទ្រង់សម្រាប់អ្នក ពេលអ្នកត្រូវបានសូមឲ្យរៀបចំ ប្រសិទ្ធិពរ ចែក ឬទទួលទានសាក្រាម៉ង់ដែរឬទេ ? »

អែលឌើរ អិម រ័សេល បាឡឺដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ( « The Greatest Generation of Young Adults » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ៦៨ ) ។



# ការរៀនធ្វើជា ពន្លឺដល់ពិភពលោកនេះ

ដោយ រិចទ័រ ឌី ដេសឺ គ្រូស វ៉ាហ្គាស



ខ្ញុំបានកើតនៅក្នុង សាធារណរដ្ឋ ដូមីនីក ហើយត្រូវបានចិញ្ចឹមឲ្យធំឡើងនៅក្នុងសាសនាចក្រ ។ អ្នកដឹកនាំដ៏អស្ចារ្យជាច្រើនបានព្យាយាមជួយខ្ញុំឲ្យដើរតាមផ្លូវត្រូវអំឡុងពេលចម្រើនវ័យធំឡើង ។ ខ្ញុំមានក្តីស្រមៃពីការបម្រើបេសកកម្ម និងការជួយមនុស្សទូទៅ ។

ដោយសារឪពុករបស់ខ្ញុំបានប្តូរទៅនៅសហរដ្ឋ ដើម្បីព្យាយាមស្វែងរកជីវិតកាន់តែប្រសើរសម្រាប់ពួកយើង នោះម្តាយរបស់ខ្ញុំបានចិញ្ចឹមបងស្រីៗ និង ខ្ញុំតែម្នាក់ឯង ។ ជូនកាលខ្ញុំមានអារម្មណ៍ឯកោ ប៉ុន្តែខ្ញុំមិនធ្លាប់ឯកោឡើយ ដោយសារខ្ញុំអាចនិយាយអំពីការលំបាកនានានៅក្នុងជីវិតរបស់ខ្ញុំ ជាមួយថ្នាក់ដឹកនាំសាសនាចក្ររបស់ខ្ញុំ ។

ពេលយើងបានប្តូរទៅរស់នៅសហរដ្ឋ ការសាកល្បងដ៏ធំបានចាប់ផ្តើមចំពោះខ្ញុំ ។ យើងបានចូលរួមសាខាតូចមួយ ហើយខ្ញុំមានថ្នាក់ដឹកនាំដែលចង់ជួយខ្ញុំ ប៉ុន្តែមិត្តភក្តិនៅសាលារបស់ខ្ញុំបានព្យាយាមទាញខ្ញុំឲ្យធ្លាក់ចេញពីផ្លូវនៃដំណឹងល្អ ។ ជាអកុសខ្ញុំបានចាប់ផ្តើមនិយាយទៅកាន់ម្តាយខ្ញុំដោយច្រឡើសបើស ហើយកម្រនឹងស្តាប់តាមការទូន្មានរបស់គាត់ណាស់ ។

ខ្ញុំទៅព្រះវិហាររាល់សប្តាហ៍ ប៉ុន្តែខ្ញុំពិតជាគ្មានបំណងទៅឡើយ ហើយខ្ញុំពុំដឹងឡើយថា តើខ្ញុំចង់ទៅបម្រើបេសកកម្មទៀតឬអត់នោះទេ ។

នាព្រឹកមួយខ្ញុំបានបើកព្រះគម្ពីរមរមន ហើយវាបើកចំទំព័រនៃខគម្ពីរដែលខ្ញុំពេញចិត្ត នីហ្វៃទី ៣ ១២:១៤–១៦៖

« ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា យើងឲ្យអ្នករាល់គ្នាធ្វើជាពន្លឺនៃប្រជាជននេះ ។ ឯទីក្រុងណាដែលនៅលើភ្នំនោះលាក់មិនកំបាំងទេ ។

មើលចុះ តើមនុស្សអុជទៀន ហើយដាក់នៅក្រោមថាំងឬ ? ទេ ប៉ុន្តែដាក់នៅលើជើងទៀនវិញ នោះទើបនឹងឲ្យពន្លឺដល់អ្នកដែលនៅក្នុងផ្ទះទាំងអស់គ្នា

ដូច្នេះ ចូរឲ្យពន្លឺរបស់អ្នករាល់គ្នា បានភ្លឺនៅមុខប្រជាជននេះ ដើម្បីឲ្យគេអាចឃើញការល្អរបស់អ្នករាល់គ្នា ហើយសរសើរតម្កើងដល់ព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅលើស្ថានសួគ៌ » ។

ខ្ញុំមានក្តីអំណរជាខ្លាំងដើម្បីអានខគម្ពីរនេះ ដោយសារវាជួយខ្ញុំឲ្យចងចាំពីអ្វីដែលខ្ញុំបានរៀននៅក្នុងថ្នាក់សិក្ខាសាលា និងផែនការដ៏មហិមារបស់ព្រះវរបិតាយើង ។ ដូច្នេះខ្ញុំបានសម្រេចចិត្តព្យាយាមធ្វើជាពន្លឺដល់ពិភពលោក ។

ខ្ញុំបានអញ្ជើញបងប្អូនជីដូនមួយរបស់ខ្ញុំពីរនាក់មកព្រះវិហារ ។ ម្នាក់មិនសូវសកម្ម ហើយគាត់បានសកម្មវិញ ។ ម្នាក់ទៀតពុំមែនជាសមាជិកឡើយ ហើយខ្ញុំបានជ្រមុជទឹកឲ្យគាត់ ។

មួយឆ្នាំក្រោយមក ខ្ញុំបានទទួលការហៅបម្រើបេសកកម្មទៅ កាលីហ្វូញ៉ា ស.រ.អា. ។ នៅពេលខ្ញុំបានបម្រើ ខ្ញុំបានឃើញដោយឥតសង្ស័យថា នេះគឺដំណឹងល្អដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទ ។ នៅពេលខ្ញុំបានជួយមនុស្ស ទីបន្ទាល់របស់ខ្ញុំបានកើនកាន់តែច្រើនឡើង ហើយគ្រប់ពេលដែលខ្ញុំអានព្រះគម្ពីរ ខ្ញុំសូត្រខគម្ពីរនៅក្នុងនីហ្វៃទី ៣ នោះជានិច្ច ដើម្បីធ្វើជាពន្លឺដល់ពិភពលោកនេះ ។ ■

*អ្នកនិពន្ធរស់នៅក្នុង សាធារណរដ្ឋ ដូមីនីក ។*



# មិនចាំបាច់ប្អូនគឺជានរណានោះទេ

ដោយ លីនដា ដាវីស
ផ្អែកទៅលើដំណើររឿងពិត

*អែនឌី បានគិតថា « អូ អត់ទេ ។ តើមានអ្វីនឹងកើតឡើង ប្រសិនបើខ្ញុំពុំបានផ្សារភ្ជាប់នឹងគ្រួសារខ្ញុំនោះ ? »*



« *ខ្ញុំជាកូនរបស់ព្រះ ហើយទ្រង់បានចាត់ខ្ញុំមក* » ( សៀវភៅចម្រៀងកុមារ *ទំព័រ ២* ) ។

អែនឌី បានគិតនៅពេលនាងមើលកញ្ចក់ « ខ្ញុំស្អាតហើយ » ។ នាងពាក់រូបពណ៌ក្រហមដែលនាងពេញចិត្ត ។ នាងចង់ឲ្យខ្លួននាងមើលទៅស្អាតជានិច្ចនៅថ្ងៃអាទិត្យ ។ នាងបានរត់ចុះទៅជាន់ក្រោមញ៉ាំអាហារពេលព្រឹក ។

អែនឌី បានញ៉ាំនំប៉័ងមួយដុំចុងក្រោយរបស់នាង នៅពេលឡានរបស់គ្រួសារ រីឌើរ ស៊ីផ្លេរនៅលើផ្លូវ ។ « ជំរាបលា ម៉ាក់ ! ជំរាបលា ប៉ា ! » អែនឌី បាននិយាយ ថើបពួកគាត់ នៅពេលនាងរត់ចេញទៅក្រៅ ។

ទោះបីជា ម៉ាក់ និង ប៉ាពុំមែនជាសមាជិកសាសនាចក្រក្ដី ពួកគាត់បានលើកទឹកចិត្តអែនឌីឲ្យទៅព្រះវិហាររាល់សប្ដាហ៍ ។ គ្រួសារ រីឌើរបានដឹកនាងស្ទើរតែរាល់ថ្ងៃអាទិត្យ តាំងពីនាងបានជ្រមុជទឹក និង បញ្ជាក់ហើយមក ។ អែនឌី ចូលចិត្តរបៀបដែលពួកគេធ្វើឲ្យនាងមានអារម្មណ៍ថាគេស្វាគមន៍ និង ស្រឡាញ់នាង ។

បន្ទាប់ពីការប្រជុំសាក្រាម៉ង់ វាដល់ម៉ោងថ្នាក់កុមារ ។ អែនឌី ចូលចិត្តនៅក្នុងថ្នាក់ ក្លាហានរបស់បងប្រុស និង បងស្រី ឡុងណាស់ ។ ពួកគាត់ចិត្តល្អ ហើយពួកគាត់តែងតែបង្រៀនមេរៀនល្អបំផុត ។

បងស្រី ឡុង និយាយថា « ថ្ងៃនេះយើងនឹងនិយាយអំពីព្រះវិហារបរិសុទ្ធ ។ តើយើងស្គាល់អ្វីខ្លះអំពីព្រះវិហារបរិសុទ្ធ ? »

អែនឌីបានដឹងចម្លើយមួយ ៖ « យើងអាចធ្វើបុណ្យជ្រមុជទឹកនៅក្នុងព្រះវិហារបរិសុទ្ធ » ។ នាងមានក្ដីរំភើបអំពីរឿងនោះ ដោយសាររាល់ឆ្នាំយុវនារីនៅក្នុងវួដរបស់នាង បានធ្វើដំណើរទៅព្រះវិហារបរិសុទ្ធដើម្បីធ្វើបុណ្យជ្រមុជទឹក ។ មិនយូរប៉ុន្មានអែនឌី អាចទៅទីនោះផងដែរ !

« អស្ចារ្យណាស់ អែនឌី ។ តើយើងដឹងអ្វីផ្សេងទៀត ? »

អាលីសុន មិត្តភក្តិរបស់អែនឌីបាននិយាយថា « អ្នកអាចរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ » ។

បងស្រី ឡុង និយាយថា « ល្អណាស់ ។ តើមានអ្វីផ្សេងទៀតទេ ? »

អាលីសុន បានបន្ថែមថា « ក្រុមគ្រួសារអាចនៅជាមួយគ្នាជានិរន្តរ៍ នៅពេលយើងផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ » ។

អែនឌីបានគិតថា « ប៉ុន្តែគ្រួសារខ្ញុំអត់បានផ្សារភ្ជាប់ផងហ្នឹង ។ ម៉ាក់ និង ប៉ាពុំបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធទេ ! » ភ្លាមនោះទឹកមុខនាងឡើងក្រហម ហើយនាងបានចាប់ផ្ដើមយំ ។

បងស្រី ឡុងបានសួរ « អែនឌី តើប្អូនកើតអី ? »

អែនឌី បានដកដង្ហើមធំ ដោយព្យាយាមមិនយំ ។ ប៉ុន្តែនាងមានអារម្មណ៍ថា បេះដូងរបស់នាងលោតខុសចង្វាក់រហូតដល់ចប់ម៉ោងរៀន ។

រូបគំនូរដោយ ប្រាដ ធៀរ



ពេលចប់ថ្នាក់ បងស្រី ឡុង បានអង្គុយក្បែរ អែនឌី ហើយដាក់ដៃលើស្មានាង ។ គាត់បានសួរថា « តើប្អូនមានរឿងអ្វី ? »

អែនឌី និយាយថា « ខ្ញុំមិនអាចរស់នៅជាមួយ ម៉ាក់ និង ប៉ារបស់ខ្ញុំជានិរន្តរ៍បានទេ ។ ពួកគាត់ពុំបានរៀបការនៅក្នុងព្រះវិហារបរិសុទ្ធទេ ។ តើខ្ញុំនឹងក្លាយជាកម្មសិទ្ធិរបស់នរណាបន្ទាប់ពីខ្ញុំស្លាប់ទៅ ? តើព្រះវរបិតាសួគ៌នៅតែស្រឡាញ់ខ្ញុំឬទេ ទោះបីជាឪពុកម្ដាយខ្ញុំមិនមែនជាសមាជិកនោះ ? »

បងស្រី ឡុង បានមើលចំកែវភ្នែករបស់អែនឌី ។ « មិនថាប្អូនគឺជានរណា ហើយមិនថាគ្រួសាររបស់ប្អូនបានទៅព្រះវិហារបរិសុទ្ធឬអត់នោះទេ ប្អូននៅតែជាផ្នែកមួយនៃគ្រួសាររបស់ព្រះវរបិតាសួគ៌ ។ *ប្អូន*អាចនៅជិតទ្រង់ ហើយធ្វើជាគំរូដល់អ្នកដទៃទៀត ។ ទ្រង់នឹងស្រឡាញ់ ណែនាំ ហើយការពារប្អូនជានិច្ច មិនថាមានរឿងអ្វីកើតឡើងឡើយ ។ ទ្រង់សព្វព្រះទ័យប្រទានពរដល់ប្អូន និង គ្រួសាររបស់ប្អូន ។ អែនឌី ប្អូនជាកូនរបស់ព្រះ » ។

បន្ទាប់ពីនោះ អែនឌី ហាក់បីដូចជាមានចិត្តរំភើប ហើយបេះដូងនាងឈប់លោតខុសចង្វាក់ទៀតហើយ ។ ឥឡូវនាងមានអារម្មណ៍កក់ក្ដៅក្នុងចិត្តវិញហើយ ។ នាងបានដឹងថាអ្វីដែលគ្រូបង្រៀនរបស់នាងបាននិយាយគឺជាការពិត ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*



## តើអ្នកអាចធ្វើអ្វីខ្លះ ?

តើអ្នកអាចធ្វើអ្វីខ្លះ ប្រសិនបើឪពុកម្ដាយរបស់អ្នក ឬ នរណាម្នាក់នៅក្នុងក្រុមគ្រួសារអ្នក ពុំចង់ធ្វើជាសមាជិកសាសនាចក្រនោះ ?

- សូមចាំថា ពួកគេមានសេរីភាពជ្រើសរើស ហើយថាព្រះវរបិតាសួគ៌ស្រឡាញ់ពួកគេ ។
- សូមឲ្យពួកគេដឹងថា អ្នកស្រឡាញ់ពួកគេ ។
- សូមធ្វើជាគំរូល្អដល់ពួកគេតាមរយៈការរស់នៅតាមដំណឹងល្អ ។
- សូមចងចាំពីរឿងល្អៗអំពីពួកគេ ។
- សូមអធិស្ឋានថាព្រះវរបិតាសួគ៌នឹងជួយពួកគេឲ្យទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ទ្រង់ ហើយដឹកនាំពួកគេទៅសាសនាចក្រ ។




# ក្លាវែនប្រកួតនឹងកីឡាករជើងឯក

**ដោយ ឡូរី ហ្វូលើរ**
ទស្សនាវដ្ដីសាសនាចក្រ
ផ្អែកទៅលើដំណើររឿងពិត

ក្លាវែនបានក្រឡេកមើលទៅក្រៅកញ្ចក់ឡាន នៅពេលមើលឃើញកំពង់ផែ ។ ទូកអណ្ដែតលើទឹកនៅពីមុខផ្ទះ និង ហាងជាច្រើនដែលមានពណ៌ចម្រុះគ្នា ។ ខូភិនហាហ្គិន ដាណាម៉ាក ជាទីក្រុងមួយដ៏ស្រស់ស្អាតដែលមាន វាំង អគារស្ដឹមស្ដែ និង សួនឧស្យានស្អាតៗ ។ វាមិនដូចជាទីក្រុងរបស់ក្លាវែននៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា.ឡើយ ។ ក្លាវែនអាចស្រមៃគិតពីផ្លូវដីហុយ ដែលជាផ្លូវគាត់រត់ប្រណាំងគ្នាកាលពីក្មេង ។ ឥឡូវនេះគាត់គឺជាសមាជិកម្នាក់នៅក្នុងក្រុមកីឡាកររត់ប្រណាំងសហរដ្ឋ ហើយថ្ងៃស្អែកគាត់នឹងជួបប្រកួតជាមួយនឹងអ្នករត់ប្រណាំងជនជាតិដាណឺម៉ាកដ៏ល្បីមួយរូបនៅក្នុងការប្រកួតដ៏សំខាន់មួយ ។

ឡានបានឈប់នៅសាលប្រជុំតូចមួយ ជាទីដែលការប្រជុំសាសនាចក្របានចាប់ផ្ដើម ។

កាលក្លាវែនបានចូលទៅសរសៀៗពីខាងក្រោយការប្រជុំ អ្នកផ្សព្វផ្សាយសាសនាម្នាក់អង្គុយនៅលើវេទិកាបានស្គាល់គាត់ ពីការអានអត្ថបទសារព័ត៌មានអំពីការប្រកួតពីម្សិលមិញ ។ ប្រធានសាខាបានស្នើសុំឲ្យក្លាវែនឡើងទៅលើវេទិកា ហើយនិយាយ ។

បន្ទាប់មកក្លាវែនប្រាប់អំពីមូលហេតុដែលគាត់មកព្រះវិហារ នោះមានក្មេងប្រុសម្នាក់បានក្រោកឡើង ហើយលើកដៃគាត់ ។ គាត់បានសួរ « តើអ្នកគិតថាអ្នកអាចយកឈ្នះលើជើងឯកដាណឺម៉ាកម្នាក់នោះដែរឬទេ ? »

ក្លាវែនទំនងដូចជាមិនដឹងថាត្រូវនិយាយអ្វីនោះទេ ។ កីឡាកររត់ប្រណាំង ដាណឺម៉ាក *បាន* រត់ក្នុងរយៈពេលតិច ក្នុងចម្ងាយជាច្រើនគីឡូម៉ែត្រនៅរដូវកាលប្រកួតនោះ ។

អ្នកផ្សព្វផ្សាយសាសនាម្នាក់នោះបានឆ្លើយពីមុនក្លាវែនបានឆ្លើយ « ពិតមែនហើយគាត់អាចធ្វើបាន ។ ដោយសារគាត់រស់នៅតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ » ។ គាត់បានបើកគម្ពីររបស់គាត់ទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩ ។ គាត់បានអានការសន្យាថា អស់អ្នកដែលគោរពតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ « នឹងរត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ » (ខទី ២០) ។

តើក្លាវែនអាចនិយាយថាដូចម្ដេច ? *គាត់*បានដឹងថាពាក្យសម្ដីនៃប្រាជ្ញាវាងវៃគឺជាការពិត ។

រូបគំនូរដោយ ម៉ាត ស្មីធ




## ជម្រើសរបស់ក្លាវែន

ក្លាវែន អែហ្វ រ៉ូប៊ីសុន បានរត់ប្រណាំងនៅក្នុងកីឡាអូឡាំពិករដូវក្ដៅឆ្នាំ ១៩៤៨ ហើយក្លាយជាគ្រូបង្វឹកអ្នករត់ប្រណាំងដ៏អស្ចារ្យនៅមហាវិទ្យាល័យ ។ កាលគាត់នៅក្មេង គាត់បានសន្យាថាគាត់នឹងគោរពតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃជានិច្ច ។ គាត់បានដឹងថា ការណ៍នេះពុំធ្វើឲ្យគាត់ឈ្នះគ្រប់ការប្រកួតរបស់គាត់ឡើយ ។ ប៉ុន្តែគាត់បានដឹងថាព្រះវរបិតាសួគ៌អាចជួយគាត់ ធ្វើឲ្យអស់ពីសមត្ថភាពរបស់ខ្លួន ពេលគាត់មានភាពស្អាតស្អំ និង សក្តិសមព្រមទាំងមានសេចក្ដីជំនឿ ។

ហើយកាលគាត់នៅពីក្មេងគាត់បានសន្យាថាគាត់នឹងគោរពតាមច្បាប់នេះជានិច្ច ។ ប៉ុន្តែការគោរពច្បាប់នេះតែមួយមុខគត់នោះ ពុំមែនមានន័យថាគាត់អាចឈ្នះលើការប្រកួតនេះឡើយ ។ ភាពជោគជ័យក៏តម្រូវឲ្យមានការអនុវត្ត និង មានជំនាញ ។ នៅពេលក្លាវែនបានចាកចេញពីការប្រជុំ គាត់បានគិតថា « មែនហើយគ្មាននរណាម្នាក់មកពីសាសនាចក្រ នឹងទៅមើលការប្រកួតនៅថ្ងៃស្អែកឡើយ » ។

នៅល្ងាចបន្ទាប់មក ពេលក្លាវែនកំពុងហាត់សមការប្រកួតរបស់ខ្លួន នោះគាត់បានមើល ហើយបានឃើញអ្នកផ្សព្វផ្សាយសាសនាពីរនាក់នៅក្នុងក្រុមយុវជនមួយដែលមានគ្នាប្រមាណ ១៧ នាក់ ។ ពួកគេ *បាន* មក !

នៅពេលពួកគេមកកាន់តែជិត មានអ្នកផ្សព្វផ្សាយបានខ្សឹបក្លាវែនថា « ប្រសិនបើអ្នកធ្លាប់រត់នៅក្នុងជីវិតរបស់អ្នក នោះអ្នកនឹងរត់បានកាន់តែល្អនាយប់នេះ » ។ ក្មេងប្រុសជាច្រើនពុំមែនជាសមាជិកសាសនាចក្រទេ ប៉ុន្តែបានមកជាមួយមិត្តភក្តិរបស់ខ្លួន ដើម្បីមើលឃើញថា តើច្បាប់ពាក្យសម្ដីនៃប្រាជ្ញាវាងវៃនោះពិតឬទេ ។

ក្លាវែនព្រួយបារម្ភណាស់ ។ នៅក្នុងការប្រកួតនេះ សមត្ថភាពរបស់គាត់ប្រហែលជាមិនល្អគ្រប់គ្រាន់ឡើយ ។ ប៉ុន្តែគាត់កំពុងធ្វើតាមគោលការណ៍មួយនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ គាត់ *ត្រូវតែ* ឈ្នះ ។ គាត់ពុំធ្លាប់អធិស្ឋានសុំឲ្យឈ្នះពីមុនឡើយ ប៉ុន្តែគាត់បានរកបន្ទប់ទំនេរមួយដើម្បីអធិស្ឋាន ។

គាត់បានអធិស្ឋានថា « ឱព្រះវរបិតា ដែលគង់នៅឋានសួគ៌ ខ្ញុំដឹងថាពាក្យសម្ដីនៃប្រាជ្ញាវាងវៃគឺពិត ហើយខ្ញុំមិនដែលរំលោភបំពានលើវាឡើយ ។ សូមប្រទានពរដល់ខ្ញុំនូវជោគជ័យនៅក្នុងការប្រកួតនេះ » ។ នៅពេលគាត់ដើរចេញទៅទីចាប់ផ្ដើម គាត់បានដឹងថាព្រះវរបិតាសួគ៌បានស្ដាប់ឮការអធិស្ឋានរបស់គាត់ ។ គាត់បានទុកចិត្តលើព្រះហឫទ័យរបស់ព្រះវរបិតាសួគ៌ ។

នាល្ងាចនោះមានភ្លៀងធ្លាក់ ហើយមានភក់ ។ នៅពេលក្លាវែនចាប់ផ្ដើមការប្រកួត វាហាក់បីដូចជាគាត់បានរត់អស់ជាច្រើនគីឡូម៉ែត្រមកហើយ ។ ល្បឿនរត់នោះលឿនណាស់ ហើយជើងឯង ដាណឺម៉ាកនោះបានរត់ទៅមុនគាត់ ។ ប៉ុន្តែនៅពេលក្លាវែនបានរត់បញ្ចប់ជុំទីបី ភ្លាមនោះគាត់មិននឿយហត់ទៀតឡើយ ។ គាត់បានចាប់ផ្ដើមរត់លឿនជាងមុន ហើយវាអត់ឈឺអ្វីឡើយ ។ រត់ទៅកាន់តែលឿនជាងមុន ហើយវាអត់ឈឺអ្វីឡើយ ។ គាត់បានរត់ហួសជើងឯក ដាណឺម៉ាក ហើយ *នៅតែ* រត់ទៅមុនយ៉ាងលឿន ។

នៅពេលក្លាវែនបានរត់មកដល់ជុំត្រឡប់វិញ គ្រូបង្វឹករបស់គាត់បានស្រែកថា « បន្ថយល្បឿន ! ប្អូននឹងមិនអាចរត់ដល់ទីផ្ដាច់ព្រ័ត្រឡើយ ! » ។ ប៉ុន្តែក្លាវែនបានដឹងថា គាត់អាចបន្តរត់ទៀតបាន ។ ហើយនៅពេលគាត់បញ្ចប់ការប្រកួតរបស់ខ្លួន គាត់បានរត់លឿនជាងកីឡាករ ដាណឺម៉ាកនោះច្រើនជាង ៤៦ ម៉ែត្រ ! គាត់បានដឹងថាគាត់ឈ្នះដោយសារព្រះវរបិតាសួគ៌បានឆ្លើយតបការអធិស្ឋានរបស់គាត់ ហើយដោយសារពាក្យសម្ដីនៃប្រាជ្ញាវាងវៃគឺជាការពិត ។ ■

# មិត្តភក្តិ និង សេចក្តីជំនឿ

ដោយ មេលីសា ហាត រដ្ឋ យូថាហ៍ ស.រ.អា.




ជំរាបសួរ ! ខ្ញុំឈ្មោះ អីវ៉ាណា ។

ខ្ញុំរស់នៅក្នុង បូហ្គូតា កូឡុំប៊ី ហើយខ្ញុំបានឈរយ៉ាងរឹងមាំ ដោយចែកចាយដំណឹងល្អជាមួយ មិត្តភក្តិ និង គ្រួសាររបស់ខ្ញុំ ។



*ខ្ញុំទៅរៀននៅសាលាកាតូលិក ។ ជំនឿរបស់ខ្ញុំមួយចំនួន ផ្សេងពីអស់អ្នកដែលនៅក្នុងថ្នាក់ និង គ្រូបង្រៀនរបស់ខ្ញុំ ប៉ុន្តែពួកគេគោរពខ្ញុំ ហើយខ្ញុំគោរពពួកគេ ។ ពួកគេចង់ដឹងពី សាសនារបស់ខ្ញុំ ហើយខ្ញុំត្រូវតែចែកចាយវាជាមួយពួកគេ ! ឥឡូវនេះខ្ញុំនៅជាមួយមិត្តភក្តិរបស់ខ្ញុំគឺ លីសា ។*



គ្រូម្នាក់បានសួរខ្ញុំ ប្រសិនបើយើងមានជំនឿដូចគ្នាទៅនឹងពួកកាតូលិកដែរឬទេ ។ ខ្ញុំប្រាប់គាត់ថា យើងជឿលើព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំក៏និយាយអំពីព្រះគម្ពីរមរមន ព្រះគម្ពីរប៊ីប និង គោលលទ្ធិ និង សេចក្ដីសញ្ញា ។

ប៉ារបស់ខ្ញុំពុំមែនជាសមាជិកនៃសាសនាចក្រឡើយ ប៉ុន្តែគាត់បានមកចូលរួមកម្មវិធីផ្សេងៗជាញឹកញាប់ ។ ខ្ញុំឌឹងគាត់ថា គាត់គឺជា « ពួកកាតាលិកមរមន » ។

យើងបានទៅទស្សនាទីក្រុង សលត៍ លេក ពេលសន្និសីទទូទៅ ហើយបានស្ដាប់ប្រធានម៉នសុន មានប្រសាសន៍ ។ ប្រសាសន៍របស់លោកគឺអស្ចារ្យណាស់ ហើយប្រសាសន៍នោះបង្រៀនអំពីដំណឹងល្អ ។





ខ្ញុំបានអញ្ជើញមិត្តភក្ដិម្នាក់មកពីសាលាមកចូលរួមបុណ្យជ្រមុជទឹករបស់ខ្ញុំ ហើយនាងបានមក ! ខ្ញុំរីករាយណាស់ដែលបានចែកចាយបទពិសោធន៍ជាមួយនាង ។



ព្រះវិហារបរិសុទ្ធ បូហ្គូតា កូឡុំប៊ីស្រស់ស្អាតណាស់ ។ ខ្ញុំចង់ចូលទៅក្នុងព្រះវិហារបរិសុទ្ធនៅថ្ងៃណាមួយ ដូច្នោះខ្ញុំអាចរៀនបន្ថែមទៀតពីដំណឹងល្អ ។ មិត្តភក្ដិរបស់ខ្ញុំឈ្មោះ ឡូរ៉ាបានមកជាមួយខ្ញុំ ។



## យោបល់របស់អ៊ីវ៉ាំណា
# ដើម្បីឈរយ៉ាងរឹងមាំ

ញញឹម ហើយចែកចាយរឿងនានាពីសាសនាចក្រ និង ព្រះគម្ពីរជាមួយអ្នកដទៃ ។



ចូលរួមការប្រជុំសាសនាចក្ររៀងរាល់ថ្ងៃអាទិត្យ ។

ធ្វើរាត្រីជួបជុំក្រុមគ្រួសារ ។

ព្យាយាមអានព្រះគម្ពីររាល់ថ្ងៃ ។

ចម្លើយមកពីសាវក



# តើអ្នកផ្សព្វផ្សាយសាសនាត្រូវបានហៅដោយរបៀបណា ?

**ដោយអែលឌើរ**
**អិម រ័សុល បាឡឺដ**
ក្នុងកូរ៉ុមនៃពួក
សាវកដប់ពីរនាក់




បន្ទាប់មក ដោយព្រះចេស្ដានៃព្រះវិញ្ញាណរបស់ព្រះអម្ចាស់ ពួកលោកចាត់តាំង
អ្នកឲ្យទៅបេសកកម្មមួយនៃបេសកកម្មទាំង ៤០៩ របស់សាសនាចក្រ ។

*ដកស្រង់ចេញពី « The Greatest Generation of Young Adults »* Liahona,
*ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ៦៧–៧០ ។*



# ពេលម្ដាយ និង ឪពុកខ្ញុំឈ្លោះគ្នា ខ្ញុំមានអារម្មណ៍ព្រួយបារម្ភ និង សោកសៅ ។ តើខ្ញុំអាចធ្វើអ្វីបាន ?



អ្នកអាចអធិស្ឋាន ដើម្បីជួយម្ដាយ និង ឪពុករបស់អ្នកឲ្យយកឈ្នះលើបញ្ហារបស់ពួកគាត់ ហើយច្រៀងចម្រៀងព្រះវិហាររហ៊ុមៗ ដើម្បីឲ្យអ្នកសប្បាយចិត្តឡើង ។

**អាឌីសុន អេស អាយុ ១០ ឆ្នាំ រដ្ឋ វ៉ាស៊ីនតោន ស.រ.អា.**



ខ្ញុំអាចអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ ។ វាតែងតែធ្វើឲ្យខ្ញុំមានអារម្មណ៍ប្រសើរជាងមុន ។

**ហេឌិន អេច អាយុ ៦ ឆ្នាំ អាល់បើតា ប្រទេសកាណាដា**



បងប្អូនខ្ញុំ និង ខ្ញុំទៅបន្ទប់របស់យើង ហើយស្ដាប់ក្រុមចម្រៀងរោងឧបោសថ ។ ការធ្វើបែបនេះបានជួយពួកយើងទទួលអារម្មណ៍សុខសាន្ត ។

**បែន អិម អាយុ ១១ ឆ្នាំ ទីក្រុង ប្រិសបាន អូស្ត្រាលី**



ដើម្បីធ្វើឲ្យពួកគាត់សប្បាយចិត្ត ខ្ញុំនិទានរឿងកំប្លែង ហើយប្រាប់ពួកគេអំពីការសិក្សានៅសាលារបស់ខ្ញុំ ។ នៅពេលពួកគាត់ចាប់ផ្ដើមសើច ខ្ញុំមានអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធប្រាប់ខ្ញុំថា ខ្ញុំបានធ្វើរឿងត្រឹមត្រូវ ។

**អ៊ីឡេណា អិម អាយុ ១២ ឆ្នាំ រដ្ឋ កាលីហ្វូញ៉ា ស.រ.អា.**



ខ្ញុំនឹងអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ ហើយទូលសុំទ្រង់ឲ្យជួយឪពុកម្ដាយខ្ញុំ ពេលពួកគាត់ឈ្លោះប្រកែកគ្នា ប្រយោជន៍ឲ្យពួកគាត់អាចទទួលអារម្មណ៍ពីព្រះវិញ្ញាណ ហើយដោះស្រាយបញ្ហារបស់ពួកគាត់ ។

**អ៊ីថាន អិម អាយុ ១១ ឆ្នាំ រដ្ឋ កាលីហ្វូញ៉ា ស.រ.អា.**



**ម៉ាស្ស ៖** ខ្ញុំនឹងឱបពួកគាត់ ហើយច្រៀងចម្រៀងថ្នាក់កុមារ ដើម្បីរំឭកពួកគាត់អំពីព្រះយេស៊ូវ ។



**ហ្គេប ៖** ធ្វើឲ្យឪពុកម្ដាយរបស់អ្នកសប្បាយចិត្ត ដោយគូររូបគ្រួសាររបស់អ្នកនៅលើឋានសួគ៌ ។

**ម៉ាស្ស និង ហ្គេប ស៊ី អាយុ ៦ និង ១០ ទីក្រុង កូឈី ប្រទេស ឥណ្ឌា**

## សំណួរបន្ទាប់

**« តើខ្ញុំដឹងថា ខ្ញុំធំល្មមនឹងចាប់ផ្ដើមតមអាហារបានដោយរបៀបណា ? »**

តើប្អូនៗមានដំបូន្មានអ្វីខ្លះ ? សូមផ្ញើចម្លើយ និង រូបថតរបស់ប្អូន ឲ្យបានត្រឹមថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៦ ។ សូមផ្ញើតាមអ៊ិនធើរណែតនៅគេហទំព័រ liahona.lds.org ឬ អ៊ីម៉ែលមកពួកយើងតាមអាសយដ្ឋាន liahona@ldschurch.org ។ ( សូមដាក់ « Question Corner » នៅក្នុងជួរនៃប្រធានបទ ) សូមចាំថាត្រូវមានការអនុញ្ញាតពីឪពុកម្ដាយរបស់ប្អូនៗ !

រូបគំនូរដោយ ម៉ាត ស្មីតសុន

# មេទ័ពមរ៉ូណៃមានចិត្តក្លាហាន

មេទ័ពមរ៉ូណៃបានដឹកនាំពួកកងទ័ពនីហ្វៃ ។ លោកស្រឡាញ់ការគោរពដល់ព្រះវរបិតាសួគ៌ ។ លោកបានជួយពួកទាហាននីហ្វៃការពារខ្លួន ប្រឆាំងនឹងពួកសាសន៍លេមិន ។ លោកបានរំឭកពួកគេពីពរជ័យរបស់ព្រះវរបិតាសួគ៌ ។ លោកបានរំឭកពួកគេអំពីសេរីភាព និង គ្រួសារពួកគេ ប្រយោជន៍ឲ្យពួកគេមានចិត្តក្លាហានឡើង ។



ក្មេងៗជាច្រើននៅសាលារៀន ប្រើពាក្យសម្ដីដែលធ្វើឲ្យខ្ញុំគ្មានអារម្មណ៍ល្អឡើយ ។ ម្ដាយរបស់ខ្ញុំ និង ខ្ញុំបានអធិស្ឋានទូលសុំនូវចិត្តក្លាហាន និងដើម្បីដឹងពីអ្វីដែលល្អបំផុតត្រូវធ្វើ ។ ថ្ងៃបន្ទាប់មក នៅពេលពួកគេបានចាប់ផ្ដើមប្រើពាក្យសម្ដីបែបនោះទៀត ខ្ញុំបាននិយាយដោយសុភាពថា « សូមឈប់ប្រើពាក្យបែបនោះទៅ ។ វាធ្វើឲ្យខ្ញុំមានអារម្មណ៍មិនល្អទេ » ។ ពួកគេនិយាយថា « យល់ព្រម ឲ្យពួកខ្ញុំសូមទោស » ។ ការណ៍នោះធ្វើឲ្យខ្ញុំសប្បាយក្នុងចិត្ត ហើយខ្ញុំសប្បាយចិត្តដែលខ្ញុំបានរៀនថា ព្រះវរបិតាសួគ៌នឹងជួយខ្ញុំពេលខ្ញុំទូលសុំជំនួយ ។

**បែលឡា ធី អាយុ ១០ ឆ្នាំ រដ្ឋ វឺជិនញ៉ា ស.រ.អា.**



*ហ្វ្រាន អិល អាយុ ១០ ឆ្នាំ រដ្ឋ ហ្វ្លរីដា ស.រ.អា.*

រូបគំនូរដោយ ឃ៉ារ៉េត ប៊េក ស្មែរ

កាត់ បត់ ហើយរក្សាកាតប្ដេជ្ញាចិត្តនេះ !




## ខ្ញុំអាចមានចិត្តក្លាហានបាន !

- ☐ សូមទន្ទេញ អាលម៉ា ៤៨:១១–១២ ។ សូមអាន ខទី ១៧ ផងដែរ !
- ☐ សូមជួយនរណាម្នាក់ដែលមានក្ដីបារម្ភ ឬ ភ័យខ្លាចក្នុងការមានចិត្តក្លាហាន ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះវរបិតាសួគ៌ជាមួយពួកគេ ។
- ☐ សូមមើលជំពូក ៣១–៣៣ និង ៣៥ នៃរឿងក្នុងព្រះគម្ពីរមរមននៅគេហទំព័រ scripturestories.lds.org ។
- ☐ ខ្ញុំប្ដេជ្ញាចិត្តខ្លួនខ្ញុំដើម្បី . . .

______________________________

## ខគម្ពីរសម្រាប់ខែនេះ

បន្ទាប់ពីអ្នកអានវគ្គបទគម្ពីររួច សូមផាត់ពណ៌លើផ្នែកមានចុះលេខត្រូវគ្នានៅលើទង់ឥស្សរភាព !

**១** អាលម៉ា ៤៣:៩–១២, ១៦–២៣, ៤៧–៥៤

**២** អាលម៉ា ៤៤:១–១០, ១២, ១៩–២០

**៣** អាលម៉ា ៤៦:១០–១៦, ២១–២២

**៤** អាលម៉ា ៥៣:១០–២១

**៥** អាលម៉ា ៥៦:២–១១, ៤១–៤៨, ៥៥–៥៦

**៦** ហេលេមិន ៥:២០–៤៤

**៧** ហេលេមិន ៨:១, ៤, ១០, ២៥–២៨

**៨** ហេលេមិន ៩:១–៥, ១៩–២៤, ៣៩–៤០






## ទង់ឥស្សរភាព

មរ៉ូណៃបានដឹកនាំពួកសាសន៍នីហ្វៃនៅក្នុងសង្គ្រាមប្រឆាំងពួកសាសន៍លេមិន ដើម្បីការពារផ្ទះសម្បែង និង គ្រួសាររបស់ពួកគេ ។ មេទ័ពមរ៉ូណៃបានធ្វើ « ទង់ឥស្សរភាព » ពីអាវរបស់លោក ។ លោកបានសរសេរសារពិសេសមួយ ដើម្បីរំឭកពួកសាសន៍នីហ្វៃពីអ្វីដែលពួកគេកំពុងទាមទារយក ៖ « នៅក្នុងការចងចាំដល់ព្រះរបស់យើង សាសនា និង សេរីភាពរបស់យើង និង សេចក្ដីសុខសាន្តរបស់យើង ភរិយារបស់យើង និង កូនចៅរបស់យើង » ( អាលម៉ា ៤៦:១២ ) ។ សូមអានបន្ថែមអំពីរឿងនេះនៅទំព័រ ៧៦ ។ ហើយរកមើលការអញ្ជើញឲ្យអានផ្សេងទៀតនៅច្បាប់ក្រោយ ! ■

រូបគំនូរដោយ ម៉ាយខ ប៊េកស្ទេន រូបគំនូរព្រាងដែលចេញមកពី *មេទ័ពម៉ូរ៉ូណៃលើកទង់ឥស្សរភាព* ដោយ អាណុល ហ្វ្រីប៊ឺក

# ទង់ជ័យរបស់មេទ័ពមរ៉ូណៃ

គ្រាមួយមានស្ដេចទុច្ចរិតមួយអង្គ ។ ទ្រង់មានព្រះទ័យចង់គ្រប់គ្រងលើប្រជាជននីហ្វៃ ។





មរ៉ូណៃគឺជាមេទ័ពនៃកងទ័ពសាសន៍នីហ្វៃ ។ លោកមានភាពរឹងមាំ ហើយស្រឡាញ់ព្រះ ។

រូបគំនូរដោយ អាប៊ើល ស្ទុត



មេទ័ពម៉ូរ៉ូណៃចង់ការពារប្រជាជនរបស់
លោកពីពួកកងទ័ពស្ដេចទុច្ចរិតនោះ ។



លោកបានសម្រេចចិត្តធ្វើទង់ជ័យមួយសម្រាប់ប្រជាជនរបស់លោក ។



ទង់ជ័យរបស់មេទ័ពម៉ូរ៉ូណៃ រំឭកប្រជាជនលោកថា ពួកគេគប្បី
ធ្វើតាមព្រះ ហើយការពារក្រុមគ្រួសាររបស់ខ្លួន ។ នោះពួកគេ
នឹងមានភាពសុខសាន្ត ។ ■

# កាលខ្ញុំឮពីកុមារត្រួសត្រាយផ្លូវ

*ដោយជឿជាក់* ♪ = ១២០–១២៦

ទំនុកច្រៀង និងទំនុកភ្លេង ដោយ ជេនីស ខាប ផើរី




© ឆ្នាំ ២០១៦ ដោយ ជេនីស ខាប ផើរី ។ រក្សាសិទ្ធិគ្រប់យ៉ាង ។
បទចម្រៀងនេះ អាចថតចម្លងសម្រាប់ការប្រើប្រាស់ជាបន្ទាប់បន្សំ ការប្រើប្រាស់នៅព្រះវិហារ ឬនៅគេហដ្ឋានដែលពុំមានលក្ខណៈជាពាណិជ្ជកម្មប៉ុណ្ណោះ ។
សេចក្តីជូនដំណឹងនេះត្រូវបិទនៅលើសំណៅចម្លងនីមួយៗ ។



ដោយ ប្រធាន
ប៊យដ៏ ឃេ ផាកកឺ
( ឆ្នាំ ១៩២៤–២០១៥ )
ប្រធានកូរ៉ុមនៃពួកសាវក
ដប់ពីរនាក់

# ក្រពើខាងវិញ្ញាណ

*ខ្ញុំបាននិយាយថា « មិនសមហេតុផលទេ ។ គ្មានឃើញសត្វក្រពើនៅទីនោះទេ » ។*



ខ្ញុំតែងតែចង់ទៅលេងអាហ្វ្រិក និងមើលសត្វ ហើយទីបំផុតឱកាសនោះបានមកដល់ ។ . . .

យើងបានឈប់នៅអណ្ដូងទឹកមួយដើម្បីមើលសត្វមកផឹកទឹក ។ អណ្ដូងនោះស្ងួតហួតហែងខ្លាំងណាស់នារដូវនោះ ហើយគ្មានទឹកច្រើននោះទេ ការពិតទៅគឺមានតែថ្លុកភក់ប៉ុណ្ណោះ ។ ពេលសត្វដំរីឈានជើងលើដីភក់សើមនោះ ទឹកក៏ជ្រៀបចេញម កចូលក្នុងស្នាមជើងរបស់វា ហើយសត្វផ្សេងៗមកផឹកទឹកនោះ ។

ជាពិសេស សត្វល្មាំង មានអារម្មណ៍ភ័យខ្លាច ។ ពួកវាបានចូលទៅជិតថ្លុកភក់ ដោយគ្រាន់តែក្រឡេកមើល ហើយក៏រត់ចេញយ៉ាងឆាប់រហ័សទាំងភ័យខ្លាច ។ ខ្ញុំអាចមើលឃើញថា គ្មានសត្វតោណានៅក្បែរនោះឡើយ ហើយខ្ញុំក៏សួរអ្នកនាំផ្លូវថា តើហេតុអ្វីពួកសត្វទាំងនោះមិនផឹកទឹក ។ ចម្លើយរបស់គាត់គឺ « សត្វក្រពើ » ហើយនេះគឺជាមេរៀន ។

ខ្ញុំបានដឹងថា គាត់ច្បាស់ជានិយាយលេង ហើយខ្ញុំបានសួរគាត់ដោយប្រាជកប្រជាថា « តើមានបញ្ហាអ្វី ? » ចម្លើយម្ដងទៀតនោះគឺថា ៖ « សត្វក្រពើ » ។

ខ្ញុំបាននិយាយថា « មិនសមហេតុផលទេ ។ គ្មានឃើញសត្វក្រពើនៅទីនោះទេ » ។ . . .

ខ្ញុំគិតថា គាត់ដឹងថា ខ្ញុំមិនជឿគាត់ទេ ហើយគាត់បានសម្រេចចិត្តបង្រៀនមេរៀនមួយដល់ខ្ញុំ ។ យើងបានបើកឡានទៅកាន់ទីតាំងមួយទៀត ដែលឡាននេះឋិតនៅលើខឿនការពារពីលើថ្លុកភក់ ដែលយើងមើលចុះទៅក្រោមបាន ។ គាត់បាននិយាយថា « នោះន៎ ។ សូមមើលដោយខ្លួនលោកផ្ទាល់ទៅ » ។

ខ្ញុំមើលមិនឃើញអ្វីសោះក្រៅតែពី ភក់ ទឹកតិចតួច និង សត្វដែលភ័យខ្លាចនៅពីចម្ងាយនោះឡើយ ។ ហើយនៅពេលមួយនោះខ្ញុំបានឃើញវា ! — ជាសត្វក្រពើដ៏ធំមួយដែលនៅក្រោមភក់ កំពុងរង់ចាំមើលសត្វមួយចំនួនដែលស្រេកទឹក ដោយពុំបានគិត ហើយមកផឹកទឹកនៅទីនេះ ។ . . .

អ្នកនាំផ្លូវនោះមានចិត្តល្អចំពោះខ្ញុំជាងខ្ញុំគិតទុកទៅទៀត ។ « ភាពអំនួត » របស់ខ្ញុំនាំឲ្យគាត់ថ្លែងឃ្លាដំបូងរបស់គាត់ថា « សត្វក្រពើ » ដែលនាំឲ្យមានការអញ្ជើញមួយថា « សូមលោកទៅមើលដោយខ្លួនលោកទៅ ! »

ខ្ញុំមើលឃើញដោយខ្លួនឯងថា គ្មានសត្វក្រពើឡើយ ។ ខ្ញុំគិតថាខ្លួនខ្ញុំគិតត្រូវ ហើយដើរចេញទៅដើម្បីមើលថាមានអ្វីនៅទីនោះ ។ ភាពក្រអឺតក្រទមបែបនោះអាចនាំមកនូវសេចក្ដីស្លាប់ ! ប៉ុន្តែគាត់មានចិត្តអត់ធ្មត់ល្មមដើម្បីបង្រៀនខ្ញុំ ។

យុវវ័យរបស់ខ្ញុំអើយ ខ្ញុំសង្ឃឹមថាប្អូនៗនឹងមានភាពឆ្លាតវៃជាងខ្ញុំនៅក្នុងការនិយាយជាមួយអ្នកនាំផ្លូវរបស់ប្អូនៗនៅក្នុងឱកាសបែបនោះ ។ គំនិតក្រអឺតក្រទម និង ការមិនគោរពដែលខ្ញុំដឹងថាពិតជាពុំសក្តិសមនឹងខ្ញុំ ហើយក៏វាមិនសក្តិសមនឹងប្អូនៗដែរ ។ ខ្ញុំគ្មានមោទនភាពចំពោះវានោះទេ ហើយខ្ញុំបានគិតថាវាជាក្ដីអាម៉ាស់មួយដែលខ្ញុំប្រាប់ប្អូនៗអំពីរឿងនេះ លើកលែងតែការប្រាប់ដល់ប្អូនៗនេះអាចជួយដល់ប្អូនៗ ។

អស់អ្នកទាំងឡាយដែលចាស់ជាងប្អូនៗ ហើយដែលបានហែលឆ្លងកាត់បទពិសោធន៍ទាំងនេះ បានព្រមានអ្នកពីគ្រោះថ្នាក់ដែលមាននៅខាងមុខប្អូនៗ ។ មិនគ្រាន់តែជាសត្វក្រពើដ៏ធំមួយដែលត្របាក់ស៊ីអ្នកជាចំរៀកៗនោះទេ ប៉ុន្តែ *សត្វក្រពើខាងវិញ្ញាណ* គឺកាន់តែគ្រោះថ្នាក់ ហើយកាន់តែបោកបញ្ឆោត និង ពិបាកមើលឃើញជាងពពួកសត្វលូន ដែលពូកែលាក់ខ្លួននៅប្រទេស អាហ្វ្រិកទៅទៀត ។

សត្វក្រពើខាងវិញ្ញាណទាំងនេះអាចសម្លាប់ ឬ ធ្វើឲ្យខូចព្រលឹងរបស់ប្អូនៗបាន ។ ពួកវាអាចបំផ្លាញភាពសុខសាន្តខាងផ្លូវចិត្តរបស់ប្អូនៗ និងភាពសុខសាន្តផ្លូវចិត្តរបស់អ្នកទាំងឡាយ ដែលស្រឡាញ់ប្អូនៗ ។ អ្វីៗទាំងអស់នោះហើយ ដែលត្រូវបានព្រមាននោះ ហើយវាស្ទើរតែគ្មានកន្លែងណាមួយក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះ ដែលមិនត្រូវបានបៀតបៀនជាមួយនឹងគ្រោះថ្នាក់ទាំងអស់នោះឡើយ ។ . . .

ជាសំណាងល្អមានអ្នកដឹកនាំផ្លូវគ្រប់គ្រាន់នៅក្នុងជីវិត ដើម្បីការពាររឿងបែបនេះកុំឲ្យកើតឡើង ប្រសិនបើយើងមានឆន្ទៈទទួលយកការទូន្មានក្នុងពេលនេះ និង ក្រោយៗទៀត ។ ■

*ដកស្រង់ចេញពី « Spiritual Crocodiles »* Ensign, *ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ៣០–៣១ ។*

រូបថត © ISTOCK/THINKSTOCK

# ការយល់ដឹងជ្រៅជ្រះ



**តើយើងអាចរីកច្រើនបាននៅក្នុងពិភពលោកដ៏ឃោរឃៅនេះបានដោយរបៀបណា ?**

« ក្នុងនាមជាសិស្សនៃព្រះគ្រីស្ទ ចំពោះការរស់នៅក្នុងពិភពលោកដ៏ឃោរឃៅដែលមានភាពចលាចល យើងអាចរីកចម្រើន ហើយលូតលាស់ទៅមុខបាន នៅពេលយើងចាក់ឫសក្នុងក្ដីស្រឡាញ់នៃព្រះអង្គសង្គ្រោះ ហើយធ្វើតាមការបង្រៀនរបស់ទ្រង់ដោយរាបសា » ។

**អែលឌើរ យ៉ូនចិន អិល យុក** ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « The Lord Is My Light » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ៦៣ ។

# មាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់យុវមជ្ឈិមវ័យ



ទំព័រ ៤៤

### ការដោះស្រាយបញ្ហាជាមួយនឹងការត្រឡប់មកផ្ទះវិញមុនកំណត់

ការត្រឡប់មកផ្ទះវិញពីបេសកកម្មមុនកាលកំណត់ គឺជាការបាក់ទឹកចិត្តមួយដ៏ខ្លាំង ប៉ុន្តែខ្ញុំបានឃើញថា វាអាចក្លាយជាជំហាននៃការរីកចម្រើន នៅពេលខ្ញុំផ្តោតចិត្តទុកដាក់លើចំណុចទាំងប្រាំមួយនេះ ។

## សម្រាប់យុវវ័យ

### ការចងចាំ ព្រះអង្គសង្គ្រោះ

រៀងរាល់សប្តាហ៍ យើងធ្វើកិច្ចសន្យាមួយដើម្បីចងចាំព្រះយេស៊ូវគ្រីស្ទជានិច្ច ហើយរៀងរាល់ថ្ងៃយើងអាចទទួលពរជ័យដោយការគោរពតាមកិច្ចសន្យានោះ ។



ទំព័រ ៦០

## សម្រាប់កុមារ



ទំព័រ ៧៦

### ទង់ជ័យរបស់មេទ័ពម៉ូរ៉ូណៃ

មេទ័ពម៉ូរ៉ូណៃបានធ្វើទង់ជ័យមួយ ដើម្បីជួយប្រជាជនរបស់លោកចងចាំរឿងសំខាន់ៗបំផុត ដូចជាក្រុមគ្រួសារ និង ព្រះរបស់ពួកគេ ។ តើអ្នកចងចាំរឿងដ៏សំខាន់ៗបំផុតនៅក្នុងជីវិតរបស់អ្នកតាមរបៀបណា ?

---

*ដើម្បីផ្តល់មតិកែលម្អអំពី លីអាហូណា សូមអ៊ីម៉ែលតាមអាសយដ្ឋាន liahona@ldschurch.org។*


សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN
4 02132 87258 4